20
ខួបលើកទី
CDRI 1990-2010

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០០៩-១០





ការបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០០៩-២០១០

*Annual Development Review*
*2009 - 2010*

ភ្នំពេញ ខែមីនា ឆ្នាំ២០១០

*ក្នុងលក្ខណៈជា វិទ្យាស្ថានឯករាជ្យមួយរបស់កម្ពុជាខាងការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ CDRI មានបេសកកម្មចូលរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយចីរភាព និងការលើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយ ចំណេះដឹង និងការកសាងសមត្ថភាព ។*

*CDRI ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការងារជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។*

© **២០១០ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

ISBN 978—99950—52-34-8

**សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៩-២០១០**

*Annual Development Review 2009-10*

ភ្នំពេញ ខែមីនា ឆ្នាំ២០១០

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
☞ អាសយដ្ឋាន ៥៦ ផ្លូវលេខ៣១៥ ខណ្ឌទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☏ (៨៥៥-២៣) ៨៨១-៣៨៤/៧០១, ៨៨៣-៦០៣, ៨៨១-៩១៦ / ០១២ ៨៦៧-២៧៨
🖶 (៨៥៥-២៣) ៨៨០ ៧៣៤
អ៊ីមែល: cdri@wicam.com.kh website: http://www.cdri.org.kh

បកប្រែដោយ: ខេង សេង និង វ៉ា វណ្ណៈ
កែសម្រួល និងរចនាដោយ: ម៉ែន-ច័ន្ទធីតា អ៊ុំ-ចាន់ថា និង យូ សិទ្ធីរិទ្ធ
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ព ស៊ុន ហ៊ាង ភ្នំពេញ

# មាតិកា


បញ្ជីអក្សរកាត់ ........ ៩
បុព្វកថា ........ ១១
សេចក្តីផ្តើម ........ ១៣

## ផ្នែកទី ១. ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល

ជំពូក ១. កម្ពុជានៅក្រោមឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល ........ ១៩
១.១. សេចក្តីផ្តើម ........ ១៩
១.២. ការរាលដាលវិបត្តិមកកម្ពុជា ........ ១៩
១.៣. ឥទ្ធិពលនៃវិបត្តិ ........ ២០
១.៤. មធ្យោបាយដើម្បីការងើបឡើងវិញ ........ ២៦
១.៥. សន្និដ្ឋាន ........ ៣០

ជំពូក ២. ការប៉ះទង្គិចពីរជាន់លើប្រជាជនក្រីក្រៈ សន្តិសុខស្បៀងនៅកម្ពុជា ក្នុងពេលមានវិបត្តិស្បៀង និងវិបត្តិសេដ្ឋកិច្ច ........ ៣១
២.១. សេចក្តីផ្តើម ........ ៣១
២.២. វិបត្តិស្បៀង និងសន្តិសុខស្បៀងនៅកម្ពុជា ........ ៣១
២.៣. វិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសាកល និងសន្តិសុខស្បៀងនៅកម្ពុជា ........ ៣៨
២.៤. សន្និដ្ឋាន ........ ៤៥

ជំពូក ៣. តើក្រុមគ្រួសារនៅជនបទកម្ពុជា ទប់ទល់យ៉ាងណាចំពោះការឡើងថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ? ........ ៤៧
៣.១. សេចក្តីផ្តើម ........ ៤៧
៣.២. ក្របខ័ណ្ឌនៃការពិនិត្យឃើញជាក់ស្តែង និងទស្សនទាន ........ ៤៨
៣.៣. ទិន្នន័យ ........ ៤៩
៣.៤. ស្ថិតិបែបពណ៌នា ........ ៤៩
៣.៥. លទ្ធផលបានពីបទពិសោធន៍ជាក់ស្តែង ........ ៥២
៣.៦. សេចក្តីសន្និដ្ឋាន ........ ៥៣

ជំពូក ៤. លទ្ធផលរកឃើញសំខាន់ៗពីការសិក្សា លើការអនុវត្តប្រព័ន្ធសុវត្ថិភាពសង្គម និង ការគ្រប់គ្រងមិនផ្លូវការលើហានិភ័យក្នុងអំឡុងពេលវិបត្តិសេដ្ឋកិច្ចនៅកម្ពុជាៈ បទពិសោធន៍សិក្សាពីក្រុមគ្រួសារ និងពលករក្រីក្រ និងងាយរងគ្រោះ ........ ៥៥
៤.១. លទ្ធផលរកឃើញសំខាន់ៗ ........ ៥៥
៤.២. វិធីសាស្ត្រស្រាវជ្រាវនៃការវាយតម្លៃនេះ ........ ៦១

## ផ្នែកទី ២. លទ្ធផលស្រាវជ្រាវដទៃទៀតរបស់វិទ្យាស្ថាន CDRI


ជំពូក ៥. របៀបចាត់ចែងការងាររបស់អ្នកគ្រប់គ្រងក្នុងវិស័យសុខាភិបាលនៅកម្ពុជា ........ ៦៧

ជំពូក ៦. ស្វែងរកច្រកដ៏ល្អ សំរាប់បង្កើនទំនាក់ទំនងរវាងសង្គមស៊ីវិលនិងសមាជិកសភានៅកម្ពុជា ........ ៧៥

ជំពូក ៧. វិនិយោគទុនចិន នៅក្នុងប្រទេសកម្ពុជា ........ ៧៧
- ៧.១. សេចក្តីផ្តើម ........ ៧៧
- ៧.២. វិនិយោគផ្ទាល់ពីបរទេស ........ ៧៨
- ៧.៣. ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ........ ៧៩
- ៧.៤. ពាណិជ្ជកម្មផលិតផល ........ ៧៩
- ៧.៥. ពាណិជ្ជកម្មសេវាកម្ម ........ ៨០
- ៧.៦. ហេតុផល និងឥទ្ធិពលនៃ FDI ពីប្រទេសចិន ........ ៨១
- ៧.៧. សន្និដ្ឋាន ........ ៨៦

ជំពូក ៨. សេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម និងកំណើននៅក្នុងប្រទេសកម្ពុជា: ករណីសិក្សាក្នុងវិស័យទូរគមនាគមន៍ និងហិរញ្ញវត្ថុ ........ ៨៩
- ៨.១. សេចក្តីផ្តើម ........ ៨៩
- ៨.២. ការអភិវឌ្ឍផ្នែកទូរគមនាគមន៍ និងហិរញ្ញវត្ថុ ........ ៩១
- ៨.៣. របបច្បាប់គ្រប់គ្រង និងលទ្ធផលតាមវិស័យ ........ ៩៣
- ៨.៤. កំហិតលើពាណិជ្ជកម្មសេវាកម្ម ក្នុងវិស័យទូរគមនាគមន៍ និងហិរញ្ញវត្ថុ ........ ៩៥
- ៨.៥. តំរូវការនិងឱកាសសំរាប់សេរីភាវូបនីយកម្មវិស័យទូរគមនាគមន៍ និងហិរញ្ញវត្ថុ ........ ៩៩
- ៨.៦. សន្និដ្ឋាន ........ ៩៩

ជំពូក ៩. ការស្វែងយល់ពីសេដ្ឋកិច្ចនយោបាយ នៃសមាហរណកម្មក្នុងមហាអនុតំបន់មេគង្គ: ការសំរប សំរួល និង ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅកម្ពុជា ដើម្បីសំរួលដល់ពាណិជ្ជកម្មក្នុងអនុតំបន់ ........ ១០៣
- ៩.១. សេចក្តីផ្តើម ........ ១០៣
- ៩.២. លទ្ធផលស្រាវជ្រាវសំខាន់ៗ និងអនុសាសន៍ ........ ១០៤

ជំពូកទី ១០. ការចូលរួមរបស់កសិករអ្នកប្រើប្រាស់ទឹក និងជោគជ័យនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រដោយកសិករ: ករណីសិក្សានៅសហគមន៍កសិករអ្នកប្រើប្រាស់ទឹក អូរត្រែង ខេត្តកំពង់ស្ពឺ ........ ១១៣
- ១០.១. សេចក្តីផ្តើម ........ ១១៣
- ១០.២. ការចូលរួមរបស់កសិករក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ........ ១១៤
- ១០.៣. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ........ ១១៧

បញ្ជីឯកសារបោះពុម្ពផ្សាយរបស់ CDRI ........ ១១៩

# បញ្ជីក្រាហ្វិក និង តារាង

ក្រាហ្វិក ១.១: ការរាលដាលវិបត្តិចូលមកកម្ពុជា ២០
ក្រាហ្វិក ១.២: កំណើន ផសស ពិត ២៥
ក្រាហ្វិក ១.៣: តំលៃនាំចេញ និងនាំចូល ២៥
ក្រាហ្វិក ១.៤: ប្រភពនៃកំណើន ២៥
ក្រាហ្វិក ១.៥: វិនិយោគផ្ទាល់ពីបរទេសសុទ្ធ ២៥
ក្រាហ្វិក ១.៦: តំលៃនៃការនាំចេញសំលៀកបំពាក់ទៅសហរដ្ឋអាមេរិក ២៥
ក្រាហ្វិក ១.៧: ភ្ញៀវអន្តរជាតិមកដល់ ២៥
ក្រាហ្វិក ១.៨: តំលៃការនាំចូលក្នុងវិស័យសំណង់ ២៥
ក្រាហ្វិក ១.៩: រូបិយវត្ថុទូទៅ ២៥

ក្រាហ្វិក ២.១: សន្ទស្សន៍ថ្លៃស្បៀងសាកល ៣៦
ក្រាហ្វិក ២.២: សន្ទស្សន៍ថ្លៃស្បៀងក្នុងស្រុក និងស្បៀងគ្មានអតិផរណា ៣៦
ក្រាហ្វិក ២.៣: ថ្លៃអង្ករ, ពាន់រៀលក្នុងមួយតោន ៣៦
ក្រាហ្វិក ២.៤: ថ្លៃសាំង និងជី, ពាន់រៀលក្នុងមួយតោន ៣៦
ក្រាហ្វិក ២.៥: ចំនួនប្រជាជនដែលអសន្តិសុខស្បៀង ៣៦
ក្រាហ្វិក ២.៦: សន្ទស្សន៍ភាពអត់ឃ្លានរបស់កម្ពុជា ៣៦
ក្រាហ្វិក ២.៧: ថ្លៃនាំចេញអង្ករ ៣៦

ក្រាហ្វិក ៨.១: សន្ទស្សន៍កំហិតខាងពាណិជ្ជកម្មនៃឧស្សាហកម្មទូរគមនាគមន៍នៅឆ្នាំ២០០៨ ៩៧
ក្រាហ្វិក ៨.២: សន្ទស្សន៍កំហិតផ្នែកពាណិជ្ជកម្ម នៃឧស្សាហកម្មហិរញ្ញវត្ថុនៅឆ្នាំ២០០៨ ៩៨

តារាង ២.១: ការផ្ទេរកើតថ្លៃអង្ករក្នុងអំឡុងពេលវិបត្តិស្បៀង ៣៣
តារាង ២.២ : ការផ្ទេរកើតថ្លៃទំនិញមិនមែនស្បៀងក្នុងអំឡុងពេលវិបត្តិស្បៀង ៣៣
តារាង ២.៣: ភាពញឹកញាប់ជាមធ្យមនៃចំណាយប្រើប្រាស់ជាអាហាររបស់គ្រួសារ ៣៤
តារាង ២.៤: ប្រភពនៃចំណាយប្រើប្រាស់ជាអាហារ ៣៤
តារាង ២.៥: ចម្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះវិបត្តិស្បៀង ៣៧

តារាង ២.៦: ការប្រែប្រួលថ្លៃអង្ករ-ក្នុងអំឡុង GFEC (Q4 2008-Q3 2009) ..... ៣៩

តារាង ២.៧: ការផ្ទេរកំរិតថ្លៃទំនិញមិនមែនស្បៀង-ក្នុងអំឡុង អធដៃ ..... ៤១

តារាង ២.៨: សង្ខេបការឆ្លើយតបភ្លាមៗរបស់រដ្ឋាភិបាលចំពោះវិបត្តិសេដ្ឋកិច្ច ..... ៤២

តារាង ២.៩: ចំណាយប្រើប្រាស់ក្នុងគ្រួសារគិតក្នុងមនុស្សម្នាក់ ជារៀល ..... ៤៤

តារាង ២.១០: ការប្រើប្រាស់ស្បៀង ..... ៤៤

តារាង ៣.១: ស្ថិតិបែបពណ៌នា (គិតជារៀល/ថ្ងៃ តាមកំរិតថ្លៃនៅខែមីនា ២០០៨) ..... ៤៩

តារាង ៣.២: ចំណាយប្រើប្រាស់ពិតក្នុងមនុស្សម្នាក់ បែងចែកតាមក្រុមបញ្ចភាគ ..... ៥១

តារាង ៣.៣: ម៉ាទ្រីសបំលាស់ប្តូរនៃក្រុមគ្រួសារ គិតតាមបញ្ចភាគនៃចំណាយក្នុងមនុស្សម្នាក់ ..... ៥១

តារាង ៤.១: គំរូតាង និងទីកន្លែងធ្វើសម្ភាសន៍ជាមួយក្រុមគ្រួសារ និងកម្មករងាយរងគ្រោះ ..... ៦៣

តារាង ៨.១: សមាសភាពសន្ទស្សន៍កំហិតពាណិជ្ជកម្ម សំរាប់វិស័យទូរគមនាគមន៍ ធនាគារ និងធានារ៉ាប់រង ..... ៩៦

# បញ្ជីអក្សរកាត់

| | |
|---|---|
| ផសស | ផលិតផលក្នុងស្រុកសរុប (Gross Domestic Product) |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) |
| ARTNeT | បណ្តាញស្រាវជ្រាវ និងបណ្តុះបណ្តាលស្តីពីពាណិជ្ជកម្មនៅអាស៊ីប៉ាស៊ីហ្វិក (Asia Pacific Research and Training Network on Trade) |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (Association of South East Asian Nations) |
| CAMINCO | ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា (Cambodian National Insurance Company) |
| CBTA | កិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន (Cross-Border Transport Agreement) |
| CCA | កន្លែងត្រួតពិនិត្យរួម (Common Control Area) |
| CCC | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (Cooperation Committee for Cambodia) |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (Council for the Development of Cambodia) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Research Institute) |
| CSEC | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (Cambodia Socio-Economic Survey) |
| CSOs | អង្គការសង្គមស៊ីវិល (Civil Society Organizations) |
| DI | សន្ទស្សន៍ក្នុងស្រុក (Domestic Index) |
| FAO | អង្គការស្បៀង និងកសិកម្ម (Food and Agriculture Organization) |
| FDR | សន្ទស្សន៍រើសអើងលើបរទេស (Foreign Discriminatory Index) |
| FGDs | ការពិភាក្សាតាមក្រុមស្នូល (Focus Group Discussions) |
| FRI | សន្ទស្សន៍កំហិតបរទេស (Foreign Restrictiveness Index) |
| GATS | កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មខាងសេវាកម្ម (General Agreement on Trade in Services) |
| GFEC | វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល (Global Financial and Economic Crisis) |
| GHI | សន្ទស្សន៍ភាពអត់ឃ្លានសាកល (Global Hunger Index) |
| GMAC | សមាគមនរោងចក្រកាត់ដេរកម្ពុជា (Garment Manufacturers Association of Cambodia) |
| GMS | មហាអនុតំបន់មេគង្គ (Great Mekong Sub-region) |
| G-PSF | វេទិការដ្ឋាភិបាល-ផ្នែកឯកជន (Government-Private Sector Forum) |
| GSP | ប្រព័ន្ធអនុគ្រោះទូទៅ (the Generalised System of Preferences) |
| IFC | អង្គការសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (International Finance Corporation) |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) |
| IRRI | វិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ (International Rice Research Institute) |

| | |
|---|---|
| ISPs | អ្នកផ្តល់សេវាអ៊ីធើណិត (Internet Service Providers) |
| MFN | លក្ខខណ្ឌអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម (Most Favoured Nation) |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (Ministry of Industry, Mines and Energy) |
| MPTC | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (Ministry of Post and Telecommunications) |
| NBC | ធនាគារជាតិនៃកម្ពុជា (National Bank of Cambodia) |
| NEDA | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចជាមួយប្រទេសជិតខាង ប្រទេសថៃ (Neighbouring Countries Economic Development Cooperation Agency) |
| NiDA | អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (National Information Communications Technology Development Authority) |
| NIS | វិទ្យាស្ថានជាតិស្ថិតិ (National Institute of Statistics) |
| NPL | ឥណទានមិនដំណើរការ (Non-Performing Loan) |
| NTTCC | គណៈកម្មាធិការជាតិសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន (National Transit Transport Coordinating Committee) |
| ODA | ជំនួយអភិវឌ្ឍន៍ផ្លូវការ (Official Development Assistance) |
| SOM | កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ (Senior Official Meetings) |
| SSIs | សម្ភាសន៍ពាក់កណ្តាលរៀបរយ (Semi-Structure Interviews) |
| TRI | សន្ទស្សន៍កំហិតពាណិជ្ជកម្ម (Trade Restrictiveness Index) |
| TTF | ការសម្របសម្រួលពាណិជ្ជកម្ម និងការដឹកជញ្ជូន (Trade and Transport Facilitation) |
| WB | ធនាគារពិភពលោក (World Bank) |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក (World Food Programme) |
| WLL | សេវាទូរស័ព្ទអចល័តគ្មានខ្សែ (Wireless Loop Line) |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក (World Trade Organisation) |

# បុព្វកថា

របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំចេញផ្សាយថ្មី សំរាប់ឆ្នាំ២០០៩-១០ នេះ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) នឹងធ្វើការផ្សព្វផ្សាយ នាឱកាសបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា លើកទី៤ ដែលរៀបចំឡើងក្នុងកិច្ចសហការជាដៃគូរវាង វិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal នៅសណ្ឋាគារភ្នំពេញ នាថ្ងៃទី១៧ មីនា ២០១០ ។ ស្របតាមប្រធានបទ "ការសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ: អាទិភាពខាងគោលនយោបាយ និងសកម្មភាពដើម្បីកំណើន និងការអភិវឌ្ឍមានចីរភាព" សន្និសីទនេះ មានរួមប្រជុំថ្នាក់ដឹកនាំមកពីខាងរដ្ឋាភិបាល វិស័យឯកជន ស្ថាប័នស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងសហគមន៍អភិវឌ្ឍន៍អន្តរជាតិ ដើម្បីត្រិះរិះពិចារណាពីសមិទ្ធផលដែលប្រទេសកម្ពុជាសំរេចបាន និងការងារ ទៅអនាគត ។ ដូចគ្នានឹងសន្និសីទចក្ខុវិស័យលើកមុនៗដែរ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី៤ នេះ ទទួលកិត្តិយសដ៏វិសេសដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមជាអធិបតី និងថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទ ។

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំនេះ ផ្តល់ជាឱកាសមួយល្អឯក សំរាប់ឱ្យថ្នាក់ដឹកនាំ និងអ្នកធ្វើគោលនយោបាយមកពីខាងរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍អភិវឌ្ឍន៍ ក៏ដូចជាអ្នកមានឥទ្ធិពលខាងគោលនយោបាយ ដែលមកពីស្ថាប័នស្រាវជ្រាវ និងសង្គមស៊ីវិល ធ្វើការចែករំលែកចំណេះដឹង និងបទពិសោធន៍ ព្រមទាំងពិនិត្យឡើងវិញ ពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចក្នុងតំបន់ និងលើសាកលលោក ការឆ្លើយតបនឹងវិបត្តិនេះ និងអាទិភាពនានា សំរាប់គោលនយោបាយ និងសកម្មភាពទៅអនាគត សំដៅគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងវិស័យគន្លឹះៗ ដូចជា កសិកម្មនិងអភិវឌ្ឍន៍ជនបទ ឧស្សាហកម្មកំពុងផុសឡើង ហេដ្ឋារចនាសម្ព័ន្ធនិងថាមពល និងទេសចរណ៍ ។ សន្និសីទចក្ខុវិស័យនៅឆ្នាំនេះ មានន័យពិសេសមួយក៏រិតទៀតសំរាប់វិទ្យាស្ថាន CDRI ព្រោះជាព្រឹត្តិការណ៍ទី១ ក្នុងចំណោមពិធីពិសេសៗមួយខ្សែដែលរៀបចំឡើង ដើម្បីអបអរសាទរខួបលើកទី២០ នៃការបង្កើត CDRI ឱ្យក្លាយជាវិទ្យាស្ថានកម្ពុជាឯករាជ្យឈានមុខ សំរាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ និងការចូលរួមចំណែករបស់ CDRI ក្នុងការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ និងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ។

របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៩-១០ គឺជារបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ លេខ៥ របស់ CDRI និងមានលើកពីបញ្ហាអភិវឌ្ឍន៍ចំបងៗសំរាប់កម្ពុជា ។ ឯកសារនេះ មានផ្តល់ការវិភាគលំអិតពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល ទៅលើម៉ាក្រូសេដ្ឋកិច្ច និងវិស័យគន្លឹះនានារបស់កម្ពុជា ព្រមទាំងទិដ្ឋភាពផ្សេងៗ ដែលមានសារៈសំខាន់សំរាប់ជនក្រីក្រ និងងាយរងគ្រោះ ដូចជា ការងារនិងសន្តិសុខក្នុងជីវភាពរស់នៅ សន្តិសុខស្បៀងនិងថាមពល និង របៀបរបបទប់ទល់ និងគ្រប់គ្រងហានិភ័យ របស់ប្រជាជនក្រីក្រ និងពលករងាយរងគ្រោះ ក៏ដូចជា ផលប៉ះពាល់ទៅលើយុទ្ធសាស្ត្រ និងគោលនយោបាយការពារសង្គមនៅកម្ពុជា ។ របាយការណ៍នេះ ក៏មានជំពូកមួយចំនួន ដែលបង្ហាញពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនាពេលថ្មីៗរបស់ CDRI ស្តីពីការផ្តល់សេវា

ផ្ទៃទាំសុខភាព អន្តរកម្មរវាងសមាជិកសភា និងសង្គមស៊ីវិល វិនិយោគចិននៅកម្ពុជា សេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម យន្តការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ អំពីសមាហរណកម្មក្នុងមហាអនុតំបន់មេគង្គ និងការចូលរួមរបស់កសិករក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។

វិទ្យាស្ថាន CDRI សង្ឃឹមថា សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ដែលប្រារព្ធធ្វើជារៀងរាល់ឆ្នាំ ព្រមទាំងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ ជាភាសាខ្មែរ និងអង់គ្លេស អាចចូលរួមចំណែកជួយផ្សព្វផ្សាយកាន់តែទូលំទូលាយនូវលទ្ធផលស្រាវជ្រាវខាងគោលនយោបាយអភិវឌ្ឍន៍ ដែលជាប់ទាក់ទិននឹងបញ្ហាសំខាន់ៗ សំរាប់អនាគតប្រទេសកម្ពុជា និងអាចក្លាយជាធនធានដ៏មានប្រយោជន៍ សំរាប់គោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍អន្តរជាតិ និងអ្នកពាក់ព័ន្ធកម្ពុជានានា ។ ឯកសារទាំងពីរនេះ ក៏ដូចជា របាយការណ៍ស្តីពីសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១០ អាចស្វែងរកបានដោយឥតគិតថ្លៃ តាមរយៈគេហទំព័ររបស់ វិទ្យាស្ថាន www.cdri.org.kh ។

*ឡារី ស្ត្រេន្ទ*
*នាយកប្រតិបត្តិ CDRI*
*ខែមីនា ឆ្នាំ២០១០*

# សេចក្តីផ្តើម

នៅឆ្នាំ២០១០ នេះ វិទ្យាស្ថាន CDRI គ្រោងប្រារព្ធខួបលើកទី២០ នៃកំណើតរបស់វិទ្យាស្ថាន ។ ក្នុងពេលកន្លងមកនេះ CDRI បានបង្កើតនូវឯកសារស្រាវជ្រាវសំខាន់ៗ និងទាន់ហេតុការណ៍ជាច្រើន ទាក់ទងនឹងបញ្ហាអភិវឌ្ឍន៍គន្លឹះៗ ។ ដើម្បីអបអរសាទរបុណ្យខួប របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ ក្នុងលេខចេញផ្សាយលើកនេះ មានចុះអត្ថបទស្រាវជ្រាវជាច្រើន ជាស្នាដៃរបស់អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI និងជាប់ទាក់ទងនឹងផ្នែកផ្សេងៗ នៃការស្រាវជ្រាវអភិវឌ្ឍន៍ជាក់ស្តែង ។

អត្ថបទមានចុះក្នុងឯកសារនេះ ចែកចេញជា ២ ផ្នែក ។ ផ្នែកទីមួយ ជាអត្ថបទមួយចំនួនទាក់ទងនឹងផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលៈ ផលប៉ះពាល់ មេរៀនទទួលបាន និងការឆ្លើយតប ចំណែកឯផ្នែកទីពីរ លើកពីលទ្ធផលស្រាវជ្រាវដទៃទៀត ជាស្នាដៃរបស់អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI ។

បន្ទាប់ពីមានកំណើនសេដ្ឋកិច្ចខ្ពស់ បានប្រហែលជាងមួយទសវត្សរ៍ នៅឆ្នាំ២០០៧ កម្ពុជា ក៏ដូចជាប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនទៀត បានជួបវិបត្តិថ្លៃអាហារយ៉ាងធ្ងន់ធ្ងរ ហើយក្រោយនោះបន្តិច ត្រូវរងគ្រោះកាន់តែខ្លាំងថែមទៀត ដោយសារវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល ។ វិបត្តិទាំងពីរនេះ មានប្រភពមកពីខាងក្រៅ ប៉ុន្តែសុទ្ធតែជះឥទ្ធិពលមកលើកម្ពុជាយ៉ាងធ្ងន់ធ្ងរ ជាពិសេសលើជនងាយរងគ្រោះ និងប្រជាជនក្រីក្រ ។ ផលប៉ះពាល់នៃវិបត្តិទាំងនេះ ជាពិសេស វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល កំពុងកើតមានជាបន្ត និងប្រហែលត្រូវបន្តទៅមុខមួយរយៈពេលទៀត ហើយយូរឆាប់ប៉ុណ្ណា អាស្រ័យលើការគ្រប់គ្រងវិបត្តិ និងប្រសិទ្ធភាពខាងគោលនយោបាយនៅក្នុងប្រទេសមានសេដ្ឋកិច្ចជឿនលឿន ។

ស្បៀងអាហារ




1 bushel = 36 litre

*ប្រភពៈ សារព័ត៌មាន Wall Street ចេញថ្ងៃទី ០៧ មករា ឆ្នាំ ២០១០ ។*

នៅជ្រុងម្ខាង វិបត្តិថ្លៃម្ហូបអាហារ និងកំណើនថ្លៃទំនិញប្រើប្រាស់សំខាន់ៗមួយចំនួន បានបង្កជាឱកាសល្អជាច្រើនដល់កម្ពុជា ។ អង្ករដែលជាផលិតផលកសិកម្មដ៏សំខាន់មួយនៅកម្ពុជា ដោយមានសក្តានុពលនាំចេញជាង ២លានតោនក្នុងមួយឆ្នាំនោះ បានឡើងថ្លៃខ្លាំងជាងគេ ក្នុងចំណោមមុខទំនិញដែលប៉ះពាល់ដោយវិបត្តិកំណើនថ្លៃអាហារ ។ ទោះបីជាកំណើនថ្លៃនេះ បានធូរស្រាលមកវិញ ដោយសារការធ្លាក់ចុះសេដ្ឋកិច្ចសាកលក្តី ក៏ថ្លៃមុខទំនិញខ្លះ មានទាំងអង្ករផង នៅតែបន្តឡើងថ្លៃ ទោះបីមិនសូវលឿនក្តី ដូចមានបង្ហាញក្នុងក្រាហ្វិក ។

នៅជ្រុងម្ខាងទៀត ដោយសារប្រជាជនមួយភាគធំ ត្រូវទិញអង្ករ និងទំនិញមូលដ្ឋានដទៃទៀតពីគេ ដូច្នេះកំណើនថ្លៃ គួបផ្សំនឹងការលំបាកតឹងតែងដោយសារឥទ្ធិពលវិបត្តិហិរញ្ញវត្ថុទៅលើសេដ្ឋកិច្ច និងក្រុមគ្រួសារប្រជាជនបានធ្វើឱ្យសន្តិសុខស្បៀងកាន់តែយ៉ាប់យ៉ឺន ហើយរុញច្រានប្រជាជនកាន់តែច្រើនឡើង ឱ្យធ្លាក់ទៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ ។ អត្ថបទចំនួន ២ ដំបូង នៅក្នុងផ្នែកទី១ ពិនិត្យពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងពេលមួយឆ្នាំក្រោយមក ព្រមទាំងឥទ្ធិពលគួបគ្នានៃវិបត្តិម្ហូបអាហារ និង វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅលើសន្តិសុខស្បៀង និងវិស័យកសិកម្មនៅកម្ពុជា ។

អត្ថបទទី ៣ ក្រោមចំណងជើងថា "តើក្រុមគ្រួសារនៅជនបទកម្ពុជា ទប់ទល់យ៉ាងណាចំពោះការឡើងថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ" ពិនិត្យពីផលប៉ះពាល់នៃវិបត្តិទៅលើក្រុមគ្រួសារ ដោយប្រើបណ្តុំទិន្នន័យដែលទទួលបាននៅ CDRI ។

វិបត្តិថ្លៃម្ហូបអាហារ និង វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល បានធ្វើឱ្យប្រជាជនក្រីក្រ និងប្រជាជនជិតក្រីក្រ កាន់តែងាយរងគ្រោះដោយសារការប៉ះទង្គិចខាងសេដ្ឋកិច្ច ។ វិបត្តិទាំងពីរនេះ ក៏បានបង្ហាញផងដែរពីលក្ខណៈច្របូកច្របល់ នៃប្រព័ន្ធសុវត្ថិភាពសង្គមនៅកម្ពុជា ។ អត្ថបទរៀបរៀងឡើងដោយ លោក សូ សុវណ្ណារិទ្ធិ មានលើកពីទិដ្ឋភាពខ្លះនៃបញ្ហានេះ ដែលផ្អែកលើលទ្ធផលនៃការវាយតម្លៃលឿនមួយ ក្នុងកិច្ចសហការរវាង CDRI និងធនាគារពិភពលោក ស្តីពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចទៅលើក្រុមគ្រួសារកម្ពុជា ។ ការសិក្សានេះដើមឡើយបានរៀបចំឡើង ដើម្បីអង្កេតពីបំលាស់ប្តូរពីត្រីមាសមួយទៅត្រីមាសមួយ នៃផលប៉ះពាល់នៃវិបត្តិទៅលើគ្រួសារនៅជនបទ និងពលករងាយរងគ្រោះ ។ ការសិក្សានេះ ចាប់ផ្តើមនៅខែឧសភា ២០០៩ ហើយរំពឹងថានឹងចប់សព្វគ្រប់នៅត្រីមាសទី១ ឆ្នាំ២០១០ ដោយផ្តោតជាពិសេសទៅលើរបៀបរបបក្រៅផ្លូវការដែលមានស្រាប់សំរាប់ផ្តល់ជំនួយគាំទ្រ និងគ្រប់គ្រងហានិភ័យ និងដែលមានប្រយោជន៍សំរាប់ក្រុមគ្រួសារ និងពលករអ្នកក្រីក្រ និងងាយរងគ្រោះនានា ។

ផ្នែកទី២ នៃសៀវភៅនេះ មានចុះនូវរបាយការណ៍ខ្លីៗ ស្តីពីការស្រាវជ្រាវរបស់ CDRI មួយចំនួនដែលទើបបញ្ចប់ ឬកំពុងដំណើរការ ។ វិទ្យាស្ថាន CDRI បានបង្កើតកម្មវិធីស្រាវជ្រាវខាងអភិវឌ្ឍន៍សង្គមតាំងពីឆ្នាំមុនម្ល៉េះ ហើយកម្មវិធីនេះ ទទួលបានជោគជ័យក្នុងការទាក់ទាញមូលនិធិពីអង្គការ DFID សំរាប់ការសិក្សាស្រាវជ្រាវសំខាន់ៗចំនួន ២ ។ ការស្រាវជ្រាវទីមួយ ដែលទើបចប់សព្វគ្រប់ និងមានចំណងជើងថា "របៀបចាត់ចែងការងាររបស់អ្នកគ្រប់គ្រង ក្នុងវិស័យសុខាភិបាលនៅកម្ពុជា" បានរាយការណ៍ពីលទ្ធផលនៃការសិក្សាមួយ អំពីអ្នកគ្រប់គ្រងក្នុងវិស័យសុខាភិបាលនៅកម្ពុជា និងលទ្ធផលការងារនៃអង្គភាពរបស់ពួកគេ ។ ការសិក្សានេះ ធ្វើឡើងក្នុងឆ្នាំ២០០៩ នៅចំពេលដែលរដ្ឋាភិបាលកំពុងធ្វើការផ្លាស់ប្តូរជាច្រើន ទាក់ទងនឹងការរៀបចំ និងគ្រប់គ្រងវិស័យ

សុខាភិបាល គឺមានកិច្ចសន្យារវាងអាជ្ញាធរខេត្ត និងអ្នកគ្រប់គ្រងសេវាតាមមន្ទីរពេទ្យ និងស្រុកប្រតិបត្តិ ដែលកំណត់ច្បាស់ជាងមុន ពីការផ្តល់សេវា, ការបង្កើនស្វ័យភាពសំរាប់អ្នកគ្រប់គ្រងមន្ទីរពេទ្យ និងស្រុកប្រតិបត្តិ ក្នុងការគ្រប់គ្រងបុគ្គលិក និងថវិការបស់អង្គភាពខ្លួន តាមលក្ខខណ្ឌក្នុងកិច្ចសន្យា និងការកែលំអការអនុវត្តរបស់បុគ្គលិក និងរបបគណនេយ្យភាព ។

អត្ថបទទីពីរ ធ្វើការពិនិត្យលើបញ្ហាផ្សេងៗ ទាក់ទងនឹងអន្តរកម្មរវាងសង្គមស៊ីវិល និងសមាជិកសភានៅកម្ពុជា ។ ការសិក្សា ព្យាយាមស្វែងយល់ពីកំរិត និងគុណភាពនៃទំនាក់ទំនង រវាងអង្គការសង្គមស៊ីវិល និងសមាជិកសភា ដោយក្នុងនោះមានការរំលេចថា របបប្រជាធិបតេយ្យនៅកម្ពុជា នៅក្មេងខ្ចីនៅឡើយ ។ ការសិក្សាបានចង្អុលបង្ហាញថា សេដ្ឋកិច្ចទីផ្សារ និងគោលការណ៍សេរីនិយមពហុបក្ស បានត្រួសត្រាយផ្លូវសំរាប់ការរីកលូតលាស់ដ៏ខ្លាំងក្លានៃអង្គការសង្គមស៊ីវិល (ជាពិសេស អង្គការមិនមែនរដ្ឋាភិបាល និងសហជីព) ។ អត្ថបទនេះបានរំលេចថា នៅក្នុងសេដ្ឋកិច្ចអន្តរកាល មានការទទួលស្គាល់យ៉ាងទូលំទូលាយពីលក្ខណៈសំខាន់ចាំបាច់ នៃអន្តរកម្មរវាងសមាជិកសភា និងអង្គការសង្គមស៊ីវិល ក្នុងការភ្ជាប់តំណាក់តំណាងរវាងអំណាចនីតិប្រតិបត្តិ និងប្រជាពលរដ្ឋ និងជំរុញឱ្យរដ្ឋាភិបាលមានគណនេយ្យភាពកាន់តែច្រើន ។

នាពេលថ្មីៗនេះ វិនិយោគចិននៅកម្ពុជា បានទាក់ទាញចំណាប់អារម្មណ៍ច្រើនណាស់ ហើយ CDRI បានធ្វើការសិក្សាមួយចំនួន លើបញ្ហាផ្សេងៗដែលបានផុសឡើង ។ អត្ថបទមួយរៀបរៀងដោយលោក តុង គឹមស៊ុន និង ហែម សុចិត្ត បានពិនិត្យពីវិនិយោគចិននៅកម្ពុជា និងមានផ្តល់ជាអនុសាសន៍ខាងគោលនយោបាយមួយចំនួន ដើម្បីជួយឱ្យសេដ្ឋកិច្ច និងប្រជាជនកម្ពុជា ទទួលបានអត្ថប្រយោជន៍ច្រើនជាអតិបរមាពីវិនិយោគទាំងនេះ ។

អត្ថបទទីបួន ដែលរៀបរៀងដោយលោក សាំង ច័ន្ទហង្ស និង កញ្ញា ផាន់ ដាលីស បានពិនិត្យពីវិស័យស្រាវជ្រាវថ្មីមួយនៅកម្ពុជា ពោលគឺ សេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម ក្នុងវិស័យទូរគមនាគមន៍ និងហិរញ្ញវត្ថុ ។ អ្នកនិពន្ធបានរំលេចថា សេដ្ឋកិច្ចកម្ពុជាបានលូតលាស់ល្អក្នុងមួយទសវត្សរ៍កន្លងទៅ ដែលជំរុញឡើងដោយដំណើរការយ៉ាងល្អក្នុងវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ ។ លទ្ធផលទាំងនេះ ទំនងជាទទួលបានពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងការបើកចំហសេដ្ឋកិច្ច ។ ដើម្បីឈានទៅមុខទៀត ចាំបាច់ត្រូវស្វែងរក និងជួយទ្រទ្រង់ដល់វិស័យមានកំណើនថ្មីៗទៀត ។ អត្ថបទនេះ ពិនិត្យពីការរួមចំណែករបស់អនុវិស័យសេវាកម្មផ្សេងៗទៀត ដើម្បីជំរុញការនាំចេញ ។

អត្ថបទមួយទៀតរបស់លោក ឃៀង សុធី ព្យាយាមស្វែងយល់ពីកំលាំងផ្សេងៗ ដែលជំរុញសមាហរណកម្មកំរិតតំបន់ ក្នុងចំណោមប្រទេសសមាជិកនៃមហាអនុតំបន់មេគង្គ (GMS) ហើយនិងលក្ខណៈផ្សេងៗ និងអន្តរកម្មនានា ដែលមានឥទ្ធិពលទៅលើដំណើរការសមាហរណកម្ម ។ អត្ថបទបានផ្តោតជាពិសេសទៅលើការសំរួលការដឹកជញ្ជូន និងពាណិជ្ជកម្ម ក្នុងនេះមានទាំងការរចនារៀបចំ និងការអនុវត្តតាមកិច្ចព្រមព្រៀងពីការដឹកជញ្ជូនឆ្លងកាត់ព្រំដែនផង ។ ម្យ៉ាងទៀត ក៏មានការផ្តល់ជាអនុសាសន៍មួយចំនួន សំដៅបង្កើនដំណើរការចូលរួមចំណែក និងការពិគ្រោះយោបល់នៅកម្ពុជា និងនៅប្រទេសសមាជិក GMS ដទៃទៀត ។

អត្ថបទចុងក្រោយ ជាការសិក្សាពីប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រដោយកសិករ តាមរយៈករណីសិក្សាលើសហគមន៍កសិករប្រើប្រាស់ទឹកអូរត្រែង នៅខេត្តកំពង់ស្ពឺ ។ អត្ថបទនេះ ពិនិត្យពីការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ

ដោយមានការចូលរួមពីកសិករ និងព្យាយាមធ្វើឱ្យការផ្គត់ផ្គង់ទឹកដល់កសិករមានសមធម៌ និងធ្វើបានទាន់ពេល តាមរយៈការបង្កើតឡើងនូវសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។ ការសន្មតជាមូលដ្ឋានមួយ នៃវិធីសាស្ត្រស្រាវជ្រាវក្នុងការសិក្សានេះ គឺកសិករមានចំណេះដឹងជាមូលដ្ឋាន ដែលធ្វើឱ្យពួកគាត់អាចគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រទ្រង់ទ្រាយតូចបាន ។ ដូច្នេះគេអាចធ្វើការវែកញែកបានថា ការផ្លាស់ប្តូរពីប្រព័ន្ធធារាសាស្ត្រ ដែលគ្រប់គ្រងដោយរដ្ឋាភិបាល ទៅជាប្រព័ន្ធដែលគ្រប់គ្រងដោយកសិករ ទំនងធ្វើឱ្យដំណើរការកាន់តែបានល្អប្រសើរ ហើយថែមទាំងអាចជួយកាត់បន្ថយបន្ទុកចំណាយរបស់រដ្ឋផង ។

# ផ្នែកទី ១
## ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល



# ជំពូក ១
# កម្ពុជានៅក្រោមឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល[១]

ដោយបណ្ឌិត *Hossein Jalilian* និង *Glenda Reyes*

## ១.១. សេចក្តីផ្តើម

ដោយសារវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល (GFEC) សេដ្ឋកិច្ចកម្ពុជា ដែលសំរេចបានអត្រាកំណើនខ្ពស់បំផុតក្នុងរយៈពេលជិត ២ ទសវត្សរ៍ បានជួបនឹងការធ្លាក់ចុះយ៉ាងខ្លាំង ។ បន្ទាប់ពីស្ថិតក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនៗបំផុត កម្ពុជាក៏ធ្លាក់មកក្នុងចំណោមប្រទេសមានការរួមចុះសេដ្ឋកិច្ចគំហុកជាងគេទៅវិញ ។ នៅមុនពេលជួបវិបត្តិ GFEC អត្រាភាពក្រីក្រប្រចាំឆ្នាំមានការថយចុះប្រហែល -១% ប៉ុន្តែគេប៉ាន់ស្មានថា ក្នុងអំឡុងពេលនៃវិបត្តិ អត្រាភាពក្រីក្របានកើនឡើងវិញ ។ ចំណុចល្អមួយគឺ សេដ្ឋកិច្ចកម្ពុជាបានឆ្លងផុតចំនុចទាបបំផុតរួចហើយក្នុងឆមាសទី២ ឆ្នាំ២០០៩ ហើយគេប្រមើលថា នឹងមានកំណើនបន្តិចវិញក្នុងឆ្នាំ២០១០ ។

អត្ថបទនេះ ដែលសង្ខេបចេញពីអត្ថបទដើមរៀបរៀងឡើងដោយបុគ្គលិករបស់វិទ្យាស្ថាន CDRI[២] ពិនិត្យពីផលប៉ះពាល់នៃGFEC នៅកម្ពុជា ។ផ្នែកទី ១.២ ពណ៌នាពីការរាលដាលវិបត្តិមកកម្ពុជា រីឯ ផ្នែកទី ១.៣ រៀបរាប់លំអិតពីផលប៉ះពាល់នៃវិបត្តិ ។ ផ្នែកទី ១.៤ ពិនិត្យពី ការរំពឹងពីការងើបសេដ្ឋកិច្ចឡើងវិញ និងគំនិតផ្តួចផ្តើមខាងគោលនយោបាយ ហើយផ្នែកទី ១.៥ គឺជាសេចក្តីសន្និដ្ឋាន ។

## ១.២. ការរាលដាលវិបត្តិមកកម្ពុជា

កម្ពុជាបានរួចផុតពីវិបត្តិនៅជុំទី១ នៃវិបត្តិហិរញ្ញវត្ថុ ពីព្រោះមិនសូវជាប់ពាក់ព័ន្ធនឹង កិច្ចការជំនួញលើកំចីលេខពីរ (sub-prime transactions) ដែលជាដើមភ្លើងបង្កវិបត្តិក្នុងប្រព័ន្ធហិរញ្ញវត្ថុនៅបរទេស ។ ទោះយ៉ាងនេះក្តី នៅពេលវិបត្តិហិរញ្ញវត្ថុ បានរាលដាលចូលដល់វិស័យអចលនទ្រព្យ កម្ពុជាក៏ត្រូវរងគ្រោះដោយសារ GFEC ដែរ ។ វិបត្តិបានជ្រាបចូលកម្ពុជា តាមរយៈឥទ្ធិពលអវិជ្ជមានរបស់វាទៅលើពាណិជ្ជកម្ម និងលំហូរមូលធន ហើយចុងក្រោយបង្អស់ គឺទៅលើវិស័យហិរញ្ញវត្ថុ និងវិស័យជំរុញកំណើនផ្សេងៗទៀតរបស់កម្ពុជា ។ ភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ដែលឆ្លងចូលមកតាមរយៈពាណិជ្ជកម្ម និងលំហូរមូលធន ត្រូវបានកំណត់ដោយទំហំនៃពាណិជ្ជកម្ម ភាពបើកចំហខាងហិរញ្ញវត្ថុ និងពាណិជ្ជកម្ម និងទីតាំងប្រទេសកម្ពុជានៅក្នុងខ្សែរយៈកំណត់តំលៃ ។ កត្តាមួយចំនួន ដែលមិនជាប់ទាក់ទងនឹងវិបត្តិ ក៏មានចំណែកបង្កឱ្យល្បឿនលូតលាស់ធ្លាក់ចុះក្នុង ៣ វិស័យ ដែលជំរុញកំណើនសេដ្ឋកិច្ច

---

១ អត្ថបទនេះ ជាស្នាដៃរបស់បណ្ឌិត Hossein Jalilian ជានាយកផ្នែកស្រាវជ្រាវ និង Glenda Reyes ជាអ្នកស្រាវជ្រាវប្រចាំវិទ្យាស្ថាន CDRI ។

២ អត្ថបទនេះ សង្ខេបចេញពីអត្ថបទដើមរបស់ Jalilian និង Reyes ដែលនឹងចេញផ្សាយនាពេលឆាប់ៗខាងមុខ ។ ឯកសារយោងមួយចំនួនតូច ត្រូវបានយកចេញពី Jalilian et al. 2009 និង Jalilian, Reyes, and Lun (ចេញផ្សាយនាពេលឆាប់ៗខាងមុខ) ។

កម្ពុជាដែរ គឺមានវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ (វិស័យកសិកម្ម ជាករណីលើកលែង) ។ វិបត្តិ GFEC មានផលប៉ះពាល់ដោយផ្ទាល់ទៅលើភាពក្រីក្រនៅកម្ពុជា ។ រដ្ឋាភិបាល បានព្យាយាមស្វែងរកវិធីកាត់បន្ថយឥទ្ធិពលនៃវិបត្តិ ទៅលើស្ថានភាពក្រីក្រ និងម៉ាក្រូសេដ្ឋកិច្ច (ក្រាហ្វិក ១.១) ។

ក្រាហ្វិក ១.១: ការរាលដាលវិបត្តិចូលមកកម្ពុជា




*ប្រភព: អ្នកនិពន្ធ*

## ១.៣. ឥទ្ធិពលនៃវិបត្តិ

### *១.៣.១. ការបន្ថយកំណើន*

រាជរដ្ឋាភិបាលកម្ពុជាបានឱ្យដឹងថា បន្ទាប់ពីមានលទ្ធផលល្អវិសេសប្រហែលមួយទសវត្សរ៍ ដោយមានអត្រាកំណើនជាមធ្យម រហូតដល់ ៩% គេបានគន់គូរថា ផសស កម្ពុជា មានកំណើនត្រឹម ២% ប៉ុណ្ណោះ នៅឆ្នាំ២០០៩ ។ មានប្រភពខ្លះទៀត បានប៉ាន់ស្មានថា ផសស កម្ពុជា បានរួមចុះ ២% ជាមធ្យម (ក្រាហ្វិក ១.២) ដែលជាការរួមចុះដ៏ធំបំផុត ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី ក្នុងរវាងឆ្នាំ ២០០៧ និង ២០០៩ (ADB 2009, IMF 2009a, WB 2009) ។ ជាចំណុចល្អវិញ គេឃើញមានសញ្ញាបង្ហាញថា សេដ្ឋកិច្ចកម្ពុជាបានឆ្លងផុតពីចំនុចចុះទាបបំផុត និងងើបឡើងវិញខ្លះហើយ នៅឆមាសទី២ ឆ្នាំ២០០៩ ។

### ១.៣.២ *ការថយចុះនៃកត្តាអំណោយផល*

ពាណិជ្ជកម្មកាន់តែខ្លាំងក្លា និងលំហូរចូលមូលធន គឺជាកត្តាអំណោយផលសំខាន់ពីរ ដែលទ្រទ្រង់ដល់ការរីកធំធាត់យ៉ាងលឿន នៃវិស័យជំរុញកំណើននៅកម្ពុជា ។ ដូចគ្នានេះដែរ ការចុះខ្សោយនៃពាណិជ្ជកម្ម និងការផ្ទេរមូលធនមកពីខាងក្រៅ គឺជាកត្តាធ្វើឱ្យអត្រាកំណើនត្រូវរលាយបាត់អស់ក្នុងអំឡុងពេលនៃវិបត្តិ ។

#### ១.៣.២.១ ពាណិជ្ជកម្ម

កំលាំងនៃវិបត្តិ អាចឃើញច្បាស់ តាមរយៈការប៉ះទង្គិចតំរូវការ (Keynesian demand shock) ដែលបានប៉ះពាល់យ៉ាងខ្លាំងទៅលើពាណិជ្ជកម្មជាមួយ បណ្ដាប្រទេសដែលមានកំណើនមួយភាគធំបានពីការផ្លាស់ប្ដូរទៅជាសេដ្ឋកិច្ចជំរុញដោយការនាំចេញ[៣] ដូចជា ប្រទេសកម្ពុជា ជាដើម ។ ការថយចុះពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងតំលៃនាំចេញ និងនាំចូលរបស់កម្ពុជា មានកំរិតជាមធ្យមប្រហែល ១០% និង ៣% សំរាប់ ១០ខែ ដើមឆ្នាំ២០០៩ បើធៀបនឹង ១០ខែដូចគ្នា ក្នុងឆ្នាំ២០០៨ (ក្រាហ្វិក ១.៣) ។ ការរួមចុះការនាំចេញនេះ បង្កឡើងជាសំខាន់ ដោយសារការថយចុះពាណិជ្ជកម្ម សំលៀកបំពាក់ (សកម្មភាពនាំចេញឈានមុខរបស់កម្ពុជា) ជាមួយសហរដ្ឋអាមេរិក ដែលជាទីផ្សារនាំចេញចំបងគេរបស់កម្ពុជា ។ ម្យ៉ាងទៀត ការថយចុះការនាំចូល បណ្ដាលមកពីការចុះថ្លៃប្រេង និងការថយចុះតំរូវការទំនិញនាំចូលប្រភេទប្រើបានយូរ ។

#### ១.៣.២.២ លំហូរមូលធន ហានិភ័យចំពោះភាពបើកចំហ

##### *១.៣.២.២.១ វិនិយោគផ្ទាល់ពីបរទេស (FDI) និងប្រាក់ផ្ញើមកផ្ទះ*

កម្ពុជា ស្ថិតក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី ដែលមានសេដ្ឋកិច្ចបើកចំហខ្លាំង ចំពោះមូលធនពីបរទេស (ADB 2009) ។ ប៉ុន្ដែគួរឱ្យស្ដាយ ភាពបើកចំហចំពោះមូលធនបរទេសនេះ ក៏បង្កជាភាពងាយរងគ្រោះចំពោះការប៉ះទង្គិចផ្សេងៗដែរ ។ នៅកម្ពុជា GFEC បានធ្វើឱ្យ FDI សុទ្ធ ធ្លាក់ចុះអស់ ៣៦% ក្នុងឆ្នាំ២០០៩ (ក្រាហ្វិក ១.៤) ។ចំពោះចំណុចវិជ្ជមានវិញ ដោយសារកង្វះទីផ្សារមូលបត្រនៅកម្ពុជា វិបត្តិសេដ្ឋកិច្ចដែលឆ្លងរាលដាលតាមច្រកវិនិយោគនោះ មានទំហំមិនធំប៉ុន្មានទេ បើធៀបនឹងប្រទេសដទៃ ។

គេបានកត់សំគាល់ថា ប្រាក់ផ្ញើមកផ្ទះដែលចូលពីបរទេស មានលក្ខណៈមាំទាំទៀងទាត់ជាងលំហូរមូលធនផ្សេងៗទៀត ។ គេប៉ាន់ស្មានថា ប្រាក់ផ្ញើមកផ្ទះពីបរទេស ដែលផ្ទេរមកកម្ពុជា បានធ្លាក់ចុះ ៨% និង ៤% នៅក្នុងឆ្នាំ ២០០៨ និង ២០០៩ (Ratha and Mohapatra 2009, Ratha et al. 2009) ។ ទោះយ៉ាងនេះក្ដី បរិមាណសរុបរបស់វានៅតែមានកំរិតខ្ពស់ជាងកាលពីមុនមានវិបត្តិ GFEC ហើយការធ្លាក់ចុះក៏មិនសូវច្រើនដូចមូលធនដទៃទៀតនៅក្នុងលំហូរ FDI ដែរ ។ ថៃ និងម៉ាឡេស៊ី ដែលជាប្រទេសគោលដៅចំបងបំផុត សំរាប់ពលករចំណាកស្រុកកម្ពុជានោះ បានបិទទ្វារជាផ្លូវការ ឈប់ទទួលពលករចំណាកស្រុកថ្មីៗពីកម្ពុជា (Ros, S. 2009) ។ សំពាធការងារ ក៏ទំនងធ្វើឱ្យពលករចំណាកស្រុកកម្ពុជាខ្លះ ត្រលប់មកស្រុកវិញដែរ ។ បញ្ហាទាំងនេះ បានធ្វើឱ្យស្ទះដល់លំហូរប្រាក់ផ្ញើមកផ្ទះដែលចូលមកកម្ពុជា ។

---

៣ សូមមើល Rodrik (2009) ។

#### ១.៣.២.២.២ ជំនួយពីបរទេស

ជាប្រវត្តិសាស្ត្រ បន្ទាប់ពីមានវិបត្តិធំៗ តែងមានការធ្លាក់ចុះជំនួយយ៉ាងខ្លាំងរបស់ ពួកម្ចាស់ជំនួយដែលបានរងផលប៉ះពាល់ពីវិបត្តិនោះដែរ (UNCTAD 2009, Roodman 2008) ។ ប៉ុន្តែ ដោយសារមានជំនួយរបស់ចិន លំហូរជំនួយសរុបចូលមកកម្ពុជា មានលក្ខណៈទ្បេងទាត់ច្រើន ហើយរឿងនេះសំខាន់បំផុតសំរាប់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវពឹងផ្អែកយ៉ាងខ្លាំងលើជំនួយទាំងនេះ គឺដល់ប្រហែល ៧៥% នៃចំណាយមូលធនរបស់ខ្លួន ។ មកទល់ពេលនេះ គេដូចមិនឃើញមានការកាត់បន្ថយបរិមាណជំនួយ (សរុបជិត ១ពាន់លានដុល្លារ) ដែលបានសន្យាផ្តល់ឱ្យកម្ពុជាសំរាប់ឆ្នាំ២០០៩ នោះទេ ។ លើសពីនេះទៀត នៅចុងឆ្នាំ២០០៩ ចិនបានយល់ព្រមផ្តល់កញ្ចប់ជំនួយមួយមានទឹកប្រាក់ ជាង ១,២ពាន់លានដុល្លារ ដល់កម្ពុជា (AFP 2009) ។ ទោះយ៉ាងនេះក្តី មានសេចក្តីរាយការណ៍ថា ម្ចាស់ជំនួយមួយចំនួនត្រៀមអនុវត្តបំលាស់ប្តូរខ្លះៗ ដូចជា ការលុបចោលគំរោងបង្កើនជំនួយនាពេលអនាគត និងការលៃចែកជំនួយសារឡើងវិញនៅទូទាំងតំបន់[៤] ។

#### ១.៣.២.៣ ការមានឱនភាពជញ្ជីងទូទាត់ឡើងវិញ

បន្ទាប់ពីមានអតិរេកច្រើនៗក្នុងរយៈពេលមួយទសវត្សរ៍មក គេប៉ាន់ស្មានថា នៅឆ្នាំ២០០៩ ជញ្ជីងទូទាត់ (BOP) សរុបរបស់កម្ពុជា នឹងមានឱនភាពដល់ ១,១% នៃផសស[៥] ។ សូចនាករជាក់លាក់ពីរនៃភាពងាយរងគ្រោះខ្លាំងដោយការប៉ះទង្គិចពីខាងក្រៅ បង្កឡើងដោយការរួមចុះនៃលំហូរមូលធន គឺឱនភាពដ៏ធំនៃគណនីចរន្ត និងធនបំរុងបរទេសកំរិតទាប (FAO and WFP 2009) ។ តាំងពីដើមរៀងមក កម្ពុជាតែងមានឱនភាពគណនីចរន្តធំណាស់ ។ ទោះយ៉ាងនេះក្តី ធនបំរុងផ្លូវការដុលរបស់កម្ពុជា តែងមានកំរិតសមល្មម គឺមានរហូតដល់ ៣,១ខែ នៃចំណាយលើការនាំចូល (WB 2009) ។

### ១.៣.៣ វិស័យជំរុញកំណើនបានថយចុះ

ក្នុងអំឡុងមួយទសវត្សរ៍មុនពេលមានវិបត្តិ GFEC ដោយសារមានកំណើនពាណិជ្ជកម្ម និងលំហូរចូល FDI ផង វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម បានដើរតួជាប្រភពដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចកម្ពុជា (ក្រាហ្វិក ១.៥) ។ ក្រៅពីវិស័យកសិកម្ម មួយចេញ វិស័យជំរុញកំណើនដទៃទៀតបានរួមចុះធ្ងន់ធ្ងរ នៅអំឡុងពេលមាន GFEC ហើយក៏បានប្រទាញឱ្យសេដ្ឋកិច្ចកម្ពុជាធ្លាក់ចុះដែរ ។ ប៉ុន្តែគួរបញ្ជាក់ឡើងវិញថា កត្តាមិនពាក់ព័ន្ធនឹងវិបត្តិមួយចំនួន ក៏មានចំណែកក្នុងការធ្លាក់ចុះវិស័យជំរុញកំណើនទាំងនេះដែរ ។

#### ១.៣.៣.១ វិស័យកាត់ដេរ

គេប៉ាន់ស្មានថា ការរួមចំណែកនៃវិស័យកាត់ដេរ ក្នុងការជំរុញកំណើន បានថយចុះដល់ ០,៣% និង -២,៣% នៅឆ្នាំ ២០០៨ និង ២០០៩ រៀងគ្នា ធៀបនឹងតួលេខជាមធ្យម ២,៤% ពីឆ្នាំ១៩៩៨-២០០៧

---

៤ សូមមើលឧបសម្ព័ន្ធ ខ នៃអត្ថបទដើមរបស់ Jalilian and Reyes (ចេញផ្សាយក្នុងពេលឆាប់ៗខាងមុខ) ។

៥ យោងតាមរូបភាពដែលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

(ក្រាហ្វិក ១.៥) ។ តំលៃ និងបរិមាណសរុប នៃសំលៀកបំពាក់នាំចេញ បានធ្លាក់ចុះប្រហែល ១៩% និង ១៥% សំរាប់ ១០ខែ ដើមឆ្នាំ២០០៩ បើធៀបនឹងអំឡុងពេលដូចគ្នា ក្នុងឆ្នាំ២០០៨ ។ រហូតមកដល់ពេលនេះ (ដើមឆ្នាំ ២០១០) មិនទាន់ឃើញមានការងើបឡើងវិញអ្វីជាក់លាក់ទេ[៦] ។

ការធ្លាក់ចុះសេដ្ឋកិច្ចធ្ងន់ធ្ងរ នៅសហរដ្ឋអាមេរិក ដែលជាទីផ្សារសំលៀកបំពាក់ចំបងគេរបស់កម្ពុជា បានធ្វើឱ្យសកម្មភាពលក់រាយថយចុះយ៉ាងខ្លាំង ។ ភ្លាមៗនោះ កម្ពុជាក៏ត្រូវចាញ់ប្រៀបគូប្រកួតប្រជែងរបស់ខ្លួន ដោយក្នុង ១១ខែ ដើមឆ្នាំ២០០៩ តំលៃការនាំចេញសំលៀកបំពាក់របស់កម្ពុជាទៅសហរដ្ឋអាមេរិក បានធ្លាក់ចុះប្រហែល ២២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០០៨ ប៉ុន្តែសំរាប់ប្រទេសចិន និងបង់ក្លាដេសវិញ វាកើនឡើងប្រហែល ១,៥% និង ២,៣% រៀងគ្នា (ក្រាហ្វិក ១.៦) ។

លក្ខណៈដែលគូប្រជែងរបស់កម្ពុជា អាចរក្សា ឬក៏ពង្រីកចំណែកទីផ្សាររបស់គេក្នុងពេលមានវិបត្តិ បង្ហាញថាមានបញ្ហាច្រើនទៀត ក្រៅពីរឿង ការថយចុះតំរូវការធ្វើឱ្យការនាំចេញធ្លាក់ចុះ ។ មូលហេតុចំបងៗ នៃការលំបាកសព្វថ្ងៃក្នុងវិស័យកាត់ដេររបស់កម្ពុជា គឺការគួបផ្សំគ្នានៃ ការបាត់បង់ចំណូលចិត្ត ឥទ្ធិពលនៃអត្រាប្តូរប្រាក់ និងឧបសគ្គខាងរចនាសម្ព័ន្ធផ្សេងៗ ដែលប៉ះពាល់ដល់កម្លាំងប្រកួតប្រជែងខាងតំលៃដើម និងដែលបង្កភាពងាយរងគ្រោះនឹងការប៉ះទង្គិចពីខាងក្រៅ ។ ឧបសគ្គទាំងនោះ មានជាអាទិ៍ កង្វះសមាហរណកម្មតាមខ្សែបញ្ឈរ របៀបរបបនាំចេញមិនទំនើប ការពឹងផ្អែកខ្លាំងពេកលើ FDI អគ្គិសនីមានថ្លៃខ្ពស់ ការលេចលឺពីចំណាយលើអំពើពុករលួយ ជាដើម ។

### ១.៣.៣.២ វិស័យទេសចរណ៍: ការធ្លាក់ចុះមិនអាចគេចផុត?

វិស័យទេសចរណ៍កម្ពុជា ពិតជាបានធ្លាក់ចុះកំណើន ធ្វើឱ្យការរួមចំណែករបស់វិស័យនេះ ក្នុងកំណើនសេដ្ឋកិច្ចថយចុះពី ១,៦% ក្នុងឆ្នាំ២០០៧ រហូតដល់ -២,៣% ក្នុងឆ្នាំ២០០៩ (ក្រាហ្វិក ១.៥) ។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃភ្ញៀវអន្តរជាតិមកដល់កម្ពុជា មានតួលេខអវិជ្ជមានជាបន្តបន្ទាប់ រហូតដល់ត្រីមាសទី៤ ឆ្នាំ២០០៨ ប៉ុន្តែបានក្លាយជាវិជ្ជមានវិញនៅខែមិថុនា ២០០៩ ដែលបង្ហាញពីការងើបឡើងវិញ គេបានទទឹងរង់ចាំជាយូរមកហើយសំរាប់វិស័យនេះ (ក្រាហ្វិក ១.៧) ។

ការចុះខ្សោយកំណើនក្នុងវិស័យទេសចរណ៍ បណ្តាលពីការរួមផ្សំគ្នា រវាងកត្តាកើតឡើងពីវិបត្តិ និងកត្តាមិនជាប់ទាក់ទងនឹងវិបត្តិ ដូចជា ឥទ្ធិពលនៃវិបត្តិទៅលើទីផ្សារទេសចរណ៍សំខាន់ៗជាយូរមកហើយរបស់កម្ពុជា (កូរ៉េខាងត្បូង និងជប៉ុន) វិបត្តិនយោបាយនៅថៃ[៧] ទំនាស់នៅព្រំដែនកម្ពុជា-ថៃ និងការឆ្លងរាលដាលវីរុស H1N1 ជាដើម ។ កត្តាដែលជួយទ្រទ្រង់កំណើនទេសចរណ៍កម្ពុជា គឺមានកំណើនភ្ញៀវទេសចរក្នុងអនុតំបន់ (ជាពិសេសមកពី វៀតណាម និងឡាវ) និងកំណើនទេសចរណ៍ក្នុងស្រុក ។ ការថយចុះនៃកំណើន គឺដោយសារចំណាយរបស់ភ្ញៀវទេសចរក្នុងស្រុក និងក្នុងអនុតំបន់ អាចប៉ះប៉ូវមិនគ្រប់លើការថយចុះប្រាក់ចំណូលដែលទទួលបានពីភ្ញៀវទេសចរមកពីប្រទេសអភិវឌ្ឍន៍ ។

---

៦ សំរាប់ឧទាហរណ៍បន្ថែម សូមមើល Finch (2010) ។

៧ ថៃ គឺជាច្រកទ្វារសំខាន់ សំរាប់វិស័យទេសចរណ៍កម្ពុជា ។

### ១.៣.៣.៣ វិស័យសំណង់: កំសួលផ្ទុះបែក

វិស័យសំណង់បានធ្លាក់ចុះខ្លាំង ដោយសារផលប៉ះពាល់នៃវិបត្តិ ដែលឆ្លងចូលតាមរយៈច្រកវិនិយោគ និង ឥទ្ធិពលនៃការផ្ទុះបែកវិស័យអចលនទ្រព្យក្នុងស្រុក ។ គេប៉ាន់ស្មានថា ការរួមចំណែករបស់វិស័យសំណង់នៅក្នុង កំណើនសេដ្ឋកិច្ច បានធ្លាក់ចុះពី ០,៥% នៅឆ្នាំ២០០៧ រហូតដល់ -០,៥% នៅឆ្នាំ២០០៩ (ក្រាហ្វិក ១.៥) ។ បរិមាណនាំចូលសម្ភារៈសំណង់ បានធ្លាក់ចុះវិញពីចំណុចខ្ពស់បំផុត (កាលពីពាក់កណ្ដាលឆ្នាំ២០០៨) ប៉ុន្តែនៅប៉ុន្មាន ខែចុងក្រោយនេះ វាបានកើនឡើងខ្លះៗហើយ (ក្រាហ្វិក ១.៨) ។

វិស័យអចលនទ្រព្យក្នុងស្រុកបានរីកដុះដាលខ្លាំងណាស់ ដោយសារសេរីភាវូបនីយកម្មហិរញ្ញវត្ថុកើតមានឡើង យ៉ាងលឿន ឥណទានបានរីកដុះដាលលឿនណាស់ ហើយវិស័យជំរុញកំណើនផ្សេងៗ ក៏រីកលូតលាស់លឿនដែរ ។ កំសួលកំណើនខ្លាំងនៃវិស័យអចលនទ្រព្យនេះ វាមិនខុសពីវិស័យដទៃឡើយ គឺត្រូវតែផ្ទុះបែកនៅពេលយូរ ឬឆាប់ បើទោះជាមាន ឬគ្មានវិបត្តិសាកលក្តី ។ ប៉ុន្តែ វិបត្តិបានពន្លឿន និងបង្កើនឥទ្ធិពលនៃការផ្ទុះបែក ធ្វើឱ្យ អចលនទ្រព្យធ្លាក់ថ្លៃអស់ ៤០% មកទល់ខែសីហា ២០០៩ (An, C. 2009) ។ នៅឆមាសទី១ ឆ្នាំ២០០៩ មាន របាយការណ៍ថា តំលៃអនុមតិគំរោងសាងសង់សរុបបានកើនឡើង បើធៀបនឹងឆមាសទី១ ឆ្នាំ២០០៨ ប៉ុន្តែ គេយល់ថា ដោយសារអនាគតសេដ្ឋកិច្ចមិនទាន់ឃើញភ្លឺស្វាងសោះ ដូច្នេះវិនិយោគិនជាច្រើន ប្រហែលគ្រាន់តែ សាកល្បង ដើម្បីស្ទង់មើលសភាពការណ៍ប៉ុណ្ណោះ (Xinhua 2009) ។

## ១.៣.៤ ស្ថានភាពរូបិយវត្ថុតានតឹង

ស្ថានភាពរូបិយវត្ថុ ពិតជាតានតឹងក្នុងអំឡុងពេលនៃវិបត្តិ ។ កំណើនរូបិយវត្ថុទូទៅពីមួយឆ្នាំទៅមួយឆ្នាំ បានធ្លាក់ចុះពីប្រហែល ៦០% នៅខែកុម្ភៈ ២០០៨ មកដល់ -១% ក្នុងពេលមួយឆ្នាំបន្ទាប់ ។ ជាភ័ព្វល្អ នៅឆមាសទី២ ឆ្នាំ២០០៩ គេឃើញមានការប្រែប្រួលល្អជាងមុន ស្របគ្នាការកើនឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច (ក្រាហ្វិក ១.៩) ។

សញ្ញាបង្ហាញភាពតានតឹងក្នុងវិស័យធនាគារ បានស្ដែងឡើងកាន់តែច្បាស់ នៅពេលវិបត្តិសេដ្ឋកិច្ចវិវត្តកាន់តែ ធ្ងន់ធ្ងរឡើង ។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃបញ្ញើជារូបិយប័ណ្ណ ដែលតំណាងឱ្យប្រហែល ៩៧% នៃបញ្ញើ នៅធនាគារសរុបនោះ បានធ្លាក់ចុះដល់ -៤% នៅខែកុម្ភៈ ២០០៩ ធៀបនឹងកំណើនប្រហែល ៧០% កាលពី ឆ្នាំ២០០៨ ។ នៅដើមឆមាសទី២ ឆ្នាំ២០០៩ មានការប្រសើរឡើងបន្តិច តែច្បាស់លាស់ ក្នុងស្ថានភាពសាច់ប្រាក់ ងាយស្រួល ។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានយល់ស្របថា សាច់ប្រាក់ងាយស្រួលមានគ្រប់គ្រាន់ហើយ នាបច្ចុប្បន្ននៅក្នុងប្រព័ន្ធធនាគារ (IMF 2009b) ។

ការព្រួយបារម្ភពីហានិភ័យនៃឥណទាន អាចមានតិច ឬច្រើនខុសៗគ្នា ប៉ុន្តែមិនទាន់រលាយបាត់អស់នៅ ឡើយទេ ។ ឥណទានវិស័យឯកជន មានអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ខ្ពស់ជាង ១០០% នៅឆមាសទី២ ឆ្នាំ២០០៨ ហើយវានៅតែខ្ពស់ដដែល ដល់ ៥០% នៅចុងឆ្នាំ២០០៨ ។ ប៉ុន្តែការរីកដុះដាលលឿននេះ ហាក់ដូច កើតមានឡើងព្រមគ្នានឹងបញ្ហាមួយចំនួន ។ កន្លងមក មានការព្រួយបារម្ភពីកំរិតពិតប្រាកដ នៃអនុបាតកម្ចី មិនដំណើរការ (NPL) និងចំណែកឥណទានធនាគារ ដែលផ្ដល់ទៅឱ្យវិស័យអចលនទ្រព្យ[៨] ។ ប៉ុន្តែ សូចនាករ

---

៨ ផ្អែកតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ (IMF 2009) ។

## ក្រាហ្វិក ១.២: កំណើន ផសស ពិត




*ប្រភព: NIS សំរាប់ឆ្នាំ 1998-2007; សំរាប់ឆ្នាំ 2008e, MoEF; សំរាប់គំរោង 2009 និង 2010, MoEF, IMF (2009a/b), ADB (2009), WB (2009), Green & Ith (2009)*

## ក្រាហ្វិក ១.៥: វិនិយោគផ្ទាល់ពីបរទេសសុទ្ធ

(3mma yoy % change)




*ប្រភព: WDI 2008 CD-ROM, WB (2009)*

## ក្រាហ្វិក ១.៦: តំលៃនៃការនាំចេញសំលៀកបំពាក់ទៅសហរដ្ឋអាមេរិក




*ប្រភព: ផ្អែកលើទិន្នន័យ USITC*

## ក្រាហ្វិក ១.៨: តំលៃការនាំចូលក្នុងវិស័យសំណង់

(3mma yoy % change)



*ប្រភព: ផ្អែកលើទិន្នន័យ MoEF*

## ក្រាហ្វិក ១.៣: តំលៃនាំចេញ និងនាំចូល (3mma yoy % change)




*ប្រភព: ផ្អែកលើទិន្នន័យ MoEF*

## ក្រាហ្វិក ១.៤: ប្រភពនៃកំណើន




*ប្រភព: ផ្អែកលើទិន្នន័យ NIS, IMF (2009b)*

## ក្រាហ្វិក ១.៧: ភ្ញៀវអន្តរជាតិមកដល់ (yoy % change)




*ប្រភព: ផ្អែកលើទិន្នន័យ MoT*

## ក្រាហ្វិក ១.៩: រូបិយវត្ថុទូទៅ (yoy % change)




*ប្រភព: ផ្អែកលើទិន្នន័យ NBC*

ប្រុងប្រយ័ត្នផ្សេងៗ និងលទ្ធផលសំរេចបាន ហាក់ដូចបង្ហាញថា ប្រព័ន្ធធនាគារមានសាច់ប្រាក់បង្ការគ្រប់គ្រាន់ សំរាប់ដោះស្រាយហានិភ័យខាងឥណទាន ។

## ១.៣.៥ ឥទ្ធិពលលើភាពក្រីក្រៈ ប្រជាជននៅចំពោះមុខវិបត្តិ

អត្រាភាពក្រីក្រនៅកម្ពុជា បានធ្លាក់ចុះពីប្រហែល ៤៥% នៅឆ្នាំ១៩៩៤ មកត្រឹមប្រហែល ៣០% ក្នុងឆ្នាំ២០០៧ (Jalilian et al. 2009) ។ ប៉ុន្តែ វិបត្តិបានបញ្ឈប់និន្នាការថយចុះនេះ ហើយពីរវាងឆ្នាំ ២០០៧ និង ២០១០ ចំនួនប៉ាន់ស្មាននៃប្រជាជនក្រីក្រ អាចកើនឡើងពី ១-៤% (WB 2009) ។

ការបាត់បង់ការងារ និងភាពអត់មានការងារធ្វើកាន់តែច្រើន ក្នុងវិស័យជំរុញកំណើន ដែលវិបត្តិបានប៉ះទង្គិចខ្លាំងនៅកម្ពុជា បានជះឥទ្ធិពលអាក្រក់ទៅលើប្រាក់ចំណូលនៃគ្រួសារក្រីក្រ ។ ក្នុង ១១ខែ ដើមឆ្នាំ២០០៩ មាន ៩៣ រោងចក្រស្បែកជើង និងសំលៀកបំពាក់ បានបិទទ្វារជាស្ថាពរ នាំឱ្យបាត់បង់ការងារអស់ ៣៨.១៩០ (ឧសភា ២០០៩) ។ ការផ្អាកដំណើរការ នៃ ៦០ រោងចក្រ ក៏បានប៉ះពាល់ដល់ការងារចំនួន ៣៥.៣៣៧ ថែមទៀត ។ ម្យ៉ាងទៀត នាទីព័ត៌មានមួយក្នុងខែធ្នូ ២០០៩ បានផ្សាយថា ការងារខាងវិស័យសំណង់ បានបាត់បង់អស់ ១០០.០០០ (Pou 2009) ។ លទ្ធផលនៃអង្កេតមួយ ទៅលើ ៧២ សណ្ឋាគារ បានបង្ហាញថា មាន ១២ សណ្ឋាគារ បានកាត់បន្ថយអ្នកធ្វើការរអស់ ៣០-៥០% ហើយសណ្ឋាគារដទៃទៀត ក៏បានកាត់បន្ថយម៉ោងធ្វើការអស់ ៣០-៥០% លើបុគ្គលិកខ្លួនដែរ (Chun and Ith 2009) ។

អង្កេតនានា របស់ CDRI ស្តីពីប្រាក់ចំណូលប្រចាំថ្ងៃ បានបញ្ជាក់គាំទ្រដល់ការអះអាងថា មានការធ្លាក់ប្រាក់ចំណូលនៅតាមវិស័យផ្សេងៗ ក្នុងអំឡុងពេល GFEC ។ លទ្ធផលអង្កេតបង្ហាញថា ក្នុងចំណោមពលករទាំង ១០ ដែលបានធ្វើសំភាសន៍ មាន ៨ក្រុម បានធ្លាក់ចុះយ៉ាងច្រើន នូវប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យម នៅចន្លោះខែវិច្ឆិកា ២០០៧ និង វិច្ឆិកា ២០០៩ ប៉ុន្តែពេលវេលាធ្លាក់ចុះជាក់ស្តែងវាប្រែប្រួលខុសៗគ្នា[៩] ។ ការពិភាក្សាតាមក្រុមស្នូល និងសម្ភាសន៍ពាក់កណ្តាលរៀបរយ[១០] របស់ CDRI មិនត្រឹមតែគាំទ្រដល់លទ្ធផលរកឃើញខាងលើ អំពីការថយចុះការងារ និងប្រាក់ចំណូលពីប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្ហាញពីយន្តការសំរាប់ទប់ទល់ផ្សេងៗផងដែរ (ឧ. ការធ្លាក់ចុះគុណភាព និងបរិមាណប្រើប្រាស់ និងកំណើនបំណុល) ។

## ១.៤. មធ្យោបាយដើម្បីការងើបឡើងវិញ

ការឆ្លើយតបទៅនឹង GFEC ធ្វើបានយ៉ាងលឿន ដោយមានការអនុមតិប្រើជាទូទៅ នូវដំណោះស្រាយ Keynesian ដើម្បីទប់ទល់ការរីករាលដាលវិបត្តិ ។ ប៉ុន្តែ ទំហំនៃការឆ្លើយតបប្រែប្រួលខុសគ្នាទៅតាមប្រទេស ដោយប្រទេសដែលមានមធ្យោបាយច្រើន គេអាចអនុវត្តយុទ្ធសាស្ត្រស្រោចស្រង់សេដ្ឋកិច្ចបានគ្រប់ជ្រុងជ្រោយ ជាងប្រទេសដែលមិនសូវមានសមត្ថភាព ដូចជា កម្ពុជា ជាដើម ។ គេរំពឹងថា នៅឆ្នាំ២០១០ ផសស កម្ពុជានឹងមានកំណើនពី ៣-៥% (ក្រាហ្វិក ១.២) ។ ការងើបឡើងវិញក្នុងរយៈពេលខ្លី ពឹងផ្អែកមួយភាគធំលើការស្ទុះ

---

៩ សំរាប់ព័ត៌មានបន្ថែម សូមមើល Tong et al. 2009 ។

១០ សំរាប់ព័ត៌មានបន្ថែម សូមមើល Theng and Kem 2009a/b nig So 2009 ។

ឡើងវិញនៃបរិយាកាសខាងក្រៅ (កត្តារុញច្រាន) និងប្រតិកម្មឆ្លើយតប ហើយការងើបឡើងវិញប្រកបដោយចីរភាព ទាមទារការដោះស្រាយនូវចំនុចខ្សោយនានា ដែលមានក្នុងកត្តាទាក់ទាញ ។

## ១.៤.១ យុទ្ធសាស្ត្រអំណោយផលដល់ការងើបឡើងវិញ

### ១.៤.១.១ យុទ្ធសាស្ត្រពង្រីកថវិកា

គេប៉ាន់ស្មានថា ឱនភាពថវិកាឆ្នាំ២០០៩ ឡើងដល់ ៦,៧% នៃ ផសស គឺធំជាងគោលដៅបានគ្រោងទុកត្រឹម ៤,៣% (IMF 2009b, WB 2009) ។ ក្នុង ១១ខែ ដើមឆ្នាំ២០០៩ ប្រាក់ចំណូលប្រមូលបាន ថយចុះអស់ ៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០០៨ ដោយសារការធ្លាក់ចុះសេដ្ឋកិច្ច បានប៉ះពាល់ដោយផ្ទាល់ទៅលើកាប្រមូលពន្ធ ។ ក្នុងពេលជាមួយគ្នា ចំណាយបានកើនឡើង ២២% ។ សំរាប់ឆ្នាំ២០១០ ការពង្រីកថវិកា (តែមានឱនភាពទាបជាងមុន ត្រឹម៥,៥% នៃ ផសស[១១]) ត្រូវប្រើជាចាំបាច់ទៀត ដើម្បីជួយសំរួលផលប៉ះពាល់នៃការដកវិធានការជំរុញសេដ្ឋកិច្ច និងការបន្ថយសំពាធលើការផ្តល់ហិរញ្ញប្បទាន ។

បញ្ហាដ៏ធ្ងន់ធ្ងរមួយគឺ ចំណាយបន្ថែមមួយភាគធំណាស់ ត្រូវបានផ្តល់ទៅលើបៀវត្សរ៍កងទ័ព និងរាជការស៊ីវិលជាជាងលើវិស័យជាអាទិភាព ។ បើវិភាគតាមតំរូវការ ក្នុងការបង្កើនផលិតផលសរុប ការជួយទប់ការធ្លាក់ចុះចំណូលគ្រួសារ និងការរក្សាគាំពារការងើបសេដ្ឋកិច្ចឡើងវិញនោះ វិធីសាស្ត្រចំណាយដូចខាងលើ អាចពុំមានប្រសិទ្ធភាព ដូចជាការផ្តល់មូលនិធិបន្ថែម ទៅដល់ផ្នែកដែលរក្សាស្ថិរភាពជាស្វ័យប្រវត្តិ និងវិស័យអាទិភាពផ្សេងៗឡើយ ។ ជាមួយគ្នានេះ គេចាំបាច់ត្រូវតែគូសបញ្ជាក់ថា កង្វះការចាត់ចែងថវិកាឱ្យត្រឹមត្រូវ ទៅតាមផ្នែកជាអាទិភាពរបស់ជាតិ គឺជាបញ្ហាដែលត្រូវលើកឡើងដាច់ដោយឡែកពីការពិភាក្សា អំពីឥទ្ធិពលនៃវិបត្តិ ។

### ១.៤.១.២ ការជំរុញលំហូមូលធនឯកជន

ការដាស់ FDI និងវិនិយោគដទៃទៀត ឱ្យហូរចូលមកកម្ពុជាឡើងវិញ មិនត្រូវផ្អែកទៅលើការងើបឡើងវិញនៃបរិយាកាសខាងក្រៅតែមួយមុខនោះទេ ។ កត្តាទាក់ទាញលំហូរ FDI គឺលក្ខណៈប្រកួតប្រជែងរបស់ប្រទេស ដែលកំណត់ឡើងដោយភាពប្រកួតប្រជែង ទាំងនៅក៏រិតសហគ្រាស និងនៅទូទាំងប្រទេស ។ វិធានការរយៈពេលខ្លីដាក់អនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីរក្សាភាពទាក់ទាញដល់ FDI មានដូចជា ការផ្អាកយកពន្ធលើវិស័យកាត់ដេរ និងកសិកម្ម ជាដើម ។ ទោះយ៉ាងនេះក្តី ការងើបឡើងវិញនៃ FDI ឱ្យបានជាប់លាប់ ទាមទារការដោះស្រាយឧបសគ្គរាំងស្ទះជាយូរមកហើយ ដែលបង្កើនបន្ទុកចំណាយធ្វើអាជីវកម្មនៅកម្ពុជា ។ អង្កេតចុងក្រោយពីបរិយាកាសវិនិយោគ បានរកឃើញថា ឧបសគ្គចំបងៗ ដែលរាំងស្ទះអាជីវកម្មនៅកម្ពុជា គឺមានអំពើពុករលួយ ភាពមិនប្រាកដប្រជាខាងផ្លូវច្បាប់ និងមីក្រូហិរញ្ញវត្ថុ គោលនយោបាយប្រឆាំងការប្រកួតប្រជែង មានជាប់ពាក់ព័ន្ធអំពើពុករលួយ និងថ្លៃថាមពលខ្ពស់ (WB and IFC 2009) ។

ការជំរុញលំហូរប្រាក់ផ្ញើមកពីបរទេស មិនមែនជាការងារសាមញ្ញទេ ។ មធ្យោបាយធ្លាប់ប្រើបានល្អមួយសំរាប់បង្កើនការផ្ញើប្រាក់មកផ្ទះគឺ ការកាត់បន្ថយចំណាយក្នុងដំណើរការផ្ទេរប្រាក់ ដែលអាចសំរេចបានតាមរយៈ

---

១១ យោងតាម IMF 2009f ។

ការបង្កើតឱ្យមានការប្រកួតប្រជែងកាន់តែច្រើន ក្នុងសេវាកម្មផ្ទេរប្រាក់ និងការតំរូវឱ្យមានតម្លាភាពក្នុងការកំណត់តំលៃ ។

### ១.៤.១.៣ ការបន្ធូរវិធានការរឹតបន្តឹងខាងរូបិយវត្ថុ និងការកែលំអផ្នែកហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជា (NBC) បានបន្ធូរវិធានការរឹតបន្តឹងខាងរូបិយវត្ថុ ស្របពេលគ្នានឹងការធូរស្រាលសំពាធអតិផរណា ដោយបានកាត់បន្ថយការតំរូវជាធនបំរុង ពី ១៦% មកត្រឹម ១២% ហើយធនាគារបានលុបចោលការដាក់កំរិតលើការផ្ដល់ឥណទានទៅឱ្យវិស័យអចលនទ្រព្យ បានបង្កើតសេវាឥណទានលើសសមតុល្យ (overdraft facility) និងរឹតបន្តឹងបទបញ្ញត្តិស្តីពីការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្ម ជាដើម ។ ជាភ័ព្វអាក្រក់ ដុល្លាររូបនីយកម្មធ្ងន់ធ្ងរនៅកម្ពុជា និងសមត្ថភាពត្រួតពិនិត្យតិចតួចរបស់ស្ថាប័នធនាគារ បានកាត់បន្ថយលទ្ធភាពរបស់ NBC ដើម្បីធ្វើការឱ្យបានច្រើនថែមទៀត ។ បញ្ហាឥណទានមិនដំណើរការរបស់វិស័យធនាគារកម្ពុជា ចាំបាច់ត្រូវមានការត្រួតពិនិត្យឱ្យម៉ត់ចត់ ។

ភាពអន់ថយនៃវិស័យហិរញ្ញវត្ថុកម្ពុជា អាចជាកត្តានាំឱ្យកម្ពុជាគេចផុតពីឥទ្ធិពលជុំទី១ នៃវិបត្តិ ។ ប៉ុន្តែភាពអន់ថយនេះ ក៏ជាឧបសគ្គរារាំងដល់សមត្ថភាពរបស់រដ្ឋាភិបាល និងស្ថាប័នហិរញ្ញវត្ថុ ដើម្បីឆ្លើយតបឱ្យបានកាន់តែសក្តិសិទ្ធិ ចំពោះឥទ្ធិពលជុំទី២ នៃវិបត្តិដែរ ។ ប្រព័ន្ធហិរញ្ញវត្ថុ ចាំបាច់ត្រូវមានការកែលំអឱ្យបានស៊ីជម្រៅ ។ ទាក់ទងនឹងផែនការបង្កើតទីផ្សារមូលបត្រ កម្ពុជានៅខ្វះបុគ្គលក្ខខណ្ឌជាច្រើនទៀត ។

### ១.៤.១.៤ យុទ្ធសាស្ត្រជាក់លាក់ផ្សេងៗសំរាប់វិស័យជំរុញកំណើន

#### *១.៤.១.៤.១ វិស័យកាត់ដេរ*

កំណើនឡើងវិញនៃការនាំចេញ ពឹងផ្អែកយ៉ាងខ្លាំងលើការរើបឡើងវិញនៃវិស័យកាត់ដេរ ។ វិធានការឆ្លើយតបក្នុងរយៈពេលខ្លីរបស់រដ្ឋាភិបាល មានត្រឹមការផ្អាកយកពន្ធបង់មុនលើប្រាក់ចំណេញ និងការកាត់បន្ថយវិភាគទានរបស់និយោជក នៅក្នុងប្រព័ន្ធសន្តិសុខសង្គម (Prasidh 2009) ។ សំរាប់ដំណោះស្រាយរយៈពេលវែង រដ្ឋាភិបាល និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) បានធ្វើការលើយុទ្ធសាស្ត្រជាច្រើន ។ មេរៀនមួយទទួលបានពីបញ្ហាការបាត់បង់ចំណូលចិត្ត គឺកម្ពុជាត្រូវប្រឹងប្រែងកែលំអកត្តានានា ដែលបង្កើនភាពប្រកួតប្រជែងខាងតំលៃដើម ។ ប៉ុន្តែកិច្ចប្រឹងប្រែងភាគច្រើន ហាក់ដូចនៅតែផ្តោតលើការស្វែងរកលក្ខខណ្ឌអនុគ្រោះថ្មីៗមកជំនួស ឬក៏ការកែលំអលក្ខខណ្ឌនៅក្នុងប្រព័ន្ធអនុគ្រោះដែលមានស្រាប់ ។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជា និង GMAC បានព្យាយាមស្នើសុំច្រកចូលទៅកាន់ទីផ្សារសហរដ្ឋអាមេរិកដោយគ្មានបង់ពន្ធ និងភាពងាយបត់បែនជាងមុន នៃវិធានកំណត់ប្រភពដើម ក្រោមកម្មវិធីរបស់គ្រប់មុខក្រៅពីអាវុធ (Everything but Arms: EBA) ។ សរុបមក ប្រសិនបើគ្មានការដោះស្រាយឧបសគ្គផ្នែកផ្គត់ផ្គង់ ដែលវិស័យកាត់ដេរនៅកម្ពុជាកំពុងប្រឈមមុខនោះទេ កម្ពុជានឹងត្រូវចាញ់គេ ឬក៏មិនអាចទាញយកប្រយោជន៍បានជាអតិបរមា ពីកិច្ចព្រមព្រៀងគ្មានបដិការនានា ។ ការដោះស្រាយឧបសគ្គចំបងៗ ដូចជា អំពើពុករលួយ ថ្លៃថាមពលខ្ពស់ និងកង្វះទំនាក់ទំនងខាងការផ្គត់ផ្គង់ ជាដើម ត្រូវកំណត់ជាការងារសំខាន់នៅក្នុងរបៀបវារៈ ។

### ១.៤.១.៤.២ វិស័យទេសចរណ៍

ការសំរួលដល់ការធ្វើដំណើរ ការបង្កើនសកម្មភាពម៉ាឃីតទីង និងការកាត់បន្ថយបន្ទុកចំណាយ គឺជាដំណោះស្រាយសំខាន់ហុចផលលឿន សំរាប់ទប់ទល់ការធ្លាក់ចុះវិស័យទេសចរណ៍ ។ វិធានការរយៈពេលវែងសំដៅលើកកំពស់គុណភាពទេសចរណ៍ កែលំអហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងការធ្វើចំរុះកម្មទីផ្សារ បានដាក់អនុវត្តហើយ ។ វិធានការចុងក្រោយ ទំនងពិបាកសំរេចបានជាងគេ ដោយសារការផ្តោតចិត្តខ្លាំងពេកទៅលើប្រាសាទអង្គរវត្តជាពិសេស និងប៉ូលអភិវឌ្ឍន៍ទាំងបី គឺសៀមរាប-ក្រុងព្រះសីហនុ-ភ្នំពេញ ជារួម ។ កម្ពុជាចាំបាច់ត្រូវតែធ្វើចំរុះកម្ម ខឿននៃវិស័យទេសចរណ៍របស់ខ្លួន ។

### ១.៤.១.៤.៣ វិស័យសំណង់

ការងើបឡើងវិញនៃវិស័យសំណង់ វាផ្សារភ្ជាប់នឹងការកើនឡើងវិញ នៃសកម្មភាពខាងអចលនទ្រព្យ ។ NBC បានលុបចោលរួចហើយ នូវការដាក់កំរិតអតិបរមាត្រឹម ១៥% លើការផ្តល់ឥណទានដល់វិស័យអចលនទ្រព្យ ។ គេសង្ឃឹមថា ការអនុញ្ញាតឱ្យជនបរទេសមានកម្មសិទ្ធិធ្វើលើអចលនទ្រព្យនៅកម្ពុជា គឺជាដំណោះស្រាយមួយកាន់តែមានចីរភាពថែមទៀត ។ នៅពាក់កណ្តាលឆ្នាំ២០០៩ មានការអនុម័តអនុក្រឹត្យមួយ ស្តីពីការអនុញ្ញាតនូវសហកម្មសិទ្ធិលើផ្ទះល្វែង ឬផ្ទះកុងដូ ។ ជាលទ្ធផល ជនបរទេសត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិធ្វើជាម្ចាស់លើបន្ទប់ ឬផ្នែកនៃអគារឯកជន ចាប់ពីជាន់ទីមួយឡើងទៅ[១២] ។ ការព្រួយបារម្ភចំបងមួយក្នុងរឿងនេះគឺ តើការអនុញ្ញាតឱ្យមានកម្មសិទ្ធិជនបរទេសនេះ នឹងបង្កើនការឆក់ឱកាសទាញយកចំណេញពីផ្នែកអចលនទ្រព្យខ្លាំងប៉ុណ្ណា ហើយប៉ះពាល់ប៉ុណ្ណា ដល់លទ្ធភាពទិញផ្ទះរបស់ប្រជាជនកម្ពុជាដែលមិនសូវធូរធារ ។

### ១.៤.១.៤.៤ វិស័យកសិកម្ម

វិស័យកសិកម្ម អាចរក្សាកំណើនថេរ ៥% ក្នុងអំឡុងពេល GFEC ។ ក្នុងពេលចំពោះមុខវិស័យនេះមានអនាគតល្អ ដោយបានពង្រីកតួនាទីពីទ្រនាប់ទប់ទល់វិបត្តិ ទៅជាសរសរទ្រូងទ្រទ្រង់ការរើបឡើងវិញនៃសេដ្ឋកិច្ចក្នុងរយៈពេលខ្លី ។ ដើម្បីក្តាប់យកនូវសក្តានុពលរបស់វិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់អនុវត្តវិធានការមួយចំនួន មានជាអាទិ ការបង្កើត មូលនិធិទ្រទ្រង់និងអភិវឌ្ឍន៍វិស័យកសិកម្ម ការលើកលែងមិនយកពន្ធរយៈពេលពាឆ្នាំ ដល់គំរោងវិនិយោគខាងកសិកម្ម និងការយកពន្ធសូន្យភាគរយលើការនាំចូលសម្ភារៈកសិកម្ម[១៣] ។ សំរាប់រយៈពេលវែងវិញ រដ្ឋាភិបាលត្រូវបង្កើនទាំងបរិមាណ និងប្រសិទ្ធភាពនៃចំណាយសាធារណៈ ទៅលើវិស័យកសិកម្ម ដើម្បីអាចដោះស្រាយនូវហានិភ័យទាំងចាស់ ទាំងថ្មី និងទាញយកចំណេញពីឱកាសល្អៗ ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ។

---

១២ សូមមើល CDRI (2009d) ។

១៣ សំរាប់ព័ត៌មានបន្ថែម សូមមើល Jalilian et al. 2009 ។

### ១.៤.១.៥ ប្រព័ន្ធសុវត្ថិភាពសង្គម

ជាមធ្យម មិនដល់ ១% នៃ ផសស របស់កម្ពុជាទេ ដែលបានផ្តល់ទៅឱ្យប្រព័ន្ធសុវត្ថិភាពសង្គម (Broderick 2009) ។ មកទល់ពេលនេះ អន្តរាគមន៍ខាងសង្គមកិច្ច មានលក្ខណៈដាច់ដោយដុំ គ្មានការសំរបសំរួល មានចំនួនតិចតួច កើតមានតាមព្រឹត្តិការណ៍ និងមិនមានចីរភាពឡើយ (CARD, WFP and WB 2009) ។ ជាបន្ថែមលើប្រព័ន្ធសុវត្ថិភាពសង្គមជាច្រើនដែលមានស្រាប់[១៤] រដ្ឋាភិបាលបានបង្កើតក្នុងអំឡុងពេលនៃវិបត្តិ នូវមូលនិធិរដ្ឋាភិបាលសំរាប់វគ្គបណ្តុះបណ្តាលជំនាញរយៈពេលខ្លី និងមូលនិធិសំរាប់ទ្រទ្រង់ការប្រកបរបរដោយខ្លួនឯង ដោយទទួលបានមូលនិធិពីម្ចាស់ជំនួយនានា[១៥] ។ ដើម្បីឱ្យមានចីរភាពកាន់តែប្រសើរ ប្រព័ន្ធសុវត្ថិភាពទាំងនេះ ត្រូវដាក់ដំណើរការនៅក្រោមប្រព័ន្ធសុវត្ថិភាពសង្គមគ្រប់ជ្រុងជ្រោយមួយ ។

## ១.៥. សន្និដ្ឋាន

ការធ្លាក់ចុះនៃសេដ្ឋកិច្ច ជាការដាស់ស្មារតីយ៉ាងឈឺចាប់មួយ ដែលធ្វើឱ្យមនុស្សឈប់ស្រមើស្រមៃ ។ បទពិសោធន៍ដែលកម្ពុជាទទួលបានពី GFEC បង្ហាញថា វិបត្តិគ្រាន់ជាផ្នែកមួយនៃបញ្ហាប៉ុណ្ណោះ ។ ការរើបឡើងវិញប្រកបដោយចីរភាព ផ្អែកលើភាពស្រស់ថ្លានៃបរិយាកាសខាងក្រៅ ហើយជាងនេះទៀត គឺភាពប្រសើរឡើងនៃកត្តាទាក់ទាញផ្សេងៗ ។ ដើម្បីមានកំណើនរយៈពេលវែង ត្រូវតែឈានឱ្យផុតពីការពឹងផ្អែកផ្សេងៗ ដែលធ្លាប់មានតាំងពីដើមរៀងមក ។ ត្រូវផ្តោតកម្លាំងលើការអភិវឌ្ឍទិដ្ឋភាពផ្សេងៗនៃការប្រកួតប្រជែង ដែលធ្លាប់តែមិនយកចិត្តទុកដាក់ក្នុងពេលកន្លងមក ហើយឆន្ទៈនយោបាយ ក៏ត្រូវតែពង្រឹងឡើង ដើម្បីជំរុញឱ្យកំណែទំរង់ដ៏ចាំបាច់នានាខាងរចនាសម្ព័ន្ធ និងអភិបាលកិច្ច អាចចេញជាផ្លែផ្កា ។

---

១៤ សូមមើល Jalilian et al. 2009 ។

១៥ សូមមើល Jalilian et al. 2009 ។

# ជំពូក ២
# ការប៉ះទង្គិចពីរជាន់លើប្រជាជនក្រីក្រ៖ សន្តិសុខស្បៀងនៅកម្ពុជា ក្នុងពេលមានវិបត្តិស្បៀង និងវិបត្តិសេដ្ឋកិច្ច[1]

*ដោយបណ្ឌិត Hossein Jalilian, Glenda Reyes និង លន់ ពិដេ*

## ២.១. សេចក្តីផ្តើម

វិបត្តិស្បៀង និង វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល (GFEC) ជាការប៉ះទង្គិចពីរជាន់ លើប្រជាជនក្រីក្រ ។ វិបត្តិទាំងពីរនេះ បង្កផលប៉ះពាល់អាក្រក់ដូចគ្នា ធ្វើឱ្យប្រជាជនក្រីក្រមានអសន្តិសុខស្បៀងកាន់តែធ្ងន់ធ្ងរឡើង ដូច្នេះហើយ ក៏មានការប្រកាសសញ្ញាអាសន្ន ២ ។ សញ្ញាអាសន្នទី១ ជាការព្រមាន ចំពោះការមិនយកចិត្តទុកដាក់តាំងពីដើមរៀងមក ក្នុងការអភិវឌ្ឍវិស័យកសិកម្ម ។ សញ្ញាអាសន្នទី២ ជាការបង្ហាញ ពីចំណងទាក់ទងកាន់តែខ្លាំងឡើង រវាងទីផ្សារទំនិញអាហារ និងទីផ្សារទំនិញមិនមែនអាហារ ដែលនាំឱ្យមានទាំងហានិភ័យ និងឱកាសល្អៗ សំរាប់កម្ពុជា ។ ភាពបើកចំហខ្លាំងខាងពាណិជ្ជកម្ម ធ្វើឱ្យកម្ពុជាប្រឈមមុខនឹងហានិភ័យ ហើយឧត្តមភាពប្រៀបធៀបខាងកសិកម្ម ផ្តល់ឱកាសល្អឱ្យកម្ពុជាទាញយកបានផលចំណេញ ។

អត្ថបទនេះ ពិនិត្យមើលពីផលប៉ះពាល់នៃវិបត្តិស្បៀង និង GFEC ទៅលើសន្តិសុខស្បៀង និងកសិកម្មនៅកម្ពុជា ។ អត្ថបទនេះ សង្ខេបចេញពីអត្ថបទធំ ដែលរៀបរៀងដោយក្រុមអ្នកនិពន្ធតែមួយ[2] ។ ផ្នែកទី ២.២ ពិនិត្យពីកត្តាកំណត់មួយចំនួន នៃផលប៉ះពាល់នៃវិបត្តិទៅលើសន្តិសុខស្បៀង និងអធិប្បាយពីផលប៉ះពាល់នៃវិបត្តិស្បៀងនៅកម្ពុជា ។ ផ្នែកទី ២.៣ បកស្រាយពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល ទៅលើសន្តិសុខស្បៀងនៅកម្ពុជា ។ ផ្នែកទី ២.៤ ជាការសន្និដ្ឋានសរុប ។

## ២.២. វិបត្តិស្បៀង និងសន្តិសុខស្បៀងនៅកម្ពុជា

លក្ខណៈខុសគេទាំងអស់ នៃចលនាថ្លៃស្បៀងនៅឆ្នាំ២០០៧-០៨ គឺទំនិញជាស្បៀង និងមិនមែនស្បៀងសំខាន់ៗ សឹងតែទាំងអស់ បានឡើងថ្លៃក្នុងពេលតែមួយ (FAO 2008) និងបែបបទដែលកម្លាំងជំរុញទាំងចាស់ ទាំងថ្មី បានបង្កើតឡើងនូវនិន្នាការរយៈពេលវែងមួយ នៃកំរិតខ្ពស់ជាងធម្មតានៃថ្លៃស្បៀង ។ សំរាប់ខែនីមួយៗ ក្នុងឆមាសទី១ ឆ្នាំ២០០៨ សន្ទស្សន៍ថ្លៃស្បៀងពិភពលោក មានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ជាមធ្យមលើសពី ៥០% ។ សន្ទស្សន៍ថ្លៃទំនិញមិនមែនស្បៀងចំបងៗក្នុងពិភពលោក ក៏មានកំណើនគំហុកប្រហែលគ្នាដែរ (ក្រាហ្វិក ២.១) ។ ផលិតកម្ម

---

១ ដោយបណ្ឌិត Hossein *Jalilian* ជានាយកផ្នែកស្រាវជ្រាវ និង Glenda *Reyes* និង លន់ ពិដេ ជាអ្នក ស្រាវជ្រាវនៅវិទ្យាស្ថាន CDRI ។

២ ឯកសារជិតចេញផ្សាយនេះ រៀបរៀងឡើងដោយ Jalilian, Reyes and Lun សំរាប់អង្គការ FAO ។

ជីវឥន្ធនៈ ថ្លៃប្រេងខ្ពស់ជាងមុន និងការធ្លាក់ថ្លៃប្រាក់ដុល្លារ ជាកត្តាចំបងៗដែលបង្កការឡើងថ្លៃស្បៀង ។ មូលហេតុរយៈពេលវែង គឺភាពស្លឹកទ្រីងនៃជំនួយ និងវិនិយោគសាធារណៈក្នុងវិស័យកសិកម្ម[៣] ។

ដើម្បីវិភាគពីឥទ្ធិពលនៃវិបត្តិទៅលើសន្តិសុខស្បៀង ត្រូវធ្វើការពិនិត្យសង្កេតលើកត្តាកំណត់ជាច្រើន ដូចជាការផ្ទេរកំរិតថ្លៃ លក្ខណៈនៃចំណាយប្រើប្រាស់របស់គ្រួសារ ចំណូលនិងចំណាយ ចម្លើយតបជាការផ្គត់ផ្គង់ផលិតផលកសិកម្ម និងចម្លើយតបរបស់រដ្ឋាភិបាល ។

## ២.២.១ ការផ្ទេរកំរិតថ្លៃ

វិបត្តិស្បៀងបានរាលដាលទូទាំងកម្ពុជា ។ អតិផរណាពីមួយឆ្នាំទៅមួយឆ្នាំនៅកម្ពុជា ឡើងដល់ ៣៦% នៅខែឧសភា ២០០៨ ធៀបនឹងអត្រាជាមធ្យមតិចជាង ៨% នៅតាមខែនីមួយៗក្នុងឆ្នាំ២០០៧ ។ អតិផរណាថ្លៃស្បៀងឡើងដល់ជាង ៥០% នៅខែ ឧសភា ២០០៨ ក្នុងនេះ សន្ទស្សន៍ថ្លៃអង្ករឡើងដល់ ១០៦% ។ ថ្លៃទំនិញមិនមែនស្បៀង ក៏បានស្ទុះឡើងដែរ (ក្រាហ្វិក ២.២) ។

ថ្លៃទំនិញក្នុងស្រុក មិនមែនថ្លៃទំនិញអន្តរជាតិទេ ដែលកំណត់ជីវិកា និងការចំណាយរបស់គ្រួសារ ។ ទោះជាយ៉ាងនេះក្តី លោក Timmer (2008) ផ្តល់គំនិតថា យ៉ាងហោចណាស់ ៧៥% នៃកំណើនថ្លៃស្បៀងអន្តរជាតិត្រូវបានផ្ទេរចូលមកជាបំរែបំរួលថ្លៃក្នុងស្រុក នៅក្នុងប្រទេសមានពាណិជ្ជកម្មសេរី ។ សំរាប់បណ្តា "ប្រទេសរក្សាស្ថិរភាព (stabilisers)" រដ្ឋាភិបាលធ្វើអន្តរាគមន៍ការពារកំរិតថ្លៃបានសក្តិសិទ្ធិគួរសម ទល់នឹងការឡើងចុះថ្លៃនៅទីផ្សារអន្តរជាតិ ។ កម្លាំងរូបិយវត្ថុជាតិ ទល់នឹងដុល្លារអាមេរិក ក៏មានឥទ្ធិពលលើការផ្ទេរកំរិតថ្លៃដែរ ។

ការផ្ទេរកំរិតថ្លៃក្នុងអត្ថបទនេះ បានគណនាឡើងតាមវិធីរបស់ Dawe (2008)[៤] ។ អង្ករជាទំនិញសំខាន់ក្នុងកញ្ចប់ចំណាយប្រើប្រាស់របស់គ្រួសារកម្ពុជា ដូច្នេះ យើងបានយកចិត្តទុកដាក់ខ្លាំងលើការផ្ទេរថ្លៃអង្ករ ។ យើងក៏យកចិត្តទុកដាក់លើប្រេងឥន្ធនៈ និងជី ដែរ ព្រោះនិន្នាការថ្លៃទំនិញទាំងពីរនេះ មានផលប៉ះពាល់ច្រើនលើការផ្គត់ផ្គង់ដើម្បីឆ្លើយតបនឹងអតិផរណាថ្លៃស្បៀង ។

ក្រាហ្វិក ២.៣ បង្ហាញពី ថ្លៃអង្ករក្នុងស្រុក និងអន្តរជាតិ គិតជារៀល ។ គេឃើញថា នៅប្រហែលពាក់កណ្តាលឆ្នាំ២០០៨ ថ្លៃអង្ករក្នុងស្រុកឈប់រត់កៀកថ្លៃអង្ករអន្តរជាតិ ។ លទ្ធផលនៃការគណនាបង្ហាញថា នៅខែមីនា-សីហា ២០០៨ បើធៀបនឹង ខែកញ្ញា ២០០៧-កុម្ភៈ ២០០៨ ការផ្ទេរបម្លាស់ប្តូរថ្លៃអង្ករអន្តរជាតិចូលក្នុងថ្លៃអង្ករក្នុងស្រុក មានត្រឹមតែ ៦៨% ប៉ុណ្ណោះ (តារាង ២.១) ។ ទោះយ៉ាងនេះក្តី តួលេខនេះមិនគ្រប់គ្រាន់ ដើម្បីធ្វើចំណាត់ថ្នាក់កម្ពុជា ជាប្រទេសរក្សាស្ថិរភាពថ្លៃ ដូចប្រទេសដទៃឡើយ ។ វាក៏ស្របគ្នានឹងរបាយការណ៍ដែលថា ការហាមឃាត់ការនាំចេញអង្ករមិនសូវមានប្រសិទ្ធភាពទេ ។

ក្រាហ្វិក ២.៤ បង្ហាញពី បែបបទដែលថ្លៃជី និងប្រេងឥន្ធនៈនៅកម្ពុជា វាខ្ពស់ខ្លាំងជាងនៅអន្តរជាតិ ។ កត្តាជាច្រើន ដូចជា គោលនយោបាយពន្ធដារ ថ្លៃដឹកជញ្ជូន និងចលនាអត្រាប្តូរប្រាក់ ។ល។ ជាកត្តាដែលបង្កភាពខុសគ្នារវាងថ្លៃប្រេងឥន្ធនៈក្នុងស្រុក និងអន្តរជាតិ ។ សមាសភាគពន្ធប្រេងសាំងនៅកម្ពុជា នៅថេរខ្លាំងណាស់ និងជា

---

៣ សំរាប់ការសិក្សាពាក់ព័ន្ធ សូមមើល Abbot, Hurt and Tyner (2008), Heady and Fan (2008), Timmer (2008) ។

៤ ការគណនានេះ ប្រើអត្រាប្តូរប្រាក់ធម្មតា ។

មូលហេតុដែលថ្លៃសាំងនៅកម្ពុជា មិនសូវឡើងចុះ និងមិនសូវរងការឆ្លងចូលថ្លៃអន្តរជាតិ (WB Cambodia 2009) ។ ការគណនា បង្ហាញថា មានប្រហែល ៦០% នៃបំរែបំរួលថ្លៃពិភពលោក បានឆ្លងចូលមកកម្ពុជា នៅត្រីមាសទី៣ ឆ្នាំ២០០៨ បើធៀបនឹងឆ្នាំ២០០៧ (តារាង ២.២) ។

ថ្លៃជីអ៊ុយរ៉េក្នុងស្រុក បានឡើងខ្ពស់ជាងនៅអន្តរជាតិ ។ ការគណនាផ្សេងៗបង្ហាញថា ថ្លៃជីអ៊ុយរ៉េក្នុងស្រុកជាមធ្យម បានកើនលើសបំរែបំរួលថ្លៃអន្តរជាតិជាមធ្យម នៅត្រីមាសទី៣ ឆ្នាំ២០០៨ ធៀបនឹងឆ្នាំ២០០៧ ។ ចំណាយក្រៅផ្លូវការ និងចំណាយនាំចូលខ្ពស់ ជាដើមហេតុចំបងនៃថ្លៃជីកសិកម្មខ្ពស់នៅកម្ពុជា ។

**តារាង ២.១: ការផ្ទេកំរិតថ្លៃអង្ករក្នុងអំឡុងពេលវិបត្តិស្បៀង**

| អំឡុងពេល | ថ្លៃពិភពលោក (US$) | ថ្លៃពិភពលោក (DC) | ថ្លៃក្នុងស្រុក (DC) | ថ្លៃឆ្លងចូល (3/1,%) |
|---|---|---|---|---|
| ត្រីមាសទី៤ ២០០៧ - ត្រីមាសទី៤ ២០០៨ | 104 | 109 | 88 | 85 |
| កញ្ញា ២០០៧ កុម្ភៈ ២០០៨ និង មីនា-សីហា ២០០៨ | 109 | 110 | 74 | 68 |

*កំណត់សំគាល់: ១/មុខទំនិញសំដៅដល់: ក្នុងស្រុក (អង្ករគុណភាពលេខ២) និង អន្តរជាតិ (អង្ករថៃបាក់ ៥%) ។*

*២/ការហាមប្រាមការនាំចេញអង្កររបស់កម្ពុជា មានប្រសិទ្ធភាពចាប់ពីខែមីនា ដល់ ឧសភា ២០០៨ ប៉ុន្តែគេបានជ្រើសប្រើរយៈពេលវែងជាងនេះ ដើម្បីគិតបញ្ចូលនូវឥទ្ធិពលយឺតយ៉ាវ ដែលអាចកើតមាន ។*

*ប្រភព: ទិន្នន័យពី NIS, IRRI*

**តារាង ២.២ : ការផ្ទេរកំរិតថ្លៃទំនិញមិនមែនស្បៀងក្នុងអំឡុងពេលវិបត្តិស្បៀង (២០០៧-ត្រីមាសទី៣ ២០០៨)**

| ផលិតផល | ថ្លៃពិភពលោក (US$) | ថ្លៃពិភពលោក (DC) | ថ្លៃក្នុងស្រុក (DC) | ថ្លៃឆ្លងចូល (3/1,%) |
|---|---|---|---|---|
| សាំង | 44 | 47 | 21 | 48 |
| ជី | 141 | 146 | 149 | 106 |

*កំណត់សំគាល់: មុខទំនិញសំដៅដល់ : ក្នុងស្រុក (សាំង ជីអ៊ុយរ៉េ ) និង អន្តរជាតិ (ថ្លៃលក់ដល់ដៃ សាំងធម្មតាសិង្ហបុរី និង ជីអ៊ុយរ៉េ (អឺរ៉ុប)) ។*

ប្រភព: ទិន្នន័យពី NIS, MAFF, IRRI & US EIA

## ២.២.២ ទំរង់នៃការប្រើប្រាស់ស្បៀង ប្រាក់ចំណូល និងការចំណាយ

ឥទ្ធិពលនៃវិបត្តិស្បៀង ជាប់ទាក់ទងមួយភាគធំលើលក្ខណៈនៃរបបអាហារ លំនាំការចំណាយ និងការបង្កើនប្រាក់ចំណូល ។ ចំណែកនៃចំណាយប្រើប្រាស់ស្បៀងនៅកម្ពុជា មានទំនាក់ទំនងអវិជ្ជមានជាមួយប្រាក់ចំណូលក្នុងមនុស្សម្នាក់ ។ នៅឆ្នាំ២០០៧ ស្បៀងតំណាងឱ្យជាង ២ភាគ៣ នៃចំណាយប្រើប្រាស់សរុបរបស់ប្រជាជនក្រីក្រ

បំផុតចំនួន ២០% និងតិចជាងពាក់កណ្ដាល នៃចំណាយប្រើប្រាស់សរុបរបស់ប្រជាជនធូរធារបំផុតចំនួន ២០%[៥] ។ លទ្ធផលនៃអង្កេតឆ្នាំ២០០៨ របស់វិទ្យាស្ថាន CDRI (តារាង ២.៣) បានបញ្ជាក់ថា អង្ករ គឺអាហារមូលដ្ឋានសំខាន់នៅកម្ពុជា និងមិនទាន់មានធញ្ញជាតិណា មកជំនួសស្រូវអង្កររឡើយ ។ អង្ករ ក៏តំណាងឱ្យប្រហែល ៦៥% នៃកាឡូរីហូបចូលសរុបនៅកម្ពុជាដែរ[៦] ។ ដូច្នេះ កង្វះរបស់មានស្រាប់សំរាប់ជំនួសអង្ករ មានផលប៉ះពាល់ធំណាស់ដល់អាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជា ។

**តារាង ២.៣: ភាពញឹកញាប់ជាមធ្យមនៃចំណាយប្រើប្រាស់ជាអាហាររបស់គ្រួសារ**

| | | ប្រទេសកម្ពុជា | ជនបទ | ទីក្រុង | ភ្នំពេញ |
|---|---|---|---|---|---|
| គ្រាប់ធញ្ញជាតិ និងមើម | អង្ករ | 7.0 | 7.0 | 7.0 | 7.0 |
| | ពោត | 0.2 | 0.2 | 0.3 | 0.4 |
| | នំប៉័ង | 0.4 | 0.2 | 0.8 | 1.2 |
| | ដំឡូងឈើ/ដំឡូងដូង | 0.2 | 0.2 | 0.1 | 0.3 |
| | ដំឡូងជ្វា/ដំឡូងបារាំង | 0.2 | 0.2 | 0.3 | 0.5 |

*ប្រភព: CDRI (2008)*

ការប្រៀបធៀបមុខចំណាយប្រើប្រាស់របស់គ្រួសារ ទៅនឹងតំរូវការរបបហូបចុកចំរុះ បង្ហាញថា នៅកម្ពុជា ប្រជាជន ដែលមានអសន្តិសុខស្បៀងនៅរដូវខ្វះខាត មានប្រហែល ២,៧៥លាននាក់ (ឬ ២០% នៃចំនួនប្រជាជនសរុប) ហើយក្នុងនេះ ប្រហែល ៩១% រស់នៅតំបន់ជនបទ (ក្រាហ្វិក ២.៥) ។

ភាពខុសគ្នាដ៏សំខាន់មួយត្រូវសំគាល់ឱ្យច្បាស់ គឺរវាងអ្នកលក់ស្បៀងសុទ្ធ និងអ្នកទិញស្បៀងសុទ្ធ ។ ការស្ទុះឡើងថ្លៃផលិតផល គឺជាលាភសំរាប់អ្នកលក់សុទ្ធ ប៉ុន្តែជារឿងស៊យសំរាប់អ្នកទិញសុទ្ធ ។ លទ្ធផលនៃអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៧ (CSES)[៧] បង្ហាញថា ក្នុងករណីអង្ករ អ្នកលក់សុទ្ធភាគច្រើនជាអ្នកនៅតំបន់ជនបទ (៩៩% នៃគ្រួសារធ្វើអង្កេត) ហើយអ្នកទិញសុទ្ធភាគច្រើន ជាអ្នករស់នៅតំបន់ទីក្រុង (ប្រហែល ៧៧%) (តារាង ៤) ។

**តារាង ២.៤: ប្រភពនៃចំណាយប្រើប្រាស់ជាអាហារ (គិតជា % នៃគ្រួសារ)**

| | ប្រទេសកម្ពុជា | ជនបទ | ទីក្រុង | ភ្នំពេញ |
|---|---|---|---|---|
| អង្ករ | | | | |
| ផលិតកម្មផ្ទាល់ខ្លួន | 49.8 | 59.3 | 13.3 | 8 |
| ទិញពីគេ | 50.2 | 35.3 | 81.1 | 90 |

*ប្រភព: CDRI (2008)*

៥ ផ្អែកលើទិន្នន័យដែលបង្ហាញក្នុង WB (2009c) ។

៦ វិទ្យាស្ថាន CDRI (2008) ។

៧ ទិន្នន័យ CSES 2004 and 2007 ទាំងអស់ ដែលឯកសារនេះបានយោងដល់ គឺជាទិន្នន័យមានបង្ហាញក្នុងឯកសារ WB (2009c) ។

ចំណុចសំខាន់មួយទៀត ត្រូវពិចារណាគឺ ភាពខ្លាំងក្លានៃការលក់ និងការទិញស្បៀងសុទ្ធ ។ អ្នកលក់ស្បៀងសុទ្ធនៅកម្ពុជា មានអតិរេកអង្ករតិចតួចណាស់សំរាប់លក់ ។ ក្នុងចំណោមគ្រួសារមានឱនភាពអង្ករ ភាគច្រើនគ្រាន់តែជាអ្នកទិញស្បៀងសុទ្ធបន្ទាប់បន្សំប៉ុណ្ណោះ ។ ពួកគេច្រើនតែជាគ្រួសារធូរធាររស់នៅទីក្រុង ដែលចំណាយប្រាក់ចំណូលមួយភាគតូចប៉ុណ្ណោះ លើអាហារ (Aksoy and Isik-Dikmelik 2009) ។

ចំណុចត្រូវគិតគូរសំខាន់មួយទៀតគឺ ការបង្កើនប្រាក់ចំណូលក្នុងមនុស្សម្នាក់ ដែលអាចជួយលុបបំបាត់ផលប៉ះពាល់នៃអតិផរណា ។ លទ្ធផលអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ២០០៤ និង ២០០៧ បង្ហាញច្បាស់ថា ទោះបីជាមានកំណើនថ្លៃអាហារ នៅចន្លោះឆ្នាំបានធ្វើអង្កេតទាំងពីរនេះក្តី ក៏ចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ និងសូចនាករភាពក្រីក្រ បានប្រែប្រួលប្រសើរឡើងសំរាប់គ្រប់ក្រុមទាំងអស់ ។ រឿងនេះ មកពីប្រាក់ចំណូលមនុស្សម្នាក់ បានកើនឡើង ៩% ពីឆ្នាំ២០០៤ ដល់ ២០០៧[៨] ។

## ២.២.៣ តារាងតុល្យការនៃផលិតកម្មកម្ពុជា

ការពិនិត្យទិន្នន័យផលិតកម្មអាហារមានសារៈសំខាន់ណាស់ ពីព្រោះផលប៉ះពាល់ចុងក្រោយទៅលើសន្តិសុខស្បៀង វាជាប់ទាក់ទងនឹង ការផ្គត់ផ្គង់ដើម្បីឆ្លើយតបទៅនឹងឥទ្ធិពលនៃវិបត្តិថ្លៃអាហារ ។ កម្ពុជា បានក្លាយជាប្រទេសនាំចេញអង្ករសុទ្ធ ចាប់តាំងពីប្រហែលឆ្នាំ២០០៤ (WB 2009a) ។ កំណើនការនាំចេញ អាចសំរេចទៅបានដោយសារមានកំណើនក្នុងផលិតកម្ម ។ ក្នុងឆ្នាំ១៩៩៨-២០០៧ ផលិតកម្មស្រូវកើនឡើងជាមធ្យមប្រហែល ៨% ក្នុងមួយឆ្នាំ ។ ប៉ុន្តែ បើប្រៀបធៀបនឹងប្រទេសជិតខាង គឺ ថៃ និងវៀតណាមនោះ គេឃើញ ទិន្នផលស្រូវនៅកម្ពុជានៅទាបជាងគេនៅឡើយ[៩] ។ ឧបសគ្គចំបងៗ ដល់ការបង្កើនទិន្នផល រួមមាន ការប្រើគ្រឿងយន្តតិច ការប្រើជីនៅអន់ខ្សោយ ប្រព័ន្ធធារាសាស្ត្រមិនគ្រប់គ្រាន់ អសន្តិសុខដីធ្លីជាទូទៅ និងវិនិយោគសាធារណៈមានកំរិតទាប ។ ការឡើងថ្លៃធាតុចូលយ៉ាងគំហុក ដូចជា សាំង និងជី ជាដើម បានធ្វើឱ្យបញ្ហាកាន់តែស្មុគស្មាញឡើងក្នុងអំឡុងពេលមានវិបត្តិអាហារ ។ ដោយសន្មតថា ការប្រើប្រាស់ជី គឺជាអថេរក្នុងរយៈពេលខ្លី លោក Yu and Fan (2009) បានរកឃើញនូវភាពយឺតវិជ្ជមាននៃថ្លៃយ៉ាងតូចមួយប៉ុណ្ណោះ សំរាប់ការផ្គត់ផ្គង់ស្រូវប្រាំង និងស្រូវវស្សានៅក្នុងរយៈពេលខ្លី ។ ដោយសន្មតថា ឧបសគ្គដទៃទៀតបានធូរស្រាលឡើងនៅចុងបញ្ចប់ ដូច្នេះ ភាពយឺតក្នុងរយៈពេលវែង ត្រូវកើនលើសពី ១ ។

---

៨ ផ្អែកលើទិន្នន័យ NIS and MoEF ។

៩ សូមមើល FAOSTAT សំរាប់ទិន្នន័យលើទិន្នផល (ស្រូវ) ។

## ក្រាហ្វិក ២.១: សន្ទស្សន៍ថ្លៃផលិតផលសាកល




*ប្រភព: FAO, IMF*

## ក្រាហ្វិក ២.២: អតិផរណាថ្លៃស្បៀង និងទំនិញមិនមែនស្បៀងក្នុងស្រុក




*កំណត់សំគាល់: សន្ទស្សន៍ថ្លៃដែលយកមកប្រើ ផ្អែកលើរយៈពេលខែតុលា-ធ្នូ ២០០៦*

*ប្រភព: ផ្អែកលើទិន្នន័យ NIS*

## ក្រាហ្វិក ២.៣: ថ្លៃអង្ករ, ពាន់រៀលក្នុងមួយតោន




*កំណត់សំគាល់: Subject commodities specifically refer to the ff : Domestic: rice quality 2#; international: Thai rice broken 5%*

*ប្រភព: ក្នុងស្រុក: NIS, អន្តរជាតិ: IRRI*

## ក្រាហ្វិក ២.៤: ថ្លៃសាំង និងជី, ពាន់រៀល



*កំណត់សំគាល់: Subject commodities specifically refer to the ff: Domestic -gasoline; urea;International-Spot prices FOB for Singapore Conventional Gasoline; Urea (Europe) Gaps are due to lack of available data for the concerned periods.*

*ប្រភព: ក្នុងស្រុក: NIS និង MAFF, អន្តរជាតិ: IRRI និង UABA*

## ក្រាហ្វិក ២.៥: ចំនួនប្រជាជនមានអសន្តិសុខស្បៀង



*ប្រភព: ការគណនារបស់ WFP ផ្អែកលើលទ្ធនៃ CSES 2007, មើលក្នុង CDRI (2008)*

## ក្រាហ្វិក ២.៦: សន្ទស្សន៍ភាពអត់ឃ្លានសរុបរបស់កម្ពុជា (GHI)



*ប្រភព: ការគណនារបស់អ្នកនិពន្ធ ផ្អែកលើទិន្នន័យ GHI របស់ Weismann et. al. (2007), Grebmer et. al. (2008/2009)*

## ក្រាហ្វិក ២.៧: ការនាំចេញអង្ករ (3mma, yoy % change)




*ប្រភព: ផ្អែកលើទិន្នន័យរបស់ MoEF*

## ២.២.៤ ចម្លើយតបរបស់រដ្ឋាភិបាល

ចម្លើយតបរបស់រដ្ឋាភិបាលពិតជាសំខាន់ខ្លាំងណាស់ ក្នុងការវាស់វែងផលប៉ះពាល់នៃវិបត្តិស្បៀង ពីព្រោះចម្លើយតបទាំងនេះ អាចធ្វើឱ្យថ្លៃស្បៀងប្រែប្រួលខុសលំនាំដើម និងជួយប្រជាជនក្រីក្រ ក្នុងការទប់ទល់នឹងបរិយាកាសមានថ្លៃអាហារខ្ពស់ ។ តារាង ២.៥ បង្ហាញត្រួសៗ ពីចម្លើយតបរបស់រាជរដ្ឋាភិបាលចំពោះវិបត្តិស្បៀង។

ចម្លើយតបដ៏សំខាន់មួយរបស់រដ្ឋាភិបាលគឺ ការហាមប្រាមការនាំចេញអង្ករនៅចុងខែមីនា ២០០៨ ។ ការរឹតបន្តឹងលើការនាំចេញអង្ករនេះ ប្រហែលពុំមានផលប៉ះពាល់ច្រើនដូចការរំពឹងទុកឡើយ ។ ការហាមប្រាមនេះត្រូវបានលើកលែងសំរាប់ ៣ខេត្ត នៅតាមបណ្តោយព្រំដែនវៀតណាម (Morning 2008, UN Cambodia 2008) ។ ការរឹតបន្តឹងទាំងនេះ ត្រូវបានលុបចេញវិញ ក្រោយពេលដាក់អនុវត្តបានចំនួន ២ខែ ហើយក៏មានពាណិជ្ជកម្មក្រៅផ្លូវការយ៉ាងធំសំបើមនៅតាមព្រំដែន ។

**តារាង ២.៥: ចម្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះវិបត្តិស្បៀង**

| វិធានការខាងគោលនយោបាយពាណិជ្ជកម្ម | វិធានការផ្អែកលើទីផ្សារក្នុងស្រុក |
|---|---|
| ការរឹតបន្តឹងការនាំចេញអង្ករ | ការបញ្ចេញស្តុកលក់តាមថ្លៃរដ្ឋជួយចេញខាត |
| ការលុបចេញការរឹតបន្តឹងការនាំចូលជ្រូក | ការកាត់បន្ថយពន្ធលើស្បៀងជាធញ្ញជាតិ |
| ប្រព័ន្ធសុវត្ថិភាព (ដោយមានការគាំទ្រពីម្ចាស់ជំនួយ) | ការបង្កើនឥណទាន និងប្រាក់ចំណូល |
| ស្បៀងពលកម្ម | ច្បាប់បង្កើនប្បេវត្សរ៍រាជការស៊ីវិល |
| កម្មវិធីផ្តល់អាហារនៅសាលារៀន | កម្ចីមានការប្រាក់ទាបដោយធនាគារអភិវឌ្ឍន៍ជនបទ |
| ជំនួយស្បៀងអាហារបន្ទាន់ | |

*កំណត់សំគាល់: ចំពោះចម្លើយតបផ្សេងៗទៀតរបស់រដ្ឋាភិបាល ដើម្បីដោះស្រាយផលប៉ះពាល់នៃវិបត្តិស្បៀង និងវិបត្តិសេដ្ឋកិច្ច សូមមើលតារាង ២.៨ ។*

*ប្រភព: Demeke et. al. (2009), ADB (2008), H.E. PM Hun Sen (2008), Brahmbhatt and Christiaensen (2008), UN Cambodia (undated), MAFF (undated), WB (undated) ។*

## ២.២.៥ ផលប៉ះពាល់

ផ្អែកលើពិន្ទុនៃសន្ទស្សន៍ភាពអត់ឃ្លានសាកល (GHI) (ក្រាហ្វិក ២.៦) ស្ថានភាពភាពអត់ឃ្លាននៅកម្ពុជាក្នុងពេលកន្លងមក មានលក្ខណៈគួរឱ្យភ័យព្រួយ ទោះបីជាបញ្ហានេះបានធូរស្រាលមកវិញជាបន្តបន្ទាប់ក្តី ។ ផលប៉ះពាល់ទី១នៃវិបត្តិស្បៀង គឺការរាំងស្ទះដល់ការរីកលូតលាស់ទៅមុខទៀត ។ មានចំនុច ៣ ដែលគួរបកស្រាយតាំងពីដំបូង ។ ទី១ ដោយសារការផ្ទេរកើតថ្លៃមិនពេញលេញនោះ ផលប៉ះពាល់នៃវិបត្តិថ្លៃស្បៀងសាកល វាមិនសូវខ្លាំងក្លាទេនៅកម្ពុជា ។ ទី២ ផលប៉ះពាល់កើតមីក្រូនៃការឡើងថ្លៃស្បៀង មានកើតខុសៗគ្នាទៅតាមលក្ខណៈរបស់គ្រួសារនីមួយៗ ។ ទី៣ ឧបសគ្គផ្សេងៗដល់ការផ្គត់ផ្គង់ ដើម្បីឆ្លើយតបនឹងការឡើងថ្លៃ បានធ្វើឱ្យកម្ពុជាមិនអាចទាញយកចំណេញពាណិជ្ជកម្មបានច្រើនពីការឡើងថ្លៃដ៏ខ្ពស់នេះ ។

ដោយប្រើទិន្នន័យបានពីការសិក្សាពីឱណាមីកនៃភាពក្រីក្រ (PDS) លោកបណ្ឌិត តុង គឹមស៊ុន (2009) បានបង្ហាញថា វិបត្តិស្បៀងបាននាំឱ្យមានការកាត់បន្ថយចំណាយប្រើប្រាស់ក្នុងគ្រួសារ ទាំងលើទំនិញអាហារ និង មិនមែនអាហារ ។ ពីខែមីនា ដល់ កញ្ញា ២០០៨ ចំណាយលើអាហារនៅក្នុងគ្រួសារ បានធ្លាក់ចុះប្រហែល ៨,៤% ។ CDRI (2008) បានបង្ហាញថា ជាង ៥០% នៃគ្រួសារក្នុងអង្កេត បានរាយការណ៍ថា បានកាត់បន្ថយ បរិមាណ និងគុណភាពស្បៀង ដែលខ្លួនហូបចុក និងបានបង្កើនការទិញស្បៀងដោយជំពាក់ ។ លោក សូ សុវណ្ណារិទ្ធិ (2008) ក៏បានបង្ហាញដែរថា វិបត្តិថ្លៃស្បៀងបានប៉ះពាល់ប្រជាជនក្រីក្រខ្លាំងជាងគេ ព្រោះពួកគាត់ភាគច្រើនជា អ្នកទិញស្បៀងសុទ្ធ និងមានដីធ្លីទំហំតូច ។

យើងបានរំលេចរួចហើយ ពីរឿងដែលការឆ្លើយតបនឹងការឡើងថ្លៃ ត្រូវបានរាំងស្ទះដោយបញ្ហាមួយ ចំនួន ។ យោងតាម CDRI (2008) យ៉ាងហោចណាស់មានគ្រួសារ ៣% ច្រើនជាងមុន បានរាយការណ៍ពី គម្រោងធ្វើការដាំដុះ ប៉ុន្តែគម្រោងទាំងនេះ ត្រូវប្រឈមនឹងបញ្ហាចោទជាយូរមកហើយ ក្នុងការធ្វើប្រពលវប្បកម្ម កសិកម្ម ។ ផលិតកម្មអាចមិនបានខ្លាំងក្លាឡើងគ្រប់ៗគ្នាក៏ពិតមែន ប៉ុន្តែ ការឡើងថ្លៃខ្ពស់ វាបានបង្កើនប្រាក់ ចំណូលពីកសិកម្ម ។ CDRI (2008) បានបង្ហាញថា ទោះបីជាតម្លៃផលិតកម្មស្រូវបានកើនឡើង ៥០% ក្តី ប៉ុន្តែ ប្រាក់ចំណេញដុលពីការលក់ស្រូវ បានកើនឡើងដល់ ៣៨% ។ ដោយហេតុថា មានកសិករតិចទាក់ណាស់ ដែលមាន អតិរេកស្រូវសម្រាប់លក់ ដូច្នេះ ប្រហែលមានតែគ្រួសារខ្លះៗប៉ុណ្ណោះ ដែលទទួលបានកំណើនប្រាក់ចំណូល ។

ផលប៉ះពាល់អវិជ្ជមាននៃវិបត្តិស្បៀងទៅលើអាហារូបត្ថម្ភ អាចមានច្រើន ដោយសារការកាត់បន្ថយបរិមាណ និងគុណភាពស្បៀងដែលបរិភោគ ។ អត្រាកុមារស្គមស្គាំង ឬខ្វះទំងន់ អាយុក្រោម៥ឆ្នាំ បានកើនឡើងពី ៨,៤ ដល់ ៨,៩% និងពី ២៨,២ ដល់ ២៨,៨% រៀងគ្នា ។ អត្រានៃភាពមិនគ្រប់ទំងន់ ក្នុងចំណោមក្មេងអាយុក្រោម ៥ឆ្នាំ បានកើនឡើងពី ២២ ដល់ ៣០% នៅចន្លោះឆ្នាំ២០០៥ និង ២០០៨ (UNICEF 2009) ។

## ២.៣. វិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសាកល និងសន្តិសុខស្បៀងនៅកម្ពុជា

ព្រឹត្តិការណ៍ដែលកើតចេញពី GFEC បានបង្ហាញពីបែបបទ ដែលទីផ្សារទំនិញជាអាហារ និងមិនមែនអាហារ មានចំណងទាក់ទងគ្នាចុះឡើងច្រើនជាងមុន ។ ពិតហើយ GFEC បានបញ្ឈប់ការឡើងថ្លៃទំនិញប្រើប្រាស់ ទោះបីជា ថ្លៃអាហារនៅតែខ្ពស់ជាងកំរិតមធ្យម និងមានសញ្ញានៃការឡើងថ្លៃខ្លះវិញ ក្នុងពេលថ្មីៗនេះក្តី ។ សន្ទស្សន៍ថ្លៃ ស្បៀងសាកល បានចាប់ផ្តើមធ្លាក់ចុះនៅត្រីមាសទី២ ឆ្នាំ២០០៨ ហើយកើនឡើងជាថ្មី ប្រហែលនៅត្រីមាសទី២ ឆ្នាំ២០០៩ (ក្រាហ្វិក ២.១) ។ ការចុះថ្លៃ បានបន្ធូរការព្រួយបារម្ភពីសន្តិសុខស្បៀងក៏ពិតមែន ប៉ុន្តែការចុះថ្លៃភ្លាមៗ ក៏ប៉ះទង្គិចដល់អ្នកដែលបានទទួលអត្ថប្រយោជន៍ពីការឡើងថ្លៃបណ្តើរៗ ហើយបានធ្វើវិនិយោគលើផលិតកម្ម ដោយ រំពឹងថា កំរិតថ្លៃខ្ពស់នេះ នៅបន្តទៅមុខបានយូរ ។ ការបាត់បង់ប្រាក់ចំណូល ដោយសារការធ្លាក់ចុះក្នុងវិស័យជំរុញ កំណើននានានៅកម្ពុជា បានធ្វើឱ្យស្ថានភាពគ្រួសារកាន់តែយ៉ាប់យ៉ឺនឡើង ក្នុងអំឡុងពេល GFEC ។

### ២.៣.១ *ការផ្ទេរកំរិតថ្លៃ*

ស្របតាមនិន្នាការអន្តរជាតិ អតិផរណានៅកម្ពុជាបានធូរស្រាលឡើង នៅពេលសេដ្ឋកិច្ចក្នុងប្រទេសបាន ចាប់ផ្តើមទទួលឥទ្ធិពលពី GFEC ។ អតិផរណាសរុបពីមួយឆ្នាំទៅមួយឆ្នាំ ចុះទាបរហូតដល់ -៥,៦% នៅខែឧសភា

២០០៩ បន្ទាប់ពីឡើងដល់កំរិតកំពូល ៣៦% កាលពីមួយឆ្នាំមុន ។ ប៉ុន្តែ នៅពេលសេដ្ឋកិច្ចរើបឡើងវិញ អតិផរណាក៏ចាប់ផ្តើមឡើងវិញដែរ ដល់ប្រហែល -១,៣% នៅខែតុលា ២០០៩ ។ អតិផរណាស្បៀងបានថយចុះដល់ -៦,៧% នៅខែឧសភា ២០០៩ រួចរើបឡើងវិញដល់ -១,៥% នៅខែតុលាឆ្នាំដដែល ។ អតិផរណាទំនិញមិនមែនអាហារក៏ថយចុះដែរក្នុងអំឡុងពេល GFEC មុនពេលកើនឡើងម្តងទៀត (ក្រាហ្វិក ២.២) ។

ដូចមានបង្ហាញក្នុងក្រាហ្វិក ២.៣ ចលនាថ្លៃអង្ករទាំងនៅក្នុងស្រុក និងជាសាកល បានធ្លាក់ចុះក្នុងអំឡុង GFEC ប៉ុន្តែ ខណៈដែលការធ្លាក់ថ្លៃនៅអន្តរជាតិមានការឡើងចុះថ្លៃច្រើនលើក ចលនាថ្លៃក្នុងស្រុកមានភាពរលូនដែលបង្ហាញពីឥទ្ធិពលនៃអន្តរាគមន៍ក្នុងស្រុក ។ ដោយប្រើវិធីសាស្ត្រ Dawe (2008) ដដែល ការគណនាការផ្ទេរកំរិតថ្លៃ ពីត្រីមាសទី៤ ឆ្នាំ២០០៨ ដល់ ត្រីមាសទី៣ ឆ្នាំ២០០៩ បង្ហាញថា ការចុះថ្លៃក្នុងស្រុកជាមធ្យម វាធំលើសការធ្លាក់ចុះថ្លៃនៅអន្តរជាតិ ។ រឿងនេះ បង្ហាញពីឥទ្ធិពលនៃការផ្ទេរកំរិតថ្លៃ និងផលប៉ះពាល់នៃអន្តរាគមន៍របស់រដ្ឋាភិបាល ។

ពីត្រីមាសទី៤ ឆ្នាំ២០០៨ ដល់ ត្រីមាសទី៣ ឆ្នាំ២០០៩ ទាំងថ្លៃប្រេងសាំងក្នុងស្រុក និងសាកល បានកើនឡើង ទោះជាមិនខ្ពស់ដូចក្នុងអំឡុងពេលមានវិបត្តិស្បៀងខ្លាំងក្តី ។ ការផ្លាស់ប្តូរកំរិតថ្លៃក្នុងស្រុកជាមធ្យមមានលក្ខណៈខ្សោយជាងមុន ដោយការផ្ទេរកំរិតថ្លៃមានត្រឹម ៦% ប៉ុណ្ណោះ (តារាង ២.៧) ។ រឿងនេះបង្ហាញពីផលប៉ះពាល់នៃអន្តរាគមន៍របស់រដ្ឋាភិបាល ។

ពីត្រីមាសទី៤ ឆ្នាំ២០០៨ ដល់ ត្រីមាសទី២ ឆ្នាំ២០០៩ ថ្លៃជី ទាំងក្នុងស្រុក និងអន្តរជាតិ បានថយចុះ ។ ប៉ុន្តែ លទ្ធផលនៃការគណនា បង្ហាញថា ការផ្លាស់ប្តូរថ្លៃជីក្នុងស្រុកជាមធ្យម វាធំលើសការផ្លាស់ប្តូរសរុបក្នុងថ្លៃអន្តរជាតិ (តារាង ២.៧) ។

**តារាង ២.៦: ការប្រែប្រួលថ្លៃអង្ករ ក្នុងអំឡុង** GFEC (Q4 2008-Q3 2009)

| ថ្លៃអន្តរជាតិ (US$) | ថ្លៃអន្តរជាតិ (DC) | ថ្លៃក្នុងស្រុក (DC) | ការឆ្លងថ្លៃចូល (៣/១%) |
|---|---|---|---|
| -៤ | -៣ | -១២ | ២៧៦ |

*កំណត់សំគាល់: មុខទំនិញសំដៅដល់: ក្នុងស្រុក-អង្ករគុណភាពលេខ២ និងអន្តរជាតិ-អង្ករថៃបាក់ ៥%*

*ប្រភព: ទិន្នន័យពី NIS, IRRI*

## ២.៣.២ ផលប៉ះពាល់នៃ GFEC លើប្រាក់ចំណូលគ្រួសារ

ផលប៉ះពាល់នៃ GFEC លើសន្តិសុខស្បៀង វាកើតឡើងមួយភាគធំ តាមរយៈផលប៉ះពាល់លើប្រាក់ចំណូលគ្រួសារ ។ ការធ្លាក់ចុះប្រាក់ចំណូល មានមូលហេតុ ៤យ៉ាង គឺ អត្រាខ្ពស់នៃការមានការងារធ្វើមិនពេញលេញ និងការអត់ការងារធ្វើ ការធ្លាក់ចុះប្រាក់កម្រៃ ការថយចុះប្រាក់ផ្ញើមកផ្ទះ និងការលំបាកកាន់តែច្រើនក្នុងការទទួលបានឥណទាន ។

ព័ត៌មានតាមវិស័យបង្ហាញថា អត្រាអត់ការងារធ្វើនៅកម្ពុជាបានកើនឡើង ហើយសមត្ថភាពស្រូបយកអ្នកចំណូលថ្មីក្នុងទីផ្សារពលកម្មក៏ថយចុះ ដោយសារមានវិបត្តិសេដ្ឋកិច្ច ។ ការពិភាក្សាតាមក្រុមស្នូល (FGDs) និងសម្ភាសន៍ពាក់កណ្តាលរៀបរយ (SSIs) របស់ CDRI បង្ហាញនូវការថយចុះជាទូទៅ នូវការងារអស់ប្រហែល ៣០

ទៅ ៤០% ទោះបីជាមានកត្តាច្រើនទៀតក្រៅពីវិបត្តិ ដែលបង្កនិន្នាការនេះឡើង[១០] ។ មានការបាត់បង់ការងារអស់ប្រហែល ៥២.០០០ នៅក្នុងវិស័យកាត់ដេរ ពីខែកញ្ញា ២០០៨ ដល់ សីហា ២០០៩ ។ បៀវត្សរ៍ប្រចាំខែសរុបបានថយចុះអស់ប្រហែល ៣,៤លានដុល្លារអាមេរិក ក្នុងពេលដូចគ្នា (Prasish 2009c) ។ ម្យ៉ាងទៀត នាទីព័ត៌មានមួយនៅខែធ្នូ ២០០៩ បានរាយការណ៍ថា ចំនួនការងារខាងសំណង់ដែលបាត់បង់ មានដល់ ១០០.០០០ (Pou 2009) ។ សំរាប់ទេសចរណ៍វិញ អង្កេតលើ ៧២សណ្ឋាគារ បង្ហាញថា មាន ១២សណ្ឋាគារ បានបញ្ឈប់ការងារ អស់ ៣០-៥០% ហើយសណ្ឋាគារឯទៀតៗ ក៏បានកាត់បន្ថយម៉ោងធ្វើការអស់ ៣០-៥០% ដែរ (Chun and Ith 2009) ។

ផលប៉ះពាល់អាក្រក់នៃវិបត្តិទៅលើការងារ ត្រូវបានសំរាលខ្លះ ដោយវិស័យកសិកម្ម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានជួយស្រូបយកអ្នកបាត់បង់ការងារមួយចំនួន ។ ប៉ុន្តែការស្រូបយកនេះ មិនសូវធំដុំប៉ុន្មានទេ ដោយសារវិស័យទាំងនេះ មានសមត្ថភាពស្រូបយកទាបស្រាប់ហើយ ។ ម្យ៉ាងទៀត ប្រាក់កម្រៃពីការងារក្នុងវិស័យទាំងនេះ មិនបានស្មើប្រាក់កំរៃនៅក្នុងវិស័យជំរុញកំណើននានានោះទេ ។

លទ្ធផលអង្កេតរបស់ CDRI លើពលករងាយរងគ្រោះ (VWS)[១១] ផ្តល់ការគាំទ្រលើការអះអាងថា មានការថយចុះប្រាក់ចំណូលក្នុងចំណោមពលករងាយរងគ្រោះ ។ អង្កេតបង្ហាញថា ក្នុងចំណោមពលករងាយរងគ្រោះ ១០ក្រុម មាន ៨ក្រុម បានធ្លាក់ចុះប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យម ច្រើនគួរកត់សំគាល់ក្នុងអំឡុងពេលមានវិបត្តិ ប៉ុន្តែ ក្នុងខែខុសៗគ្នា ។ ចំណុចគួរចាប់អារម្មណ៍ គឺពលករពីរក្រុម ដែលផ្អែកលើការងារកសិកម្ម (អ្នកស៊ីឈ្នួលធ្វើស្រែ និងអ្នកលក់បន្លែតូចតាច) មានប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃពិត កើនឡើងគួរកត់សំគាល់ក្នុងចន្លោះខែវិច្ឆិកា ២០០៧ និង វិច្ឆិកា ២០០៨ នៅពេលស្បៀងស្ទុះឡើងថ្លៃ និងធ្លាក់ចុះគួរកត់សំគាល់ ក្នុងចន្លោះខែវិច្ឆិកា ២០០៨ និង វិច្ឆិកា ២០០៩ នៅពេលមានការធ្លាក់ចុះសេដ្ឋកិច្ច និងការចុះថ្លៃស្បៀង ។

មានអត្រាគ្រួសារកម្ពុជាច្រើនគួរកត់សំគាល់ក្នុងគ្រប់ក្រុមប្រាក់ចំណូល ដែលទទួលបានប្រាក់ផ្ញើមកផ្ទះ ។ យោងតាមលទ្ធផល របស់ CSES គ្រួសារក្រីក្របំផុត និងគ្រួសារជិតក្រីក្របំផុត ប្រហែល ១៧ ទៅ ២០% បានទទួលប្រាក់ផ្ញើមកផ្ទះពីប្រភពក្នុងស្រុក ។ ដូចមុនដែរ កង្វះទិន្នន័យធ្វើឱ្យយើងមិនអាចកំណត់ជាតួលេខ នូវផលប៉ះពាល់ នៃវិបត្តិទៅលើប្រាក់ផ្ញើមកផ្ទះពីប្រភពក្នុងស្រុក ប៉ុន្តែ ព័ត៌មានដែលទទួលបានបង្ហាញថា មានការធ្លាក់ចុះដោយវិបត្តិ ។ លទ្ធផល FGDs និង SSIs របស់ CDRI ក៏បង្ហាញដែរថា មានការផ្ញើប្រាក់បញ្ច្រាសទៅវិញ ពោលគឺការផ្ទេរពីគ្រួសារនៅជនបទទៅសមាជិកគ្រួសារ ដែលធ្វើការនៅតំបន់ទីក្រុងផ្សេងៗ ។

ករណីប្រទេសកម្ពុជា បានបង្ហាញពីបែបបទ ដែលការពឹងផ្អែកលើបំណុលបានថយចុះ នៅពេលដែលលទ្ធភាពទទួលបានឥណទានកើនឡើង ស្របតាមកំណើននៃប្រាក់ចំណូលក្នុងមនុស្សម្នាក់ និងចំណាយប្រើប្រាស់ ។ លទ្ធផលអង្កេត CSES បង្ហាញពីបែបបទ ដែលជិតពាក់កណ្តាលនៃគ្រួសារក្រីក្របំផុត មានជាប់បំណុលមិនទាន់សងធៀបនឹង ២០% នៃគ្រួសារធូរធារបំផុត ។ វិបត្តិ GFEC បានបង្កជាសំខាន់នូវការរឹតត្បិតឥណទានដល់វិស័យឯកជន និងបង្កើនបន្ទុកចំណាយនៃការខ្ចីប្រាក់គេ នៅពេលកំពុងខ្វះខាតសាច់ប្រាក់ ។ ព្រឹត្តិការណ៍វិវត្តមិនល្អបានប៉ះពាល់ទាំងគ្រួសារធូរធារ និងគ្រួសារក្រីក្រ ប៉ុន្តែការខាតបង់ខាងសុខុមាលភាពកើតចេញពីស្ថានភាពនេះ

១០ សូមមើល Theng and Kem 2009a/b and So 2009 ។

១១ សូមមើល Tong et. al. 2009 ។

វារឹតតែធ្ងន់ធ្ងរទៀត ដោយសារពួកគេត្រូវពឹងផ្អែកច្រើនលើឥណទាន និងមានប្រភពចំណូលតិច ។ លទ្ធផល FGDs និង SSIs របស់ CDRI បង្ហាញថា ភាពជាប់បំណុលក្នុងចំណោមគ្រួសារឆ្លើយសម្ភាសន៍ បានកើនឡើងនៅពេលដែលឥណទានកាន់តែក្រខ្សត់ និងពិបាករកបាន ។ ប្រាក់ខ្ចីគេ ត្រូវបានប្រើសំរាប់ធ្វើជាសោហ៊ុយធ្វើចំណាកស្រុករបស់សមាជិកគ្រួសារ សងបំណុលនៅជំពាក់គេ និងទិញទំនិញប្រើប្រាស់ចាំបាច់ ដូចជា ស្បៀងអាហារជាដើម ។

## ២.៣.៣ ផលប៉ះពាល់នៃ GFEC លើផលិតកម្មកសិកម្ម និងការនាំចេញ

ការធ្លាក់ថ្លៃផលិតផលកសិកម្ម ដោយសារវិបត្តិសេដ្ឋកិច្ចសាកល អាចជាលាភសំរាប់គ្រួសារដែលមានអសន្តិសុខស្បៀង ប៉ុន្តែ វាជាការឈឺចាប់សំរាប់អ្នកដែលបានវិនិយោគបង្កើនផលិតកម្ម ដោយរំពឹងថាការឡើងថ្លៃនេះបន្តបានយូរឆ្នាំ ។ ផលិតកម្មស្រូវនៅកម្ពុជា អាចទប់ទល់បាននឹងផលប៉ះពាល់ភាគច្រើននៃការធ្លាក់ថ្លៃ ប៉ុន្តែ ការធ្លាក់ថ្លៃ និងការថយចុះតម្រូវការជ័រកៅស៊ូ និងដំឡូងឈើ បានធ្វើឱ្យអន្តរាយដល់អ្នកដាំកៅស៊ូ និងដំឡូងឈើនៅកម្ពុជា ។

ដោយសារឧបសគ្គដូចខាងលើ គេមិនឃើញមានចម្លើយតបជាវិជ្ជមានអ្វីលើការផ្គត់ផ្គង់ទេ ក្រោយពេលដែលស្បៀងបានឡើងថ្លៃដល់កំពូល ។ គេសង្ស័យថា អាចមានការយឺតយ៉ាវខ្លះក្នុងការឆ្លើយតប ដោយសារអ្នកពាក់ព័ន្ធកំពុងខិតខំដោះស្រាយឧបសគ្គ ដែលរាំងស្ទះផលិតកម្ម ដើម្បីទាញយកចំណេញពីការឡើងថ្លៃស្បៀងខ្ពស់ជាងមុននេះ ។ តម្លៃ និងបរិមាណអង្ករនាំចេញ បានថយចុះ (គិតពីមួយឆ្នាំទៅមួយឆ្នាំ) ជាង ៥០% រវាងខែមេសា និង មិថុនា ២០០៨ នៅពេលដែលថ្លៃអង្ករអន្តរជាតិឡើងខ្ពស់ដល់កំពូល ប៉ុន្តែ បានកើនឡើងវិញយ៉ាងទៀងទាត់នៅខែក្រោយៗមកទៀត ។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃតម្លៃ និងបរិមាណ នៃការនាំចេញអង្ករប្រចាំខែ មានជាមធ្យម ៤៣០% និង ២៨០% រៀងគ្នា ចាប់ពីខែកក្កដា ដល់ វិច្ឆិកា ២០០៩ (តារាង ២.៧) ។ យោងតាមរបាយការណ៍សង្ខេប របស់ FAO ស្ដីពីប្រទេសកម្ពុជា អតិរេកស្រូវអង្ករដ៏ច្រើនបំផុត ទំនងកើតមាននៅឆ្នាំ២០១០ ដោយសារមានផលស្រូវប្រមូលបានច្រើនណាស់ ពីខែធ្នូ ២០០៩ ដល់ កុម្ភៈ ២០១០ ។ ក្នុងឆ្នាំ២០០៩ មានភ្លៀងធ្លាក់ធម្មតាទេ ដូច្នេះ កំណើនផលស្រូវបានមកពីកំណើនផ្ទៃដីដាំដុះ ដោយសារស្រូវឡើងថ្លៃខ្ពស់ ។

**តារាង ២.៧: ការផ្ទេរកំរិតថ្លៃទំនិញមិនមែនស្បៀង-ក្នុងអំឡុង GFEC**

| ផលិតផល | ថ្លៃអន្តរជាតិ (US$) | ថ្លៃអន្តរជាតិ (DC) | ថ្លៃក្នុងស្រុក (DC) | ការផ្ទេរកំរិតថ្លៃ (៣/១%) |
|---|---|---|---|---|
| **ត្រីមាសទី៤ ឆ្នាំ២០០៨ -ត្រីមាសទី៣ ឆ្នាំ២០០៩** | | | | |
| ប្រេងសាំង | ៣៨ | ៤០ | ២ | ៦ |
| **ត្រីមាសទី៤ ឆ្នាំ២០០៨ ត្រីមាសទី២ ឆ្នាំ២០០៩** | | | | |
| ជី | -១៧ | -១៨ | -៣៩ | ២២៥ |

*កំណត់សំគាល់: មុខទំនិញសំដៅដល់: ក្នុងស្រុក-សាំង ជីអ៊ុយរ៉េ ។ អន្តរជាតិ ថ្លៃលក់ដល់ដៃ FOB សំរាប់សាំងធម្មតារបស់សិង្ហបុរី ជីអ៊ុយរ៉េ (អឺរ៉ុប) ។*

*ប្រភព: ទិន្នន័យពី NIS, MAFF, IRRI & US EIA ។*

### ២.៣.៤ ការឆ្លើយតបរបស់រដ្ឋាភិបាល

កសិកម្ម គឺជាគ្រឹះនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល ។ រឿងនេះ មិនស៊ីចង្វាក់នឹងស្ថានភាព ដែលវិនិយោគសាធារណៈ និងជំនួយក្នុងវិស័យនេះ តែងមានកំរិតទាបតាំងពីដើមរៀងមក ។ ទិន្នន័យមានស្រាប់ បង្ហាញថា នៅចន្លោះឆ្នាំ១៩៩៨ និង ២០០៦ មានជាមធ្យមតែ ១% នៃ ផសស ប៉ុណ្ណោះ ដែលបានបង្វែរទៅខាងកសិកម្ម[១២] ។

**តារាង ២.៨: សង្ខេបការឆ្លើយតបភ្លាមៗរបស់រដ្ឋាភិបាលចំពោះវិបត្តិសេដ្ឋកិច្ច**

| | |
|---|---|
| កសិកម្ម | វិស័យសំលៀកបំពាក់ |
| មូលនិធិអភិវឌ្ឍន៍ និងទ្រទ្រង់កសិកម្ម | ការផ្អាកការបង់ពន្ធមុនលើប្រាក់ចំណេញ |
| ការផ្អាកយកពន្ធ រយៈពេល៣ឆ្នាំសំរាប់ | ការកាត់បន្ថយវិភាគទានរបស់និយោជក |
| គំរោងវិនិយោគកសិកម្ម | នៅក្នុងប្រព័ន្ធសុវត្ថិភាពសង្គម |
| អត្រាពន្ធគយសូន្យលើការនាំចូលធាតុចូលកសិកម្ម | |
| ការលើកលែង VAT លើផលិតផលកសិកម្ម | |
| វិស័យទេសចរណ៍ | វិស័យសំណង់ |
| ការលើកលែងការយកកំរៃទិដ្ឋាការ | ការលុបកំរិតអតិបរមាលើកំចីដល់វិស័យអចលនៈទ្រព្យ |
| យុទ្ធនាការផ្សាយពាណិជ្ជកម្មអន្តរជាតិ | |
| ការបើកច្រកត្រួតពិនិត្យព្រំដែន និងផ្លូវទឹកថ្មីៗ | |
| សកម្មភាពតាំងបង្ហាញឃោសនាផ្សព្វផ្សាយ | |
| គោលនយោបាយផ្អែកលើពាណិជ្ជកម្ម | ប្រព័ន្ធសុវត្ថិភាពសង្គមផ្សេងៗ |
| និងការគាំទ្រក្នុងស្រុក | |
| ឧត្តម្ភធនសំរាប់ប្រេងនាំចូល | មូលនិធិរដ្ឋាភិបាល សំរាប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ រយៈពេលខ្លី |
| ឧបត្ថម្ភធនសំរាប់អគ្គិសនី | មូលនិធិសំរាប់ការប្រកបរបរខ្លួនឯង |
| ការអនុញ្ញាតឡើងវិញនូវការនាំចូលជ្រូក | កម្មវិធីសន្តិសុខស្បៀង |
| | ការជួយសំរួលខាងស្បៀង |
| | ស្បៀងពលកម្ម |
| | កម្មវិធីផ្តល់អាហារនៅសាលារៀន |
| | ជំនួញស្បៀងអាហារបន្ទាន់ |

*កំណត់សំគាល់: អត្ថបទសង្ខេបនេះ ផ្អែកលើព័ត៌មានប្រមូលបាន តែមិនសព្វគ្រប់ទាំងអស់ទេ និងមិនបានរួមបញ្ចូលយុទ្ធសាស្ត្ររយៈពេលវែងរបស់រដ្ឋាភិបាលកម្ពុជាទេ ។*

*ប្រភព: Jalilian et. al. (2009), MAFF (undated), Naron (2008) ។*

១២ ផ្អែកតាមទិន្នន័យបង្ហាញក្នុង WB (2009a) ។

ការអនុវត្តឱនភាពថវិកាធំក្នុងឆ្នាំ២០០៩ គឺជាមធ្យោបាយគន្លឹះរបស់រដ្ឋាភិបាល ដើម្បីជួយជំរុញសេដ្ឋកិច្ច ។ តំរូវការហិរញ្ញប្បទាន បានបង្កើនការប្រកួតប្រជែងរវាងវិស័យនានា ដើម្បីបានមូលនិធិ ។ បញ្ហាយ៉ាងធំមួយ គឺការផ្តល់អាទិភាពដល់កំណើនចំណាយលើវិស័យយោធា និងការពារជាតិ ជាជាងលើវិស័យអាទិភាពនានា ជាពិសេសការអភិវឌ្ឍកសិកម្ម និងជនបទ ។ ចំពោះជំនួយវិញ ចំណែកក្នុងជំនួយសរុបនៃវិស័យកសិកម្ម មានប្រហែល ៥,៥% ជាច្រើនឆ្នាំមកហើយ (នៅទាបគួរសម ជាងចំណែកនៃវិស័យសង្គមកិច្ច) ហើយចំណែកនៃការអភិវឌ្ឍជនបទនៅថេរប្រហែល ៨%[១៣] ។ មិនមានការកាត់បន្ថយជំនួយណា ត្រូវបានធ្វើឡើងនៅក្នុងគំរោងប្តេជ្ញាផ្តល់ជំនួយសំរាប់ឆ្នាំ២០០៩ ឡើយ ទោះជារបៀបបែងចែកជំនួយ សំរាប់វិស័យកសិកម្មនៅក្នុងឆ្នាំដែលលើកឡើងនេះ នៅមិនទាន់អាចធានាច្បាស់លាស់ក៏ដោយ ។

តារាង ២.៨ បង្ហាញត្រួសៗពីការឆ្លើយតបភ្លាមៗរបស់រដ្ឋាភិបាលទៅនឹងវិបត្តិសេដ្ឋកិច្ច ក្នុងនេះមានមួយចំនួនឧបត្ថម្ភគាំទ្រដោយម្ចាស់ជំនួយ ។ គួរបញ្ជាក់ថា ទោះបីមិនឃើញមានការពង្រីកធំដុំគួរឱ្យកត់សំគាល់នូវថវិកាផ្នែកកសិកម្មរបស់រដ្ឋាភិបាលកម្ពុជាក្តី ក៏រដ្ឋាភិបាលបានអនុវត្តវិធានការជាច្រើនទៀត សំដៅប្រើប្រាស់សក្តានុពលរបស់វិស័យកសិកម្ម ដើម្បីកាត់បន្ថយផលប៉ះពាល់នៃ GFEC ។ វិធានការណ៍ទាំងនេះ រួមមានការបង្កើតមូលនិធិអភិវឌ្ឍន៍ និងគាំទ្រកសិកម្ម ការអនុវត្តវិធានការផ្អាកយកពន្ធរយៈពេល៣ឆ្នាំ សំរាប់គំរោងវិនិយោគកសិកម្ម និងការផ្អាកយកពន្ធគយ និងអាករលើតម្លៃបន្ថែម (VAT) លើធាតុចូលកសិកម្ម[១៤] ។

## ២.៣.៥ ផលប៉ះពាល់នៃ GFEC លើសន្តិសុខស្បៀង

វិបត្តិ GFEC ភាគច្រើនគឺជាដំណឹងអាក្រក់សំរាប់សន្តិសុខស្បៀងគ្រួសារ ។ ការធ្លាក់ចុះប្រាក់ចំណូលដោយសារផលប៉ះពាល់នៃ GFEC ទៅលើអត្រាអត់ការងារធ្វើ ប្រាក់ចំណូល ប្រាក់ផ្ញើមកផ្ទះ និងឥណទាន ចោទជាបញ្ហាធ្ងន់ធ្ងរដល់លទ្ធភាពរបស់គ្រួសារ ក្នុងការទទួលបាន ឬអនុវត្តបាននូវបរិមាណ និងគុណភាពចំណាយប្រើប្រាស់ដែលសមរម្យ និងគ្រប់គ្រាន់ ។ គួរបញ្ជាក់ថា នៅកម្ពុជា សកម្មភាពវិស័យជំរុញកំណើននានា ច្រើនប្រមូលផ្តុំនៅតាមតំបន់ទីក្រុង ។ ដូច្នេះ ការធ្លាក់ចុះក្នុងវិស័យទាំងនេះ ប៉ះពាល់ជាសំខាន់ដល់ពលករ និងក្រុមប្រជាជនងាយរងគ្រោះនៅតាមតំបន់ទីក្រុង ដែលភាគច្រើនជាអ្នកទិញស្បៀងសុទ្ធ ។ ជាការពិតហើយដែលពលករជាច្រើន ជាពិសេសក្នុងវិស័យកាត់ដេរ ជាជនចំណាកស្រុកមកពីតំបន់ជនបទ និងមានក្រុមគ្រួសារ ដែលពឹងផ្អែកលើប្រាក់ផ្ញើមកផ្ទះរបស់ពួកគេ ។ ដូច្នេះ ការធ្លាក់ចុះក្នុងសកម្មភាពនៅទីក្រុង ដោយសារ GFEC បានជះឥទ្ធិពលដល់សន្តិសុខស្បៀងនៅជនបទ ។

ការស្រាវជ្រាវនានារបស់ CDRI បង្ហាញភស្តុតាងច្បាស់លាស់ថា មានផលអាក្រក់ធ្ងន់ធ្ងរកើតមានក្នុងសន្តិសុខស្បៀង ជាពិសេស ចំពោះក្រុមជនងាយរងគ្រោះ ។ លទ្ធផលនៃ FGD និង SSI បង្ហាញថា ការថយចុះប្រាក់ចំណូលបានប៉ះពាល់ជៀសមិនផុត ដល់បរិមាណ និងខ្លាំងជាងនេះទៀតគឺ គុណភាពស្បៀងដែលគ្រួសារឆ្លើយសម្ភាសន៍បានបរិភោគក្នុងអំឡុងពេលមានវិបត្តិ ។ វិបត្តិ ក៏នាំឱ្យមានការលះបង់លើការប្រើប្រាស់ទំនិញមិនមែនស្បៀងដែរ ។

---

១៣ ផ្អែកតាមទិន្នន័យបង្ហាញក្នុង CDC-CRDB (2008) ។

១៤ សូមមើល Jalilian et. al. (2009) សំរាប់ការពិពណ៌នាខ្លីៗពីការផ្តួចផ្តើមគំនិតទាំងនេះ ។

ដោយផ្តោតលើគ្រួសារនៅជនបទ ទិន្នន័យ PDS ដែលប្រមូលបានក្នុងខែកញ្ញា ២០០៩[១៥] បានបង្ហាញនិន្នាការដូចគ្នា នៃការកាត់បន្ថយការប្រើប្រាស់ស្បៀង និងទំនិញមិនមែនស្បៀង ។ នៅចន្លោះខែកញ្ញា ២០០៨ និងកញ្ញា ២០០៩ ការប្រើប្រាស់ស្បៀងបានធ្លាក់ចុះ ជាមធ្យមអស់ ៣១% ហើយការប្រើប្រាស់ទំនិញមិនមែនស្បៀងធ្លាក់ចុះអស់ ១០% (តារាង ២.៩) ។ តារាង ២.១០ បង្ហាញថា ជាមធ្យម ការប្រើប្រាស់អង្ករធ្លាក់ចុះ ៣៦% ហើយការប្រើប្រាស់ត្រី បន្លែស្រស់និងផ្លែឈើ បានធ្លាក់ចុះ ២៧.១៦% និង ៤៦% ក្នុងខែកញ្ញា ២០០៩ បើធៀបនឹងខែកញ្ញា ២០០៨ ។ ការសិក្សាបានរកឃើញដែរ នូវការកាត់បន្ថយចំណាយប្រើប្រាស់ទំនិញមិនមែនអាហារ ដូចជាប្រេងសាំង ដែលថ្លៃក្នុងស្រុកនៅតែខ្ពស់ជាងមុន និងការជួសជុលផ្ទះ ដែលបង្ហាញពីការធ្លាក់ចុះក្នុងវិស័យសាងសង់ ។

**តារាង ២.៩: ចំណាយប្រើប្រាស់ក្នុងគ្រួសារគិតក្នុងមនុស្សម្នាក់ ជារៀល** (2008 vs. 2009)

| | មធ្យម | |
|---|---|---|
| ចំណាយប្រើប្រាស់ | **2008** | **2009** |
| ស្បៀង | 2203 | 1515 |
| ទំនិញមិនមែនស្បៀង | 1404 | 1263 |
| សរុប | 3607 | 2778 |

*ប្រភព: ទិន្នន័យ PDS*

**តារាង ២.១០: ការប្រើប្រាស់ស្បៀង**

| ប្រភេទស្បៀង | ការប្រើប្រាស់ រៀល_២០០៨ | ការប្រើប្រាស់ រៀល_២០០៩ | ការប្រែប្រួលជា % ២០០៨_២០០៩ |
|---|---|---|---|
| អង្ករ | 852.25 | 545.44 | -36 |
| ធញ្ញជាតិផ្សេងៗ | 107.66 | 72.65 | -32.52 |
| ត្រី | 487 | 353.98 | -27.31 |
| បន្លែ (ស្រស់) | 119.41 | 99.78 | -16.44 |
| សាច់ជ្រូក និង សាច់គោ | 114.35 | 117.4 | 2.67 |
| ផ្លែឈើ | 88.66 | 47.6 | -46.31 |

*ប្រភព: PDS*

ការកាត់បន្ថយបរិមាណ និងគុណភាពនៃស្បៀងប្រើប្រាស់ ពិតជាបានចោទបញ្ហាកាន់តែធ្ងន់ធ្ងរដល់ស្ថានភាពខាងសុខភាព និងអាហារូបត្ថម្ភរបស់ប្រជាជនក្នុងអំឡុងពេលនៃវិបត្តិស្បៀង ។ ជាការគួរឱ្យស្តាយ ដែលមិនទាន់មានការសិក្សាថ្មីទៀត ដើម្បីកំណត់ជាតួលេខនូវផលប៉ះពាល់នៃ GFEC ទៅលើសុខភាព និងអាហារូបត្ថម្ភ ។ អន្តរាគមន៍របស់រដ្ឋាភិបាល ត្រូវតែជួយសំរាលបានខ្លះហើយ នូវផលប៉ះពាល់ដ៏ធ្ងន់ធ្ងរ នៃ GFEC ទៅលើសន្តិសុខស្បៀងរបស់គ្រួសារ ។ ប៉ុន្តែ ដោយសារមូលនិធិមានកំរិត និងបញ្ហាចោទក្នុងការគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពសង្គម

១៥ គួរកត់សំគាល់ថា រឿងនេះពាក់ព័ន្ធនឹងគំរូតាងតូចមួយមានត្រឹម ៩០គ្រួសារប៉ុណ្ណោះ ។

នៅកម្ពុជា អន្តរាគមន៍ទាំងនេះ ជះឥទ្ធិពលមិនបានឆ្ងាយទេ ។ ផ្អែកតាម FGDs និង SSIs របស់ CDRI គេមិនឃើញមានកំណើនអ្វីទេ ក្នុងការផ្តល់ប្រព័ន្ធសុវត្ថិភាពសង្គមជាផ្លូវការ[១៦] ។

ការបង្កើនផលិតកម្ម និងកំណើនអត្រាប្រាក់ចំណេញ ដោយសារស្បៀងឡើងថ្លៃ គឺជាលាភមួយ ប៉ុន្តែភាគច្រើនសំរាប់តែអ្នកលក់ស្បៀងសុទ្ធ ដែលមានផលិតផលលើសច្រើនសំរាប់លក់ទៅទីផ្សារ ។ តួអង្គធំៗនៅក្នុងខ្សែចង្វាក់កំណត់តម្លៃ ទំនងនឹងទទួលបានផលចំណេញច្រើនជាងអ្នកមានដីធ្លីតូចៗ ដែលត្រូវតស៊ូពុះពារឧបសគ្គជាច្រើន ដើម្បីបង្កើនផលិតកម្ម ។

សរុបមក GFEC បានទាញថយក្រោយវិញ នូវលទ្ធផលសំរេចបានក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ គេប៉ាន់ស្មានថា វិបត្តិនេះ អាចធ្វើឱ្យអត្រាជនក្រីក្រដែលរាប់ឃើញនៅឆ្នាំ២០០៧ (ប្រហែល ៣០%) កើនឡើងពី ១ ទៅ ៤% នៅឆ្នាំ២០១០ (WB 2009b) ។ មានការពិភាក្សានៅខាងដើមរួចហើយ ពីបែបបទដែលកំណើនប្រាក់ចំណូលក្នុងមនុស្សម្នាក់ អាចលុបចោលបាននូវឥទ្ធិពលនៃការឡើងថ្លៃទំនិញ ។ ផ្អែកលើការប៉ាន់ស្មានរបស់ IMF ដែលថា ផលិតផលសរុបនៅកម្ពុជា ត្រូវរួមចុះអស់ ២,២% នៅឆ្នាំ២០០៩ (IMF 2009) ដូច្នេះគេប៉ាន់ស្មានថា ប្រាក់ចំណូលក្នុងមនុស្សម្នាក់ ត្រូវធ្លាក់ចុះអស់ ៣% នៅចន្លោះឆ្នាំ២០០៨ និង ២០០៩ ។

## ២.៤. សន្និដ្ឋាន

ខណៈពេលដែលគេរំពឹងថា ប្រទេសកម្ពុជាទាំងមូលនឹងចាប់មានកំណើនជាថ្មី យុទ្ធសាស្ត្រកសិកម្ម និងអភិវឌ្ឍន៍ជនបទរបស់កម្ពុជា ត្រូវតែធ្វើការវាយតម្លៃឡើងវិញ ដើម្បីឱ្យប្រជាជនកម្ពុជាអាចទទួលបានដោយសមធម៌នូវអត្ថប្រយោជន៍នៃកំណើនសេដ្ឋកិច្ច ហើយកសិកម្មអាចក្លាយជាទ្រនាប់រឹងមាំ សំរាប់ទប់ទល់ការប៉ះទង្គិចផ្សេងៗ និងសំខាន់ជាងនេះទៀត ក្លាយជាកំលាំងរឹងមាំសំរាប់ទ្រទ្រង់កំណើនក្នុងរយៈពេលវែង ។

ការងារសំខាន់ទី១ គឺត្រូវបង្កើនចំនួន និងប្រសិទ្ធភាពនៃចំណាយសាធារណៈក្នុងវិស័យកសិកម្ម ។ របៀបប្រើប្រាស់ថវិកាបន្ថែម ត្រូវផ្អែកលើការវាយតម្លៃជាក់ស្តែងនូវតំរូវការនានា ដែលការអភិវឌ្ឍវិស័យកសិកម្មគួរដោះស្រាយ ផ្អែកតាមលក្ខណៈផ្ទាល់នៃវិស័យកសិកម្មនៅកម្ពុជា ។ ការងារសំខាន់បំផុតមួយទៀតគឺ ត្រូវកំណត់ទិសដៅច្បាស់លាស់ សំរាប់ការអភិវឌ្ឍកសិកម្ម ។ យោងតាមអាទិភាពនៃការកាត់បន្ថយភាពក្រីក្រ និងស្ថានភាពជាក់ស្តែង ដែលប្រជាជនក្រីក្រភាគច្រើននៅកម្ពុជា រស់នៅក្នុងតំបន់ជនបទ និងជាកសិករកាន់កាប់ដីធ្លីតូចៗ មានផលិតកម្មទាបនោះ គោលដៅទី១ ច្បាស់ជាការអភិវឌ្ឍពួកអ្នកកាន់កាប់ដីធ្លីតូចៗ ។ ការងារចាំបាច់មួយទៀតគឺ ត្រូវប្រឹងប្រែងធ្វើឱ្យមានស្បៀងគ្រប់គ្រាន់ និងធ្វើការអភិវឌ្ឍកសិកម្ម សំរាប់បំរើការនាំចេញឱ្យបានព្រមគ្នាតែម្តង ។

វិបត្តិស្បៀង និងវិបត្តិសេដ្ឋកិច្ច ត្រូវតែចងចាំទុក ព្រោះវាបានជួយប្រកាសភាពអាសន្ន ពីស្ថានភាពអត់ឃ្លានដ៏ធ្ងន់ធ្ងរក្នុងពិភពលោក ។ ដោយសារថ្លៃស្បៀងកំពុងកើនឡើងវិញទៀត ហើយលទ្ធភាពមានវិបត្តិសេដ្ឋកិច្ចមួយទៀត មិនអាចជៀសផុតទេនៅក្នុងស្ថានភាពបច្ចុប្បន្ននៃសាកលភាវូបនីយកម្ម ដូច្នេះ សកម្មភាពភ្លាមៗត្រូវតែអនុវត្តតាមការចាំបាច់ ។

---

១៦ សូមមើល Jalilian et. al. (2009), Theng and Kem (2009a/b) and So (2009) ។

# ជំពូក ៣
# តើក្រុមគ្រួសារនៅជនបទកម្ពុជា ទប់ទល់យ៉ាងណា ចំពោះការឡើងថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ?[១]

*ដោយបណ្ឌិត តុង គឹមស៊ុន*

## ៣.១. សេចក្តីផ្តើម

នៅប្រទេសកម្ពុជា ម្ហូបអាហារ និងប្រេងឥន្ធនៈបានឡើងថ្លៃយ៉ាងខ្លាំង តាំងពីចុងឆ្នាំ២០០៧ មក ។ នៅខែឧសភា ២០០៨ អត្រាអតិផរណា ឡើងដល់ ២៦% ដែលជាកំរិតខ្ពស់បំផុតក្នុង ៣ ទសវត្សរ៍កន្លងទៅនេះ ។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ សំរាប់អាហារ កើនឡើងលឿនណាស់ ដល់ ៤៦% ក្នុងរយៈពេល ១២ខែ ដល់ខែឧសភា ២០០៨ ។ អង្ករដែលជាអាហារមូលដ្ឋានរបស់ប្រជាជនកម្ពុជា បានឡើងថ្លៃ ១០០% ។ ដោយសារវិបត្តិនេះ អង្គការកម្មវិធីស្បៀងអាហារពិភពលោក បានផ្អាកកម្មវិធីចែកចាយអង្ករបស់ខ្លួន ទៅឱ្យសាលារៀន ។ មានការសិក្សាជាច្រើន បានព្យាយាមវាយតម្លៃពីផលប៉ះពាល់ផ្សេងៗ និងមានការសិក្សាមួយចំនួនតូច បានពិនិត្យពីយន្តការដោះស្រាយរបស់ក្រុមគ្រួសារ តាមរយៈការវិភាគបែបពិពណ៌នា ដោយប្រើប្រាស់អង្កេតច្រើនវិស័យលើក្រុមគ្រួសារ និងការពិភាក្សាតាមក្រុមស្នូល ។ ដោយមានកំហិតខាងទិន្នន័យ និងវិធីសាស្ត្រ អ្នកស្រាវជាវជាច្រើនបានរាយការណ៍ថា ជនក្រីក្រត្រូវប៉ះពាល់ខ្លាំងជាងគេពីកំណើនថ្លៃនេះ (see CDRI 2009) ។ ក្រុមគ្រួសារជាច្រើន ប្រហែលត្រូវទិញអាហារថោកៗ កាត់បន្ថយបរិមាណអាហារបរិភោគ លក់ដី ឬទ្រព្យសម្បត្តិដទៃទៀត បញ្ឈប់ការសិក្សារបស់កូនៗ ឬបង្កើនអាជីវកម្មលើធនធានធម្មជាតិ ដើម្បីទប់ទល់នឹងបញ្ហាមិនទៀងទាត់ ដូចជា អាហារឡើងថ្លៃខ្ពស់ ជំងឺដំកាត់ និងឥន្ធនៈឡើងថ្លៃខ្ពស់ ជាដើម (So 2009; Chan 2009) ។

ការវិភាគហ្មត់ចត់គ្រប់ជ្រុងជ្រោយកំរមានណាស់ ពីព្រោះត្រូវមានយ៉ាងហោចណាស់ក៏ពីរដែរ នូវអង្កេតច្រើនវិស័យលើក្រុមគ្រួសារ ហើយអង្កេតទាំងនេះ ត្រូវមានលក្ខណៈអាចប្រៀបធៀបគ្នាបាន ប៉ុន្តែវិទ្យាស្ថានស្រាវជ្រាវជាច្រើន មិនបានធ្វើអង្កេតបែបនេះទេ ។ ទិន្នន័យជាក្រុម ដែលមានប្រយោជន៍ច្រើនជាង ក៏ស្ទើរតែរកមិនបានដែរ ។ វិទ្យាស្ថាន CDRI មានទិន្នន័យជាក្រុមលើក្រុមគ្រួសារ ស្តីពីផលប៉ះពាល់ខាងម៉ាក្រូសេដ្ឋកិច្ចនាពេលថ្មីៗ ជាពិសេស ពាក់ព័ន្ធនឹងការឡើងថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ ។ ឯកសារនេះ ប្រើប្រាស់ទិន្នន័យជាក្រុមមួយសំណុំ ដែលប្រមូលលើតំបន់ជនបទកម្ពុជា កាលពីខែមីនា ២០០៨ និង កញ្ញា ២០០៨ ដើម្បីពិនិត្យពីវិធីដែលគ្រួសារនានាទប់ទល់នឹងបញ្ហាកង្វះខាតស្បៀងអាហារបរិភោគ ។ អត្រាអតិផរណាប្រចាំឆ្នាំ សំរាប់ម្ហូបអាហារ គឺ ១៣% នៅខែកញ្ញា ២០០៧ និង ៣៥% នៅខែមីនា ២០០៨ មុននឹងឡើងដល់កំរិតកំពូល ៤៦% នៅខែឧសភា ២០០៨ ។

---

១ អត្ថបទនេះ ជាស្នាដៃរបស់បណ្ឌិត តុង គឹមស៊ុន អ្នកសំរបសំរួលកម្មវិធី នៅវិទ្យាស្ថាន CDRI ។

២ អត្រាអតិផរណា (ទំនិញគ្រប់មុខ) មានលើសពី ១០% នៅខែធ្នូ ២០០៧, ២០% នៅខែមីនា ២០០៨ ហើយឡើងខ្ពស់បំផុតដល់ ២៦% នៅខែឧសភា ២០០៨ (វិទ្យាស្ថានជាតិស្ថិតិ) ។

ទិន្នន័យជាក្រុមបង្ហាញទៀតថា នៅខែមីនា និង កញ្ញា ២០០៨ ចំណាយលើស្បៀងអាហារសរុប ជាមធ្យមក្នុងមនុស្សម្នាក់ កើនឡើងជាង ២០% បើធៀបនឹង ខែកញ្ញា ២០០៤ និង មីនា ២០០៥ ។ ដូច្នេះ យើងបានសម្រេចយកអថេរ ដែលទទួលបានពីខែមីនា ២០០៨ ធ្វើជាស្ថានភាពកំណត់ទុកជាមុននៃវិបត្តិថ្លៃម្ហូបអាហារ។

## ៣.២. ក្របខ័ណ្ឌនៃការពិនិត្យឃើញជាក់ស្តែង និងឧស្សនទាន

នៅពេលស្ថានការណ៍ប្រែប្រួលមិនទៀងទាត់នេះ គ្រួសារនៅជនបទត្រូវដោះស្រាយបញ្ហាបន្ទុំប្រាក់ចំណូលដែលឡើងចុះ ជាមួយនឹងចំណាយប្រើប្រាស់ដែលគេចង់ឱ្យមានស្ថិរភាព ។ ឯកសារមានស្រាប់ មិនត្រឹមតែបានកំណត់ពីប្រសិទ្ធភាពនៃយន្តការកាត់បន្ថយហានិភ័យជាផ្លូវការ និងមិនផ្លូវការ របស់គ្រួសារនានាប៉ុណ្ណោះទេ (Alderman and Paxson 1992; Besley 1995; Deaton 1997; Kang and Sawada 2003b; Kang et al. 2005; Morduch 1994, 1995; Paxson 1992; Ravallion and Chaudhury 1997; Rosenzweig 1988; Townsend 1994, 1995; Udry 1994) ប៉ុន្តែថែមទាំងបានញែកចេញពីគ្នានូវយុទ្ធសាស្ត្រ ២ ពោលគឺ ការគ្រប់គ្រងហានិភ័យ និងការទប់ទល់ហានិភ័យ ដើម្បីដោះស្រាយបញ្ហាចំណូលឡើងចុះ និងស្ថិរភាពចំណាយប្រើប្រាស់ ។ យុទ្ធសាស្ត្រគ្រប់គ្រង សំដៅដល់សកម្មភាពត្រូវអនុវត្តជាមុន ដើម្បីធ្វើឱ្យចំណូលមានស្ថិរភាពនៅចំពោះមុខហានិភ័យ និងភាពមិនទៀងទាត់ផ្សេងៗ (Alderman and Paxson 1992) ដូចជា ការធ្វើចំរុះកម្មប្រភពចំណូល (មុខដំណាំ) ការដាំដំណាំចំរុះលើដីមួយកន្លែង វិនិយោគអាចបត់បែនបាន ការប្រើបច្ចេកវិទ្យាមានហានិភ័យទាប កិច្ចសន្យាពិសេសៗ ដូចជា ការបែងចែកផលដំណាំ (Goh et al. 2005) ការដោះដូរទំនិញ និងសេវា ដោយផ្អែកលើលក្ខណៈជនជាតិ ឬចំណងសាច់ញាតិ (Fafchamps 1999 2000) ។

យុទ្ធសាស្ត្រទប់ទល់ សំដៅដល់សកម្មភាពតាមក្រោយ សំរាប់កាត់បន្ថយការឡើងចុះចំណាយប្រើប្រាស់ ដែលបង្កឡើងដោយការឡើងចុះប្រាក់ចំណូល ។ ការសិក្សាពីមុនមួយចំនួន បានរកឃើញយុទ្ធសាស្ត្រទប់ទល់ផ្សេងៗ របស់គ្រួសារ ដូចជា គ្រោងការណ៍ធានារ៉ាប់រងខ្លួនឯង និងគ្រោងការណ៍ធានារ៉ាប់រងទៅវិញទៅមក ជាដើម (Alderman and Paxson 1992; Besley 1995; Coat and Ravallion 1993; Glewwe and Hall 1998; Kang and Sawada 2003a, 2005; Morduch 1995; Rosenzweig 1988; Ogaki and Zhang 2001; Townsend 1995; Udry 1994) ។ រដ្ឋាភិបាលអាចឆ្លើយតបទៅនឹងការប៉ះទង្គិចជាលក្ខណៈម៉ាក្រូសេដ្ឋកិច្ចបាន តាមរយៈការពង្រីកប្រព័ន្ធសុវត្ថិភាពសង្គម (Cox and Jimenez 1990 Cox, Eser and Jimenez 1998) ។

ការសិក្សានេះ ប្រើប្រាស់ក្របខ័ណ្ឌពិសោធន៍ឃើញជាក់ស្តែង ដែលលើកឡើងដោយ Glewwe and Hall (1998) និង Goh et al. (2005) និងប្រើ OLS regression with the Huber-White Robust Standard Errors to correct for heteroskedasticity ។

## ៣.៣. ទិន្នន័យ

ការសិក្សានេះ ប្រើប្រាស់ទិន្នន័យនៃការសិក្សាពីឌីណាមិកនៃភាពក្រីក្រ ដែលប្រមូលបានក្នុងខែមីនា និង កញ្ញា ២០០៨ ។ អង្កេតនានា បានធ្វើឡើងក្នុង ៩ភូមិ (សំរាប់ព័ត៌មានលំអិតស្តីពីលក្ខណៈសំគាល់របស់ភូមិ និងវិធីយកគំរូតាង សូមមើល Chan and Acharya 2002; Fitzgerald and So 2007) ហើយរំពឹងថា នឹងអាចចង្អុលបង្ហាញពីកត្តាកំណត់នៃភាពក្រីក្ររ៉ាំរ៉ៃ និងភាពក្រីក្របណ្តោះអាសន្ន[៣] ។

## ៣.៤. ស្ថិតិបែបពិពណ៌នា

ដូចមានបង្ហាញក្នុងតារាង ៣.១ ចំណូលសរុបបានធ្លាក់ចុះ ៨% នៅចន្លោះខែមីនា និង កញ្ញា ២០០៨ ។ មុខចំណូលចំបងៗ ដូចជា ចំណូលពីកសិដ្ឋាន និងចំណូលពីធនធានទ្រព្យរួម ជាដើម ស្ថិតនៅថេរ ប៉ុន្តែចំណូលពីការងារក្រៅកសិដ្ឋាន និងប្រភពផ្សេងទៀត ធ្លាក់ចុះ ៣២,៥% និង ៤៥% រៀងគ្នា ។ នៅពេលជាមួយគ្នា បំណុលដែលមានទាំងកំចីផ្លូវការ និងមិនផ្លូវការ បានថយចុះ ២៣% ហើយចំនួនគ្រួសារជំពាក់បំណុលគេ ក៏បានថយចុះ ២៥% ដែរ ។

**តារាង ៣.១: ស្ថិតិបែបពិពណ៌នា (គិតជារៀល/ថ្ងៃ តាមកំរិតថ្លៃនៅខែមីនា ២០០៨)**

| អថេរ | មីនា ២០០៨ | | កញ្ញា ២០០៨ | | %បំលាស់ប្តូរ (មធ្យមភាគ) |
|---|---|---|---|---|---|
| | ចំនួន | មធ្យមភាគ | ចំនួន | មធ្យមភាគ | |
| ទំហំគ្រួសារ | 1003 | 5.76 | 1003 | 5.70 | -1.04 |
| ចំណូលសរុប | 999 | 4647.6 | 1001 | 4270.97 | -8.10 |
| ចំណូលពីការងារក្នុងកសិដ្ឋាន | 674 | 2944.22 | 679 | 2923.51 | -0.70 |
| ចំណូលពីការងារក្រៅកសិដ្ឋាន | 640 | 1850.45 | 585 | 1249.93 | -32.45 |
| ចំណូលពីធនធានទ្រព្យរួម | 924 | 1256.83 | 900 | 1263.66 | 0.54 |
| ចំណូលផ្សេងៗ | 328 | 954.11 | 804 | 524.47 | -45.03 |
| បំណុល (កំចីផ្លូវការ និងមិនផ្លូវការ) | 499 | 198.16 | 372 | 152.01 | -23.29 |
| ចំណាយសរុប | 1003 | 3989.11 | 1003 | 3533.58 | -11.42 |
| ទំនិញមិនមែនអាហារ | 1003 | 1312.7 | 1003 | 1081.96 | -17.58 |
| ម្ហូបអាហារ | 1003 | 2676.41 | 1003 | 2451.62 | -8.40 |
| ចំនួនគ្រួសារ | 1003 | | 1003 | | |

*កំណត់ចំណាំ: ចំណូល និងចំណាយក្នុងមនុស្សម្នាក់ ក្នុងកំរិតថ្លៃគិតត្រឹមខែមីនា ២០០៨, គិតជារៀល*

*ប្រភព: ទិន្នន័យបានពីអង្កេតឆ្នាំ២០០៨ របស់ CDRI*

៣ ការសិក្សានេះ កំពុងធ្វើឡើងដោយ CDRI ហើយគ្រោងហើយស្រេចបាច់ សំរាប់ការជួយមតិបន្ថែមក្នុងពេលឆាប់ៗនេះ ។

ដោយសារចំណូលបានធ្លាក់ចុះ ចំណាយសរុបក៏ធ្លាក់ចុះអស់ ១១% ដែរ ពីខែមីនា ដល់ កញ្ញា ២០០៨ ។ ចំណាយលើទំនិញមិនមែនអាហារ ធ្លាក់ចុះខ្លាំងបំផុតអស់ ១៨% បន្ទាប់មក គឺអាហារ ដែលធ្លាក់ចុះ ៨% ។ ចំណាយលើអាហារបានធ្លាក់ចុះក៏ពិតមែន ប៉ុន្តែវារួមចំណែក ៦៩% ក្នុងចំណាយសរុបប្រចាំគ្រួសារក្នុងខែកញ្ញា ឬកើនឡើង ២% បើធៀបនឹងចំណែករបស់វាក្នុងចំណាយសរុបប្រចាំគ្រួសារកាលពីខែមីនា ហើយវាបង្ហាញថា គ្រួសារនានាបានកាត់បន្ថយចំណាយលើទំនិញមិនមែនអាហារ ដើម្បីយកទៅទប់នឹងចំណាយលើអាហារ ។

ចំណាយប្រើប្រាស់សរុបនៃគ្រួសារមានបុរសជាមេគ្រួ បានធ្លាក់ចុះច្រើនជាង បើធៀបនឹងគ្រួសារមានស្ត្រីជាមេគ្រួ ។ ម្យ៉ាងទៀត គ្រួសារដែលមេគ្រួមានការអប់រំតិច (នារីជាមេគ្រួ ច្រើនតែមានការអប់រំតិចជាងបុរសជាមេគ្រួ) ក៏មានចំណោយប្រើប្រាស់សរុបធ្លាក់ចុះតិចជាងគេដែរ ។ ស្ថានការណ៍ប្រហាក់ប្រហែលគ្នានេះក៏ឃើញមានកើតឡើងដែរ នៅពេលគេធ្វើការបែងចែកមេគ្រួសារជា មេគ្រួធ្វើពលកម្ម និងមេគ្រួមិនធ្វើពលកម្ម ។ ទោះយ៉ាងណាក្តី លទ្ធផលទាំងពីរខាងលើ វាផ្ទុយនឹងសម្មតិកម្មដែលថា គ្រួសារដែលមានមេគ្រួមានការអប់រំល្អ និងគ្រួសារដែលមេគ្រួធ្វើពលកម្ម តែងមានភាពងាយទទួលរងគ្រោះតិចជាង ។ ក្រុមគ្រួសារដែលខ្ចីប្រាក់ពីធនាគារពាណិជ្ជ (Acleda) ស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬប្រភពមិនផ្លូវការផ្សេងៗ ហាក់ដូចពុំមានការធ្លាក់ចុះចំណាយប្រើប្រាស់សរុប តិចជាងគ្រួសារដែលមិនបានខ្ចីប្រាក់គេនោះទេ ។ ដោយពិនិត្យតាមតួលេខបំណុល និងចំនួនគ្រួសារដែលជាប់បំណុលនោះ យើងឃើញថា ក្រុមគ្រួសារដែលមានលទ្ធភាពប្រើប្រាស់ឥណទាន ទំនងជាមិនបានទប់ទល់នឹងការប៉ះទង្គិច ដោយទៅខ្ចីប្រាក់គេ ដើម្បីដោះស្រាយចំណាយប្រើប្រាស់ឡើយ ។

តារាង ៣.២ បង្ហាញពីកំណើនចំណាយប្រើប្រាស់ជាមធ្យម នៃក្រុមបញ្ចភាគគ្រួសារបែងចែកតាមកំរិតធនធាន ។ តារាងនេះបង្ហាញថា គ្រួសារក្នុងក្រុមបញ្ចភាគទាបបំផុត មានការធ្លាក់ចុះចំណាយប្រើប្រាស់ជាអាហារ និងចំណាយប្រើប្រាស់មិនមែនអាហារ តិចជាងគ្រួសារក្នុងក្រុមបញ្ចភាគខ្ពស់ៗជាងខ្លួន ។ គ្រប់ក្រុមបញ្ចភាគទាំងអស់ លើកលែងក្រុមនៅកណ្តាលគេចេញ សុទ្ធតែបានកាត់បន្ថយចំណាយប្រើប្រាស់មិនមែនអាហារ ច្រើនជាងចំណាយលើម្ហូបអាហារ ។ ដូចគ្នានឹង តារាង ៣.១ ដែរ តារាង ៣.២ បង្ហាញថា ជាទូទៅគ្រួសារកម្ពុជា បានកាត់បន្ថយចំណាយប្រើប្រាស់មិនមែនអាហារ ក្នុងពេលមានការប៉ះទង្គិច ។

មធ្យមភាគចំណាយប្រចាំគ្រួសារ ធ្លាក់ចុះ ១៣% ស្របពេលដែលមធ្យមភាគចំណាយក្នុងមនុស្សម្នាក់ធ្លាក់ចុះប្រហែល ១១% ។ ចំណាយក្នុងមនុស្សម្នាក់ ធ្លាក់ចុះតិចជាងចំណាយប្រចាំគ្រួសារបែបនេះ បង្ហាញថា យុទ្ធសាស្ត្រដោះស្រាយតាមក្រោយ ដូចជា ការកេណ្ឌសមាជិកគ្រួសារឱ្យធ្វើពលកម្មជាដើម គេមិនបានសង្កេតឃើញឡើយ ។ ផ្ទុយទៅវិញ មានឯកសារច្រើនណាស់បង្ហាញថា សមាជិកគ្រួសារតែងមកប្រមូលផ្តុំគ្នា ដើម្បីទាញយកចំណេញពីការចំណាយរួមគ្នាច្រើននាក់ នៅអំឡុងពេលមានវិបត្តិសេដ្ឋកិច្ច ។ ជាពិសេស សមាជិកនៃក្រុមគ្រួសារក្រីក្រខ្លាំងដែលទៅរស់នៅតំបន់ទីក្រុង តែងធ្វើចំណាកស្រុកទៅកាន់ទីជនបទ ព្រោះនៅទីនោះចំណាយលើការរស់នៅមានកំរិតទាបជាង ហើយឱកាសរកចំណូលមានច្រើនជាងនៅតំបន់ទីក្រុង ។

**តារាង ៣.២: ចំណាយប្រើប្រាស់ពិតក្នុងមនុស្សម្នាក់ បែងចែកតាមក្រុមបញ្ចភាគ (គិតជារៀល/ថ្ងៃ តាមកំរិតថ្លៃនៅខែមីនា ២០០៨)**

| បញ្ចភាគនៃចំណាយសរុប | ចំណាយសរុប | | ម្ហូបអាហារ | | ចំណាយមិនមែនអាហារ | | ចំណាយសរុប | អាហារ | ចំណាយមិនមែនអាហារ |
|---|---|---|---|---|---|---|---|---|---|
| | មីនា ២០០៨ | កញ្ញា ២០០៨ | មីនា ២០០៨ | កញ្ញា ២០០៨ | មីនា ២០០៨ | កញ្ញា ២០០៨ | %បំលាស់ប្តូរ មីនា-កញ្ញា ២០០៨ | %បំលាស់ប្តូរ មីនា-កញ្ញា ២០០៨ | %បំលាស់ប្តូរ មីនា-កញ្ញា ២០០៨ |
| 1 (ទាបបំផុត) | 2100.2 | 1969.6 | 1674.8 | 1571.6 | 425.4 | 398.1 | -6.22 | -6.16 | -6.44 |
| 2 | 2836.9 | 2619.5 | 2190.5 | 2030.6 | 646.4 | 589.0 | -7.66 | -7.30 | -8.89 |
| 3 | 3403.3 | 3143.8 | 2605.4 | 2394.0 | 797.9 | 749.8 | -7.62 | -8.11 | -6.03 |
| 4 | 4266.0 | 3796.6 | 3039.1 | 2795.5 | 1226.8 | 1001.1 | -11.00 | -8.02 | -18.40 |
| 5 (ខ្ពស់បំផុត) | 7426.4 | 6207.1 | 3906.8 | 3496.0 | 3519.6 | 2711.1 | -16.42 | -10.51 | -22.97 |
| សរុប | 3889.1 | 3553.6 | 2676.4 | 2451.6 | 1312.7 | 1082.0 | -8.63 | -8.40 | -17.58 |

*ប្រភព: ទិន្នន័យបានពីអង្កេតរបស់ CDRI ២០០៨*

តារាង ៣.៣ បង្ហាញពីបំលាស់ទីនៃគ្រួសារ ទៅកាន់ក្រុមបញ្ចភាគផ្សេងទៀត ក្នុងអំឡុងពេលអាហារឡើងថ្លៃ ។ មានគ្រួសារលើសពី ៤២% ក្នុងក្រុមបញ្ចភាគទាបបំផុត និងក្រុមបញ្ចភាគខ្ពស់បំផុត ដែលស្ថិតនៅក្នុងក្រុមបញ្ចភាគដើមដដែល ប៉ុន្តែមានតែ ១៩% នៃគ្រួសារនៅក្នុងបញ្ចភាគទី៣ ប៉ុណ្ណោះ ដែលស្ថិតនៅក្នុងបញ្ចភាគដូចដើម ។ គ្រួសារក្នុងក្រុមបញ្ចភាគទី៤ និង ទី៥ នៅខែមីនា ២០០៨ ដែលបានផ្លាស់ទីទៅកាន់បញ្ចភាគទាបជាងនោះ នៅខែកញ្ញា ២០០៨ មានប្រហែល ៥៧% ។ ប្រហែល ៤១% នៃគ្រួសារក្នុងក្រុមបញ្ចភាគទី៣ កាលពីខែមីនា ២០០៨ បានប្តូរទៅក្នុងក្រុមបញ្ចភាគទី១ និង ទី២ នៅខែកញ្ញា ២០០៨ ។ យើងឃើញថា ភាគរយនៃគ្រួសារក្នុងក្រុមបញ្ចភាគទី៣ ទី៤ និង ទី៥ ដែលផ្លាស់ប្តូរទៅកាន់ក្រុមបញ្ចភាគទី១ និង ទី២ ហាក់ដូចជាមានចំនួនច្រើន ហើយក៏មិនមានភស្តុតាងអ្វីបង្ហាញថា ក្រុមបញ្ចភាគទី១ និង ទី២ (ក្រុមទាបៗបំផុត) បានរងផលប៉ះពាល់ខ្លាំងជាងដោយកំណើនថ្លៃម្ហូបអាហារឡើយ ។

**តារាង ៣.៣: ម៉ាទ្រីសបំលាស់ប្តូរនៃក្រុមគ្រួសារ គិតតាមបញ្ចភាគនៃចំណាយក្នុងមនុស្សម្នាក់ ពីខែមីនា-កញ្ញា ២០០៨ (%)**

| បញ្ចភាគ ខែមីនា ២០០៨ | បញ្ចភាគ ខែកញ្ញា ២០០៨ | | | | | |
|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | Total |
| 1 | 42 | 22 | 16 | 11 | 8 | 100 |
| 2 | 26 | 22 | 24 | 16 | 10 | 100 |
| 3 | 15 | 26 | 19 | 23 | 17 | 100 |
| 4 | 11 | 19 | 27 | 22 | 20 | 100 |
| 5 | 6 | 11 | 13 | 27 | 43 | 100 |

*ប្រភព : ទិន្នន័យបានពីអង្កេតរបស់ CDRI ២០០៨*

## ៣.៥. លទ្ធផលបានពីបទពិសោធន៍ជាក់ស្តែង

ការពិភាក្សាពីខាងដើម បានផ្តល់គំនិតជារួមមួយពីបទពិសោធន៍របស់គ្រួសារក្នុងគំរូតាង នៅអំឡុងពេលម្ហូបអាហារឡើងថ្លៃ ប៉ុន្តែវាមិនបានផ្តល់ជាទិដ្ឋភាពបែបបរិមាណនៃការប៉ះទង្គិចឡើយ ។ ផ្នែកនេះជួយបំពេញបន្ថែមលើការវិភាគបែបពិពណ៌នារបស់យើង ដោយផ្តល់ការវាយតម្លៃខាងសេដ្ឋកិច្ចមាត្រសាស្ត្រ (econometric) លើរង្វាស់មួយនៃសុខុមាលភាព គឺឡូការីតនៃចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ (log per capita consumption) ។

ការប៉ាន់ស្មានតាមបទពិសោធន៍ជាក់ស្តែង (ដោយប្រើ fixed effect panel data regression technique) បង្ហាញថា កម្រិតអប់រំ ភេទ និងស្ថានភាពមានប្តីប្រពន្ធ ឬអត់ នៃមេគ្រួសារ មិនមានសារៈសំខាន់ខាងស្ថិតិឡើយ ។ បច្ចេកទេសនេះសន្មតថា អ្នកមានការអប់រំខ្ពស់ មិនមែនសុទ្ធតែអាចរកបានការងារល្អជាងឡើយ ហើយមិនមានការខុសគ្នាអ្វីឡើយ រវាងគ្រួសារដែលមានមេគ្រួជាស្រី ឬមេគ្រួជាប្រុស ឬមួយរវាងមេគ្រួដែលមានប្តី-ប្រពន្ធ និងមេគ្រួដែលនៅលីវ ។ មេគុណអាយុមេគ្រួសារមានតួលេខអវិជ្ជមាន ប៉ុន្តែមិនមានសារៈសំខាន់ខាងស្ថិតិឡើយ បើទោះជាវាមានតំលៃស្មើនឹង ១០% នៃសមីការចំណាយលើម្ហូបអាហារ និងចំណាយសរុបក៏ដោយ ។ រឿងនេះបង្ហាញថា បទពិសោធន៍ការងាររបស់មេគ្រួសារ មិនមែនជាកត្តាកំណត់ចំបងមួយលើចំណាយប្រើប្រាស់ឡើយ ។ គួរកត់សម្គាល់ថា បទពិសោធន៍ការងាររបស់មេគ្រួសារ មានឥទ្ធិពលវិជ្ជមានលើចំណាយប្រើប្រាស់មិនមែនអាហារ ។ មេគ្រួសារដែលធ្វើការក្នុងវិស័យសេវាកម្ម ដូចជា ពាណិជ្ជកម្មខ្នាតតូច ឬការដឹកជញ្ជូនជាដើម ច្រើនតែមានចំណាយប្រើប្រាស់សរុប (ជាពិសេស ចំណាយប្រើប្រាស់មិនមែនអាហារ) ខ្ពស់ជាងមេគ្រួសារដែលធ្វើការក្នុងវិស័យកសិកម្ម ឬឧស្សាហកម្មធុនស្រាល ។ ជាមធ្យម គ្រួសារធំៗ និងគ្រួសារមានកូនច្រើន តែងមានភាពក្រីក្រច្រើនជាងគ្រួសារផ្សេងៗទៀត (ក្រសួងផែនការ ឆ្នាំ២០០៦) ។ យើងរកឃើញថា គ្រួសារធំៗតែងមានឥទ្ធិពលអវិជ្ជមានលើចំណាយប្រើប្រាស់មិនមែនអាហារ ប៉ុន្តែមានឥទ្ធិពលវិជ្ជមានលើចំណាយប្រើប្រាស់ជាម្ហូបអាហារ ។ គ្រួសារដែលមានកូនក្រោមអាយុ១៥ឆ្នាំ ច្រើននាក់ តែងចំណាយតិចជាងលើម្ហូបអាហារ ប៉ុន្តែច្រើនជាងលើទំនិញមិនមែនអាហារ ។ រឿងនេះប្រហែលមកពីកត្តាជាច្រើន ដូចជា នៅពេលជីវភាពលំបាកតឹងតែង ព្រមគ្នានឹងការកាត់បន្ថយចំណាយប្រើប្រាស់មិនមែនអាហារ តែងមានសមាជិកគ្រួសារកាន់តែច្រើននាក់ ចូលរួមក្នុងសកម្មភាពរកចំណូល ឬក៏គ្រួសារបន្តដោះស្រាយចំណាយលើការសិក្សា ដើម្បីជៀសវាងការបញ្ឈប់ការសិក្សារបស់កូនៗ ។

គ្រួសារមានសមាជិកអាយុលើស ៦០ឆ្នាំ ច្រើននាក់ មិនបង្កជាគុណវិបត្តិអ្វីទេ ។ គ្រួសារដែលជាប់បំណុលគេទំនងជាប្រើប្រាស់ឥណទាន ដើម្បីពង្រីកចំណាយប្រើប្រាស់ ជាពិសេស ចំណាយមិនមែនអាហារ ។ គ្រួសារដែលទទួលបានប្រាក់ផ្ញើមកផ្ទះ ទំនងជាបង្កើនចំណាយប្រើប្រាស់មិនមែនអាហារ ច្រើនជាងចំណាយខាងម្ហូបអាហារ ។ អថេរដែលបង្ហាញពីស្ថានភាពនៅមុនពេល និងនៅក្រោយពេលមានវិបត្តិ វាមានមេគុណអវិជ្ជមានធំគួរកត់សំគាល់សំរាប់រាល់មុខចំណាយប្រើប្រាស់ ហើយវាបង្ហាញថា ចំណាយប្រើប្រាស់មិនមែនអាហារធ្លាក់ចុះខ្លាំងជាងគេ រីឯចំណាយលើម្ហូបអាហារធ្លាក់ចុះតិចជាងគេ គឺមានលក្ខណៈស្របគ្នានឹងរបកគំហើញដែលបានលើកឡើងពីខាងដើម ។ គួរកត់សំគាល់ដែរថា លំនាំចំណាយប្រើប្រាស់នៅតាមតំបន់ជនបទកម្ពុជា តែងប្រែប្រួលខុសគ្នារវាងរដូវប្រាំង (មករា-មិថុនា) និងរដូវវស្សា (កក្កដា-ធ្នូ) ។ Fitzgerald and So (2007) បានកត់សម្គាល់ថា គ្រួសារជាទូទៅតែងកាត់បន្ថយចំណាយប្រើប្រាស់ជាអាហារ និងមិនមែនជាអាហារ នៅពេលចំណូល ឬសន្តិសុខស្បៀងធ្លាក់ចុះ ដូចជា នៅរដូវវស្សាជាដើម ។ ចំពោះលទ្ធផលខាងលើនេះ គេមិនបានយកមកគិតគូរនូវបំរែបំរួលតាមរដូវកាលនេះទេ ។

ការប៉ាន់ស្មានដោយប្រើ OLS regression technique បានផ្តល់នូវភស្តុតាងច្បាស់លាស់ ពីប្រភេទគ្រួសារងាយរងគ្រោះ និងយុទ្ធសាស្ត្រទប់ទល់ហានិភ័យរបស់ពួកគេ ។ លទ្ធផលរកឃើញបង្ហាញថា ភាពងាយរងគ្រោះនៃគ្រួសារមានស្ត្រីជាមេគ្រួ មិនធ្ងន់ធ្ងរជាងគ្រួសារមានបុរសជាមេគ្រួទេ ។ គ្រួសារដែលមេគ្រួមានការអប់រំកម្រិតខ្ពស់ ក៏មានភាពងាយរងគ្រោះ មិនតិចជាងគ្រួសារដែលមេគ្រួមានការអប់រំកម្រិតទាបដែរ គឺខុសពីសម្មតិកម្មរបស់ Schultz's (1975) ។ គ្រួសារទំហំធំ ហាក់ដំណើរការមិនបានល្អជាងគ្រួសារតូចៗទេ ក្នុងអំឡុងពេលនៃវិបត្តិម្ហូបអាហារ ។ គេរកមិនឃើញភាពខុសគ្នាធំដុំទេ រវាងគ្រួសារដែលមានកូនអាយុក្រោម ១៥ឆ្នាំ តិចនាក់ ឬក៏ច្រើននាក់នោះ ។ លទ្ធផលនេះ ផ្ទុយគ្នានឹងឯកសារមានស្រាប់ភាគច្រើនដែលពិនិត្យឃើញថា គ្រួសារធំៗមានការការពារល្អជាង ទល់នឹងការធ្លាក់ចុះចំណាយប្រើប្រាស់ ហើយគ្រួសារមានកូនអាយុក្រោម ១៥ឆ្នាំ ច្រើននាក់តែងតែកាត់បន្ថយចំណាយលើម្ហូបអាហារ ដើម្បីដោះស្រាយចំណាយលើការសិក្សារបស់កូនៗ (ដែលជាចំណាយប្រើប្រាស់មិនមែនអាហារ) (សូមមើល Goh et al., 2005) ។ មានភស្តុតាងតិចតួចដែរ ដែលបញ្ជាក់ថា គ្រួសារមានសមាជិករវៀយចំណាស់ច្រើននាក់ មានលក្ខណៈងាយទទួលរងគ្រោះជាង ដោយវិបត្តិម៉ាក្រូសេដ្ឋកិច្ច ។ ឥណទាន និងការផ្ទេរប្រាក់ជំនួយពីរដ្ឋ ក៏ហាក់ដូចមិនឃើញមានប្រើជាយុទ្ធសាស្ត្រដោះស្រាយទេ ទាំងនៅមុនពេល និងនៅក្រោយពេលមានវិបត្តិ ។ ដើម្បីគ្រប់គ្រងចំណាយប្រើប្រាស់ពីមួយខែទៅមួយខែ គ្រួសារទំនងតែងប្រើប្រាស់ប្រាក់ផ្ញើមកផ្ទះ ធ្វើជាយុទ្ធសាស្ត្រដោះស្រាយក្រោយពេលជួបហានិភ័យ ។ គ្រួសារមានមេគ្រួ ធ្វើការងារក្នុងវិស័យកសិកម្ម ទំនងដំណើរការបានល្អជាងគ្រួសារមានមេគ្រួធ្វើការក្នុងវិស័យឧស្សាហកម្ម ឬសេវាកម្ម ។ គ្រួសារមានមេគ្រួធ្វើការក្នុងវិស័យសេវាកម្ម ទំនងធ្វើការកាត់បន្ថយចំណាយប្រើប្រាស់មិនមែនអាហារ ដើម្បីរក្សាលទ្ធភាពចំណាយលើម្ហូបអាហារ ។ សត្វចិញ្ចឹមដើរតួសំខាន់ណាស់ ក្នុងការការពារទល់នឹងកង្វះចំណាយប្រើប្រាស់ក្នុងអំឡុងពេលមានកំណើនថ្លៃអាហារ ។ ភស្តុតាងពីប្រទេសដទៃទៀតនៅអាស៊ីបង្ហាញថា ពេលខ្លះសត្វចិញ្ចឹមត្រូវបានចាត់ទុកជាទ្រព្យដ៏សំខាន់ សំរាប់ជួយសម្រួលដល់ចំណាយប្រើប្រាស់ក្នុងរដូវខ្វះខាត ឬនៅពេលមានការប៉ះទង្គិចជាធម្មតា (Kurosaki, 1995) ។

## ៣.៦. សេចក្តីសន្និដ្ឋាន

ដោយប្រើទិន្នន័យជាក្រុម ដែលប្រមូលបាននៅពីរពេលខុសគ្នា នៅខែមីនា និង កញ្ញា ២០០៨ ឯកសារនេះបានសិក្សាថា តើគ្រួសារនៅទីជនបទ ទប់ទល់យ៉ាងដូចម្តេចនឹងការប៉ះទង្គិចលើប្រាក់ចំណូល ។ យើងរកឃើញថា សត្វចិញ្ចឹមដើរតួសំខាន់ណាស់ ក្នុងការការពារទល់នឹងកង្វះចំណាយប្រើប្រាស់ ហើយគ្រួសារមានមេគ្រួធ្វើការក្នុងវិស័យកសិកម្ម ទំនងដំណើរការបានល្អជាងគ្រួសារមានមេគ្រួធ្វើការក្នុងវិស័យផ្សេងទៀត ។ គ្រួសារនៅតាមជនបទ ច្រើនប្រើប្រាស់ប្រាក់ផ្ញើមកផ្ទះ ធ្វើជាយុទ្ធសាស្ត្រដោះស្រាយក្រោយពេលជួបហានិភ័យ នៅអំឡុងពេលមានវិបត្តិអាហារឡើងថ្លៃ ។

គ្មានភស្តុតាងអ្វីបង្ហាញថា ឥណទាន និងការផ្ទេរប្រាក់ជំនួយពីរដ្ឋ ត្រូវបានប្រើជាយុទ្ធសាស្ត្រដោះស្រាយនៅមុនពេល ឬនៅក្រោយពេលជួបហានិភ័យនោះឡើយ ។ រឿងនេះអាចមកពីកង្វះឥណទាន ដែលជាលទ្ធផលនៃការរឹតបន្តឹងនយោបាយរូបិយវត្ថុ និងអវត្តមាននៃបណ្តាញសន្តិសុខសង្គម ។ យើងបានកត់សម្គាល់ថា យុទ្ធសាស្ត្រដោះស្រាយតាមក្រោយ ដូចជា ការកេណ្ឌប្រមូលសមាជិកគ្រួសារឱ្យចូលរួមធ្វើពលកម្ម ជាដើម មិនឃើញមាន

អនុវត្តទេ ។ គ្រួសារធំៗ ហាក់ដូចមិនមានដំណើរការប្រសើរជាងគ្រួសារតូចៗឡើយ ។ គ្រួសារមានស្ត្រីជាមេគ្រួ និងគ្រួសារមានបុរសជាមេគ្រួ មានលក្ខណៈងាយរងគ្រោះប្រហែលៗគ្នា គឺផ្ទុយពីការទទួលស្គាល់ជាទូទៅដែលថា គ្រួសារធំៗមានប្រៀបជាង ដោយសារគេធ្វើចំណាយជុំក្នុងគ្រាមានវិបត្តិ និងថា គ្រួសារមានស្ត្រីជាមេគ្រួតែងងាយរងគ្រោះខ្លាំងជាងគ្រួសារមានបុរសជាមេគ្រួ ។ គ្រួសារដែលមានមនុស្សចាស់ច្រើននាក់ តែងងាយរងគ្រោះជាងគ្រួសារដទៃទៀត ។

លទ្ធផលពិនិត្យឃើញជាក់ស្តែងក្នុងការសិក្សានេះ ក៏ជួយបំភ្លឺបានខ្លះដែរថា នរណាងាយរងគ្រោះដោយសារវិបត្តិម៉ាក្រូសេដ្ឋកិច្ច ។ របកគំហើញបង្ហាញថា កម្មវិធីការពារសង្គមមានរយៈពេលខ្លី ដូចជា ការផ្ទេរប្រាក់ជំនួយស្បៀងពលកម្ម ប័ណ្ណរបបអាហារ និងអាហារតាមសាលារៀន ជាដើម គួរផ្តោតលើគ្រួសារធំៗ និងគ្រួសារមានមនុស្សវ័យចំណាស់ច្រើននាក់ ។ សំរាប់រយៈពេលវែង បំលាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចចំបងៗ ដូចជា ការបង្កើនទ្រព្យរូបវ័ន្ត និងធនធានមនុស្សជាដើម មានលក្ខណៈសមស្របល្អសំរាប់គ្រួសារមានស្ត្រីជាមេគ្រួ ។ ជាពិសេសទៀតការធានារ៉ាប់រង និងកម្មវិធីរក្សាស្ថិរភាពថ្លៃ គឺជាឧបករណ៍ខាងគោលនយោបាយដ៏សំខាន់បំផុត ។ ទោះយ៉ាងនេះក្តីគួរមានធ្វើការសិក្សាស្រដៀងគ្នានេះមួយទៀត ដើម្បីស្វែងយល់ពីលក្ខណៈលំអិតនៃក្រុមជនងាយរងគ្រោះ ក៏ដូចជាដើម្បីពិនិត្យមើលថា ហេតុអ្វីពួកគេងាយរងគ្រោះជាងអ្នកឯទៀត និងដើម្បីកំណត់ពីយន្តការដ៏ប្រសើរសំរាប់ការពារក្រុមទាំងនោះ ។

# ជំពូក ៤
# លទ្ធផលរកឃើញសំខាន់ៗពីការសិក្សា លើការអនុវត្តប្រព័ន្ធសុវត្ថិភាពសង្គម និងការគ្រប់គ្រងមិនផ្លូវការលើហានិភ័យ ក្នុងអំឡុងពេលវិបត្តិសេដ្ឋកិច្ចនៅកម្ពុជា៖ បទពិសោធន៍សិក្សាពីក្រុមគ្រួសារ និងពលករក្រីក្រ និងងាយរងគ្រោះ[១]

*ដោយលោក សូ សុវណ្ណារិទ្ធិ ជាមួយបណ្ឌិត តុង គីមស៊ុន និង លោកស្រី ប៉ុន ដូរីណា*

## ៤.១. លទ្ធផលរកឃើញសំខាន់ៗ

លទ្ធផលរកឃើញទាំងនេះ បានមកពីការវាយតម្លៃលឿនប្រចាំត្រីមាស អំពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចមកលើគ្រួសារនៅកម្ពុជា ដែលធ្វើឡើងដោយ CDRI ជាមួយនឹងធនាគារពិភពលោក ចំនួន ៣លើក គឺក្នុងខែឧសភា សីហា និងវិច្ឆិកា ឆ្នាំ២០០៩ ។ ផ្នែកទី២ បង្ហាញពីវិធីសាស្ត្រស្រាវជ្រាវនៃការវាយតម្លៃនេះ ។ លទ្ធផលរកឃើញសំខាន់ៗខាងក្រោមនេះ ទាញចេញពីការសិក្សាដែលមានស្រាប់ និងឆ្លើយតបទៅនឹងគោលបំណងនៃការវាយតម្លៃលឿនខាងលើ ។ សំរាប់ព័ត៌មានលំអិត សូមរកមើលក្នុងអត្ថបទដើមទាំងមូល ដែលមាននៅក្នុងជំពូកទី៤ នៃរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ របស់ CDRI ចេញផ្សាយក្នុងខែមីនា ឆ្នាំ២០១០ ។

### *៤.១.១. សារៈសំខាន់នៃការបង្កើតប្រព័ន្ធសុវត្ថិភាពសង្គម*

បច្ចុប្បន្ន មានការជជែកវែកញែកកាន់តែច្រើននៅកម្ពុជា ស្តីពីផ្លែផ្កានៃការអភិវឌ្ឍសំរាប់ជនក្រីក្រ និងការគិតគូរបែបថ្មីក្នុងមជ្ឈដ្ឋានខាងគោលនយោបាយ ដើម្បីកសាងកម្មវិធី និងគោលនយោបាយប្រព័ន្ធសុវត្ថិភាពមួយថ្មីនៅកម្ពុជា ។ ការវាយតំលៃនេះ បានធ្វើឡើងទាន់ពេលល្អ ដោយអាចផ្តល់ជាគំនិតដល់អ្នកកសាងគោលនយោបាយ និងអ្នកអនុវត្តការងារអភិវឌ្ឍន៍ អំពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច ទៅលើការកាត់បន្ថយភាពក្រីក្រ និងវិធីសាស្ត្រដែលជនក្រីក្រកំពុងប្រើ ដើម្បីដោះស្រាយហានិភ័យ ក្នុងពេលដែលប្រព័ន្ធសុវត្ថិភាពជាផ្លូវការរបស់រដ្ឋាភិបាលនៅខ្វះខាតជាទូទៅនៅឡើយ ។ គេសង្ឃឹមថា ការយល់ដឹងកាន់តែប្រសើរ ពីប្រព័ន្ធសុវត្ថិភាពសង្គមក្រៅផ្លូវការដែលមានស្រាប់ អាចផ្តល់ជាជំនួយដល់ការរចនារៀបចំប្រព័ន្ធសុវត្ថិភាពរបស់រដ្ឋាភិបាល ឱ្យកាន់តែមានប្រសិទ្ធភាព និងមិនប្រទាំងប្រទើសគ្នាជាមួយរបៀបរបបអនុវត្តក្រៅផ្លូវការ ហើយថែមទាំងជួយបំពេញបន្ថែមចំនុចខ្វះខាតផ្សេងៗ ដែលរបៀបរបបក្រៅផ្លូវការមិនមានផ្តល់ទៀតផង ។

---

១ អត្ថបទនេះ ជាស្នាដៃរបស់លោក សូ សុវណ្ណារិទ្ធិ អ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ជាមួយនឹងការជួយជ្រោមជ្រែងយ៉ាងថ្លៃថ្លាពីបណ្ឌិត តុង គីមស៊ុន ជាអ្នកសំរបសំរួលកម្មវិធី និង លោកស្រី ប៉ុន ដូរីណា អ្នកសំរបសំរួលការងារចុះដល់កន្លែងរបស់ CDRI ។ ឯកសារនេះអាចរៀបចំឡើងបាន ក៏ដោយសារការជួយមតិពីសមាជិកក្រុមស្រាវជ្រាវផ្សេងៗទៀត ប្រចាំ CDRI ដែលរួមមាន បណ្ឌិត ថេង វុទ្ធី លោក គីម សុធន លោក ឈឹម ឈន់ កញ្ញា ផាន់ ដាលីស និង លោក យៀង សុធី ។

ការបង្កើត និងការពង្រឹងប្រព័ន្ធសុវត្ថិភាពសង្គម រួមជាមួយនឹងចំលើយតបខាងគោលនយោបាយ ចំពោះឥទ្ធិពលអវិជ្ជមាននៃវិបត្តិសេដ្ឋកិច្ចសាកល បានក្លាយជាចំនុចប្រមូលផ្តុំចំណាប់អារម្មណ៍ចំបងមួយ ពីសំណាក់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា សំរាប់ការកាត់បន្ថយភាពក្រីក្រ និងការជំរុញកំណើន ។ ការកាត់បន្ថយភាពក្រីក្រអាចធ្វើឡើងតាមពីររបៀប គឺការបង្ការប្រជាជនមិនក្រីក្រ កុំឱ្យធ្លាក់ខ្លួនក្រីក្រ និងការលើកស្ទួយអ្នកក្រីក្រ ឱ្យចាកផុតពីភាពក្រីក្រ ។ កំណើនសេដ្ឋកិច្ច គឺជាកត្តាសំខាន់ សំរាប់លើកស្ទួយប្រជាជនឱ្យចាកផុតពីភាពក្រីក្រ ប៉ុន្តែត្រូវមានគោលនយោបាយជាច្រើនទៀត ដើម្បីធានាថា ទី១-អត្ថប្រយោជន៍ទទួលបានពីកំណើន ត្រូវចែករំលែកឱ្យបានធំទូលាយ (ជាពិសេស បានទៅដល់ប្រជាជនក្រីក្រ) និង ទី២-កុំឱ្យប្រជាជនមិនក្រីក្រ គេធ្លាក់ចុះទៅក្រោមបន្ទាត់ក្រីក្រ ។ ប្រព័ន្ធសុវត្ថិភាពសង្គម អាចជួយដោះស្រាយការព្រួយបារម្ភទាំងពីរនេះបាន ។ វាក៏ជួយឱ្យគ្រួសារក្រីក្រ និងគ្រួសារជិតក្រីក្រ អាចចូលរួមក្នុងដំណើរការរីកលូតលាស់ ដើម្បីឱ្យពួកគេតាមទាន់គ្រួសារនៅជិតខាង ដែលធូរធារជាង ។ សង្គមជាតិ ក៏ទទួលបានអត្ថប្រយោជន៍ដែរ ដោយសារប្រជាជនក្រីក្រ ដែលមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធសុវត្ថិភាពសង្គម អាចចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច បានល្អប្រសើរជាង ទាំងតាមរយៈការបង្កើនផលិតភាព និងចំរុះកម្មផលិតកម្ម ហើយនិងការរក្សាតំរូវការចំណាយប្រើប្រាស់ ។

ហានិភ័យមានជាប់ជានិច្ចក្នុងជីវភាពប្រចាំថ្ងៃនៅប្រទេសកម្ពុជា ។ ក្នុងករណីជាច្រើន ប្រជាជនបានធ្លាក់ចូល និងចាកផុតពីភាពក្រីក្រច្រើនដង ចុះឡើងក្នុងឆាកជីវិតរបស់ខ្លួន ដោយសារការប៉ះទង្គិច និងវដ្តនៃជីវិត (អាពាហ៍ពិពាហ៍ កសាងផ្ទះសម្បែង មានកូនចៅ ចូលវ័យចំណាស់ មរណភាពក្នុងគ្រួសារ) ។ កំណើនសេដ្ឋកិច្ចនាពេលថ្មីៗ ជំនួយអភិវឌ្ឍន៍ និងអន្តរាគមន៍ផ្សេងៗ បានជួយលើកកំពស់កំរិតជីវភាព ប៉ុន្តែសមត្ថភាពរបស់ជនក្រីក្រ ដើម្បីដោះស្រាយវិបត្តិ ឬហានិភ័យមើលមិនឃើញ គឺនៅតែត្រូវការការការពារ និងកែលំអបន្ថែមទៀត ។ ភូមិធូរធារ និងរីកលូតលាស់លឿន និងគ្រួសារធូរធារនៅក្នុងភូមិក្រីក្រ ហាក់ដូចមានសមត្ថភាពខ្ពស់ជាង ដើម្បីទប់ទល់នឹងការប៉ះទង្គិចផ្សេងៗ (Fitzgerald and so, 2007) ។ ជនក្រីក្រ និងក្រុមងាយរងគ្រោះឯទៀត ដូចជា ជនចាស់ជរា និងជនពិការ ជាដើម តែងងាយរងគ្រោះថ្នាក់ ពីព្រោះពួកគេមានប្រាក់ចំណូលសរុបតិចតួច មានប្រាក់សន្សំតិច មានទ្រព្យរបស់តិច និងមានធនធានមនុស្សតិច (Devereux, 2001) ។ ហានិភ័យផ្សេងៗ មានផលប៉ះពាល់លឿនជាង និងធ្ងន់ធ្ងរជាង ទៅលើជនក្រីក្រ និងងាយរងគ្រោះ ជាពិសេស គឺទៅលើសុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត និងការរីកលូតលាស់របស់ពួកគេក្នុងរយៈពេលវែង ។ ដោយឡែក ស្ត្រី និងកុមារ ច្រើនរងគ្រោះខ្លាំងជាងគេ នៅពេលក្រុមគ្រួសារជួបការលំបាក ។ សំរាប់ជនក្រីក្រ ការបាត់បង់ប្រាក់ចំណូល ធ្វើឱ្យពួកគេត្រូវបង្ខំចិត្តលក់ដីធ្លី សត្វចិញ្ចឹម ឬទ្រព្យផលិតកម្មផ្សេងទៀត, បញ្ជូនកូនអោយទៅធ្វើការរកប្រាក់ ជាជាងឱ្យកូនទៅសាលារៀន ឬបរិភោគអាហារតិច (CDRI, 2008) ។ វិធានការទាំងអស់នេះ ប្រហែលអាចជួយគ្រួសាររបស់ពួកគេឱ្យរស់រានបានពីមួយថ្ងៃទៅមួយថ្ងៃ ប៉ុន្តែ ក៏នឹងធ្វើអោយពួកគេពិបាកចាកផុតពីភាពក្រីក្រនៅថ្ងៃអនាគតផងដែរ (Fitzgerald and So, 2007) ។ វាក៏អាចជាកត្តានាំឱ្យមានទំនាក់ទំនងអន់ខ្សោយខាងពលកម្ម និងអស្ថិរភាពសង្គម ផងដែរ (Ballard et al., 2007) ។

ប្រជាជនក្រីក្រ និងងាយរងគ្រោះ ដែលមានទ្រព្យសម្បត្តិ ឬប្រាក់សន្សំតិចតួច តែងស្វែងរកជំនួយ (អង្ករ ឬប្រាក់កាស) ពីសាច់ញាតិ មិត្តភក្តិ ឬអ្នកជិតខាង ដែលមានជីវភាពធូរធារ នៅពេលជួបការខ្វះខាត ឬក៏ទៅបេះប្រមូលផលដែលអាចហូប/លក់បាន ពីព្រៃឈើ បឹងបួរ និងដីរួម ឬក៏ខ្ចីបុលពីអ្នកដទៃ ។

ទំលាប់អនុវត្តន៍បែបនេះ ដែលអាចចាត់ទុកជាប្រព័ន្ធក្រៅផ្លូវការ សំរាប់គ្រប់គ្រង និងចែករំលែកហានិភ័យ គឺជាប្រព័ន្ធសុវត្ថិភាពក្រៅផ្លូវការ សំរាប់ប្រជាជនក្រីក្រ ហើយបានដំណើរការនៅក្នុងសង្គមកម្ពុជា ជាច្រើនជំនាន់មកហើយ[២] ។ វាបានផ្លាស់ប្តូររូបភាពទៅតាមពេលវេលា ប៉ុន្តែនៅតែមានអនុវត្តជាទូទៅ នៅក្នុងចំណោមសាច់ញាតិជិតស្និទ្ធ ក្រុមគ្រួសារធំទូលាយ មិត្តភក្តិ និងបណ្តាញសង្គមមួយចំនួន ។ សេដ្ឋកិច្ចប្រាក់កាសសព្វថ្ងៃកំពុងធ្វើឱ្យខូចខាតដល់ប្រព័ន្ធសុវត្ថិភាពក្រៅផ្លូវការនេះហើយ ដោយសារកំណើនវិសមភាព និងបរាជ័យនៃអន្តរាគមន៍ជួយអភិវឌ្ឍមួយចំនួន (Devereux, 2001) ។

នៅប្រទេសកម្ពុជា មានកម្មវិធីគាំពារសង្គមជាផ្លូវការជាច្រើន សំរាប់ជួយដល់ជនក្រីក្រ ស្រ្តី មនុស្សចាស់ និងជនងាយរងគ្រោះ នៅតំបន់ជនបទ ដូចជា មូលនិធិសមធម៌ កម្មវិធីផ្តល់អាហារនៅសាលារៀន ការចាក់ថ្នាំបង្ការដល់មាតានិងទារក និងកម្មវិធីផ្តល់អាហាររូបត្ថម្ភ ប្រាក់សោធននិវត្តន៍សំរាប់មន្ត្រីរាជការ (Chan & Ear 2004) និងក្រុមជួយខ្លួនឯង ដែលបង្កើតឡើងដោយអង្គការមិនមែនរដ្ឋាភិបាល (ធនាគារស្រូវ និងគ្រោងការសន្សំប្រាក់) (Fitzgerald & So 2007) ។ ប៉ុន្តែកម្មវិធីទាំងនេះ ហាក់ដូចមិនទាន់រឹងមាំគ្រប់គ្រាន់ អាចប្រើជាប្រព័ន្ធសុវត្ថិភាពសំរាប់ជនក្រីក្រនៅឡើយទេ ។ គ្រោងការណ៍នានា បានដាក់អនុវត្តន៍តាមបែប "អាវបំណះ" ដោយគ្របដណ្តប់ជនងាយរងគ្រោះ ឬតំបន់ភូមិសាស្ត្រមួយចំនួន ជួនកាលជាន់គ្នា ជួនកាលរំលងចោលខ្លះ គ្រោងការខ្លះមានប្រសិទ្ធភាពជាងគ្រោងការខ្លះទៀត ហើយប្រព័ន្ធកំណត់មុខសញ្ញាត្រូវជួយក៏មានច្រើន និងប្រទាំងប្រទើសគ្នាជារឿយៗ ។

## ៤.១.២. ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចទៅលើ កំណើន ការងារ និង ភាពក្រីក្រ

មុនពេលមានវិបត្តិហិរញ្ញវត្ថុសាកល កម្ពុជាទទួលបាននូវកំណើនលឿនចេញពីមូលដ្ឋានទាបមួយ (World Bank 2007) បើធៀបទៅនឹងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតនៅក្នុងតំបន់ ហើយបានជាប់ឈ្មោះក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតទាំង ១០ នៅលើពិភពលោក ។ វិបត្តិសាកល បានប៉ះពាល់ធ្ងន់ធ្ងរលើពាណិជ្ជកម្ម វិស័យកំណើនសេដ្ឋកិច្ចសំខាន់ៗ និងប្រាក់ផ្ញើពីបរទេសមកផ្ទះ ហើយបានបណ្តាលឱ្យជំនួយអភិវឌ្ឍន៍ផ្លូវការមានការធ្លាក់ចុះខ្លាំង (Jalilian et al. 2009) ។ ការធ្លាក់ចុះនៃចំនួនការងារ នៅក្នុងវិស័យផ្សេងៗ គឺជាលទ្ធផលនៃភាពអន់ថយខ្លាំងក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ ដែលរួមមាន វិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ នៅរវាងពាក់កណ្តាលឆ្នាំ២០០៨ និងចុងឆ្នាំ២០០៩ ។ រោងចក្រកាត់ដេរជាច្រើន កាន់កាប់ដោយវិនិយោគិនបរទេស ហើយមានទិសដៅនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ។ បរិមាណ និងតំលៃការនាំចេញសំលៀកបំពាក់ បានធ្លាក់ចុះអស់ ១៧% និង ២៤% បន្តបន្ទាប់គ្នានៅឆមាសទី១ ឆ្នាំ២០០៩ ។ នៅរវាងខែកញ្ញា ២០០៨ និងខែកុម្ភៈ ២០០៩ មានរោងចក្រកាត់ដេរ ១៣០ បានបិទទ្វារ ដែលបណ្តាលឱ្យកម្មករ ៥១.០០០នាក់ ឬ ស្មើនឹង ១៥% នៃចំនួនកម្មករនៅក្នុងវិស័យកាត់ដេរនេះ ត្រូវបាត់បង់ការងារ ។

ដូចគ្នានេះដែរ កំណើនលេខពីរខ្ទង់នៃវិស័យទេសចរណ៍ បានធ្លាក់ចុះមកនៅប្រហែល ៩% ក្នុងឆ្នាំ២០០៩ ។ ចំនួនភ្ញៀវទេសចរ មានការថយចុះយ៉ាងលឿន នៅរវាងត្រីមាសទី៤ ឆ្នាំ២០០៨ និងត្រីមាសទី១ ឆ្នាំ២០០៩ ។ ការថយចុះនៃវិស័យនេះ បណ្តាលមកពីកត្តាស្មុគស្មាញនានា ដែលមានទាំងបញ្ហាទាក់ទងនឹងវិបត្តិ (ការធ្លាក់ចុះនៃ

២ ព័ត៌មានអំពីការជួយគ្នាទៅវិញទៅមកនៅក្នុងប្រទេសកម្ពុជា មានបកស្រាយក្នុងឯកសាររបស់ Murshid (1998) និង McAndrew (1998)

ទេសចរណ៍ ពីប្រទេសមួយចំនួន ដូចជា កូរ៉េខាងត្បូង និងជប៉ុន ជាដើម) និងបញ្ហាមិនទាក់ទងនឹងវិបត្តិ (ឧ. ទំនាស់គោលនយោបាយផ្ទៃក្នុងប្រទេសថៃ ដែលជាច្រកសំខាន់មួយ សំរាប់ទេសចរណ៍មកកាន់កម្ពុជា) ។ នៅក្នុងអំឡុងប៉ុន្មានខែថ្មីៗនេះ វិស័យទេសចរណ៍មានការងើបឡើងវិញ ប៉ុន្តែក្នុងល្បឿនមួយយឺត ។ ការងើបឡើងវិញបន្តិចនេះ បានមកពីកំណើនទេសចរណ៍មកពីប្រទេសវៀតណាម និងទេសចរណ៍ក្នុងស្រុកតាមរដូវកាល ។ ទោះយ៉ាងណាក្តី ភ្ញៀវទេសចរបរទេស នៅតែមានភាពប្រយ័ត្នប្រយែងខ្លាំងលើចំណាយ ហើយបញ្ហានេះមានផលប៉ះពាល់ខ្លះៗ ទៅដល់ចំណូល និងការងារ សំរាប់កម្មករក្នុងវិស័យទេសចរណ៍ ។

វិស័យសំណង់ រួមចំណែក ៦,៧% ទៅក្នុង ផសស ឆ្នាំ២០០៧ បន្ទាប់ពីកំណើនលេខពីរខ្ទង់ទទួលបានក្នុងឆ្នាំ២០០៥ និង ២០០៦ ។ វិស័យនេះ បានផ្តល់ការងារចំនួន ២៩៩.០០០កន្លែង (៣,៦% នៃកំលាំងពលកម្មកម្ពុជា) ក្នុងឆ្នាំ២០០៧ ។ គំរោងសាងសង់ ទទួលបានហិរញ្ញប្បទានចំបងពីក្រុមហ៊ុន និងវិនិយោគិនបរទេស ដែលបានរងនូវផលប៉ះពាល់ពីវិបត្តិ នៅក្នុងប្រទេសរបស់ពួកគេ ។ វិបត្តិហិរញ្ញវត្ថុសាកល គួបផ្សំនឹងទំនាស់ព្រំដែនជាមួយប្រទេសថៃ បានធ្វើឱ្យកំណើនវិស័យសំណង់ធ្លាក់ចុះ តាមរយៈការថយចុះនៃវិនិយោគផ្ទាល់ពីបរទេស លើការអភិវឌ្ឍផ្នែកអចលនទ្រព្យនៅកម្ពុជា ចាប់តាំងពីឆមាសទី២ ឆ្នាំ២០០៨ មក ។ គំរោងសាងសង់អគារស្នាក់នៅ និងអគារពាណិជ្ជកម្មជាច្រើន ត្រូវបានពន្យាពេល ។ ជាលទ្ធផល នៅចុងឆ្នាំ២០០៩ មានកម្មករក្នុងវិស័យសំណង់ ៣០% បានបាត់បង់ការងារ ហើយពួកគេភាគច្រើន មិនមានជំរើសអ្វីផ្សេងក្រៅពីត្រលប់ទៅផ្ទះវិញឡើយ (Jalilian et al. 2009) ។

ប្រាក់ផ្ញើពីបរទេសមកផ្ទះ បានធ្លាក់ចុះពី ៤,២% មកត្រឹម ៣,៤% នៃ ផសស ក្នុងឆ្នាំ២០០៨ ហើយគេគិតទុកថា វានឹងបន្តធ្លាក់ចុះទៀតនៅក្នុងឆ្នាំ២០០៩ ។ តាមតួលេខប៉ាន់ស្មានបង្ហាញថា នៅឆ្នាំ២០០៥ ជនចំណាកស្រុកឆ្លងកាត់ព្រំដែនកម្ពុជា មានប្រហែល ៣៤៩.០០០នាក់ ។ គោលដៅចំបងរបស់ពួកគេ គឺប្រទេសថៃ កូរ៉េខាងត្បូង ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ។ ភាគច្រើននៃកម្មករចំណាកស្រុកទាំងនោះ ចូលបំរើការងារដែលមិនទាមទារជំនាញ និងមិនស្របច្បាប់ (CDRI 2009b) ហើយពួកគេទំនងជារងការប៉ះទង្គិចខ្លាំង និងប្រហែលជាអាចត្រលប់មកផ្ទះវិញ ដោយសារវិបត្តិនៅក្នុងប្រទេស ដែលពួកគេកំពុងធ្វើការនោះ ។ ផលប៉ះពាល់នៃការបាត់បង់ការងារ និងវិលត្រលប់មកផ្ទះវិញនេះ ទៅលើសុខុមាលភាពរបស់គ្រួសារ មានសភាពមិនសូវធ្ងន់ធ្ងរទេ ដោយសារវិស័យកសិកម្មមិនបានរងឥទ្ធិពលពីវិបត្តិឡើយ ។ គេជឿថា វិស័យកសិកម្មជាទ្រនាប់ដែលជួយការពារកម្មករបាត់បង់ការងារ និងក្រុមគ្រួសារនៅទីជនបទជាច្រើន កុំឱ្យផុងជ្រៅទៅក្នុងភាពក្រីក្រ ។ ទោះបីជាមានការជជែកដេញដោល ស្តីពីទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ចរឹងមាំ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាក្តី (World Bank 2006, 2007) ក៏វិបត្តិទំនងជាបានរុញច្រានប្រជាជនជាច្រើន ឱ្យធ្លាក់ចូលកាន់តែជ្រៅទៅក្នុងភាពក្រីក្រ ។ កម្ពុជា ស្ថិតនៅក្នុងលំដាប់នៃប្រទេសក្រីក្រ និងងាយរងគ្រោះខ្លាំង បន្ទាប់ពីប្រទេស ហ្កាណា ហ្សមប៊ី បង់ក្លាដេស និង បឺនីន (វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស ២០០៩) ។ ភាពក្រីក្រ នៅតែមានកំរិតខ្ពស់ដដែលនៅក្នុងតំបន់ បើទោះជាបានធ្លាក់ចុះពី ៤៥% ក្នុងឆ្នាំ១៩៩៤ មកត្រឹម ៣០% ក្នុងឆ្នាំ២០០៧ ក៏ដោយ (World Bank 2007) ។ Grebmer et al. (2009: 13) បានលើកឡើងថា បើពិនិត្យមើលលើសន្ទស្សន៍ភាពអត់ឃ្លានសាកលលោក កម្ពុជា ជាប្រទេសមួយនៅតំបន់អាស៊ីអាគ្នេយ៍ ដែលរងភាពអត់ឃ្លានធ្ងន់ធ្ងរ និងមានស្ថានភាពលំបាក ជាងប្រទេសជិតខាង ដូចជា ប្រទេសថៃ វៀតណាម និង ឡាវ ជាដើម ។

### ៤.១.៣. ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច នៅលើកម្មករងាយរងគ្រោះ និងក្រុមគ្រួសារក្រីក្រនៅជនបទ

ការវាយតម្លៃលឿន របស់ CDRI និងធនាគារពិភពលោក បានលើកឡើងថា ប្រជាជនដែលមានចំណូលទាប ប៉ុន្តែមានភាពរឹងមាំ និងមិនសូវរងផលប៉ះពាល់នៅអំឡុងពេលវិបត្តិទើបនឹងចាប់ផ្តើមនោះ ក៏បានជួបប្រទះនូវភាពលំបាកផងដែរ ចាប់ពីដើមឆ្នាំ២០០៩ មក ។ អង្កេតកាលពីខែសីហា ឆ្នាំ២០០៩ បានរកឃើញនូវសញ្ញាបង្ហាញពីស្ថិរភាពនៃ ៩ក្រុមកម្មករ (ក្រៅពីវិស័យកាត់ដេរ) ការងើបឡើងវិញនៃចំណូលប្រចាំថ្ងៃរបស់កម្មករក្នុងវិស័យទេសចរណ៍ និងស្ថានភាពកាន់តែអាក្រក់ឡើង ចំពោះកម្មករកាត់ដេរ ។ អង្កេតនៅខែវិច្ឆិកា ២០០៩ បានផ្តល់នូវការយល់ដឹងបន្ថែមទៀត ទៅលើឥទ្ធិពលនៃវិបត្តិ ។ យើងរកឃើញថា កម្មករសំណង់មានជំនាញ និងគ្មានជំនាញ គឺជាក្រុមដែលរងផលប៉ះពាល់តិចតួចបំផុត អ្នកធាក់ស៊ីក្លូ អ្នករត់ម៉ូតូឌុប និងអ្នកស៊ីឈ្នួលធ្វើស្រែ ជាក្រុមដែលរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុត ហើយកម្មកររោងចក្រកាត់ដេរ កម្មករក្នុងវិស័យទេសចរណ៍ និងអ្នកបម្រើតាមភោជនីយដ្ឋាន ជាក្រុមដែលងើបឡើងវិញមុនគេ ពីផលប៉ះពាល់នៃវិបត្តិ ស្របពេលដែលមិនមានការសន្និដ្ឋានជាក់លាក់ណាលើកឡើងពីក្រុមអ្នកលីសែង អ្នករើសអេតចាយ ពលករចំណាកស្រុក និងអ្នកលក់បន្លែតូចតាចឡើយ ។

សំរាប់ពួកអ្នកឆ្លើយសម្ភាសន៍ ការប៉ះទង្គិចភាគច្រើន មិនមែនជារឿងថ្មី ឬបណ្តាលមកពីនិន្នាការសេដ្ឋកិច្ចមិនល្អនាពេលថ្មីៗនេះទេ ។ ហានិភ័យភាគច្រើន ជាករណីដោយឡែកដូចជាៈ ជំងឺ/មរណភាពរបស់សមាជិកគ្រួសារ, ការខូចខាតផលដំណាំ ឬការស្លាប់សត្វចិញ្ចឹម, ការលែងលះ ឬចែកផ្លូវគ្នា ។ ទោះជាយ៉ាងនេះក្តី វិបត្តិសេដ្ឋកិច្ច បានធ្វើឱ្យការប៉ទង្គិចកាន់តែធ្ងន់ធ្ងរឡើង ដោយសារឱកាសរកចំណូលបានថយចុះ ហើយភាពងាយរងគ្រោះបានកើនឡើង ។

ការពុំមានប្រព័ន្ធសុវត្ថិភាពសង្គមផ្លូវការ ធ្វើឱ្យប្រជាជនក្រីក្រភាគច្រើន ជាពិសេស គ្រួសារមានស្ត្រីគ្មានប្តីជាមេគ្រួ មនុស្សចាស់ជរា ជនពិការ ស្ត្រី និងកុមារ បានធ្លាក់កាន់តែជ្រៅក្នុងភាពក្រីក្រ ដោយសារផលប៉ះពាល់ថ្មីៗនៃហានិភ័យពាក់ព័ន្ធគ្នា ដូចជា ការធ្លាក់ចុះឱកាសការងារ និងប្រាក់ចំណូល ដោយសារការឡើងថ្លៃម្ហូបអាហារយ៉ាងខ្ពស់ ក្នុងអំឡុងខែមករា និង តុលា ឆ្នាំ២០០៨ និងវិបត្តិសេដ្ឋកិច្ចសកលដែលផ្ទុះឡើងជាបន្តមកទៀត ។ អ្នកដែលមិនមានគ្រួសារជិតស្និទ្ធគ្នា កាន់តែងាយរងគ្រោះឡើង ពីព្រោះពួកគេពុំមានមធ្យោបាយរកបានជំនួយគាំទ្រនៅក្នុងសហគមន៍ ។ អ្នកមានបញ្ហាចោទច្រើនជាងគេ ដូចជា មេគ្រួសារជាស្ត្រី ដែលមានកូន ឬសមាជិកគ្រួសារមិនទាន់ធំពេញវ័យ គឺកាន់តែងាយធ្លាក់ចូលកាន់តែជ្រៅទៅក្នុងភាពក្រីក្រ ។

ការប៉ះទង្គិចទៅលើកុមារ វាហុចផលភ្លាមៗ និងធ្ងន់ធ្ងរ ។ ដើម្បីមានប្រាក់គ្រប់គ្រាន់ សំរាប់ចាយវាយប្រចាំថ្ងៃ និងសងបំណុល គ្រួសារក្រីក្រជាច្រើន បានដកកូនចៅពីសាលារៀន ដើម្បីឱ្យទៅធ្វើការទាំងនៅវ័យក្មេងៗ ។ ការវាយតំលៃនេះបានបង្ហាញថា កុមារក្រីក្រជាច្រើន (ភាគច្រើនកុមារី) ត្រូវបានបង្ខំឱ្យឈប់រៀនដើម្បីជួយឪពុកម្តាយរកលុយ ។ វិធានការដ៏តឹងតែងបែបនេះ ប្រហែលអាចជួយគ្រួសារក្រីក្រឱ្យរស់រានបាន ប៉ុន្តែហុចផលមិនល្អទេក្នុងរយៈពេលវែង ចំពោះធនធានមនុស្សក្នុងគ្រួសារ និងសមត្ថភាពរកចំណូលឱ្យបានច្រើនថែមទៀត ។ ម្យ៉ាងទៀត គ្រួសារនៅតែមានស្ថានភាពផុយស្រួយ ដើម្បីទប់ទល់នឹងការប៉ះទង្គិចនៅថ្ងៃអនាគតទៀត ។ បញ្ហានេះ មិនមែនថ្មីៗទេ ប៉ុន្តែនៅតែជាចំណុចព្រួយបារម្ភធ្ងន់ធ្ងរ ដែលត្រូវមានការធ្វើអន្តរាគមន៍យ៉ាងសមស្រប ។

ប្រជាជនក្រីក្រភាគច្រើន ដែលរងការប៉ះទង្គិចខាងសេដ្ឋកិច្ច ឬសង្គមកិច្ចបែបណាមួយ បានធ្លាក់ខ្លួនជំពាក់បំណុលគេកាន់តែធ្ងន់ធ្ងរឡើង ។ ស្ថានភាពនេះ អាចមើលឃើញតាមការលក់ដោះទ័ល នូវទ្រព្យផលិតកម្ម និងកំណើនភាពគ្មានដីធ្លី និងគ្មានលំនៅដ្ឋាន សំរាប់អ្នកដែលមិនអាចសងបំណុលគេបាន ។ និន្នាការនេះ ទំនងកើតមានបន្តទៀត ប្រសិនបើ ឱកាសមានការងារធ្វើនៅតែមិនទៀងទាត់ទៀត ក្នុងរយៈពេល ៦ខែ ឬ ១២ខែ ខាងមុខនេះ ។

### ៤.១.៤. ការគ្រប់គ្រងមិនផ្លូវការលើហានិភ័យដែលមានស្រាប់ និងការអនុវត្តប្រព័ន្ធសុវត្ថិភាពសង្គម

ការវាយតំលៃនេះ បានគាំទ្រដល់ការសន្មតថា ការជួយគ្នាទៅវិញទៅមកជាប្រពៃណី ក្នុងទំរង់ជាការផ្តល់ម្ហូបអាហារ និងកំចីគ្មានការប្រាក់ ក្នុងចំណោមសាច់ញាតិ ក្រុមគ្រួសារធំ និងខ្សែរយៈក្រៅផ្លូវការក្នុងក្រុមមានអាជីពដូចគ្នា នៅតែមានជារូបរាងក្នុងពេលចាំបាច់ ។ ប៉ុន្តែ ដោយសារសេដ្ឋកិច្ចប្រើប្រាក់កាស របៀបរបបបែបប្រពៃណីទាំងនេះ បានផ្លាស់ប្តូរទ្រង់ទ្រាយ ក្លាយទៅជារបៀបរបបផ្តល់ឥណទាន ឬរបៀបរបបធ្វើអាជីវកម្មមានកិច្ចសន្យាវិញ ។ ក្នុងករណីរបៀបរបបជាប្រពៃណីនៅកើតមាន វាតែងកើតមានរវាងសមាជិកគ្រួសារ និងសាច់ញាតិជិតស្និទ្ធគ្នាប៉ុណ្ណោះ ព្រោះនៅពេលលំបាកតឹងតែងបែបនេះ អ្នកណាក៏មានមិនគ្រប់ សំរាប់ចែករំលែកជាមួយគ្រួសារអ្នកដទៃទៀតដែរ ។ ប្រជាជនកាន់តែប្រកាន់លក្ខណៈបុគ្គលនិយមយករួចខ្លួន ឬក៏កាន់តែប្រុងប្រយ័ត្នក្នុងការជួយជ្រោមជ្រែងអ្នកដទៃ ក្នុងអំឡុងពេល ១២ខែកន្លងទៅ ដោយសារភាពមិនទៀងទាត់នៅក្នុងការងារនិងប្រាក់ចំណូល ។ សាច់ញាតិជាអ្នកធូរធារ ក៏អាចសន្សំប្រាក់មិនបានច្រើនដូចមុនទេ ដោយសារវិបត្តិនាពេលថ្មីៗ ។ ក្នុងនេះ អ្នកងាយរងគ្រោះជាងគេគឺមនុស្សចាស់ជរា និងជនក្រីក្រ ដែលគ្មានសាច់ញាតិ និងគ្មានទំនាក់ទំនង ឬខ្សែរយៈក្នុងសង្គមសព្វថ្ងៃ ។ ពួកគេអាចត្រូវផាត់ចេញពីប្រព័ន្ធជួយឧបត្ថម្ភក្រៅផ្លូវការផ្សេងៗ ហើយទុកឱ្យនៅតែឯង និងកាន់តែងាយរងគ្រោះថែមទៀត ។

រូបភាពក្រៅផ្លូវការខ្លះ នៃការចែករំលែក និងគ្រប់គ្រងហានិភ័យ ឬការជួយគ្នាទៅវិញទៅមក នៅតែរឹងប៉ឹងនៅឡើយនៅក្នុងសហគមន៍ ទោះក្នុងក្រុមសង្គមប្រជាជនបែបណាក៏ដោយ ដូចជា ក្នុងការជួយរៀបចំពិធីបុណ្យសព ឬមង្គលការ ឬការជួយជ្រោមជ្រែងដល់អ្នកជួបគ្រោះថ្នាក់ ដូចជា អគ្គីភ័យ ខ្យល់ព្យុះ និងរន្ទះបាញ់ ជាដើម ។ ប៉ុន្តែប្រពៃណីនេះ កាន់តែមានតិចហើយ ។

នៅកម្ពុជា សព្វថ្ងៃនៅមានការដោះដូរកំលាំងពលកម្ម និងសត្វចិញ្ចឹម នៅក្នុងក្រុមគ្រួសារធំ និងខ្សែរយៈសង្គមក្រៅផ្លូវការ ដោយឈរលើទំនុកចិត្ត និងកិច្ចសហប្រតិបត្តិការមានផលប្រយោជន៍ទៅវិញទៅមក ។ ប៉ុន្តែបច្ចុប្បន្ននេះ ការដោះដូរពលកម្ម ដូចជា ក្នុងការដាំដុះជាដើម កំពុងតែជំនួសដោយប្រព័ន្ធជួលកំលាំងពលកម្មវិញ ។ រឿងនេះ បានបង្កើតការងារដល់ជនក្រីក្រដែលគ្មានដីធ្លី ប៉ុន្តែ ក៏បានបង្កបញ្ហាជាច្រើន សំរាប់គ្រួសារមានមេគ្រួជាស្ត្រីគ្មានប្តី ដែលខ្វះខាតសត្វអូសទាញ និងពលកម្មបុរស និងដែលឥឡូវនេះ គ្មានទទួលបានជំនួយអ្វីសោះក្នុងការងារភ្ជួររាស់ដី ហើយទីបំផុត ក៏ត្រូវលក់ដីនោះទៅ ។

ក្រុមជួយខ្លួនឯង ដូចជា ក្រុមសន្សំប្រាក់ ធនាគារស្រូវ និងធនាគារគោ ជាដើម សព្វថ្ងៃមានដំណើរការជាក់ស្តែង និងជំរុញឡើងដោយកម្មវិធីអភិវឌ្ឍន៍ជួយអ្នកក្រ ដំណើរការដោយ NGOs ដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការ និងទំនុកចិត្តក្នុងសហគមន៍ ។ ប៉ុន្តែសមាជិកក្រុមទាំងនេះ មិនមែនសុទ្ធតែជាជនក្រីក្រ ឬក្រីក្រខ្លាំងនោះទេ ពីព្រោះអ្នកក្រីក្រ ឬក្រីក្រខ្លាំង អាចពុំមានលទ្ធភាពបង់ប្រាក់កំរៃសមាជិកភាពបាន ។ មេគ្រួសារជាស្ត្រី

គ្មានប្តី ជនពិការ និងជនចាស់ជរា (លើកលែងតែនៅក្នុងភូមិក្រសាំង ដែលមានអង្គការ HelpAge International បានផ្តោតការងារលើ ក្រុមជនពិការ និងចាស់ជរានេះតែម្តង) និងអ្នកក្រក្រខ្លាំង ដែលបានឆ្លើយសម្ភាសន៍ ពួកគេមិនទាន់បានទទួលផលប្រយោជន៍អ្វីពីការផ្តួចផ្តើមគំនិតទាំងនេះទេ ។ សកម្មភាពជួយខ្លួនឯង ក៏ងាយដួលរលំដែរក្នុងពេលបច្ចុប្បន្ន ពីព្រោះមានសមាជិកជាច្រើនមិនអាចសងបំណុលបាន ។ ធនាគារគោកំពុងដំណើរការទៅមុខ ប៉ុន្តែ យឺតយ៉ាវក្នុងការឈោងឱ្យដល់អ្នកក្រ ។

ជនចាស់ជរា និងជនក្រីក្រខ្លាំង ជួនកាលអាចទទួលបានសេវាឧបត្ថម្ភនៅតាមវត្តអារាមពុទ្ធសាសនា និងព្រះវិហារគ្រឹះសាសនាដែរ ប៉ុន្តែ សេវានេះ ជួយបានតិចនាក់ណាស់ (ឧ. អ្នករស់នៅជិតវត្ត ឬគ្រឹះបរិស័ទ្ធ) ។

ក្នុងពេលថ្មីៗនេះ ជំនួយឧបត្ថម្ភផ្នែកមនុស្សធម៌ រួមមាន ជំនួយសង្គ្រោះបន្ទាន់ពីកាកបាទក្រហមកម្ពុជា (CRC) និងគណបក្សនយោបាយផ្សេងៗ ដល់គ្រួសារអ្នករងគ្រោះមហន្តរាយដោយសារធម្មជាតិ និងអំណោយជាប្រាក់ ឬជាសំភារៈ ពីគណបក្សនយោបាយ ។ ជំនួយនេះ វាយោងតាមកង្វះខាត ហើយពលករក្រីក្រ និងងាយរងគ្រោះ ដែលស្ថិតក្នុងការវាយតំលៃនេះ គឺធ្លាប់ទទួលបានជាក់ស្តែង ។ ប៉ុន្តែជំនួយបែបនេះ អាចមានផ្តល់សំរាប់ជាការជួយសង្គ្រោះបន្ទាន់ប៉ុណ្ណោះ ដូច្នេះ វាជាប្រភពសន្តិសុខមួយមិនអាចទុកចិត្តបានទេ ហើយអាចជាជំនួយមានចំណងខាងនយោបាយ និង/ឬ មិនគ្រប់គ្រាន់ សំរាប់ស្តារស្ថានភាពឱ្យបានទាំងស្រុងឡើយ ។ ម្យ៉ាងទៀត ជំនួយបែបនេះ កាន់តែកំរឡើងហើយក្នុង ៦ខែកន្លងទៅនេះ ។

សរុបមក ក្រុមក្រីក្រទាំងអស់ កាន់តែងាយចុះក្រខ្លាំងថែមទៀត ដោយសារវិបត្តិសេដ្ឋកិច្ចបច្ចុប្បន្ន ហើយអ្នកដែលងាយរងគ្រោះជាងគេ គឺជនគ្មានក្រុមគ្រួសារ/សាច់ញាតិជិតស្និទ្ធ មេគ្រួសារជាស្ត្រីគ្មានប្តី ជនចាស់ជរា ជនពិការ អ្នករស់នៅឆ្ងាយពីវត្តអារាម និងកុមារ ។ បើសិនគ្មានអន្តរាគមន៍សមរម្យ ជួយឧបត្ថម្ភគាំទ្រដល់ជនក្រីក្រទេ ពួកគេមានសមត្ថភាពតិចតួចណាស់ ដើម្បីទប់ទល់នឹងការប៉ះទង្គិចផ្សេងៗលើប្រាក់ចំណូល និងដកខ្លួនឱ្យផុតពីភាពក្រីក្រ ។

## ៤.២. វិធីសាស្ត្រស្រាវជ្រាវនៃការវាយតម្លៃនេះ

ការវាយតម្លៃលឿន របស់ CDRI និងធនាគារពិភពលោក ស្តីពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចទៅលើក្រុមគ្រួសារកម្ពុជានេះ ត្រូវបានបង្កើតឡើង ដើម្បីធ្វើការអង្កេតប្រចាំត្រីមាស និងវិភាគពីផលប៉ះពាល់នៃវិបត្តិលើពលករងាយរងគ្រោះ និងក្រុមគ្រួសារនៅជនបទ ។ ការសិក្សា បានចាប់ផ្តើមនៅក្នុងខែឧសភា ២០០៩ និងត្រូវបានបញ្ចប់នៅក្នុងខែកុម្ភៈ ២០១០ ហើយលទ្ធផលទាំងឡាយដែលរកឃើញ នឹងត្រូវផ្តុំបញ្ចូលគ្នាទៅក្នុងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ របស់ CDRI ដែលនឹងបោះផ្សាយចេញក្នុងខែមីនា ២០១០ ។ អត្ថបទនេះពិនិត្យឡើងវិញជាពិសេស ពីរបៀបរបបក្រៅផ្លូវការដែលមានស្រាប់ និងដែលពលករ និងគ្រួសារក្រីក្រ និងងាយរងគ្រោះនៅកម្ពុជាអាចប្រើបាន សំរាប់គ្រប់គ្រងហានិភ័យ និងជួយគ្នាទៅវិញទៅមក ។ ការវាយតំលៃនេះ បានស្រាវជ្រាវលើសំនួរមួយចំនួនដូចខាងក្រោមៈ

- តើបច្ចុប្បន្នមានប្រព័ន្ធសុវត្ថិភាពក្រៅផ្លូវការអ្វីខ្លះ? តើប្រជាជនទៅពឹងពាក់នរណានៅពេលជួបកង្វះខាតប្រាក់ចំណូល ឬចំណាយប្រើប្រាស់? តើគ្រួសារខុសៗគ្នាមានប្រភពជំនួយគាំទ្រខុសៗគ្នា ឬយ៉ាងណា?
- តើរបៀបរបបអនុវត្តទាំងនេះមានផ្លាស់ប្តូរឬទេ ក្នុងអំឡុង ១៨ខែកន្លងទៅ? ប្រសិនបើមានផ្លាស់ប្តូរ តើផ្លាស់ប្តូរបែបណា?

- តើសព្វថ្ងៃនេះ សាមគ្គីភាពសង្គមរឹងប៉ឹងប៉ុណ្ណា? តើប្រជាជនអាចរកបានជំនួយគាំទ្របែបណាខ្លះ?
- តើកិច្ចប្រឹងប្រែងសម្បុរសធម៌ជាលក្ខណៈឯកជន មានច្រើនទូទៅប៉ុណ្ណា?
- តើកិច្ចខិតខំប្រឹងប្រែងសប្បុរសធម៌ជំរុញដោយ NGOs បានជួយពង្រឹង ឬប៉ះពាល់ដល់ប្រព័ន្ធសុវត្ថិភាពក្រៅផ្លូវការជាប្រពៃណី ឬទេ?
- តើមានអន្តរកម្មអ្វីខ្លះ រវាងប្រព័ន្ធសុវត្ថិភាពក្រៅផ្លូវការ និងអាជ្ញាធរភូមិ ឃុំ/សង្កាត់?
- តើប្រជាជនប្រើប្រាស់វិធីដោះស្រាយអ្វីខ្លះ នៅពេលជួបនឹងវិបត្តិសេដ្ឋកិច្ច?

ក្រុមស្រាវជ្រាវ បានប្រើប្រាស់វិធីសាស្ត្របែបគុណភាព (សម្ភាសន៍ពាក់កណ្ដាលរៀបរយ និងការពិភាក្សាតាមក្រុមស្នូល) ដើម្បីស្រាវជ្រាវលើសំណួរទាំងនេះ ។ តារាង ៤.១ បង្ហាញពីអ្នកឆ្លើយតប និងទីកន្លែងដែលបានជ្រើសរើសសំរាប់សម្ភាសន៍ ។ សម្ភាសន៍ពាក់កណ្ដាលរៀបរយ ត្រូវបានធ្វើឡើងជាមួយជនក្រីក្រនៅជនបទ និងពលករងាយរងគ្រោះ ចំនួន ៤៧នាក់ និងមេភូមិ ៩នាក់ ដើម្បីស្រាវជ្រាវស៊ីជំរៅពីបទពិសោធន៍ ដែលពួកគេបានឆ្លងកាត់ ក្នុងអំឡុង ១២ខែ និង ៦ខែ មុនពេលមានការប្រមូលទិន្នន័យនៅខែឧសភា ២០០៩ ។ អ្នកឆ្លើយសម្ភាសន៍ ត្រូវបានជ្រើសរើសដោយមានគោលដៅចេញពីគ្រួសារ ដែល CDRI បានសម្ភាសន៍ក្នុងពេលធ្វើការសិក្សាពីឌីណាមិកភាពក្រីក្រ (អង្កេតធ្វើបន្តពីអង្កេតគ្រួសារ ដែលបានធ្វើឡើងក្នុងភូមិ ចំនួន៩ កាលពីឆ្នាំ២០០៤-២០០៥) និងចេញពីកន្លែងនានា ដែលបានធ្វើអង្កេតពលករងាយរងគ្រោះ កាលពីដើមឆ្នាំ២០០៩ ។

សំរាប់ការសិក្សានៅលើកទី២ និងលើកទី៣ ក្នុងខែសីហា និង វិច្ឆិកា ឆ្នាំ២០០៩ យើងប្រើតែវិធីសាស្ត្រការពិភាក្សាតាមក្រុមស្នូលប៉ុណ្ណោះ ជាមួយនឹងក្រុមពលករ និងក្រុមគ្រួសារនៅទីជនបទ ដែលជាគំរូតាងក្នុងការសិក្សាលើកទី១ ។ លទ្ធផលរកឃើញបន្ថែម បង្ហាញត្រឹមបទពិសោធន៍នៃក្រុមគំរូតាងទាំងនេះប៉ុណ្ណោះ ។ ដូច្នេះ ត្រូវមានការប្រុងប្រយ័ត្ន ចំពោះការយកលទ្ធផលនេះ ទៅប្រើជាមូលដ្ឋានតំណាងឱ្យក្រុមពលករ និងក្រុមគ្រួសារជនបទ ជារួម ។ ក្រៅពីនេះ យើងក៏បានធ្វើការពិនិត្យ និងវិភាគផងដែរ លើភស្តុតាងជាក់ស្តែងទាក់ទងនឹងផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច ទៅលើចំណូល និងចំណាយប្រើប្រាស់ របស់ពលកររងាយរងគ្រោះ ដែលទទួលបានពីការអង្កេតបែបបរិមាណ របស់ CDRI លើក្រុមពលករងាយរងគ្រោះ ។ ចាប់ពីឆ្នាំ១៩៩៨ CDRI បានធ្វើអង្កេតប្រចាំត្រីមាសមួយ លើក្រុមពលករងាយរងគ្រោះ ៤ក្រុម អ្នកធាក់ស៊ីក្លូ អ្នកលីសែង អ្នកលក់បន្លែតូចតាច និងអ្នករើសអេតចាយ នៅក្នុងទីក្រុងភ្នំពេញ ។ ក្នុងឆ្នាំ២០០០ អង្កេតនេះ ត្រូវបានពង្រីកឱ្យធំជាងមុន ដោយបន្ថែមចូល ៦ក្រុមផ្សេងទៀត គឺ អ្នករត់ម៉ូតូឌុប កម្មករសំណង់គ្មានជំនាញ កម្មករសំណង់មានជំនាញ អ្នកបម្រើតាមភោជនីយដ្ឋាន កម្មកររោងចក្រកាត់ដេរ និងអ្នកស៊ីឈ្នួលធ្វើស្រែ (ក្នុងខេត្តកណ្តាល និងកំពង់ស្ពឺ) ។ គំរូតាងសរុបមានចំនួន ៤៨០នាក់ ក្នុងនោះ កម្មកររោងចក្រកាត់ដេរ មាន ១២០នាក់ និងពលករ ៩ក្រុមផ្សេងទៀត មាន ៤០នាក់ ក្នុងមួយក្រុម១ ។ ចំពោះអង្កេតកាលពីខែឧសភា ឆ្នាំ២០០៩ ដែលទទួលបានហិរញ្ញប្បទានពីធនាគារពិភពលោកនោះ CDRI បានបញ្ចូលបន្ថែមពលករ ២ក្រុមទៀត គឺ ពលករចំណាកស្រុក (២០នាក់ ក្នុងខេត្តបាត់ដំបង) និងអ្នកធ្វើការក្នុងវិស័យទេសចរណ៍ (២០នាក់ ក្នុងខេត្តសៀមរាប) ដែលធ្វើឱ្យចំនួនគំរូតាងសរុបកើនដល់ ៥២០នាក់ ។ អង្កេតក្នុងខែ សីហា និង វិច្ឆិកា ២០០៩ មានបន្ថែមគំរូតាង ២០នាក់ទៀត ទៅក្នុងក្រុមនីមួយ១ នៃពលករចំណាកស្រុក និងអ្នកធ្វើការក្នុងវិស័យទេសចរណ៍ ។ ដូច្នេះ ទំហំគំរូតាងសរុប បានកើនដល់

៥៦០នាក់ ។ គំរូតាង ត្រូវបានជ្រើសរើសដោយមានគោលដៅច្បាស់លាស់ គឺភាគច្រើនរើសចេញពីតំបន់ទីក្រុង ហើយគំរូតាងទាំងនោះ ជាអ្នកដែលកំពុងធ្វើការឱ្យគេ ឬអ្នកប្រកបរបរដោយខ្លួនឯង ។ ដូចនេះ លទ្ធផលទទួលបាន មិនតំណាងឱ្យក្រុមសេដ្ឋកិច្ចនីមួយៗឡើយ ហើយក៏មិនអាចយកទៅប្រើដើម្បីកំណត់ថា តើវិស័យខាងសេដ្ឋកិច្ច ណាមួយ បានស្រូបយកពលករដែលត្រូវបញ្ឈប់ពីការងារ ក្នុងវិស័យដទៃទៀតឡើយ ។

**តារាង ៤.១: គំរូតាង និងទីកន្លែងធ្វើសម្ភាសន៍ជាមួយក្រុមគ្រួសារ និងកម្មករងាយរងគ្រោះ**

| កម្មករងាយរងគ្រោះ | ចំនួន | ទីតាំង |
|---|---|---|
| **អ្នកជាក់ស៊ីកួ** | 2 | ផ្សារកណ្តាល ក្នុងរាជធានីភ្នំពេញ |
| អ្នករត់ម៉ូតូឌុប | 2 | ផ្សារក្បាលថ្នល់ ក្នុងរាជធានីភ្នំពេញ |
| អ្នកលក់បន្លែតូចតាច | 2 | ផ្សារដើមគរ ក្នុងរាជធានីភ្នំពេញ |
| អ្នកលីសែង | 2 | ផ្សារនាគមាស ក្នុងរាជធានីភ្នំពេញ |
| អ្នករើសអេតចាយ | 2 | វាលចាក់សំរាមស្ទឹងមានជ័យ ក្នុងរាជធានីភ្នំពេញ |
| **កម្មករសំណង់គ្មានជំនាញ** | 2 | បឋមសិក្សាទួលគោក ក្នុងរាជធានីភ្នំពេញ |
| **កម្មករសំណង់មានជំនាញ** | 2 | ការដ្ឋានសំណង់ក្នុងសង្កាត់ទឹកល្អក់ ១ រាជធានីភ្នំពេញ |
| អ្នកបំរើតាមភោជនីយដ្ឋាន | 2 | ភោជនីយដ្ឋាន មួយកន្លែង ក្នុងរាជធានីភ្នំពេញ |
| កម្មកររោងចក្រកាត់ដេរ | 5 | រោងចក្រវាយនភណ្ឌសាកល* (មួយរូប) រោងចក្រវាយនភណ្ឌមិថុនា (២រូប) និងរោងចក្រវាយនភណ្ឌ ឡុង វ៉ា (២រូប) ក្នុងរាជធានីភ្នំពេញ |
| បុគ្គលិកសណ្ឋាគារ និងភោជនីយដ្ឋាន | 2 | ក្រុងសៀមរាប |
| អ្នករត់ម៉ូតូទុកទុក/អ្នកលក់ដូរតូចតាច | 2 | ក្រុងសៀមរាប |
| **អ្នកស៊ីឈ្នួលធ្វើស្រែ** | 2 | ភូមិដូនវង្ស ខេត្តកណ្តាល |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 2 | ភូមិ ប៉ែលហែល ខេត្តកំពង់ស្ពឺ |
| **ប្រជាជនពីភូមិចំនួន ៩ ក្នុងការសិក្សាពីឌីណាមិកនៃភាពក្រីក្រ** | 18 | អ្នកឆ្លើយតប ២នាក់ ពីភូមិនីមួយៗ: អណ្តូងត្រាច និងក្រសាំង (បាត់ដំបង) ខ្សាច់ជីរស់ និងដងក្តារ (កំពង់ធំ) កញ្ជរ (ក្រចេះ) ព្រៃកក្មេង (កណ្តាល) បាបោង (ព្រៃវែង) ត្រពាំងប្រិយ (កំពង់ស្ពឺ) និងកំពង់ត្នោត (កំពត) |
| ប្រធានភូមិ | 9 | ប្រធានភូមិមួយរូប ចេញពីភូមិនីមួយៗខាងលើ |
| ចំនួនសម្ភាសន៍សរុប | **56** | ២១នាក់ នៅរាជធានីភ្នំពេញ ៤នាក់ នៅខេត្តសៀមរាប ២នាក់ នៅខេត្តកណ្តាល ២នាក់ នៅខេត្តកំពង់ស្ពឺ និង ២៧នាក់ នៅក្នុងភូមិនៃការសិក្សាពីឌីណាមិកនៃភាពក្រីក្រ |

**សំគាល់: ការពិភាក្សាតាមក្រុមស្នូលចំនួន ៣ ខាងលើ ដែលជាផ្នែកនៃការសិក្សាពីឌីណាមិកនៃភាពក្រីក្រនោះ បានធ្វើឡើង នៅក្នុងភូមិ ត្រពាំងប្រិយ បាបោង និងកំពង់ត្នោត ។ វាយនភណ្ឌសាកល ត្រូវបានគេស្គាល់ផងដែរថា ជាវាយនភណ្ឌ ហ៊ុយ ចៀន (Huy Chean Textiles) និងវាយនភណ្ឌ ៦ ជាន់ (ឈ្មោះហៅក្នុងពេលសន្ទនាទូទៅ) ។*

**References**


American Friends Service Committee (2000), Socio-Cultural Vulnerability and Coping Strategies Research Project (Phnom Penh: AFSC).

Ballard, B., C. Sloth, D. Wharton, I. Fitzgerald, K. Murshid, K. Hansen, Phim R. & Lim S. (2007), We Are Living with Worry All the Time: A Participatory Poverty Assessment of Tonle Sap (Phnom Penh: CDRI).

Cambodia Development Resource Institute (2008), Impact of High Food Prices in Cambodia (Phnom Penh: CDRI).

Cambodia Development Resource Institute (2009a), Annual Development Review 2008–2009 (Phnom Penh: CDRI).

Cambodia Development Resource Institute, (2009b), Economic Costs and Benefits of Cross-Border Labour Migration in the GMS: Cambodia Country Study (Phnom Penh: CDRI).

Chan S. & Ear S. (2004), "Towards Understanding Social Protection in Cambodia", Cambodia Development Review, Vol. 8, No 4 (Phnom Penh: CDRI).

Devereux, S. (2001) "Livelihood Insecurity and Social Protection: A Re-emerging Issue in Rural Development", Development Policy Review, 19(4), pp. 507–519.

Fitzgerald, I. & So S. (2007) Moving Out of Poverty? Trends in Community Well-being and Household Mobility in Nine Cambodian Villages (Phnom Penh: CDRI).

Godfrey, M., Chan S., Kato T., Vou P., Dorina P., Saravy T. & So S. (2000), "Technical Assistance and Capacity Development in an Aid-dependent Economy: Experience of Cambodia", World Development, 30(3) pp. 355–373.

Grebmer, K.V., B. Nestorova, A. Quisumbing, R. Fertziger, H. Fritschel, R. Pandya-Lorch & Y. Yohannes (2009:pp:7-11), Global Hunger Index: The Challenge of Hunger: Focus on Financial Crisis and Gender Inequality (Washington DC: International Food Policy Research Institute, Concern Worldwide and Welthungerhilfe).

Jalilian H., Chan S., G. Reyes, Saing C.H., Phann D. & Pon D., (2009), Global Financial Crisis Discussion Series—Paper 4: Cambodia (London: Overseas Development Institute).

Kim S. (2001), "Reciprocity: Informal Patterns of Social Interactions in a Cambodian Village", MA thesis (Northern Illinois University, Department of Anthropology).

Koy R. & Em S. (2009) "Building Community Capacity for Poverty Reduction Initiatives" (CDRI: forthcoming).

Kang C., Sok S., Kim S. & Liv D., (2009), Rapid Assessment on the Impact of the Financial Crisis in Cambodia (Phnom Penh: CIDS).

Krishnamurthy, V. (1999), The Impact of Armed Conflict on Social Capital: A Study of Two Villages in Cambodia (Phnom Penh: World Bank).

McAndrew, J. (1998) Independence in Household Livelihood Strategies in Two Cambodian Villages, Working Paper 7 (Phnom Penh: CDRI).

Murshid, K. (1998) Food Security in an Asian Transitional Economy: The Cambodian Experience (Phnom Penh: CDRI).

Overseas Development Institute (2009), The Global Financial Crisis and Developing Countries: Preliminary Synthesis of Ten Draft Country Reports (London: Overseas Development Institute).

Phlong P. (2009), "Informal Credit System in Cambodia", MA thesis (Northern Illinois University).

Tong K., Saing C.H. & Hem S. (2009), Trends in Living Standards of 90 Rural Households in Poverty Dynamics Study Villages (Phnom Penh: CDRI).

Tong K., Khieng S. & Phann D., (2009), Vulnerable Workers Survey in Phnom Penh, Kandal, Kompong Speu, Siem Reap and Battambang (Phnom Penh: CDRI).

Tong K. & Pon D., (2009), "Quarterly Vulnerable Workers Survey in Phnom Penh, Kandal, Kompong Speu, Siem Reap and Battambang" (unpublished Phnom Penh: CDRI).

Tong K., (forthcoming), How did Cambodian Rural Households Cope with Shocks from Food and Oil Price Increase? (Phnom Penh: CDRI).

World Bank (2006), Halving Poverty by 2015?Poverty Assessment 2006 (Phnom Penh: World Bank).

World Bank, (2007), Sharing Growth: Equity and Development Report 2007 (Phnom Penh: World Bank).

# ផ្នែកទី២

## លទ្ធផលស្រាវជ្រាវដទៃទៀត របស់វិទ្យាស្ថាន CDRI



# ជំពូក ៥
# របៀបចាត់ចែងការងាររបស់អ្នកគ្រប់គ្រង ក្នុងវិស័យសុខាភិបាល នៅកម្ពុជា[1]

*ដោយលោក នេត នាថ លោក សេង ប៊ុនដេត Roger Hay និង សុខ សិទ្ធា*

ថ្វីបើមានឯកសារទ្រឹស្តីជាច្រើន បានធ្វើការសន្មតថា គុណភាពនៃការគ្រប់គ្រងនាំឱ្យអង្គភាពមានលទ្ធផលល្អក្តី ប៉ុន្តែ ទ្រឹស្តីទាំងនេះមិនស៊ីគ្នាទេ ហើយក៏គ្មានទ្រឹស្តីណាមួយ ដែលច្បាស់លាស់លើសលុបគេដែរ ។ ម្យ៉ាងទៀត គេឃើញមានភស្តុតាងជាក់ស្តែងតិចតួចណាស់ ដែលគាំទ្រដល់ការអះអាងក្នុងឯកសារខាងការគ្រប់គ្រងទាំងនេះ ។ ដោយប្រើប្រាស់បណ្តុំទិន្នន័យយ៉ាងច្រើន បានពីស្ថាប័នសិក្សានៅសហរដ្ឋអាមេរិក លោក Fernandez បានរកឃើញថា មានចំណុច ចំនួន ៦ ដែលផ្សារភ្ជាប់ការអនុវត្ត និងគុណភាពនៃការគ្រប់គ្រង ទៅនឹងលទ្ធផលការងាររបស់អង្គភាព គឺមាន (១) ចំនួនពេលចំណាយធ្វើការគ្រប់គ្រងបរិស្ថានខាងក្រៅ (២) ស្វែងរកការគាំទ្រពីសហគមន៍ (៣) មិនគួរប្រគល់ការងារពិបាកឱ្យថ្នាក់ក្រោមទេ (៤) ជំរុញឱ្យមានការផ្លាស់ប្តូរ នៅពេលអង្គភាពដំណើរការអន់ខ្សោយ (៥) ឱ្យសិទ្ធិសំរេចទៅថ្នាក់ក្រោម នៅពេលការងារពិបាកខ្លាំង (៦) បទពិសោធន៍របស់អ្នកគ្រប់គ្រងសំខាន់ណាស់ នៅពេលការងារត្រូវធ្វើពិបាកខ្លាំង ។ Basley និង Machin លើកឡើងថា លទ្ធផលការងាររបស់អង្គភាពក្នុងវិស័យឯកជន គឺអាស្រ័យលើរបៀបផ្តល់រង្វាន់លើកទឹកចិត្តដល់អគ្គនាយក ហើយរឿងនេះ ក៏សំខាន់ដូចគ្នាដែរសំរាប់វិស័យសាធារណៈ បើទោះជាគេអាចសន្មតបានដែរថា បញ្ហាថ្នាក់គ្រប់គ្រងក្នុងវិស័យសាធារណៈ វាមិនដូចគ្នានឹងវិស័យឯកជនទេ ពីព្រោះគេយល់ថា វិស័យសាធារណៈទទួលរង សំពាធទីផ្សារតិចតួចជាង ។ អ្នកនិពន្ធទាំងពីរនេះបានសរសេរថា "ជាគោលការណ៍ ភ្នាក់ងារណាដែលទទួលបានការលើកទឹកចិត្ត តែងប្រកាន់ឥរិយាបថខុសប្លែកចំពោះការងារ" ។ ពួកគេទំនងឆ្លើយតបមិនសូវខ្លាំងប៉ុន្មានទេ ចំពោះការលើកទឹកចិត្តជាលុយកាក់ ប៉ុន្តែ មានទឹកចិត្តខ្លាំងជាង បើសិនបានគ្រប់គ្រងលើបេសកកម្មរបស់អង្គភាព ។

អត្ថបទនេះ រាយការណ៍ពីលទ្ធផលនៃការសិក្សាមួយ ស្តីពីថ្នាក់គ្រប់គ្រងវិស័យសុខាភិបាលនៅកម្ពុជា និងលទ្ធផលការងារនៃអង្គភាពរបស់ពួកគេ ។ ការសិក្សានេះ ធ្វើឡើងក្នុងឆ្នាំ២០០៩ នៅចំពេលដែលរដ្ឋាភិបាលកំពុងធ្វើការផ្លាស់ប្តូរជាច្រើនក្នុងរបៀបរៀបចំ និងការគ្រប់គ្រងសេវាសុខាភិបាល គឺមាន (១) កិច្ចសន្យារវាងអាជ្ញាធរខេត្ត និងអ្នកគ្រប់គ្រងសេវាតាមមន្ទីរពេទ្យ និងស្រុកប្រតិបត្តិ ដែលកំណត់ច្បាស់ជាងមុន ពីការផ្តល់សេវា (២) ការបង្កើនស្វ័យភាព សំរាប់អ្នកគ្រប់គ្រងមន្ទីរពេទ្យ និងស្រុកប្រតិបត្តិ ក្នុងការគ្រប់គ្រងបុគ្គលិក និងថវិការបស់អង្គភាពខ្លួនស្របតាមលក្ខខណ្ឌក្នុងកិច្ចសន្យា និង (៣) ការកែលំអការអនុវត្តរបស់បុគ្គលិក និងរបបគណនេយ្យភាព ។ បរិបទសំរាប់ការផ្លាស់ប្តូរដូចខាងលើ និងសំរាប់ការសិក្សានេះ គឺរបៀបរៀបចំ និងការគ្រប់គ្រងសេវាសុខាភិបាល

[1] អត្ថបទនេះ រៀបរៀងដោយលោក នេត នាថ លោក សេង ប៊ុនដេត និងលោកស្រីសុខ សិទ្ធា អ្នកស្រាវជ្រាវ រីឯលោក Roger Hay គឺជាទីប្រឹក្សាបច្ចេកទេសនៃវិទ្យាស្ថាន CDRI ។

នៅកម្ពុជាក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ ។ រចនាសម្ព័ន្ធវិស័យសុខាភិបាល មានឋានានុក្រមដូចតទៅ: ក្រសួងសុខាភិបាលមជ្ឈិម និងនាយកដ្ឋាននានារបស់ខ្លួន មន្ទីរពេទ្យជាតិសាធារណៈចំនួន ៧ (រាប់បញ្ចូលទាំងមជ្ឈមណ្ឌលប្រយុទ្ធជំងឺរបេង និងហង់សិន និងមជ្ឈមណ្ឌលសុខភាពមាតា និងកុមារ) ដែលផ្តល់សេវាជំនាញនៅទីក្រុងភ្នំពេញ (ក្រសួងសុខាភិបាល ឆ្នាំ២០០៨) មជ្ឈមណ្ឌលជាតិចំនួន ១៩ ដែលទ្រទ្រង់ដល់សេវាផ្សព្វផ្សាយអប់រំ និងបង្ការជំងឺ មន្ទីរសុខាភិបាលនៅតាម២៤ខេត្ត-ក្រុង មន្ទីរពេទ្យបង្អែកចំនួន ៦៩ ស្រុកប្រតិបត្តិ (ODs) ចំនួន ៧៧ ដែលចែកចេញជាក្រុមមន្ទីរពេទ្យតូចៗ និង ៩៦៦ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ។ ការសិក្សាផ្តោតលើនាយកនៃអង្គភាព ២ប្រភេទ គឺ មន្ទីរពេទ្យ និងស្រុកប្រតិបត្តិ ដែលផ្តល់សេវាថែទាំសុខភាពដល់អ្នកជំងឺដោយផ្ទាល់ ។ ការសិក្សាមិនបានផ្តោតលើអង្គភាព ៤ប្រភេទ ទៀត គឺមិនមែនដោយសារមិនសូវសំខាន់ ឬក៏មិនមានឥទ្ធិពលលើបរិមាណ និងគុណភាពសេវាសុខាភិបាលនោះឡើយ ប៉ុន្តែដោយសារមិនអាចរកទិន្នន័យបាន ឬក៏លទ្ធផលការងារមានលក្ខណៈទូលំទូលាយពេកពិបាកធ្វើការវាស់វែង ។ យោងតាមភស្តុតាងមានស្រាប់ សំនួរថា តើការគ្រប់គ្រងជះឥទ្ធិពលលើលទ្ធផលការងារអង្គភាពដល់កំរិតណា និងដោយរបៀបណានោះ គឺគ្មានចំលើយច្បាស់លាស់ទេ ។ ប្រសិនបើការគ្រប់គ្រងសំខាន់មែននោះ ឥទ្ធិពលទៅលើគុណភាព ប្រសិទ្ធភាព និងសមធម៌នៃការផ្លាស់ប្តូរផ្សេងៗក្នុងសេវាសុខាភិបាលនៅកម្ពុជា គឺត្រូវពឹងផ្អែកមួយភាគធំ ទៅលើគុណភាពនៃអ្នកគ្រប់គ្រងមន្ទីរពេទ្យ និងស្រុកប្រតិបត្តិ ។ ការសិក្សានេះ មានគោលដៅធ្វើការស្វែងយល់ពីទំនាក់ទំនងជាវិជ្ជមាននានា រវាងរបៀបអនុវត្ត និងលក្ខណៈរបស់អ្នកគ្រប់គ្រង ហើយនិងលទ្ធផលការងាររបស់អង្គភាព ព្រមទាំងផ្តល់នូវព័ត៌មានជាមូលដ្ឋាន សំរាប់ការកែលំអនាពេលអនាគត នូវគុណភាពនៃការគ្រប់គ្រង ដើម្បីជំរុញលទ្ធផលការងាររបស់អង្គភាព ។

វិធីសាស្ត្រប្រើប្រាស់ក្នុងការសិក្សានេះ ផ្អែកលើវិធីសាស្ត្រ របស់ Fernandez ដែលបានរកឃើញប្រពៃណីចំនួនបី នៅក្នុងទ្រឹស្តីការគ្រប់គ្រង ដែលជាប់ទាក់ទងនឹងលទ្ធផលរបស់អង្គភាព គឺមាន (១) លក្ខណៈនៃទំនាក់ទំនងជាឋានានុក្រម រវាងអ្នកគ្រប់គ្រង និងបុគ្គលិក (២) តួនាទីនៃនិមិត្តសញ្ញាផ្លូវអារម្មណ៍ និងចរិតលក្ខណៈទាក់ទាញពីកំណើត (ស្នេហ៍មុខ) ក្នុងការជំរុញឱ្យបុគ្គលិកខំធ្វើការងារ និង (៣) វិធីសាស្ត្រនាពេលថ្មីៗនេះ ដែលផ្អែកលើក្របខ័ណ្ឌសរុបរួមគ្នាមួយ សំរាប់ពិនិត្យពីទំនាក់ទំនង រវាងគុណភាពនៃការគ្រប់គ្រង និងលទ្ធផលអង្គភាព ។ ដោយហេតុថា វិស័យសុខាភិបាលសាធារណៈរបស់កម្ពុជា ពឹងផ្អែកខ្លាំងលើគុណភាពនៃអ្នកគ្រប់គ្រងមន្ទីរពេទ្យ និងស្រុកប្រតិបត្តិនោះ យើងបានលើកជាសម្មតិកម្ម ៣ ឡើង ដើម្បីបញ្ជាក់មើលថា តើលទ្ធផលរបស់ស្ថាប័នពិតជាពឹងផ្អែកជាវិជ្ជមានមែនទេលើ: ចក្ខុវិស័យរបស់ថ្នាក់គ្រប់គ្រង (សម្មតិកម្ម ១), ពេលវេលាចំណាយលើការសំរបសំរួលសកម្មភាពផ្សេងៗ (សម្មតិកម្ម ២), និង ប្រសិទ្ធភាពនៃការគ្រប់គ្រងលើការងាររបស់បុគ្គលិក (សម្មតិកម្ម ៣) ។ ការសិក្សានេះ ប្រើប្រាស់ប្រភពទិន្នន័យចំនួន ២ ។ ទី១ គឺទិន្នន័យប្រភព ទី២ ស្តីពីលទ្ធផលការងាររបស់មន្ទីរពេទ្យបង្អែក និងស្រុកប្រតិបត្តិ ដែលមាននៅក្នុងប្រព័ន្ធព័ត៌មានសុខភាពរបស់ក្រសួងសុខាភិបាល ។ លទ្ធផលរបស់មន្ទីរពេទ្យបង្អែក គឺមានប្រសិទ្ធភាពមូលធន (អត្រាគ្រែកំពុងប្រើប្រាស់ និងរយៈពេលជាមធ្យមនៃការស្នាក់នៅ) ផលិតភាពរបស់បុគ្គលិក (ចំនួនការផ្តល់សេវាពិគ្រោះយោបល់នៃបុគ្គលិកផ្នែកវេជ្ជសាស្ត្រម្នាក់ក្នុងមួយថ្ងៃ តួលេខនៃស្ត្រីមានគភ៌ឆ្លងទន្លេ ដោយមានការជួយពីពេទ្យឆ្មបម្នាក់ក្នុងមួយថ្ងៃ ចំនួនថ្ងៃអ្នកជំងឺម្នាក់សំរាកនៅពេទ្យ ក្រោមការព្យាបាលពីបុគ្គលិកផ្នែកវេជ្ជសាស្ត្រមួយរូប ចំនួនថ្ងៃអ្នកជំងឺម្នាក់សំរាកនៅពេទ្យក្រោមការព្យាបាលពីវេជ្ជបណ្ឌិតមួយរូប ចំនួនអ្នកជំងឺ ដែលបុគ្គលិកផ្នែកវេជ្ជសាស្ត្រម្នាក់អនុញ្ញាតឱ្យចេញពីពេទ្យក្នុងមួយថ្ងៃ

និងចំនួនអ្នកជំងឺ ដែលវេជ្ជបណ្ឌិតម្នាក់អនុញ្ញាតឱ្យចេញពីពេទ្យក្នុងមួយថ្ងៃ) និងគុណភាពនៃការមើលថែទាំ (អត្រាមរណៈនៅក្នុងមន្ទីរពេទ្យ និងភាគរយនៃករណីជំងឺមកពីស្រុកដទៃទៀត) ។ លទ្ធផលរបស់ស្រុកប្រតិបត្តិគឺមានប្រសិទ្ធភាពមូលធន (រយៈពេលជាមធ្យមនៃការស្នាក់នៅ) ផលិតភាពរបស់បុគ្គលិក (ការផ្តល់សេវាពិគ្រោះយោបល់ដល់អ្នកជំងឺស្នាក់នៅក្រៅមន្ទីរពេទ្យ ដោយបុគ្គលិកផ្នែកវេជ្ជសាស្ត្រម្នាក់ក្នុងមួយថ្ងៃ តួលេខនៃការឆ្លងទន្លេដោយមានការជួយពីពេទ្យឆ្មបម្នាក់ក្នុងមួយថ្ងៃ និងតួលេខនៃការឆ្លងទន្លេនៅមណ្ឌលសុខភាព និងនៅតាមផ្ទះដោយមានការជួយពីអ្នកជំនាញផ្នែកសុខាភិបាល ធ្លាប់ទទួលបានការបណ្តុះបណ្តាលម្នាក់) ការគ្របដណ្តប់លើផ្នែកសុខភាព (ការមកពិនិត្យផ្ទៃពោះ២លើក នៃស្ត្រីមានគភ៌ និងការចាក់វ៉ាក់សាំងការពារកុមារអាយុក្រោម ១ឆ្នាំ) និងតម្រូវការសេវាកម្ម (ចំនួនសរុបនៃការពិគ្រោះជំងឺគិតក្នុងអ្នកជំងឺម្នាក់ និងសមាមាត្រនៃអ្នកជំងឺទទួលការពិគ្រោះយោបល់ ដែលមកពីតំបន់ខាងក្រៅ) ។ ទិន្នន័យជំងឺរបេង ដូចជា រយៈពេលស្នាក់នៅជាមធ្យមរបស់អ្នកជំងឺរបេង និងអត្រាចំនួនគ្រែកំពុងប្រើប្រាស់ដោយអ្នកជំងឺរបេង ជាដើម មិនត្រូវបានបញ្ចូលទៅក្នុងការវិភាគឡើយ ដោយសារការបារម្ភពីគុណភាពទិន្នន័យ និងការសង្កេតឃើញមានបាត់ទិន្នន័យច្រើន ។ ប្រភពទិន្នន័យទី២ គឺអង្កេតគំរូតាងមួយ ដែលប្រមូលបានពីគំរូតាងថៃដន្យនិងឯករាជ្យ ដែលជ្រើសចេញពីនាយកនៃមន្ទីរពេទ្យបង្អែក និងស្រុកប្រតិបត្តិ នៅក្នុងតំបន់ដែលជ្រើសយកមកធ្វើការសិក្សានេះ ក្នុងឆ្នាំ២០០៩ ។ គំរូតាងរបស់មន្ទីរពេទ្យបង្អែកគឺជ្រើសយកក្នុងចំណោមមន្ទីរពេទ្យដែលមានលើសពី ៦០គ្រែ ដោយគិតចូលទាំងមន្ទីរពេទ្យបង្អែក នៅកម្រិតស្រុក ខេត្ត និងជាតិ ផងដែរ ។ ក្នុងការអង្កេតនេះ គេមើលទៅលើចរិតលក្ខណៈរបស់អ្នកគ្រប់គ្រង (ភេទ អាយុ កំរិតជំនាញ បទពិសោធន៏ខាងការគ្រប់គ្រងនិងខាងវេជ្ជសាស្ត្រ និងចំណាប់អារម្មណ៏លើតួនាទីនៃការគ្រប់គ្រង) ចរិតលក្ខណៈស្ថាប័ន (ប្រភពអ្នកជំងឺ ចំនួនអ្នកជំងឺ ចំនួនគ្រែ ចំនួនបុគ្គលិក និងកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល) ការអនុវត្តរបស់អ្នកគ្រប់គ្រង (ចក្ខុវិស័យរបស់អ្នកគ្រប់គ្រង ការសម្របសម្រួល និងការគ្រប់គ្រងបុគ្គលិក) និង គ្រឿងលើកទឹកចិត្ត និងការគ្រប់គ្រងពេលវេលារបស់អ្នកគ្រប់គ្រង ។ ការវិភាគទំនាក់ទំនង និងការវិភាគជាកត្តាៗ ត្រូវបានប្រើប្រាស់ ដើម្បីកាត់បន្ថយអថេរយ៉ាងច្រើន ដែលប្រើនៅក្នុងបញ្ជីសំនួរអង្កេតលើអ្នកគ្រប់គ្រងនៅមន្ទីរពេទ្យបង្អែក និងស្រុកប្រតិបត្តិ ឱ្យទៅជាអថេរជាមូលដ្ឋាន ។ បច្ចេកទេស Regression Analysis Technique ត្រូវបានប្រើប្រាស់ ដើម្បីវិភាគពីទិន្នន័យ និងសាកពិសោធសម្មតិកម្ម ។ យើងក៏បានប្រើស្ថិតិបែបពិពណ៌នាផងដែរ ដើម្បីពិពណ៌នាពីទិន្នន័យលទ្ធផលរបស់មន្ទីរពេទ្យបង្អែក និងស្រុកប្រតិបត្តិ ។ គំរូវិភាគសំរាប់មន្ទីរពេទ្យ និងស្រុកត្រិបត្តិ មានអថេរត្រួតពិនិត្យខុសៗគ្នា ដោយសារលក្ខណៈខុសគ្នានៃប្រព័ន្ធទាំងពីរនេះ ។ ឧទាហរណ៏ ប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព និងអតីតមន្ទីរពេទ្យស្រុក ដែលនៅក្រោមស្រុកប្រតិបត្តិផ្តល់ជាចំបងនូវសំណុំសកម្មភាពអប្បបរមា ដែលរួមមាន សេវាព្យាបាល ការពារ និងផ្សព្វផ្សាយ ទាំងនៅក្នុងទីតាំងរបស់អង្គភាព និងការចេញទៅផ្តល់សេវានៅខាងក្រៅ រីឯមន្ទីរពេទ្យបង្អែកវិញ ផ្តល់នូវសំណុំសកម្មភាពបង្គ្រប់ (CPA) ។ ការផ្តល់មូលនិធិសមធមិសុខភាព ត្រូវបានអនុវត្តជាចំបងនៅមន្ទីរពេទ្យបង្អែក និងមិនមានអនុវត្តនៅប៉ុស្តិ៍សុខភាព និងមណ្ឌលសុខភាព នៅក្នុងស្រុកប្រតិបត្តិឡើយ ។ ស្រុកប្រតិបត្តិ ត្រូវបានបង្កើតឡើង ដើម្បីទទួលខុសត្រូវលើចំនួនប្រជាជន និងតំបន់ភូមិសាស្ត្រជាក់លាក់មួយ ចំណែកឯមន្ទីរពេទ្យបង្អែកមិនមានកំណត់តំបន់ត្រួតពិនិត្យជាក់លាក់ឡើយ ។ យើងមិនបានរកឃើញថា បទពិសោធន៏ក្នុងការគ្រប់គ្រងកំរិតជំនាញ (វេជ្ជបណ្ឌិត

ធៀបនឹងជំនួយការពេទ្យ) និងមូលនិធិសមធម៌សុខភាព មានទំនាក់ទំនងអ្វីធំដុំទៅនឹងលទ្ធផលរបស់មន្ទីរពេទ្យបង្អែកឡើយ ។ ដូច្នេះ យើងក៏បានដកអថេរទាំងនេះ ចេញពីគំរូវិភាគទិន្នន័យមន្ទីរពេទ្យ ។

លទ្ធផលនៃស្ថិតិបែបពណ៌នា ស្តីពីលទ្ធផលការងាររបស់មន្ទីរពេទ្យបង្អែក និងស្រុកប្រតិបត្តិ បង្ហាញថា ប្រសិទ្ធភាពមូលធនជាមធ្យមមានកំរិតទាប ។ នៅតាមមន្ទីរពេទ្យមួយចំនួន អត្រាគ្រែកំពុងប្រើប្រាស់គឺ ១២០,៦% ដែលបង្ហាញថា អ្នកជំងឺមានចំនួនច្រើនជាងគ្រែមន្ទីរពេទ្យ ដូច្នេះ មានអ្នកជំងឺខ្លះ ត្រូវគេងផ្ទាល់កំរាលឥដ្ឋ ។ រយៈពេលស្នាក់នៅជាមធ្យម (ALS) (៥,៧៨៧ថ្ងៃ) ស្ថិតនៅក្នុងចន្លោះស្តង់ដារ ៥-៨ថ្ងៃ រីឯរយៈពេលស្នាក់នៅតិចបំផុត (៣,៩៥៦ថ្ងៃ) និងខ្ពស់បំផុត (១០,១៥ថ្ងៃ) ស្ថិតនៅក្រៅចន្លោះស្តង់ដារខាងលើ ដែលបង្ហាញថា ការផ្តល់សេវាកម្មមិនសូវមានប្រសិទ្ធភាពឡើយ ។ ផលិតភាពការងាររបស់បុគ្គលិក ក៏មានកំរិតទាបដែរ នៅតាមមន្ទីរពេទ្យបង្អែក និងស្រុកប្រតិបត្តិជាច្រើន ។ តួលេខនៃអ្នកមករកការពិគ្រោះយោបល់ពីបុគ្គលិកផ្នែកវេជ្ជសាស្ត្រ មានពី 0-២នាក់ សំរាប់បុគ្គលិកវេជ្ជសាស្ត្រម្នាក់ក្នុងមួយថ្ងៃ ។ គុណភាពនៃការព្យាបាលជំងឺ នៅមិនទាន់បានដល់កំរិតស្តង់ដារទេ ។ ជាមធ្យម អត្រាមរណៈនៅមន្ទីរពេទ្យគឺ ២,0១% ដែលខ្ពស់ជាងនៅប្រទេសវៀតណាម (១,៧%) និងប្រទេសថៃ (0,៨%) ។ អត្រាស្ត្រីឆ្លងទន្លេនៅមណ្ឌលសុខភាព និងនៅផ្ទះ ដោយមានជំនួយពីបុគ្គលិកជំនាញនោះ នៅមានកំរិតទាបនៅឡើយ ។ ស្ត្រីឆ្លងទន្លេ ដែលទទួលបានការចូលរួមជួយពីបុគ្គលិកជំនាញ មានមធ្យមភាគតិចជាង ១កំណើតកូន ទោះនៅមណ្ឌលសុខភាព ឬនៅតាមផ្ទះក្តី ។ តម្លៃមធ្យម (mean value) នៃស្ត្រីមានគភ៌ដែលមកទទួលការពិនិត្យផ្ទៃពោះចំនួន ២លើកត្រឹមត្រូវ គឺ 0,៦៩៣ ឬ ៦៩,៣% ។ គំរូវការសេវាសុខភាពនៅស្រុកប្រតិបត្តិមួយចំនួន នៅមានកំរិតទាប ។ តម្លៃមធ្យម និងសូម្បីតែតម្លៃខ្ពស់បំផុត នៃការមកពិគ្រោះយោបល់នៃអ្នកជំងឺម្នាក់ គិតក្នុងរយៈពេល១ឆ្នាំនោះ ក៏នៅតែតិចជាង ១ ដែរ សំរាប់ប្រជាជនដែលរស់នៅក្នុងតំបន់ទទួលខុសត្រូវដោយស្រុកប្រតិបត្តិនោះ ។

លទ្ធផលនៃការវិភាគ regression analysis នូវអថេរជាមូលដ្ឋាន បង្ហាញថា ចក្ខុវិស័យរបស់អ្នកគ្រប់គ្រង ការសំរបសំរួលការងារគ្រប់គ្រងរបស់អ្នកគ្រប់គ្រង និងរបៀបគ្រប់គ្រងបុគ្គលិករបស់អ្នកគ្រប់គ្រង ហាក់មិនសូវជាប់ទាក់ទងខ្លាំងនឹងលទ្ធផលរបស់ស្ថាប័នឡើយ ។ ការសម្រេចជោគជ័យនៃបេសកកម្មរបស់ក្រសួងសុខាភិបាល ហាក់មិនមានទំនាក់ទំនងអ្វីជាមួយនឹងអថេរលទ្ធផលរបស់ស្ថាប័នឡើយ ប៉ុន្តែ ហាក់ដូចមានទំនាក់ទំនងខ្លាំងជាមួយនឹង ALS នៅក្នុងទិន្នន័យរបស់ស្រុកប្រតិបត្តិ ។ ទំនាក់ទំនងរវាងការសម្រេចជោគជ័យ នៃបេសកកម្មរបស់ក្រសួងសុខាភិបាល និង ALS នៅក្នុងទិន្នន័យរបស់ស្រុកប្រតិបត្តិ ផ្តល់គំនិតថា នៅពេលនាយកគ្រប់គ្រងស្គាល់តួនាទីរបស់ខ្លួន បានដឹងពីក្រសួងសុខាភិបាល នូវគោលដៅសំខាន់ៗបំផុត បានបង្កើតនូវដំណើរការផ្សេងៗ ដើម្បីធានាថា បុគ្គលិកគ្រប់គ្នាក្នុងស្ថាប័នខ្លួន សុទ្ធតែយល់ដឹងពីគោលដៅទាំងនោះ បានធ្វើការកែលំអច្រើនក្នុងឆ្នាំកន្លងទៅ និងបានបង្កើតច្រកប្រាស្រ័យទាក់ទងគ្នានៅក្នុងស្ថាប័ននោះ រយៈពេលស្នាក់នៅជាមធ្យមរបស់អ្នកជំងឺ អាចថយចុះអស់ 0,៧៧៥ថ្ងៃ ។ ការគ្រប់គ្រងឱសថ និងការគ្រប់គ្រងពេលវេលា ទំនងមានទំនាក់ទំនងច្រើនជាមួយ ALS រីឯអថេរជាមូលដ្ឋានផ្សេងៗទៀត (ការត្រួតពិនិត្យគុណភាពសេវា ការផ្ទេរកាតព្វកិច្ចព្យាបាលជំងឺ និងការគ្រប់គ្រងហិរញ្ញវត្ថុ) គ្មានទំនាក់ទំនងអ្វីច្រើនទេ ជាមួយនឹងអថេរភាគច្រើននៃលទ្ធផលមន្ទីរពេទ្យ ។ មានតែការផ្ទេរកាតព្វកិច្ចព្យាបាលជំងឺប៉ុណ្ណោះ ដែលគេពិនិត្យឃើញថា មានទំនាក់ទំនងច្រើន ជាមួយនឹងលទ្ធផលរបស់ស្រុកប្រតិបត្តិ ដែលរួមមាន ការផ្តល់សេវាពិគ្រោះយោបល់ដល់អ្នកជំងឺស្នាក់នៅក្រៅមន្ទីរពេទ្យ ដោយបុគ្គលិកផ្នែកវេជ្ជសាស្ត្រម្នាក់

ក្នុងមួយថ្ងៃ (OPDCSD) និងតួលេខនៃការឆ្លងទន្លេ ដោយមានការជួយពីពេទ្យឆ្មបម្នាក់ក្នុងមួយថ្ងៃ (DMD) ។ ប្រសិនបើ នាយកគ្រប់គ្រងផ្ទេរអ្នកជំងឺ និងការគ្រប់គ្រងដំណើរការព្យាបាលជំងឺ ទៅឱ្យអ្នករួមការងាររបស់ខ្លួននោះ OPDCSD ទំនងជាធ្លាក់ចុះអស់ ១,៣៣៨ ហើយ DMD ទំនងជាថយចុះអស់ 0,១២៦កំណើតទារក ។ ទំនាក់ទំនងរវាងការគ្រប់គ្រងឱសថ និង ALS បង្ហាញថា ប្រសិនបើនាយកគ្រប់គ្រងបានដឹងច្បាស់ពីការផ្គត់ផ្គង់ឱសថ និងអាចដោះស្រាយបញ្ហាកង្វះឱសថនៅក្នុងមន្ទីរពេទ្យរបស់ខ្លួននោះ ALS ទំនងជាកើនឡើង ១,៣0៩ថ្ងៃ ។ គេមិនដឹងច្បាស់ថា ហេតុអ្វីបានជាអថេរទាំងពីរមានទំនាក់ទំនងបញ្ច្រាសបែបនេះទៅវិញ ។ មូលហេតុចំបង ប្រហែលមកពីការគ្រប់គ្រងឱសថ កើតចេញពីការដាក់ពិន្ទុដែលមិនសូវរឹងប៉ឹង ។ បញ្ហានេះ កាន់តែស្មុគស្មាញ ដោយសារគំរូតាងមានទំហំតូច ហើយអថេរជាច្រើន សំរាប់គណនាសមីការមានទំនាក់ទំនងគ្នាខ្លាំង[២] ។ ទំនាក់ទំនងច្រើនរវាងការគ្រប់គ្រងពេលវេលា និង ALS បង្ហាញថា នៅពេលវេជ្ជបណ្ឌិត អាចលៃចែកពេលម៉ោងប្រកបដោយប្រសិទ្ធភាព អាចគ្រប់គ្រងមន្ទីរពេទ្យ និងសម្របសម្រួលជាមួយមន្ទីរសុខាភិបាលខេត្ត ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍ផ្នែកខាងក្រៅនោះ ALS ទំនងជាថយចុះអស់ 0,៣៣១ថ្ងៃ ។ ការគ្រប់គ្រងបុគ្គលិក និងការផ្តល់រង្វាន់ហាក់មិនមានទំនាក់ទំនងច្រើន ជាមួយនឹងលទ្ធផលមន្ទីរពេទ្យឡើយ ប៉ុន្តែគេសង្កេតឃើញថា ការរីកចំរើនរបស់បុគ្គលិក មានជាប់ពាក់ព័ន្ធនឹងលទ្ធផលមួយចំនួន ដូចជា អត្រាគ្រែកំពុងប្រើប្រាស់ (BOR) ចំនួនថ្ងៃអ្នកជំងឺម្នាក់សំរាកនៅពេទ្យ ក្រោមការព្យាបាលពីបុគ្គលិកផ្នែកវេជ្ជសាស្ត្រមួយរូប (EHDCSD) ចំនួនអ្នកជំងឺដែលបុគ្គលិកផ្នែកវេជ្ជសាស្ត្រម្នាក់អនុញ្ញាតឱ្យចេញពីពេទ្យក្នុងមួយថ្ងៃ (DCSD) ចំនួនថ្ងៃអ្នកជំងឺម្នាក់សំរាកនៅពេទ្យ ក្រោមការព្យាបាលពីវេជ្ជបណ្ឌិតមួយរូប (EHDPD) ចំនួនអ្នកជំងឺ ដែលវេជ្ជបណ្ឌិតម្នាក់អនុញ្ញាតឱ្យចេញពីពេទ្យក្នុងមួយថ្ងៃ (DPD) និងអត្រាមរណៈនៅក្នុងមន្ទីរពេទ្យ (HMR) ។ ទំនាក់ទំនងរវាងការរីកចំរើនរបស់បុគ្គលិក និងទិន្នន័យលទ្ធផលការងារមន្ទីរពេទ្យ ដូចជា BOR, EHDCSD, DCSD, EHDPD, DPD និង HMR បង្ហាញថា ប្រសិនបើនាយកគ្រប់គ្រង ដោះស្រាយបញ្ហាបុគ្គលិកអនុវត្តការងារមិនសូវបានល្អ ដោយផ្លាស់ពួកគេទៅធ្វើការងារមិនសូវល្អ និងដាក់ពិន័យពួកគេ នោះអថេរលទ្ធផលទាំងឡាយ ទំនងមានការកើនឡើង BOR កើន 0,១៣៥% EHDCSD កើន 0,៤៦១ថ្ងៃ DCSD កើន 0,0៨៣ថ្ងៃ EHDPD កើន ២,៦0៧ថ្ងៃ DPD កើន 0,៤៩៨ថ្ងៃ និង HMR កើន 0,៥៨៥% ។ គេមិនច្បាស់ទេថា ហេតុអ្វីការការរីកចំរើនរបស់បុគ្គលិក នាំឱ្យមានកំណើនអត្រាមរណៈ ។ ប៉ុន្តែរឿងនេះ ប្រហែលមកពីបញ្ហាស្មុគស្មាញ ដោយសារគំរូតាងមានទំហំតូច និងកំហុសធ្ងន់ធ្ងរ ក្នុងការវាស់វែង ។ នៅក្នុងទិន្នន័យស្រុកប្រតិបត្តិ គេសង្កេតឃើញថា ទំនាក់ទំនងរវាងការគ្រប់គ្រងបុគ្គលិកនិងការផ្តល់រង្វាន់ ហើយនិងការរីកចំរើនរបស់បុគ្គលិក មានលទ្ធផលចំរុះនៅក្នុងលទ្ធផលការងាររបស់ស្រុកប្រតិបត្តិ ។ ការគ្រប់គ្រងបុគ្គលិកនិងការផ្តល់រង្វាន់ មានទំនាក់ទំនងជាមួយការមកពិនិត្យផ្ទៃពោះ ២លើក នៃស្ត្រីមានគភ៌ និងសមាមាត្រអ្នកជំងឺទទួលការពិគ្រោះយោបល់ ដែលមកពីតំបន់ខាងក្រៅ រីឯការរីកចំរើនរបស់បុគ្គលិក មានទំនាក់ទំនងជាមួយនឹង ALS ។ ទំនាក់ទំនងរវាងការគ្រប់គ្រងបុគ្គលិកនិងការផ្តល់រង្វាន់ ហើយនិងលទ្ធផលរបស់ស្រុកប្រតិបត្តិទាំងពីរខាងលើ បង្ហាញថា នៅពេលដែលនាយកគ្រប់គ្រង មានបង្កើតជាផែនការសំរាប់និយោជិកម្នាក់ៗ ដូចជាគោលដៅលទ្ធផលត្រូវអនុវត្តបាន ដោយមានការវាយតម្លៃ និងការផ្តល់រង្វាន់ញឹកញាប់ ជាដើមនោះ អត្រាស្ត្រី

---

២ The mean of VIF (variance of inflation factor) is 1.54.

មានគភិមកពិនិត្យសុខភាព ២ដង មុនពេលសម្រាលកូន បានធ្លាក់ចុះអស់ ៨,៣% ហើយសមាមាត្រអ្នកជំងឺទទួលការពិគ្រោះយោបល់ ដែលមកពីតំបន់ខាងក្រៅ ធ្លាក់ចុះអស់ ១២,៥% ។ ទំនាក់ទំនងខ្លាំងរវាងការរីកចំរើនរបស់នៃបុគ្គលិក ហើយនិង ALS នៅក្នុងទិន្នន័យរបស់ស្រុកប្រតិបត្តិ បង្ហាញថា ប្រសិនបើនាយកប្រតិបត្តិដោះស្រាយបញ្ហាបុគ្គលិកអនុវត្តការងារមិនបានល្អ ដោយផ្លាស់ពួកគេទៅធ្វើការងារមិនសូវល្អ ឬដាក់ពិន័យពួកគេនោះ ALS ទំនងជាមានការថយចុះអស់ ១,៣៩៨ថ្ងៃ ។

កត្តាផ្សេងៗទៀត ហាក់មានឥទ្ធិពលចំរុះទៅលើលទ្ធផលការងាររបស់មន្ទីរពេទ្យ និងស្រុកប្រតិបត្តិ ។ អថេរចំនួនបុគ្គលិកផ្នែកវេជ្ជសាស្ត្ររបស់មន្ទីរពេទ្យ មានផលប៉ះពាល់សំខាន់ទៅលើ DCSD និង DPD រីឯអថេរចំងាយពីមន្ទីរពេទ្យមកភ្នំពេញ និង CPA មានចំណងទាក់ទងជាមួយនឹងអត្រាមរណៈក្នុងមន្ទីរពេទ្យ ។ ឥទ្ធិពលនៃអថេរចំនួនបុគ្គលិកផ្នែកវេជ្ជសាស្ត្ររបស់មន្ទីរពេទ្យ ទៅលើ DCSD និង DPD បង្ហាញថា កំណើនបុគ្គលិកផ្នែកវេជ្ជសាស្ត្ររបស់មន្ទីរពេទ្យ ១នាក់ ទំនងនាំឱ្យ DCSD និង DPD ថយចុះអស់ 0,00២ និង 0,00៨ រៀងគ្នា ។ ទំនាក់ទំនងនេះ ក៏អាចបង្ហាញទៀតថា ពិនិត្យតាមលទ្ធផលការងារមន្ទីរពេទ្យជាក់លាក់ទាំងនោះ ប្រហែលជាមានបុគ្គលិកផ្នែកវេជ្ជសាស្ត្រច្រើននាក់ពេក ។ ឥទ្ធិពលនៃចំងាយផ្លូវទៅមន្ទីរពេទ្យ ទៅលើអត្រាមរណៈ បង្ហាញថា ប្រសិនបើចំងាយពីមន្ទីរពេទ្យទៅកាន់កន្លែងដាច់ស្រយាលកើនឡើង ១គីឡូម៉ែត្រ ថែមទៀត អត្រាមរណៈទំនងជាកើនឡើង 0,00៣% ។ គេសង្កេតឃើញថា មន្ទីរពេទ្យបង្អែកកម្រិត CPA3 មានអត្រាមរណៈ ខ្ពស់ជាងមន្ទីរពេទ្យបង្អែកកម្រិត CPA2 ។ តំលៃមធ្យមនៃអត្រាមរណៈ នៅមន្ទីរពេទ្យបង្អែកកម្រិត CPA2 គឺ ១,៤៨២% ចំណែកនៅមន្ទីរពេទ្យបង្អែកកម្រិត CPA3 គឺ ២,៤៧៨% ។ អ្នកជំងឺធ្ងន់ធ្ងរភាគច្រើន ត្រូវបញ្ជូនពីមន្ទីរពេទ្យបង្អែកកម្រិត CPA1 និង CPA2 ទៅកាន់មន្ទីរពេទ្យបង្អែកកម្រិត CPA3[៣] ហើយនេះ អាចជាមូលហេតុនាំឱ្យមន្ទីរពេទ្យកម្រិត CPA3 មានអត្រាមរណៈខ្ពស់ជាងគេ ។ ជាទូទៅ អ្នកជំងឺដែលបាត់បង់ជីវិត គឺច្រើនបាត់បង់ជីវិតនៅពេលបញ្ជូនទៅដល់មន្ទីរពេទ្យ ។ អថេរចំនួនគ្រែគិតក្នុងមនុស្ស ១000នាក់ ហាក់មានឥទ្ធិពលទៅលើ BOR ការផ្តល់សេវាពិគ្រោះយោបល់ ដល់អ្នកជំងឺស្នាក់នៅក្រៅមន្ទីរពេទ្យ ដោយបុគ្គលិកផ្នែកវេជ្ជសាស្ត្រម្នាក់ក្នុងមួយថ្ងៃ (CCSD) និង DCSD ។ ឥទ្ធិពលនៃអថេរចំនួនគ្រែគិតក្នុងមនុស្ស ១000នាក់ ទៅលើ BOR, CCSD និង DCSD បង្ហាញថា កាលណាមន្ទីរពេទ្យមានកំណើនគ្រែ ១ នោះ អត្រាគ្រែកំពុងប្រើប្រាស់ ទំនងជាថយចុះ ៧,៩៦៥% CCSD ទំនងជាកើនឡើង ១៨,៤១៦% ហើយ ឌុជរុឌ ទំនងជាថយចុះ ៦,៥៨៤នាក់ ។ ការបណ្តុះបណ្តាលការគ្រប់គ្រងសេវាសុខភាព ហាក់មានចំណងទាក់ទងអវិជ្ជមាន ជាមួយលទ្ធផលរបស់មន្ទីរពេទ្យ និងស្រុកប្រតិបត្តិ ទោះបី

---

១ CPA1 ជាមន្ទីរពេទ្យបង្អែក ដែលមិនមានផ្តល់ការវះកាត់ធំ (មិនមានថ្នាំសន្លប់) ប៉ុន្តែយ៉ាងហោចណាស់ អាចមានផ្តល់សេវាវះកាត់បង្កើតកូន ។ CPA2 ជាមន្ទីរពេទ្យបង្អែក ដែលមានសកម្មភាពច្រើនជាងមន្ទីរពេទ្យកម្រិត១ ប៉ុន្តែ តិចជាងមន្ទីរពេទ្យកម្រិត៣ ។ ជាទូទៅ មន្ទីរពេទ្យនេះ មានសេវាសង្គ្រោះបន្ទាន់ និងការវះកាត់ (មានប្រើថ្នាំសន្លប់) ។ CPA3 ជាមន្ទីរពេទ្យបង្អែក ដែលមានសកម្មភាពច្រើនជាងគេបំផុត ។ មន្ទីរពេទ្យនេះ មានផ្តល់សេវាវះកាត់ (មានប្រើថ្នាំសន្លប់) និងមានសកម្មភាព (ទាំងចំនួនអ្នកជំងឺ និងសកម្មភាពព្យាបាល) ច្រើនជាងមន្ទីរពេទ្យកម្រិត២ ។ មន្ទីរពេទ្យនេះថែមទាំងមានសេវាឯកទេសផ្សេងៗ (សំរាប់ព័ត៌មានលំអិត សូមមើលសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ស្តីពីសំណុំសកម្មភាពបង្គ្រប់ សំរាប់អភិវឌ្ឍន៏មន្ទីរពេទ្យបង្អែក ពីឆ្នាំ២00៦ ដល់ ២0១0) ។

មិនមែនក្នុងគ្រប់ករណីទាំងអស់ក្តី ។ ទំនាក់ទំនងរវាងអថេរការបណ្តុះបណ្តាលការគ្រប់គ្រងសេវាសុខភាព ទៅលើ DCSD និង HMR នៅក្នុងទិន្នន័យលទ្ធផលរបស់មន្ទីរពេទ្យ បង្ហាញថា ប្រសិនបើនាយកគ្រប់គ្រង បានចូលរួមវគ្គបណ្តុះបណ្តាលការគ្រប់គ្រងសេវាសុខភាព នោះ DCSD ទំនងនឹង ថយចុះអស់ 0,១៨៨% ប៉ុន្តែ HMR ទំនងនឹងកើនឡើង 0,៧៦៩% ។ ឥទ្ធិពលជាអវិជ្ជមាននៃការបណ្តុះបណ្តាលការ គ្រប់គ្រងសេវាសុខភាព ទៅលើ HMR ប្រហែលមានជាប់ពាក់ព័ន្ធនឹងប្រភេទមន្ទីរពេទ្យ ។ នៅក្នុងទិន្នន័យ លទ្ធផលការងារស្រុកប្រតិបត្តិ ការបណ្តុះបណ្តាលការគ្រប់គ្រងសេវាសុខភាព ក៏ទំនងជាមានផលប៉ះពាល់ទៅលើ អត្រាស្ត្រីមានគភ៌ដែលមកពិនិត្យផ្ទៃពោះ ២លើកត្រឹមត្រូវ (2ANC) ។ អត្រា 2ANC ទំនងជាថយចុះ ១៨% នៅស្រុក ប្រតិបត្តិដែលនាយកគ្រប់គ្រងបានចូលរួមវគ្គបណ្តុះបណ្តាលការគ្រប់គ្រងសេវាសុខភាព បើធៀបនឹងស្រុកដែលនាយកគ្រប់គ្រងមិនបានចូលរួមវគ្គបណ្តុះបណ្តាល ។ ចំនួនបុគ្គលិកផ្នែកវេជ្ជសាស្ត្រក្នុងស្រុកប្រតិបត្តិ ទំនងមានការពាក់ព័ន្ធនឹង OPDCSD និង DMD ។ ប្រសិនបើស្រុកប្រតិបត្តិបន្ថែមបុគ្គលិកផ្នែកវេជ្ជសាស្ត្រមួយរូប នោះ OPDCSD និង DMD ទំនងជាថយចុះអស់ 0,0២៥ និង 0,00២៥រៀងគ្នា ។ ចំនួនមណ្ឌលសុខភាពគិតក្នុងប្រជាជន ១000នាក់ និង ចំនួនស្រុកប្រតិបត្តិដែលដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល (NGOs) ក្រោមកិច្ចសន្យាជាមួយរដ្ឋាភិបាល ទំនងជាមានឥទ្ធិពលលើ ចំនួនការពិគ្រោះយោបល់សរុបគិតក្នុងមនុស្សម្នាក់ (TCC) ។ កាលណាចំនួនមណ្ឌលសុខភាពគិតក្នុងប្រជាជន ១000នាក់ កើនឡើង ១មណ្ឌល នោះ TCC ទំនងនឹងកើនឡើង 0,00២ ។ ស្រុកប្រតិបត្តិដែលដំណើរការដោយ NGO ក្រោមកិច្ចសន្យាជាមួយរដ្ឋាភិបាលទំនងជាមានអត្រា TCC 0,៣២៤ ច្រើនជាង ស្រុកប្រតិបត្តិដំណើរការដោយរដ្ឋាភិបាលតែឯង ។ បទពិសោធន៍គ្រប់គ្រង និងកំរិតជំនាញនៃនាយកគ្រប់គ្រង មានឥទ្ធិពលលើ DMD ។ម្យ៉ាងទៀត កំរិតជំនាញនៃនាយកគ្រប់គ្រង ក៏ហាក់ដូចមានឥទ្ធិពលទៅលើ អត្រាកុមារអាយុក្រោម១ឆ្នាំដែល ទទួលការចាក់វ៉ាក់សាំងការពារត្រឹមត្រូវ (IMM) និង 2ANC ទៀតផង ។ ឥទ្ធិពលនៃបទពិសោធន៍គ្រប់គ្រង ទៅលើ DMD បង្ហាញថា កំណើន១ឆ្នាំនៃបទពិសោធន៍គ្រប់គ្រងរបស់នាយកគ្រប់គ្រង ទំនងជានាំឱ្យមានកំណើន DMD ប្រមាណ 0,0២៣ ។ ចំណែកអថេរកំរិតជំនាញវិញបង្ហាញថា នាយកគ្រប់គ្រងដែលបញ្ចប់វគ្គសិក្សាកំរិតផ្នែកវេជ្ជសាស្ត្រ ទំនងជានាំឱ្យ DMD កើន 0,១៧៤ IMM កើន ១៦% និង 2ANC កើន ១៤,៣% បើធៀបនឹងនាយកគ្រប់គ្រងដែលបញ្ចប់វគ្គសិក្សាកំរិតជំនួយការផ្នែកវេជ្ជសាស្ត្រ ។ សំរាប់ OPDCSD និង IMM គេឃើញមានការខុសគ្នាច្រើនរវាង អត្រាអ្នករស់នៅទីក្រុង និងអ្នករស់នៅទីជនបទ ។ អ្នករស់នៅទីជនបទ មករកសេវាពិគ្រោះជំងឺផ្នែកខាងក្រៅ (មិនស្នាក់នៅមន្ទីរពេទ្យ) គិតក្នុងគ្រូពេទ្យម្នាក់ក្នុង១ថ្ងៃ មានចំនួន ២,៧៥១ដង លើសអ្នករស់នៅទីក្រុង ។ សេវាចាក់វ៉ាក់សាំងការពារជំងឺដល់កុមារ មានផ្តល់ទៅឱ្យកុមារនៅទីជនបទមានអត្រា ១១,៩% ច្រើនជាងកុមារនៅទីក្រុង ។

អថេរមូលដ្ឋានភាគច្រើន មិនមានទំនាក់ទំនងអ្វីសំខាន់ជាមួយនឹង អថេរលទ្ធផលភាគច្រើនរបស់ស្ថាប័ន ដោយសារមូលហេតុជាច្រើន ដូចជា នាយកគ្រប់គ្រងទទួលបានសិទ្ធិសំរេចតិចតួចលើទិដ្ឋភាពជាច្រើននៃការគ្រប់គ្រង គំរូតាងតូចក្នុងការសិក្សា បញ្ហាគុណភាពទិន្នន័យ អថេរជំនួសមានលក្ខណៈអន់ខ្សោយ និងលក្ខណៈបច្ចេកទេសនៃគំរូវិភាគ ។ កង្វះសិទ្ធិសំរេចរបស់នាយកគ្រប់គ្រង ជះឥទ្ធិពលខ្លាំងជាងគេ និងអាចចាត់ទុកជា កត្តាសំខាន់ទីមួយ ។ របៀបគ្រប់គ្រងនៅតាម មន្ទីរពេទ្យ និងស្រុកប្រតិបត្តិ ហាក់ដូចជាមានលក្ខណៈស្តង់ដារដូចៗគ្នា ។ ទីពីរ គុណភាពទិន្នន័យលទ្ធផលការងារស្ថាប័ន មានបញ្ហាចោទគួរឱ្យបារម្ភ ដូចមានបង្ហាញក្នុងផ្នែកលទ្ធផលស្រាវជ្រាវនៃអត្ថបទដើម ដែលមានលើកឡើងនូវគំរូតាងជាប់សង្ស័យមួយចំនួន ។ ទីបី ដំបូងឡើយ អង្កេតនេះបានជ្រើសយក គំរូតាងចំនួន ៣0 ។

ប៉ុន្តែ ទិន្នន័យលទ្ធផលរបស់មន្ទីរពេទ្យជាតិចំនួន៣ មិនឃើញមានកត់ត្រានៅក្នុងប្រព័ន្ធព័ត៌មានសុខភាពរបស់ក្រសួងសុខាភិបាលទេ ដែលនាំឱ្យទំហំគំរូតាងថយចុះមកត្រឹម ២៧ ឬតិចជាងនេះទៀត ប្រសិនបើគំរូតាងជាប់សង្ស័យមួយចំនួនទៀត ត្រូវដកចេញដែរនោះ ។ ទីបួន ពិន្ទុនៃការគ្រប់គ្រងឱសថ ដែលទទួលបានពីអថេរជំនួសមានលក្ខណៈអន់ខ្សោយ ដោយប្រើវិធីសាស្ត្រគិតពិន្ទុអថេរ ដែលមិនមានពន្យល់ច្បាស់ពីបំរែបំរួលផ្សេងៗជាច្រើន ។ ទីប្រាំ លក្ខណៈបច្ចេកទេសនៃគំរូវិភាគ ដូចជា អថេរត្រួតពិនិត្យមិនគ្រប់គ្រាន់ជាដើម ដែលគេមិនបានរកឃើញ ក៏ប្រហែលជាដើមហេតុនៃបញ្ហាផងដែរ ។ ទីប្រាំមួយ យើងសង្កេតឃើញថា អថេរសំរាប់គណនាសមីការមួយចំនួន មិនសូវមានទំនាក់ទំនងគ្នាខ្លាំងទេ ។

ក្នុងការសិក្សានេះ អថេរជំនួសពីរ (អថេរការគ្រប់គ្រងនិងផ្តល់រង្វាន់ដល់បុគ្គលិក និងអថេរការរីកចំរើនរបស់បុគ្គលិក) ដែលប្រើសំរាប់តំណាងឱ្យប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់ស្ថាប័ននោះ មានទំនាក់ទំនងសំខាន់ៗច្រើនជាមួយនឹងទិន្នន័យលទ្ធផលការងាររបស់មន្ទីរពេទ្យ ប៉ុន្តែមិនបានគាំទ្រខ្លាំងក្លាទេដល់សម្មតិកម្ម ។ លទ្ធផលការសិក្សាបង្ហាញថា ការរីកចំរើនរបស់បុគ្គលិក មានទំនាក់ទំនងជាមួយនឹងអថេរលទ្ធផលជាច្រើនរបស់មន្ទីរពេទ្យ រីឯការគ្រប់គ្រង និងផ្តល់រង្វាន់ដល់បុគ្គលិកវិញ មានទំនាក់ទំនងជាអវិជ្ជមានជាមួយនឹង ២៧ណេជ និង សមាមាត្រនៃ អ្នកជំងឺទទួលការពិគ្រោះយោបល់ដែលមកពីតំបន់ខាងក្រៅ ។ អវត្តមាននៃទំនាក់ទំនងរវាងការគ្រប់គ្រងនិងការផ្តល់រង្វាន់ ដល់បុគ្គលិក ជាមួយនឹងអថេរលទ្ធផលភាគច្រើនរបស់មន្ទីរពេទ្យ និងស្រុកប្រតិបត្តិ ប្រហែលជាមានមូលហេតុដូចគ្នានឹងករណីនៃសម្មតិកម្ម១ និង សម្មតិកម្ម២ ប៉ុន្តែមូលហេតុចំបងប្រហែលមកពីស្រុកប្រតិបត្តិ និងមន្ទីរពេទ្យសាធារណៈភាគច្រើន មិនមានប្រព័ន្ធល្អៗសំរាប់គ្រប់គ្រងបុគ្គលិក ដូចជា គោលដៅសំរាប់បុគ្គល ការវាយតម្លៃលទ្ធផលការងារបុគ្គលជាដើម ។ នាយកគ្រប់គ្រងមន្ទីរពេទ្យ (៨៣,៨៧%) និងស្រុកប្រតិបត្តិ (៧៨,១៣%) បានរាយការណ៍ថា អង្គភាពរបស់ខ្លួនមិនបានធ្វើការកំណត់នូវគោលដៅសំរាប់បុគ្គល ឬក៏បានធ្វើការកំណត់នូវគោលដៅសំរាប់បុគ្គល ប៉ុន្តែមិនមានលក្ខណៈច្បាស់លាស់ទេ ហើយ ៧៧,៤២% នៃនាយកគ្រប់គ្រងមន្ទីរពេទ្យ ៦៨,៧៥% នៃនាយកគ្រប់គ្រងស្រុកប្រតិបត្តិ បានរាយការណ៍ថា ស្ថាប័នរបស់ខ្លួនមិនមានធ្វើការវាយតម្លៃពីលទ្ធផលការងារបុគ្គល ឬធ្វើការវាយតម្លៃចំពោះកិច្ច (ad hoc assessment) ឡើយ ។ ទោះបីមាននាយកគ្រប់គ្រងមួយចំនួនរាយការណ៍ថា ស្ថាប័នរបស់ខ្លួនមានគោលដៅសំរាប់បុគ្គល និងមានធ្វើការវាយតម្លៃ ជាទៀងទាត់ក្តី ក៏មិនមានការបង្ហាញឱ្យជាក់ច្បាស់ណាមួយថា តើការវាយតម្លៃធ្វើឡើងរបៀបណា តើគោលដៅសំរាប់បុគ្គលត្រូវបានកំណត់តាមរបៀបណា ឬតើការវាយតម្លៃបានហុចលទ្ធផលអ្វីឡើយ ។

លទ្ធផលនៃការសិក្សានេះ ប្រហែលមិនអាចឱ្យគេធ្វើការសន្និដ្ឋានភ្លាមៗបានទេ ដោយសារមានបញ្ហាជាច្រើនដូចបានពន្យល់នៅខាងលើ ។ ដូច្នេះ គួរមានធ្វើការសិក្សាស្រដៀងគ្នានេះមួយទៀត ដើម្បីជំរះបញ្ហាទាំងនេះចេញ ។ ទិន្នន័យលទ្ធផលការងារស្ថាប័ន នៅក្នុងប្រព័ន្ធព័ត៌មានសុខភាពរបស់ក្រសួងសុខាភិបាល ក៏ត្រូវមានដែរ ដើម្បីផ្ទៀងផ្ទាត់មើលពីភាពត្រឹមត្រូវ និងភាពគួរជឿទុកចិត្តបាននៃការសិក្សានេះ នៅមុនពេលធ្វើការសន្និដ្ឋានពីភាពត្រឹមត្រូវនៃសម្មតិកម្ម ។

# ជំពូក ៦
# ស្វែងរកច្រកដ៏ល្អ សំរាប់បង្កើនធំនាក់ធំនងរវាងសង្គមស៊ីវិល និងសមាជិកសភានៅកម្ពុជា

**នឹងមានចេញផ្សាយនៅពេលខាងមុខ**

# ជំពូក ៧
# វិនិយោគចិន នៅក្នុងប្រទេសកម្ពុជា[១]

*ដោយបណ្ឌិត តុង គីមស៊ុន*

### ៧.១. សេចក្តីផ្តើម

ចាប់តាំងពីឆ្នាំ១៩៨៩ មក កម្ពុជាបានធ្វើការផ្លាស់ប្តូរជាបណ្តើរៗ ពីសេដ្ឋកិច្ចផែនការប្រមូលផ្តុំ មកជាសេដ្ឋកិច្ចទីផ្សារ តាមរយៈការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងគោលនយោបាយវិនិយោគ ។ បន្ទាប់ពីការបោះឆ្នោតជាទូទៅលើកទី១ ក្នុងឆ្នាំ១៩៩៣ រដ្ឋាភិបាល ដោយរួមសហការជាមួយស្ថាប័នអន្តរជាតិ ដូចជាធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិរូបិយវត្ថុអន្តរជាតិ ជាដើម បានអនុវត្តកម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធមួយ ដើម្បីរក្សាស្ថិរភាពសេដ្ឋកិច្ច និងទាក់ទាញវិនិយោគផ្ទាល់ពីបរទេស (Foreign Direct Investment: FDI) ។ ច្បាប់ស្តីពីវិនិយោគ បានអនុម័តឡើងដោយរដ្ឋសភាជាតិក្នុងឆ្នាំ១៩៩៤ ហើយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ក៏ត្រូវបានបង្កើតឡើង ដើម្បីត្រួតពិនិត្យទាំងវិនិយោគិនក្នុងស្រុក និងពីបរទេស ។

កម្ពុជា បានខិតខំជំរុញដល់លំហូរចូល FDI តាំងពីឆ្នាំ១៩៩៤ មកម៉្លេះ ។ ក្រុមហ៊ុនពីប្រទេសចិន កូរ៉េខាងត្បូង សហរដ្ឋអាមេរិក ម៉ាឡេស៊ី និងថៃ បានបង្កើតមូលដ្ឋានផលិតកម្មជាបណ្តើរៗនៅកម្ពុជា ដែលមានពលកម្មថ្លៃទាបជាង និងបរិយាកាសវិនិយោគអំណោយផលជាងប្រទេសឯទៀត ។ ពីឆ្នាំ១៩៩៨ ដល់ ២០០៣ កម្ពុជាទាក់ទាញ FDI បានសរុប ១២៦០លានដុល្លារ ។ តៃវ៉ាន់ នាំមុខគេក្នុងតារាងវិនិយោគ បន្ទាប់មកគឺ ចិន ម៉ាឡេស៊ី ហុងកុង និងកូរ៉េខាងត្បូង ។ វិនិយោគស្ទើរតែទាំងអស់ ប្រមូលផ្តុំក្នុងវិស័យអតិពលកម្ម ដូចជាវិស័យកាត់ដេរ ទេសចរណ៍ និងឧស្សាហកម្មវាយនភណ្ឌ ជាដើម ។

កម្ពុជា បានបន្តធ្វើសេរីភាវូបនីយកម្មគោលនយោបាយវិនិយោគរបស់ខ្លួនបន្ថែមទៀត ហើយនៅឆ្នាំ២០០៣ បានធ្វើវិសោធនកម្មលើច្បាប់ស្តីពីវិនិយោគឆ្នាំ១៩៩៤ ដើម្បីសម្រួលដល់ដំណើរការវិនិយោគ ។ ជាលទ្ធផល ក្នុងអំឡុងឆ្នាំ២០០៤-០៨ តំលៃវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ ដែល CDC បានអនុម័ត កើនឡើងជិត ១០ដង រហូតដល់ ១២.១៣៦លានដុល្លារ ក្នុងនេះវិនិយោគពីប្រទេសចិន មានចំនួន ៥៨០៧លានដុល្លារ ឬស្មើនឹង ៤៨% នៃអនុមតិវិនិយោគសរុប ហើយបន្ទាប់មកទៀតគឺ កូរ៉េខាងត្បូង (២៤៥៨លានដុល្លារ) សហរដ្ឋអាមេរិក (១៤១០លានដុល្លារ) ម៉ាឡេស៊ី (៣៣១លានដុល្លារ) និង ថៃ (៣១៦លានដុល្លារ) ។ វិនិយោគដែលបានអនុម័ត មិនមែនអនុវត្តបានទាំងអស់ទេ ។ មន្ត្រី CDC ម្នាក់បានប្រាប់ថា មានប្រហែល ៣០% នៃគំរោងវិនិយោគ ដែលបានអនុម័តប៉ុណ្ណោះ ដែលអនុវត្តបានជាក់ស្តែង ។

---

១ អត្ថបទនេះ ជាស្នាដៃរបស់បណ្ឌិត តុង គីមស៊ុន អ្នកសំរបសំរួលកម្មវិធី នៅវិទ្យាស្ថាន CDRI ។

នៅឆ្នាំ១៩៩៨-២០០៣ FDI មិនបានបែងចែកស្មើភាពគ្នាទៅគ្រប់ផ្នែកសេដ្ឋកិច្ចនៅកម្ពុជាឡើយ ។ ដោយឡែក វិស័យកាត់ដេរទាក់ទាញ FDI បានច្រើនជាងគេ ដោយសារការផ្តល់លក្ខខណ្ឌអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម ប្រព័ន្ធអនុគ្រោះទូទៅ លក្ខខណ្ឌអនុគ្រោះផ្សេងទៀត ខាងទីផ្សារដល់កម្ពុជា ដោយសហរដ្ឋអាមេរិក តំបន់អឺរ៉ុប និងប្រទេសផ្សេងៗ បានជួយជំរុញដល់ការនាំសំលៀកបំពាក់របស់កម្ពុជា ។ វិស័យកសិកម្ម ក៏ទាក់ទាញបានគំរោងមួយចំនួនតូចដែរ ប៉ុន្តែ វិស័យអតិមូលធន ដូចជា ខាងហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន ជាដើម ទទួលបាន FDI តិចតួចណាស់ ។

## ៧.២. វិនិយោគផ្ទាល់ពីបរទេស

យោងតាម CDC តំលៃនៃអនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ បានកើនឡើងយ៉ាងខ្លាំងក្នុងបីឆ្នាំចុងក្រោយ រហូតដល់ ២៣៣៤លានដុល្លារ នៅឆ្នាំ២០០៦ (ធៀបនឹង ៦៨២លានដុល្លារ នៅឆ្នាំ២០០៥) ប៉ុន្តែបានធ្លាក់ចុះមកត្រឹម ១៣៤៥លានដុល្លារ នៅឆ្នាំ២០០៧ បន្ទាប់មកបានកើនឡើងវិញដល់ ៧៦២១លានដុល្លារ នៅឆ្នាំ២០០៨ ដែលជាបរិមាណច្រើនបំផុត ចាប់តាំងពីកម្ពុជាបានបើកចំហដល់វិនិយោគពីបរទេសក្នុងឆ្នាំ១៩៩៤ មក ។ CDC បានឱ្យដឹងទៀតថា អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់នៅឆ្នាំ១៩៩៨-២០០៨ បានចូលទៅក្នុងវិស័យទេសចរណ៍ (៦១៦១លានដុល្លារ) សេវាកម្ម (១១៥០លានដុល្លារ) សំណង់ (១០៣៨លានដុល្លារ) កាត់ដេរ (៨០១លានដុល្លារ) និងផ្សេងៗទៀត (៤២៤៧លានដុល្លារ) ។ ប្រទេសចិន ជាវិនិយោគិនចំបងគេ (៦០៤៨លានដុល្លារ) បន្ទាប់មកមាន កូរ៉េខាងត្បូង (២៥៦៥លានដុល្លារ) សហរដ្ឋអាមេរិក (១៤៥១លានដុល្លារ) ម៉ាឡេស៊ី (៥២៧លានដុល្លារ) និង រុស្ស៊ី (៤៣៤លានដុល្លារ) ។

អ្នកស្រាវជ្រាវជាច្រើន បានកត់សម្គាល់ថា FDI មានសារៈសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៤ មក ។ ទោះយ៉ាងនេះក្តី FDI បានប្រមូលផ្តុំតែក្នុងវិស័យមួយចំនួន ជាពិសេស វិស័យកាត់ដេរដែលគ្របដណ្តប់ដោយសហគ្រាសចិន ។ FDI របស់ចិន ដែលបានចុះបញ្ជីលើ ៤០គំរោង នៅឆ្នាំ១៩៩៨ បានធ្លាក់ចុះអស់បីឆ្នាំបន្តបន្ទាប់គ្នា មកត្រឹម ៥គំរោង នៅឆ្នាំ២០០១ រួចកើនឡើងវិញដល់កំរិតកំពូលនៅឆ្នាំ២០០៥ ហើយបន្ទាប់មកបានធ្លាក់ចុះម្តងទៀតអស់ពេលបីឆ្នាំបន្តបន្ទាប់ ។ ក្នុងចំណោមគំរោងវិនិយោគរបស់ប្រទេសចិន មាន ១៤៩អនុមតិ ខាងកាត់ដេរ ៨អនុមតិ ខាងកសិឧស្សាហកម្ម និង ៦អនុមតិ ខាងការដាំដុះ សេវាកម្ម និងស្បែកជើង ។ អនុមតិគំរោងគិតជាទ្រព្យសកម្មជាប់លាប់នៃ FDI របស់ចិន មាន ១០៥លានដុល្លារ នៅឆ្នាំ១៩៩៨ ហើយពីឆ្នាំ១៩៩៤-២០០៤ ស្ថិតក្នុងចន្លោះ ៥-៨៣លានដុល្លារ បន្ទាប់មកកើនដល់ ៤៥២លានដុល្លារ និង ៧១៧លានដុល្លារ នៅឆ្នាំ២០០៥ និង ២០០៦ ប៉ុន្តែបានធ្លាក់ចុះវិញទៀតនៅឆ្នាំ២០០៧ រួចកើនឡើងវិញដល់កំរិតខ្ពស់បំផុតគឺ ៤៣៧៥លានដុល្លារ នៅឆ្នាំ២០០៨ ។ វិស័យទេសចរណ៍ ទទួលបានអនុមតិគំរោងត្រឹមតែ ៣ ប៉ុណ្ណោះ ប៉ុន្តែមានទឹកប្រាក់សរុបដល់ទៅ ៣៨៦១លានដុល្លារ ដែលជាបរិមាណអនុមតិធំបំផុត ធៀបនឹងវិស័យដទៃទៀត ។ គំរោងអភិវឌ្ឍន៍ឆ្នេរកោះកុងរបស់សហគ្រាសចិនមួយ បានទទួលការអនុម័តនៅឆ្នាំ២០០៨ និងមានទឹកប្រាក់ដល់ ៣៨០៥លានដុល្លារ ដែលជាគំរោងវិនិយោគរបស់បរទេសដ៏ធំបំផុតនៅកម្ពុជា ។ ជំណាលគ្នានេះដែរ អនុមតិគំរោងគិតជាទ្រព្យសកម្មជាប់លាប់ក្នុងវិស័យថាមពល មានចំនួន ៦៤២លានដុល្លារ និងក្នុងវិស័យកាត់ដេរមាន ៣០២លានដុល្លារ ។

## ៧.៣. ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA)

ប្រទេសកម្ពុជា ទទួលបានជំនួយបច្ចេកទេស និងហិរញ្ញវត្ថុច្រើនណាស់ ពីដៃគូទ្វេភាគី និងដៃគូពហុភាគី ។ ជំនួយទាំងនោះ រួមមាន អំណោយហិរញ្ញវត្ថុ និងកំចី ដែលជាទូទៅមានអត្រាការប្រាក់ទាបណាស់ ។ ប្រទេសជប៉ុន ស្ថិតនៅលំដាប់ខ្ពស់បំផុតក្នុងតារាងម្ចាស់ជំនួយ ហើយប្រទេសចិន ក៏ស្ថិតនៅលំដាប់ក្បែរៗនោះដែរ ។ ឯកសាររបស់រាជរដ្ឋាភិបាលកម្ពុជា (២០០៨) បានឱ្យដឹងថា គំរោងដែលទទួលបានជំនួយពីដៃគូអភិវឌ្ឍន៍ មាននៅគ្រប់វិស័យ ។ គំរោងខ្លះពាក់ព័ន្ធផ្ទាល់ជាមួយរដ្ឋាភិបាល ហើយខ្លះទៀតត្រូវបានចុះកិច្ចសន្យាបន្តទៅឱ្យអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ។

កម្ពុជា នៅតែត្រូវការ ODA នៅឡើយ ។ បៀវត្សរ៍មួយភាគរបស់មន្ត្រីសង្គមស៊ីវិលមួយចំនួន ត្រូវបានផ្គត់ផ្គង់ដោយអង្គការអន្តរជាតិ ដូចជា ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ជាដើម ។ បរិមាណនៃជំនួយ ឆ្លុះបញ្ចាំងពីទំនាក់ទំនងការទូតរវាងប្រទេសម្ចាស់ជំនួយ និងប្រទេសកម្ពុជា វត្ថុបំណងរបស់ម្ចាស់ជំនួយ និងតំរូវការរបស់កម្ពុជា ។

តួនាទីខាងការទូតរបស់ប្រទេសចិន នៅក្នុងប្រទេសកម្ពុជា បាននិងកំពុងកើនឡើងយ៉ាងខ្លាំង ។ ឆ្នាំ២០០៨ ជាឆ្នាំទី៥០ នៃទំនាក់ទំនងកម្ពុជា-ចិន ។ ប្រទេសចិន ជាប្រភព ODA ដ៏សំខាន់មួយរបស់កម្ពុជា ។ គំរោងភាគច្រើនដែលទទួលជំនួយពីចិន ស្ថិតក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងរដ្ឋបាលរដ្ឋ ដែលរួមមាន អគារ យានយន្ត និងបរិក្ខារដទៃទៀត សំរាប់រាជការស៊ីវិល និងកងទ័ព ។ យោងតាម CDC ក្នុងអំឡុងឆ្នាំ២០០២-២០០៧ មានគំរោងចំនួន ៣១ បានអនុវត្តចប់សព្វគ្រប់ ឬកំពុងដំណើរការ ។

## ៧.៤. ពាណិជ្ជកម្មផលិតផល

ចាប់តាំងពីការបើកចំហសេដ្ឋកិច្ចមក កម្ពុជាបានធ្វើពាណិជ្ជកម្មនៅទូទាំងសាកលលោក ជាពិសេស ជាមួយប្រទេសធំៗមួយចំនួន ។ ការនាំចេញពីចិន មកកម្ពុជា បានកើនឡើងជាបណ្តើរៗ ចាប់ពីឆ្នាំ២០០១ ដល់ ២០០៧ ។ ក្នុងពេលដំណាលគ្នានេះ ការនាំចេញទំនិញពីកម្ពុជា ទៅចិន កើនឡើងបន្តិចប៉ុណ្ណោះ ។ ការនាំចេញសរុបរបស់កម្ពុជា បង្ហាញច្បាស់ពីនិន្នាការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។

ផលិតផលចំបងៗ ដែលចិននាំចេញមកកម្ពុជា មាន សាច់ក្រណាត់ចាក់ (knitted or crocheted fabrics) ក្រណាត់អំបោះ បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ប្រដាប់កំដៅទឹក គ្រឿងម៉ាស៊ីន សរសៃអំបោះសិប្បនិម្មិត (artificial staple fibres) ផលិតផលសេរ៉ាមិក ទូក កប៉ាល់ និងគ្រឿងអណ្តែតទឹក (មានតែក្នុងឆ្នាំ២០០៧) សរសៃសិប្បនិម្មិត (artificial filaments) យានយន្ត (មិនមែនសំរាប់ផ្លូវដែក) អយស្ម័យយានអគ្គិសនី tramways ដែក និងដែកថែប ។ ផលិតផលទាំងនេះ មួយចំនួនយកមកប្រើប្រាស់ក្នុងវិស័យកាត់ដេរ និងសំណង់ ។ វិស័យកាត់ដេររបស់កម្ពុជា បានរីកដុះដាលលឿនចាប់ពីឆ្នាំ១៩៩៥ ប៉ុន្តែវាគ្រាន់តែជាចំណែកមួយតូចណាស់នៅក្នុងខ្សែចង្វាក់នៃតំលៃ ។ កម្ពុជាត្រូវនាំចូលវត្ថុធាតុដើមទាំងអស់ ដើម្បីផលិតសំលៀកបំពាក់ ដោយសារកង្វះការផ្គត់ផ្គង់ពីវិស័យទី១ នៅកម្ពុជា ។ កំណើនក្នុងវិស័យអចលនទ្រព្យ និងសំណង់ នាំឱ្យមានកំណើនការនាំចូលដែកថែប និងបរិក្ខារអគ្គិសនីច្រើនណាស់ ។ ប៉ុន្តែ វិបត្តិហិរញ្ញវត្ថុសាកល បានធ្វើឱ្យវិស័យកាត់ដេរ អចលនទ្រព្យ និងសំណង់ធ្លាក់ចុះកំណើនវិញ ។

ផលិតផលសំខាន់ៗ ដែលកម្ពុជានាំចេញទៅប្រទេសចិន រួមមាន ឈើ ត្បូង កៅស៊ូ ត្រី សិប្បិសត្វ សត្វរស់ និងសំលៀកបំពាក់មិនមែនចាក់ដោយម្ជុល ។ នៅក្នុងករណីនេះ យើងប្រើប្រាស់ទិន្នន័យរបស់ចិន ព្រោះយើងមិនអាចរកបានទិន្នន័យរបស់កម្ពុជា ស្តីពីការនាំចេញទៅចិនឡើយ ។ ការនាំចូលរបស់ប្រទេសចិន ពីកម្ពុជា ឡើងចុះមិនឋិតថេរឡើយ ហើយនៅឆ្នាំ២០០៧ វាឡើងដល់ ៥១លានដុល្លារ ធៀបនឹង ៣៥លានដុល្លារ នៅឆ្នាំ២០០៦ ។ ពីឆ្នាំ២០០១ ដល់ ២០០៧ ការនាំចេញពីកម្ពុជាទៅចិន កើនបានតែ ៤៧% គឺទាបជាខ្លាំង បើធៀបនឹងកំណើនការនាំចេញពីចិន មកកម្ពុជា ។

ការនាំចេញរបស់កម្ពុជា ទៅកាន់ប្រទេសផ្សេងៗក្នុងពិភពលោក កើនឡើងពីជិត ១,៦ពាន់លានដុល្លារ នៅឆ្នាំ២០០១ រហូតដល់ជាង ៤,៣ពាន់លានដុល្លារ នៅឆ្នាំ២០០៧ ដោយសារមានស្ថិរភាពនយោបាយនៅកម្ពុជា និងភាពប្រសើរឡើង នៃទំនាក់ទំនងការទូត និងសេដ្ឋកិច្ច ជាមួយដៃគូទ្វេភាគី និងពហុភាគី ។ ការចូលជាសមាជិក នៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍នៅឆ្នាំ១៩៩៩ និងអង្គការពាណិជ្ជកម្មពិភពលោកនៅឆ្នាំ២០០៤ បានជំរុញឱ្យពាណិជ្ជកម្មរបស់កម្ពុជាមានកំណើនកាន់តែខ្លាំង តាមរយៈការបញ្ចុះអត្រាពន្ធគយ និងលក្ខខណ្ឌអនុគ្រោះដល់ការចូលទៅទីផ្សារ ។ ផលិតផលចំបងៗ ដែលកម្ពុជានាំចេញ រួមមាន សំលៀកបំពាក់ ឈើ កៅស៊ូ គ្រឿងសំរាប់ពាក់នៅជើង គុជខ្យង និងត្បូងថ្មមានតំលៃ ។ លើសពីនេះទៀត កម្ពុជាមានសក្តានុពលល្អសំរាប់ការកែច្នៃម្ហូបអាហារ ហើយប្រហែលជាអាចនាំចេញម្ហូបអាហារកែច្នៃបានក្នុងអនាគតដ៏ខ្លី ។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ បានឱ្យដឹងថា ការនាំចេញសំលៀកបំពាក់ រួមចំណែក ៩៣% នៃការនាំចេញសរុបរបស់កម្ពុជាក្នុងឆ្នាំ២០០៧ ។ ពីឆ្នាំ២០០១ ដល់ ២០០៧ ក្នុងការនាំចេញសរុបរបស់កម្ពុជា មានជាមធ្យម ១,២៥% ដែលទៅកាន់ប្រទេសចិន ហើយក្នុងការនាំចូលសរុបរបស់កម្ពុជា មានជាមធ្យម ១៦,១២% នាំចូលមកពីប្រទេសចិន ។

## ៧.៥. ពាណិជ្ជកម្មសេវាកម្ម

ពាណិជ្ជកម្មសេវាកម្មរបស់កម្ពុជា រួមមាន សេវា សណ្ឋាគារ និងភោជនីយដ្ឋាន គមនាគមន៍ និងដឹកជញ្ជូន ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ អចលនទ្រព្យ ជំនួញ និងសេវាផ្សេងៗទៀត ។ តាមទិន្នន័យប្រមូលបាន ដោយធនាគារជាតិនៃកម្ពុជា ពាណិជ្ជកម្មសេវាកម្មរបស់កម្ពុជា កើនដល់ជាង ២៤៥០លានដុល្លារ នៅឆ្នាំ២០០៧ ដែលក្នុងនេះ ការនាំចេញមាន ១៥៤៧,៥លានដុល្លារ ។

អត្រាកំណើនប្រចាំឆ្នាំ ពីឆ្នាំ ២០០៣ ដល់ ២០០៧ នៃពាណិជ្ជកម្មសេវាកម្ម មានតួលេខពីរខ្ទង់ជានិច្ច ដោយសាររដ្ឋាភិបាល បានធ្វើសេរីភាវូបនីយកម្មសេវាកម្ម ដែលបានទាក់ទាញការវិនិយោគទុនមកក្នុងវិស័យនេះ ។ សេវាកម្ម រួមចំណែកប្រហែល ៤០% នៃ ផសស ពីឆ្នាំ ២០០៣ ដល់ ២០០៧ ដោយមានអត្រាកំណើនជាមធ្យម ខ្ពស់គួរឱ្យកត់សំគាល់ ដល់ ១០,៥% ។ ក្នុងចំណោមសេវាកម្មទាំងអស់ ពាណិជ្ជកម្មមានចំណែកធំជាងគេនៅគ្រប់ឆ្នាំ បន្ទាប់មកគឺ អចលនទ្រព្យ និងជំនួញ ។ ពីឆ្នាំ ២០០៣ ដល់ ២០០៧ សេវាផ្សេងទៀត បានកើនឡើងយ៉ាងទៀងទាត់ បើទោះជាតួលេខរបស់វា មិនទាន់ធំដុំគួរកត់សំគាល់ក្តី ។ កន្លងមក ប្រទេសចិន គឺជាទីផ្សារនាំចេញសេវាដ៏ចំបងមួយរបស់កម្ពុជា ។

## ៧.៦. ហេតុផល និងឥទ្ធិពលនៃ FDI ពីប្រទេសចិន

### ៧.៦.១ វិស័យកាត់ដេរ

អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ សំរាប់វិស័យកាត់ដេរមិនសូវធំប៉ុន្មានទេ ធៀបនឹងវិស័យផ្សេងៗទៀត ប៉ុន្តែវិស័យនេះ តំណាងឱ្យប្រហែល ៩០% នៃផលិតផលនាំចេញរបស់កម្ពុជា (សំរាប់ឆ្នាំ២០០០-២០០៨) ហើយផ្តល់ការងារដល់ប្រជាជនជាង ៣៥៥.០០០នាក់ ដែលភាគច្រើនជានារីមកពីទីជនបទក្រីក្រ ។ គេប៉ាន់ស្មានថា ប្រជាជនសរុបប្រមាណ ១,៧លាននាក់ ពឹងផ្អែកដោយផ្ទាល់ ឬដោយប្រយោល លើឧស្សាហកម្មកាត់ដេរ ។ ការសិក្សារបស់ Yamagata (2006) ដោយប្រើទិន្នន័យបានពី ១៦៤គំរូតាង ក្នុងឆ្នាំ២០០៣ បានរកឃើញថា ឧស្សាហកម្មកាត់ដេរមានឥទ្ធិពលច្រើនគួរកត់សំគាល់ លើការកាត់បន្ថយភាពក្រីក្រ ព្រោះ (១) កម្មករទើបចូលថ្មីទទួលបានបៀវត្សរ៍ស្មើ ឬលើសពី ៤៥ដុល្លារ/ខែ ដែលខ្ពស់ច្រើនជាងខ្សែបន្ទាត់ក្រីក្រ (២) នារីទទួលបានការងារភាគច្រើនក្នុងឧស្សាហកម្មនេះ (៣) របាំងចំពោះការទទួលបានការងារ និងការឡើងកាំថ្នាក់មិនសូវមានកំរិតខ្ពស់ទេ ។ កត្តាជំរុញទឹកចិត្តចំបងដល់ការវិនិយោគ លើវិស័យកាត់ដេរក្នុងប្រទេសកម្ពុជាអាចជាការដែលកម្ពុជាទទួលបានលក្ខខណ្ឌអនុគ្រោះបំផុត ផ្នែកពាណិជ្ជកម្ម (MFN) និងលក្ខខណ្ឌនៃប្រព័ន្ធអនុគ្រោះទូទៅ (GSP) ពីសំណាក់ សហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងប្រទេសអភិវឌ្ឍន៍ដទៃទៀត (Yamagata 2006; Cuyver et al. 2006, 2008) ។ ដូច្នេះ មួយភាគធំនៃ FDI លើឧស្សាហកម្មកាត់ដេរនៅកម្ពុជា កំពុងប្រើប្រាស់កម្ពុជាធ្វើជាកន្លែងនាំចេញ ដើម្បីជៀសពីកូតា និងពន្ធគយ ដែលដាក់អនុវត្តដោយសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប (Cuyber et al. 2006) ។

ទោះជាកូតាអនុគ្រោះក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មវាយនភណ្ឌ និងសំលៀកបំពាក់ (MFA) បានផុតកំណត់តាំងពីថ្ងៃ ១ មករា ២០០៥ ក្តី ក៏ឧស្សាហកម្មកាត់ដេរនៅតែមានកំណើនខ្លាំងក្នុង ៤ឆ្នាំបន្តមកទៀត ដោយឡើង ដល់ ២,៨៣ពាន់លានដុល្លារ នៅឆ្នាំ២០០៨ ឬ កើនជិត ៣១% បើធៀបនឹងឆ្នាំ២០០៥ ។ កំណើននេះបង្ហាញថា កម្ពុជាមានឧត្តមភាពប្រៀបធៀបខ្លាំងក្នុងឧស្សាហកម្មកាត់ដេរ (Cuyver et al. 2006) ។ ប្រាក់ចំណេញជាមធ្យមខ្ពស់ (អនុបាតរវាងប្រាក់ចំណេញ និងប្រាក់លក់បាន) អាចជាកត្តាគន្លឹះនៃកំលាំងឧស្សាហកម្មនេះ ក្នុងការទប់ទល់នឹងការប្រកួតប្រជែងដ៏ខ្លាំងក្លា បន្ទាប់ពី MFA បានផុតកំណត់ (Yamagata 2006) ។

### ៧.៦.២ វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម

ក្រុមហ៊ុនចិន បានចូលពាក់ព័ន្ធកាន់តែច្រើនក្នុងកសិ-ឧស្សាហកម្ម ដោយសាររដ្ឋាភិបាល បានផ្តល់គ្រឿងលើកទឹកចិត្ត ជាសម្បទានដីរយៈពេលវែងដល់ក្រុមហ៊ុនបរទេស និងក្នុងស្រុកនានា[២] ។ លើសពីនេះទៀត កម្ពុជាបានទទួលអត្ថប្រយោជន៍ពីលក្ខខណ្ឌអនុគ្រោះ ដល់ការនាំផលិតផលកសិកម្មជាក់លាក់មួយចំនួន ចូលទៅទីផ្សារប្រទេស

---

២ គ្រឿងលើកទឹកចិត្ត បានផ្តល់ទៅឱ្យ (១) កសិកម្ម និងឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម (២) ការការពារបរិស្ថាន (៣) ឧស្សាហកម្មបំរើការនាំចេញ (៤) ឧស្សាហកម្មបង្កើតការងារបានច្រើន (៥) ការវិនិយោគនៅក្នុងតំបន់ដែលកំពុងមានការជំរុញជាពិសេស (៦) ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងថាមពល (៧) ឧស្សាហកម្មឈានមុខ និង/ឬ ឧស្សាហកម្មមានបច្ចេកវិទ្យាខ្ពស់ (៨) ការអភិវឌ្ឍខេត្ត និងទីជនបទ និង(៩) ទេសចរណ៍ និងឧស្សាហកម្មពាក់ព័ន្ធ (UN and ICC 2003) ។

ចិន ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ជាពិសេស ក្នុងកម្មវិធីប្រមូលផលដើមដៃ (Early Harvest Programme) និងសម្បទានពិសេស សំរាប់ប្រទេសលូតលាស់តិចជាងគេនៅតំបន់អាស៊ាន ។ Cuyver et al. (2008) បានបញ្ជាក់ថា អត្រាកំណើន ផសស នៅប្រទេសដើមនៃ FDI ពាណិជ្ជកម្មទ្វេភាគីជាមួយប្រទេសទទួល FDI ហើយនិងពាណិជ្ជកម្មអន្តរជាតិ និងអត្រាប្តូរប្រាក់ សុទ្ធតែមានផលប៉ះពាល់លើលំហូរ FDI មកក្នុងប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ១៩៩៥-២០០៥ ។ គេរកឃើញថា រយៈចំងាយភូមិសាស្រ្ត វិបត្តិអាស៊ីឆ្នាំ១៩៩៧-៩៨ និងសមាជិកភាពចិន ក្នុងអង្គការពាណិជ្ជកម្មពិភពលោក មានផលប៉ះពាល់អវិជ្ជមានគួរកត់សំគាល់ លើសមត្ថភាពរបស់កម្ពុជា ក្នុងការទាក់ទាញ FDI ។

វិនិយោគរបស់ចិន ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ភាគច្រើនសំដៅធានាឱ្យមានប្រភពធនធានធម្មជាតិ សំរាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចចិន ។ ឧទាហរណ៍ បន្ទាប់ពីរដ្ឋាភិបាលចិន បានប្រកាសក្នុងឆ្នាំ១៩៩៨ ហាមមិនឱ្យកាប់ឈើមក ការនាំចូលឈើ ម្សៅឈើ និងក្រដាស មកក្នុងប្រទេសចិន បានកើនឡើងយ៉ាងខ្លាំង (Middleton 2008b) ។ ឯកសារ Middleton (2008b) បានឱ្យដឹងថា ក្រោមកិច្ចសហការជាដៃគូជាមួយក្រុមហ៊ុនកម្ពុជា ក្រុមហ៊ុនចិនទទួលបានដីសម្បទានសំរាប់ដាំដើមឈើ យកធ្វើម្សៅឈើ និងក្រដាស ។ នៅឆ្នាំ២០០៤ ក្រុមហ៊ុន Pheapimex របស់កម្ពុជា បានចាប់ដៃគូជាមួយក្រុមហ៊ុនចិន Wuzhishan ដើម្បីបង្កើតចំការដើមស្រល់លើដីសម្បទានចំនួន ១៩៩.៩៩៩ហិកតា (ជិត ២០ដង នៃកំហិតតាមផ្លូវច្បាប់សំរាប់ខេត្តមណ្ឌលគីរី) ដោយទទួលបានការអនុម័តផ្តល់ដីសម្បទានចំនួន ១០.០០០ហិកតា ភ្លាមៗ សំរាប់ធ្វើការដាំដុះសាកល្បង ជាលក្ខណៈពាណិជ្ជកម្ម ។ នៅឆ្នាំ២០០០ ក្រុមហ៊ុន Pheapimex ទទួលបានដីសម្បទាន ៣០០.០០០ហិកតា សំរាប់ធ្វើចំការដើមប្រេងខ្យល់ក្នុងខេត្តពោធិ៍សាត់ និងកំពង់ឆ្នាំង ។ កិច្ចសន្យាដីសម្បទាននេះ បានចុះហត្ថលេខា បន្ទាប់ពីមានកិច្ចព្រមព្រៀងមួយជាមួយក្រុមហ៊ុនសហប្រតិបត្តិការកសិកម្មចិន (China Farm Cooperation Group) ក្នុងការវិនិយោគលើគំរោងដាំដើមឈើនេះ បើទោះជាគំរោងនេះត្រូវបានបញ្ឈប់វិញ ដោយការប្រឆាំងតវ៉ារបស់ប្រជាពលរដ្ឋមូលដ្ឋានក៏ដោយ ។ តាំងពីឆ្នាំ២០០៤ មក ក្រុមហ៊ុន Pheapimex បានសហការជាមួយក្រុមហ៊ុន Wuzhishan ក្នុងការព្យាយាមជំរុញគំរោងនេះឱ្យមានដំណើរការទៅមុខ" ។

ត្រឹមខែធ្នូ ២០០៦ មានយ៉ាងហោចណាស់ ៥៧សម្បទានដីសេដ្ឋកិច្ច (ដីមួយកន្លែងៗ មានទំហំធំជាង ១០០០ហិកតា ហើយទំហំដីសរុប គឺ ៩៤៣.០៦៩ហិចតា ឬស្មើនឹង ១៥% នៃផ្ទៃដីអាចដាំដុះបាននៅកម្ពុជា) ដែលបានបែងចែកទៅឱ្យក្រុមហ៊ុនមកពីបរទេស ឬក្នុងស្រុក សំរាប់គំរោងកសិកម្ម ឬកសិ-ឧស្សាហកម្ម (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទៈ របាយការណ៍តាមឆ្នាំផ្សេងៗ) ។ ក្នុងចំណោម ២៦សម្បទានដីសេដ្ឋកិច្ច ដែលបានផ្តល់ទៅឱ្យក្រុមហ៊ុនបរទេស ក្រុមហ៊ុនចិនទទួលបាន ១៣សម្បទាន (ប្រហែល ១៨៨.០០០ហិកតា) ។ នៅពេលសរសេររបាយការណ៍នេះ យើងរកឃើញក្រុមហ៊ុនចិន ត្រឹមតែ ១១ក្រុមហ៊ុន ប៉ុណ្ណោះ ប៉ុន្តែដីសម្បទានមួយចំនួនដែលបានផ្តល់ឱ្យក្នុងឆ្នាំថ្មីៗនេះ គេមិនអាចដឹងបានទេ (Rutherford et al. 2008) ។

## ៧.៦.៣ វិស័យរ៉ែ ប្រេងកាត និងឧស្ម័ន

ធនធានរ៉ែមួយភាគធំនៅកម្ពុជា មិនទាន់ធ្វើការរុករកនៅឡើយទេ ។ នៅថ្ងៃទី ១៣ កក្កដា ២០០១ ច្បាប់ស្តីពីការគ្រប់គ្រង និងការរុករកធនធានរ៉ែ ត្រូវបានប្រកាសឱ្យប្រើប្រាស់ ដើម្បីទាក់ទាញវិនិយោគក្នុងស្រុក និងពីបរទេសលើការអភិវឌ្ឍ និងរុករកធនធានរ៉ែ (UN & ICC 2003) ។ CDC នឹងចេញអាជ្ញាប័ណ្ណរយៈពេល ពី ២ ទៅ ៦ឆ្នាំ ទៅឱ្យវិនិយោគិនដែលចាប់អារម្មណ៍លើវិស័យនេះ ដើម្បីធ្វើការរុករករ៉ែ ហើយបន្ទាប់មករៀបចំការសិក្សាមួយពីភាពអាចធ្វើបាននៅក្នុងតំបន់បានកំណត់ ហើយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) ជាអ្នកផ្តល់ការគាំទ្រជាអនុសាសន៍ ខាងបច្ចេកទេស ។ ក្រោយធ្វើការរុករកបានជោគជ័យហើយ វិនិយោគិនត្រូវដាក់ស្នើឡើងនូវផែនការគោល នៃគំរោងអភិវឌ្ឍអាជីវកម្មរ៉ែ មុននឹងទទួលបានអាជ្ញាប័ណ្ណធ្វើអាជីវកម្មរ៉ែ ។ ម្យ៉ាងទៀត ត្រូវមានការបង់សួយ និងថ្លៃឈ្នួលលើផ្ទៃដីអាជីវកម្ម នៅលើរ៉ែដែលយកបាន ។

ក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ ក្រុមហ៊ុនមកពីអូស្ត្រាលី ចិន កូរ៉េខាងត្បូង ថៃ និងសហរដ្ឋអាមេរិក បានចូលរួមក្នុងសកម្មភាពរុករករ៉ែនៅកម្ពុជា ដែលមានដូចជា ការអភិវឌ្ឍធនធានរ៉ែក្នុងដី ប្រេងកាតនៅក្នុងសមុទ្រ និងឧស្ម័ន ។ ថ្មីៗនេះ រដ្ឋាភិបាលបានជំរុញ និងជួយសម្រួលដល់ការវិនិយោគលើការជីករករ៉ែ ដោយសារគេបានរកឃើញរ៉ែសំខាន់ៗជាច្រើន ដូចជា បុកស៊ីត ទង់ដែង មាស រ៉ែដែក នីកែល ត្បូងថ្ម ថ្មកំបោរ ប្រេងកាត និងឧស្ម័ន ។ អាជីវកម្មរ៉ែ រួមចំណែកត្រឹមតែ ០,៤១% នៃ ផសស កម្ពុជា ក្នុងឆ្នាំ២០០៦ (ឆ្នាំចុងក្រោយដែលរកបានទិន្នន័យ) ឬកើនឡើង ០,០២% ធៀបនឹងឆ្នាំ២០០៥ ។ វិស័យនេះ ផ្តល់ការងារដល់ប្រជាជនប្រមាណ ២០.០០០នាក់ នៅឆ្នាំ២០០៦ និង ២២.០០០នាក់ នៅឆ្នាំ២០០៧ ឬស្មើនឹង ០,២% និង ០,៣% នៃចំនួនការងារសរុប ក្នុងឆ្នាំទាំងពីររៀងគ្នា (IMF 2009) ។

អង្គការ Global Witness (2009) បានឱ្យដឹងថា រដ្ឋាភិបាលបានផ្តល់អាជ្ញាប័ណ្ណរុករករ៉ែជាង ១០០កន្លែងរួចហើយ នៅទូទាំងផ្ទៃប្រទេស ដោយភាគច្រើនបានទៅក្រុមហ៊ុន-ចិន កូរ៉េខាងត្បូង និងក្រុមហ៊ុនក្នុងស្រុក ។ Rutherford et al. (2008) បានពិនិត្យឃើញមានប្រតិបត្តិការអាជីវកម្មរ៉ែចំនួន ៦ អនុវត្តដោយក្រុមហ៊ុនចិន ប៉ុន្តែនៅពេលកំពុងសរសេរអត្ថបទនេះ យើងមិនអាចបញ្ជាក់បានទេពីចំនួនគំរោងដែលកំពុងដំណើរការ ។

## ៧.៦.៤ វារីអគ្គិសនី

ប្រទេសចិន ក៏ដើរតួសំខាន់ដែរ ក្នុងការវិនិយោគលើវារីអគ្គិសនី ។ ការបូកសរុបពីវិស័យវារីអគ្គិសនីទូទាំងប្រទេសមួយ ដែល MIME បានរៀបចំឡើងនៅឆ្នាំ២០០៣ បានបង្ហាញថា មានគំរោងជាអាទិភាពចំនួន ១៤ និងគំរោងមានសក្តានុពលសំខាន់ៗ ចំនួន ៤ ទៀត ។ ក្នុងចំណោមគំរោងទាំងនេះ មាន ៨គំរោង (KirIrmü III, កំចាយ ស្ទឹងអាតៃ ស្ទឹងឫស្សីខាងក្រោម ស្ទឹងជ័យអារែង ស្ទឹងតាតៃ ស្រែពកខាងក្រោមលេខ៣ និងសំបូរ) ដែលប្រើទុនរបស់ក្រុមហ៊ុនចិននោះ រដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឱ្យធ្វើការសាងសង់ ឬការសិក្សាមុនការសិក្សាពីភាពអាចធ្វើបាន និងការសិក្សាពីភាពអាចធ្វើបាន ។ មានគំរោងអភិវឌ្ឍន៍វារីអគ្គិសនីមួយចំនួនទៀត (ដូចជា សេសានខាងក្រោមលេខ២ ស្រែពកខាងក្រោមលេខ២ និងលេខ៤ ជាដើម) ក៏បានផ្តល់ទៅឱ្យក្រុមហ៊ុនចិន ដើម្បីធ្វើការសិក្សាមុនការសិក្សាពីភាពអាចធ្វើបាន និងការសិក្សាពីភាពអាចធ្វើបានដែរ ។ ក្នុងចំណោមគំរោងទាំងនេះ មាន ៤គំរោងធំៗ ដែលទទួលបានការអនុម័តរួចរាល់ឱ្យសាងសង់ គឺមានគំរោងកំចាយ ស្ទឹងអាតៃ ស្ទឹងតាតៃ និងស្ទឹងឫស្សីជ្រុំ ។

ក្រុមហ៊ុនទាំងឡាយខាងលើនេះ ទទួលបានការគាំទ្រខាងនយោបាយក៏រិតខ្ពស់ ពីថ្នាក់ដឹកនាំនយោបាយនៃប្រទេសកម្ពុជា និងប្រទេសចិន ។ ឧទាហរណ៍ នៅខែវិច្ឆិកា ២០០៦ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុនសែន បានស្នើឱ្យឯកអគ្គរដ្ឋទូតចិន ជួយទាក់ទាញក្រុមហ៊ុនចិន ឱ្យមកវិនិយោគលើការផលិតថាមពលវារីអគ្គិសនីនៅកម្ពុជា (សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៧ វិច្ឆិកា ២០០៦) ។ ក្នុងពេលធ្វើទស្សនកិច្ចនៅកម្ពុជា កាលពីខែមេសា ២០០៧ លោក Qin Guangrong អភិបាលនៃខេត្តយូណាន់ បានជំរាបដល់មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់របស់ចិន និងកម្ពុជា និងអ្នកតំណាងវិស័យឯកជន ចំនួន ៤០០នាក់ នៅក្នុងពិព័រណ៍ពាណិជ្ជកម្ម និងវិនិយោគកម្ពុជា-ចិន (យូណាន់) ថាខេត្តយូណាន់ គ្រោងពង្រីកកិច្ចសហប្រតិបត្តិការជាមួយប្រទេសកម្ពុជា ក្នុងវិស័យកសិកម្ម ដឹកជញ្ជូន វារីអគ្គិសនី វិនិយោគ ពាណិជ្ជកម្ម រុក្ខាប្រមាញ់ ទេសចរណ៍ និងការយករ៉ែ ។ ទីស្តីការគណៈរដ្ឋមន្ត្រីកម្ពុជា បានជ្រើសរើសយកក្រុមហ៊ុន China Yunnan Corporation for International Techno-Economic Cooperation ដើម្បីអភិវឌ្ឍគំរោងស្ទឹងអាតៃ នៅខែកុម្ភៈ ២០០៧ (Middleton 2008a) ។

ការគាំទ្ររបស់រដ្ឋាភិបាលប្រទេសទាំងពីរ មានទំរង់ច្រើនបែបយ៉ាង ។ ក្នុងករណីទំនប់កំចាយ រដ្ឋាភិបាលចិនផ្តល់ឧបត្ថម្ភធន ជាអត្រាការប្រាក់ទាប ដើម្បីផ្តល់ទុនឱ្យគំរោង ហើយរដ្ឋាភិបាលកម្ពុជាបានធានាប៉ះប៉ូវសងខាងហិរញ្ញវត្ថុ ប្រសិនបើគំរោងជួបប្រទះការលំបាក ឬមានដំណើរការមិនល្អ (Middleton 2008a) ។ គុណប្រយោជន៍ និងគុណវិបត្តិនៃគំរោងនេះ បានលើកឡើងរួចហើយក្នុងការសិក្សាមុនៗ (e.g. Middleton 2008a; Rutherford et al. 2008; Malmquist and Sigfridsson 2002) ។ រដ្ឋាភិបាលតំណាងដោយ MIME បានពន្យល់ថា ទំនប់កំចាយអាចផ្តល់ថាមពលអគ្គិសនីមានតំលៃថោក និងអាចពន្លឿនដល់ការវិនិយោគ និងការបង្កើតការងារបន្ថែមទៀត ។ អត្ថប្រយោជន៍នៅតំបន់មូលដ្ឋាន រួមមាន ការការពារទឹកជំនន់ និងការកាត់បន្ថយសំពាធលើប្រភពធនធានអុសដែលជួយការពារព្រៃឈើ និងទាក់ទាញភ្ញៀវទេសចរកាន់តែច្រើនឡើង ។ ផលប៉ះពាល់នៃគំរោងទៅលើបរិស្ថានមានតិចតួចបំផុត ព្រោះផ្ទៃដីឧទ្យានជាតិបូគោ ដែលត្រូវក្លាយជាអាងផ្ទុកទឹក មានត្រឹម ២០០០ហិកតា ឬតិចជាង ២% នៃផ្ទៃសរុបរបស់ឧទ្យាននេះ ដែលជាទំហំមួយអាចទទួលយកបាន ធៀបនឹងផលចំណេញដែលទទួលបានពីគំរោងនេះ[៣] ។ ការវាយតម្លៃផលប៉ះពាល់បរិស្ថាន បានបង្ហាញថា ថ្លៃអគ្គិសនី (ប្រហែល ៧០០៛/គីឡូវ៉ាត់ម៉ោង) អាចខ្ពស់ជាងអគ្គិសនីនាំចូលពីប្រទេសវៀតណាម (៦០០-៦៥០៛/គីឡូវ៉ាត់ម៉ោង) ដោយសារការសាងសង់មានតំលៃខ្ពស់ ប៉ុន្តែនៅទាបច្រើនជាងថ្លៃអគ្គិសនីផលិតដោយម៉ាស៊ីនភ្លើងម៉ាស៊ូតនាពេលបច្ចុប្បន្ន (ប្រហែល ១២០០៛/គីឡូវ៉ាត់ម៉ោង) ។ សំខាន់ជាងនេះទៀត កម្ពុជានឹងដំណើរការរោងចក្រអគ្គិសនីដោយខ្លួនឯង ជាជាងពឹងផ្អែកលើប្រទេសជិតខាង ។ ផ្ទុយទៅវិញ ក្រុមអង្គការសង្គមស៊ីវិលលើកឡើងថា ការបាត់បង់ ២% នៃផ្ទៃដីឧទ្យានជាតិជាបញ្ហាសំខាន់ ពីព្រោះវានាំឱ្យមានការបាត់បង់ជីវៈចំរុះព្រៃឈើ ជំរកសត្វព្រៃ និងតំបន់ការពារធម្មជាតិ[៤] ។ ការសិក្សាមួយរបស់ Middleton (2008a) បានបង្ហាញថា នៅកន្លែងអាងស្តុកទឹកកំចាយ មានថនិកសត្វ

---

៣ ដោយមានជំនួយពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ នៃប្រទេសកាណាដានោះ ក្រុមហ៊ុនរបស់កាណាដា Hydro-Quebec, Pomerleau International nig Experco International បានប៉ាន់ស្មានថា ទំនប់នេះ អាចរកចំណូលបាន ៥៥លានដុល្លារ/ឆ្នាំ ពីការលក់ចរន្តអគ្គិសនី ។

៤ ឧទ្យានជាតិបូគោ ត្រូវបានបញ្ចូលជាតំបន់ការពារធម្មជាតិ ដូចចែងក្នុងរាជក្រឹត្យលេខ ១២៦ ចុះពីថ្ងៃទី ១ វិច្ឆិកា ១៩៩៣ ស្តីពី "ការបង្កើត និងកំណត់តំបន់តំបន់ការពារធម្មជាតិ" ។

៣១ប្រភេទ និងប្រភេទសត្វស្ទើរផុតពូជចំនួន ១០ប្រភេទ (ដូចជា ដំរីអាស៊ី ខ្លាឃ្មុំ ខ្លារខិន ខ្លាដំបង) ដែលត្រូវបានកត់ត្រាក្នុងបញ្ជីក្រហម នៃប្រភេទសត្វកំពុងរងការគំរាមកំហែង របស់អង្គការសហគមន៍អន្តរជាតិអភិរក្សធម្មជាតិ ។ តំបន់នេះ ក៏ជាប្រភពអនុផលព្រៃឈើដ៏សំខាន់ដែរសំរាប់ប្រជាជនមូលដ្ឋាន ដែលភាគច្រើនពឹងផ្អែកលើប្រាក់ចំណូលបានពីការលក់អនុផលទាំងនោះ ។ លើសពីនេះទៀត មុនពេលផ្ទេរមកឱ្យរដ្ឋាភិបាលកម្ពុជា ទំនប់ទឹកនេះ នឹងត្រូវកាន់កាប់ និងដំណើរការដោយសហគ្រាសរដ្ឋរបស់ចិនមួយឈ្មោះ Sinohydro Corporation ក្នុងរយៈពេល ៤៤ឆ្នាំ មិនមែន ២៥-៣០ឆ្នាំ ដូចធម្មតានោះឡើយ ។

Rutherford et al. (2008) បានដាស់ស្មារតីថា ការអភិវឌ្ឍវារីអគ្គិសនី អាចធ្វើឱ្យប្រជាជនកម្ពុជារាប់ពាន់នាក់ត្រូវផ្លាស់កន្លែងរស់នៅ និងអាចប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន ប្រសិនបើមិនមានកិច្ចប្រឹងប្រែងធ្វើការវាយតម្លៃ និងដោះស្រាយផលប៉ះពាល់ខាងបរិស្ថាន និងសង្គម ដោយមានការពិគ្រោះគ្នាជាមួយសាធារណជនទេនោះ ។

ការសិក្សាមួយដឹកនាំដោយ McDonald et al. (2008) បានបញ្ជាក់ច្បាស់ថា ការពង្រីកឧស្សាហកម្មទំនប់វារីអគ្គិសនីរបស់ប្រទេសចិន បណ្តាលជាចំបងមកពី (១) កំណើនតំរូវការធនធាននៃប្រទេសចិន (២) កំណែទំរង់ និងការពង្រីកឧស្សាហកម្មវារីអគ្គិសនីក្នុងស្រុករបស់ចិន និង (៣) យុទ្ធសាស្ត្រ "ឆ្ពោះទៅក្រៅ" ដែលបានចាប់ផ្តើមក្នុងឆ្នាំ២០០១ ។ ដើម្បីឆ្លើយតបនឹងតំរូវការថ្មីៗ ចិនបានជ្រើសអនុវត្តយុទ្ធសាស្ត្រការប្រើប្រាស់ធនធានស្រទាប់រ៉ែ ដែលមិនទាន់បានធ្វើអាជីវកម្មនៅឡើយ ដោយសារប្រទេសផ្សេងៗប្រហែលគិតថា រ៉ែទាំងនោះមិនសូវសំខាន់ យោងតាមទំហំស្រទាប់រ៉ែ ទីតាំងភូមិសាស្ត្រដាច់ស្រយាល ឬហានិភ័យខាងនយោបាយ ។ ម្យ៉ាងទៀត រដ្ឋាភិបាលចិនបានជួយទ្រទ្រង់ប្រទេសអាហ្វ្រិក ទាំងផ្នែកសេដ្ឋកិច្ច និងនយោបាយ ដោយពុំមានលក្ខខណ្ឌអ្វីឡើយ ចាប់តាំងពីទសវត្សរ៍១៩៦០ ហើយជាលទ្ធផល ចិនក៏ទទួលបានការគាំទ្រពីរដ្ឋាភិបាលអាហ្វ្រិកជាច្រើន សំរាប់តំណែងនៅក្នុងស្ថាប័នផ្សេងៗនៃអង្គការសហប្រជាជាតិ ។ McDonald et al. (2008) បានគូសបញ្ជាក់ដែរថា មានការព្រួយបារម្ភមួយចំនួន អំពីផលប៉ះពាល់អវិជ្ជមានជាយថាហេតុ នៃការពង្រីកក្រុមហ៊ុនចិនក្នុងទីផ្សារទំនប់ទឹកនៅប្រទេសដទៃ ដូចជា (១) ឧស្សាហកម្មទំនប់ទឹក ចិនមិនទាន់បង្ហាញថា អាចទទួលខុសត្រូវបានល្អខាងបញ្ហាបរិស្ថាន និងសង្គមនៅក្នុងប្រទេសខ្លួនទេ ដូច្នេះសមត្ថភាពទទួលខុសត្រូវនៅឯបរទេសនោះ រឹតតែត្រូវចោទសួរថែមទៀត (២) យុទ្ធសាស្ត្រគន្លឹះរបស់វិនិយោគិនចិន គឺប្រែក្លាយធនធានដែលមិនអាចចូលទៅដល់ពីមុននោះឱ្យទៅជាធនធានអាចចូលទៅដល់ និងយកមកប្រើប្រាស់បាន និង (៣) វិនិយោគិនចិនចំបងៗ អ្នកផ្តល់ហិរញ្ញប្បទាន និងអ្នកផ្គត់ផ្គង់សម្ភារៈនានា សំរាប់ការអភិវឌ្ឍទំនប់ទឹកនៅឯបរទេស មិនទាន់មានគោលនយោបាយច្បាស់លាស់ខាងបរិស្ថាន ឬសិទ្ធិមនុស្សនៅឡើយទេ ហើយក៏មិនទាន់មានបង្កើតជាគោលនយោបាយផ្សេងៗ ឱ្យត្រឹមត្រូវតាមស្តង់ដារអន្តរជាតិឡើយ ។

## ៧.៧. សន្និដ្ឋាន

អត្ថបទនេះ ពិនិត្យពីកត្តាដែលអាចជះឥទ្ធិពលដល់លំហូរ FDI ចិន ចូលមកកម្ពុជា ។ លទ្ធផលនៃការសិក្សានេះ បានមកពីការប្រមូលព័ត៌មាន ដូចជា ការសិក្សាលើឯកសារពាក់ព័ន្ធផ្សេងៗ សម្ភាសន៍ពាក់កណ្តាលរៀបរយ ជាមួយអ្នកផ្តល់ព័ត៌មាន ដូចជា មន្ត្រីរាជការតាមខេត្ត អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ និងសម្ភាសន៍មានបញ្ជីសំនួររៀបរយ ជាមួយនឹងម្ចាស់ ឬអគ្គនាយកនៃក្រុមហ៊ុនចិននានា ។

ការសិក្សាបានផ្តល់លទ្ធផលសំខាន់ៗជាច្រើន ជាពិសេស កំណើន FDI របស់ចិន ប្រែប្រួលតាមវិស័យដែលបានជ្រើសរើស សំរាប់ធ្វើការសិក្សា ។ លក្ខខណ្ឌអនុគ្រោះបំផុតខាងពាណិជ្ជកម្ម និងលក្ខខណ្ឌនៃប្រព័ន្ធអនុគ្រោះទូទៅ ដែលទទួលបានពីសហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងប្រទេសអភិវឌ្ឍន៍ដទៃទៀត ព្រមទាំងលទ្ធភាពទទួលបានអត្រាចំណេញជាមធ្យមកំរិតខ្ពស់នោះ មានផលប៉ះពាល់វិជ្ជមាន ទៅលើវិនិយោគរបស់ចិនក្នុងវិស័យកាត់ដេរនៅកម្ពុជា ។ តំរូវការក្នុងស្រុកខ្ពស់របស់ចិន នូវធនធានធម្មជាតិ ដូចជា ក្រដាស និងកៅស៊ូ ជាដើម ព្រមទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ចិន និងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មរបស់រដ្ឋាភិបាលកម្ពុជា បានជះឥទ្ធិពលវិជ្ជមានលើកំរិតនៃការវិនិយោគរបស់ចិន ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មរបស់កម្ពុជា ។

ស្ថានភាពក្នុងវិស័យវារីអគ្គិសនី វាខុសគ្នាខ្លះពីវិស័យកាត់ដេរ ដោយការគាំទ្រខាងនយោបាយក្នុងកំរិតខ្ពស់ពីសំណាក់ថ្នាក់ដឹកនាំចិន និងកម្ពុជា ទំនងបានរួមចំណែកដល់កំណើនចំនួនក្រុមហ៊ុនចិន ។ គេជឿថា ក្រុមហ៊ុនចិននឹងបង្កើនលទ្ធភាពទទួលបានធនធានធម្មជាតិដទៃទៀត ដូចជា រ៉ែ ប្រេងកាត ដីកសិកម្ម និងកសិ-ឧស្សាហកម្ម ជាដើម ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចរបស់ខ្លួន ។ លើសពីនេះទៅទៀត ចិនទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋាភិបាលកម្ពុជា លើ "នយោបាយប្រទេសចិនមានតែមួយ" ក៏ដូចជា លើការកសាងទំនប់នៅខ្សែទឹកខាងលើនៃទន្លេមេគង្គ ។

លំហូរ FDI ចិន ទៅក្នុងឧស្សាហកម្មកាត់ដេរ ទំនងជះឥទ្ធិពលច្រើនដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមតាមរយៈពាណិជ្ជកម្មអន្តរជាតិ និងការកាត់បន្ថយភាពក្រីក្រ ។ ផលប៉ះពាល់នៃ FDI របស់ចិន ក្នុងវិស័យកសិកម្ម កសិ-ឧស្សាហកម្ម អាជីវកម្មរ៉ែ ប្រេងកាត និងឧស្ម័ន ពិបាកធ្វើការសន្និដ្ឋានជាទូទៅណាស់ ប៉ុន្តែ FDI របស់ចិនក្នុងវិស័យវារីអគ្គិសនី ពិតជាធ្វើឱ្យអន្តរាយដល់ប្រព័ន្ធបរិស្ថាននៅតំបន់មូលដ្ឋាន ដែលជាប្រភពផ្គត់ផ្គង់ធនធានធម្មជាតិច្រើនបែបយ៉ាងដល់សហគមន៍មូលដ្ឋាន សំរាប់ប្រើជាទំនិញលក់ដូរ និងជាប្រព័ន្ធសុវត្ថិភាពទប់ទល់នឹងការប៉ះទង្គិចធម្មតា និងមិនធម្មតានានា ។ លក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើសក្រុមហ៊ុន ដែលមកធ្វើវិនិយោគលើវិស័យផ្សេងៗក្នុងប្រទេសកម្ពុជា ដូចជា កសិកម្ម កសិ-ឧស្សាហកម្ម អាជីវកម្មរ៉ែ ប្រេងកាត ឧស្ម័ន និងវារីអគ្គិសនី ជាដើម មានលក្ខណៈមិនច្បាស់លាស់ទេ ។ម្យ៉ាងវិញទៀត ព័ត៌មានលំអិតស្តីពីស្ថានភាពគំរោង និងកិច្ចសន្យារវាងរដ្ឋាភិបាល និងម្ចាស់គំរោង ក៏មិនឃើញមានបង្ហាញដល់សាធារណជនដែរ ។ កង្វះតម្លាភាពនេះ អាចនាំឱ្យមានសកម្មភាពអភិវឌ្ឍន៍អន់ខ្សោយ និងអំពើពុករលួយ ។

**ជាវិធានការខាងគោលនយោបាយ រដ្ឋាភិបាលកម្ពុជាគួរៈ**

- បង្កើនកិច្ចប្រឹងប្រែងកែលំអស្ថាប័ននានា ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធច្បាប់របស់ខ្លួន តាមរយៈការលុបបំបាត់របាំងផ្នែករដ្ឋបាលផ្សេងៗ ដែលអាចជះឥទ្ធិពលអវិជ្ជមានទៅលើលំហូរចូល FDI និងការកាត់បន្ថយភាពក្រីក្រ ។
- ក្នុងការអនុមតិគំរោងត្រូវអនុវត្តពេញលេញតាមលក្ខណៈវិនិច្ឆ័យមានតម្លាភាពដើម្បីកំណត់ភាពមានសិទ្ធិរបស់ក្រុមហ៊ុន និងធ្វើការដេញថ្លៃ ។
- ផ្សព្វផ្សាយជាសាធារណៈ នូវផ្នែកអពាណិជ្ជនៃកិច្ចព្រមព្រៀងផ្ដល់សម្បទាន និងកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី និង
- ធានាថា ការសាងសង់ទំនប់ ពិតជាផ្ដល់ការរីកចំរើនដល់ប្រជាពលរដ្ឋ ទាំងខាងសេដ្ឋកិច្ច សមធម៌សង្គម និងចីរភាពបរិស្ថាន ។

រដ្ឋាភិបាលចិន គួរតម្រូវឱ្យក្រុមហ៊ុនចិននានា ធ្វើប្រតិបត្តិការនៅក្រៅប្រទេសប្រកបដោយទំនួលខុសត្រូវ និងគោរពតាមគោលការណ៍ណែនាំ ដែលកំណត់ឡើងដោយអង្គការអន្តរជាតិ ដូចជា អង្គការសារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (International Finance Corporation) វិទ្យាស្ថានបរិស្ថានពិភពលោក (Global Environmental Institute) និងគណៈកម្មការពិភពលោកខាងទំនប់ (World Commission on Dams) ជាដើម ដើម្បីដាក់បញ្ចូលនូវការគិតគូរពីបញ្ហាបរិស្ថាន និងសង្គមទៅក្នុងគំរោងហិរញ្ញប្បទាន ។

# ជំពូក ៨
# សេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម និង កំណើន នៅក្នុងប្រទេសកម្ពុជាៈ ករណីសិក្សាក្នុងវិស័យ ទូរគមនាគមន៍ និង ហិរញ្ញវត្ថុ[១]

*ដោយលោក សាំង ច័ន្ទហង្ស*

## ៨.១. សេចក្តីផ្តើម

នៅទសវត្សរ៍១៩៨០ កម្ពុជា គឺជាប្រទេសសេដ្ឋកិច្ចកសិកម្ម ដែលអនុវត្តប្រព័ន្ធសេដ្ឋកិច្ចមានផែនការប្រមូលផ្តុំ និងមានសកម្មភាពពាណិជ្ជកម្មអន្តរជាតិតិចតួច ទោះបីជាមានអតិរេកផលិតផលកសិកម្ម ជាពិសេសស្រូវក៏ដោយ ។ សេរីភាវូបនីយកម្មឈានទៅអនុវត្តរបបសេដ្ឋកិច្ចទីផ្សារ បានចាប់ផ្តើមនៅចុងទសវត្សរ៍១៩៨០ ។ សិទ្ធិគ្រប់គ្រងពាណិជ្ជកម្មផ្តាច់មុខរបស់រដ្ឋ បានបញ្ចប់នៅឆ្នាំ១៩៨៧ ហើយនៅឆ្នាំ១៩៨៩ មានការប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគជាលើកដំបូងបំផុត ដោយអនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជន ។ ក្នុងទសវត្សរ៍១៩៩០ រដ្ឋបានបើកចំហទីផ្សារកាន់តែធំទូលាយឡើង ដោយធ្វើឯកជននីយកម្មលើសហគ្រាសអាជីវកម្មរបស់រដ្ឋ និងអនុញ្ញាតឱ្យវិនិយោគិនបរទេស និងឯកជន ចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មអន្តរជាតិ ។

ដោយបានទទួលស្គាល់ពីតួនាទីដ៏សំខាន់បំផុត នៃពាណិជ្ជកម្មទំនិញ និងសេវាកម្ម ក្នុងលក្ខណៈជាក្បាលម៉ាស៊ីននៃកំណើន និងជាយន្តការសំរាប់ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ នៅពាក់កណ្តាលទសវត្សរ៍១៩៩០ រដ្ឋាភិបាល បានធ្វើកំណែទំរង់កាន់តែស៊ីជំរៅ និងគ្រប់ជ្រុងជ្រោយថែមទៀត លើសេដ្ឋកិច្ច និងពាណិជ្ជកម្ម និងប្រឹងប្រែងធ្វើសមាហរណកម្មនៅក្នុងតំបន់ និងសាកលលោក ហើយសភាជាតិ ក៏បានអនុម័តច្បាប់ និងបទបញ្ញត្តិជាច្រើន ដើម្បីជួយពន្លឿនដំណើរការនេះ ។ គួបផ្សំនឹងការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការធ្វើកំណែទម្រង់ និងការបើកចំហទីផ្សាររបស់ខ្លួនផង កម្ពុជាក៏បានក្លាយជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) ក្នុងឆ្នាំ១៩៩៨ និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងឆ្នាំ ២០០៤។ ក្នុងលក្ខណៈជាប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន កម្ពុជា គឺជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសនៅមហាអនុតំបន់មេគង្គ ដែលមានគោលដៅពង្រឹងកិច្ចសហប្រតិបត្តិការ ខាងវិនិយោគ និងពាណិជ្ជកម្មក្នុងតំបន់ ។

ចាប់តាំងពីការដាក់អនុវត្តគោលនយោបាយសេដ្ឋកិច្ចបើកចំហមក ពាណិជ្ជកម្មរបស់កម្ពុជា បានរីកដុះដាលយ៉ាងខ្លាំង ។ ការបើកចំហ (ដែលគិតជាចំណែកនៃពាណិជ្ជកម្មនៅក្នុង ផសស) មានកំរិតខ្ពស់ណាស់ គឺលើសពី

១ អត្ថបទនេះ រៀបចំដោយ លោក សាំង ច័ន្ទហង្ស ជាអ្នកស្រាវជ្រាវ ដោយមានជំនួយការងារពី កញ្ញា ផាន់ ដាលីស ជំនួយការស្រាវជ្រាវ របស់វិទ្យាស្ថាន CDRI ។

១00% ក្នុងទសវត្សរ៍កន្លងទៅនេះ ។ ដើម្បីទទួលបានលទ្ធភាពចូលទៅកាន់ទីផ្សារ ដែលមានលក្ខខណ្ឌអនុគ្រោះ រដ្ឋាភិបាលបានប្តេជ្ញាចិត្ត ធ្វើសេរីភាវូបនីយកម្មទីផ្សាររបស់ខ្លួនសំរាប់សេវាកម្ម ពីព្រោះសេវាកម្មភាគច្រើន តែងមានបង្កប់នៅក្នុងពាណិជ្ជកម្មផលិតផល ។ ពាណិជ្ជកម្មអន្តរជាតិ តម្រូវឱ្យមានសេវាកម្មផ្សេងៗ ដូចជា ការដឹកជញ្ជូន អន្តរការីកម្មហិរញ្ញវត្ថុ ព័ត៌មាននិងទំនាក់ទំនង និងសេវាចែកចាយ ។ ដូច្នេះ ការពង្រីកពាណិជ្ជកម្មផលិតផល អាចជំរុញឡើងបាន ដោយការផ្តល់សេវាមានគុណភាពខ្ពស់ និងតំលៃថោក ។ Markusen et al. (2005) បានបញ្ជាក់នៅក្នុងការសិក្សារបស់គាត់ថា វិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យសេវាកម្ម អាចជួយដល់ប្រទេសដែលទទួលទុនឱ្យអាចផលិត និងនាំចេញផលិតផលមានគុណភាពកាន់តែល្អ ។ ដូចគ្នាដែរ Fink et al. (2005) បានបង្ហាញថា ចំណាយលើទំនាក់ទំនងអន្តរជាតិ គឺជាកត្តាកំណត់លើប្រតិបត្តិការនាំចេញ រីឯ Beck (2002) បានរកឃើញនូវទំនាក់ទំនងជាវិជ្ជមានរវាង សេដ្ឋកិច្ចហើយនិងប្រព័ន្ធហិរញ្ញវត្ថុមានការវិវត្តល្អ និងឧស្សាហកម្មផលិតកម្មផ្តោតទៅលើការនាំចេញ ។ Francois and Wooton (2006) បង្ហាញថា អវត្តមាននៃការប្រកួតប្រជែងនៅក្នុងសេវាកម្មក្នុងស្រុក អាចជាឧបសគ្គដល់ការនាំចូល ដូច្នេះ សេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម អាចជំរុញដល់ពាណិជ្ជកម្មទំនិញ ។

ក្រៅពីគោលបំណងជំរុញពាណិជ្ជកម្មទំនិញ តាមរយៈការបើកចំហផ្នែកសេវាកម្ម រដ្ឋាភិបាលក៏មានបំណងកែលំអសេវាអាជីវកម្មផងដែរ ដើម្បីធ្វើឱ្យបរិយាកាសវិនិយោគមានលក្ខណៈល្អប្រសើរឡើង និងជួយប្រជាជនកម្ពុជាក្នុងការអភិវឌ្ឍជំនាញ ដែលមានតំរូវការក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ហើយរឿងនេះ នឹងជួយដល់ការបង្កើនគុណភាពសេវាថែទាំសុខភាព និងសេវារំដោះទឹកលូ/សំរាម និងសេវាអនាម័យ (Sok 2005: 51) ។ ក្នុងឋានៈជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) កម្ពុជា ត្រូវបំពេញតាមការសន្យាខាងសេវាកម្មរបស់ខ្លួនជាពិសេស លទ្ធភាពចូលទៅកាន់ទីផ្សារ និងការចាត់ចែងនៅក្នុងប្រទេស ដូចមានចែងនៅក្នុងបទបញ្ញត្តិនៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មខាងសេវាកម្ម (General Agreement on Trade in Services—GATS) ។ ការសន្យាខាងសេវាកម្ម មាន ១៩ ប្រភេទ ហើយកម្ពុជាបានបែងចែកវាទៅជា ៧៩ អនុប្រភេទ នៅក្នុងកាលវិភាគរបស់ខ្លួន ។ ការសន្យារបស់រដ្ឋាភិបាល ក្នុងការលុបបំបាត់ការដាក់កំហិតលើពាណិជ្ជកម្មសេវាកម្ម មានលក្ខណៈខុសគ្នាទៅតាមអនុប្រភេទនីមួយៗ: អនុប្រភេទខ្លះមានលក្ខណៈពេញលេញ ខ្លះទៀតមិនទាន់ពេញលេញ រីឯខ្លះទៀតស្ថិតក្នុងអន្តរកាល ។ កម្ពុជាក៏ត្រូវគោរពទៅតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម[២] ដែលតម្រូវឱ្យប្រទេសជាសមាជិក ធ្វើសេរីភាវូបនីយកម្មទីផ្សាររបស់ខ្លួន និងធានាមិនឱ្យមានការរើសអើង រវាងអ្នកផ្គត់ផ្គង់សេវាកម្មក្នុងតំបន់អាស៊ានដូចគ្នា ។ ការសន្យា មាន ៦ កញ្ចប់ធំៗ ដែលមានលក្ខណៈស្របគ្នានឹងវិធាននៃ WTO-GATS ។

ក្នុងមួយទសវត្សរ៍កន្លងទៅ សេដ្ឋកិច្ចកម្ពុជាមានដំណើរការល្អគួរឱ្យកោតសរសើរ ដោយមានអត្រាកំណើនជាមធ្យមខ្ពស់ដល់ ៩% ដែលទទួលបានពីប្រតិបត្តិការល្អប្រសើរក្នុងវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ ។

---

២ កិច្ចព្រមព្រៀងនេះ បានធ្វើឡើងនៅឆ្នាំ១៩៩៥ និងធ្វើវិសោធនកម្មនៅឆ្នាំ២00៣ ដើម្បីពន្លឿនសេរីភាវូបនីយកម្ម ដោយអនុញ្ញាតឱ្យមានការប្រើរូបមន្ត "អាស៊ាន ដក X" ដែលក្នុងនេះ បណ្តាប្រទេសដែលបានត្រៀមរួចស្រេច ដើម្បីធ្វើសេរីភាវូបនីយកម្មនូវសេវាកម្មជាក់លាក់ណាមួយ គឺអាចចាប់ដំណើរបាន ដោយមិនចាំបាច់ផ្តល់សម្បទានទៅដល់ប្រទេសដែលមិនបានចូលរួមនោះទេ ។

ការលូតលាស់ដ៏ល្អប្រសើរនេះ ទំនងជាលទ្ធផលនៃការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងការបើកចំហសេដ្ឋកិច្ច ។ ការសិក្សាមួយចំនួន (Francois 1990 and Mattoo et al. 2006) បានរំលេចថា សេរីភាវូបនីយកម្មសេវា និងទំនិញ គឺជាគន្លឹះនៃការអភិវឌ្ឍសេដ្ឋកិច្ច ។

អត្ថបទនេះ មិនមែនសំដៅកំណត់នូវបរិមាណឥទ្ធិពលជាវិជ្ជមាន នៃសេរីភាវូបនីយកម្មសេវាទូរគមនាគមន៍ និងហិរញ្ញវត្ថុ (ផ្តោតទៅលើផ្នែកធនាគារ និងធានារ៉ាប់រង) លើកំណើនសេដ្ឋកិច្ចសរុបឡើយ ប៉ុន្តែសំដៅតាមដានមើលថា តើសេរីភាវូបនីយកម្មនៃផ្នែកទាំងនោះសំរេចបានក៏រិតណា ហើយវាពាក់ព័ន្ធទៅនឹងកំណើនសេដ្ឋកិច្ចយ៉ាងដូចម្តេច ។ ក្នុងផ្នែកទី២ មានការពិភាក្សាពីរចនាសម្ព័ន្ធឧស្សាហកម្ម ។ ផ្នែកទី៣ អធិប្បាយពីរបបច្បាប់/បទបញ្ញត្តិ និងលទ្ធផលតាមវិស័យ ។ ផ្នែកទី៤ ផ្តល់ការវាយតម្លៃជារួមពីភាពបើកចំហតាមវិស័យ ដោយប្រើប្រាស់សន្ទស្សន៍នៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម ។ ផ្នែកទី៥ បង្ហាញពីឱកាស និងតំរូវការធ្វើសេរីភាវូបនីយកម្ម ដោយផ្អែកតាមលទ្ធផលអង្កេត លើការយល់ឃើញរបស់អ្នកគ្រប់គ្រងអាជីវកម្ម ។ ផ្នែកចុងក្រោយ គឺជាការសន្និដ្ឋាន និងការផ្តល់អនុសាសន៍ខាងគោលនយោបាយ ។

## ៨.២. ការអភិវឌ្ឍផ្នែកទូរគមនាគមន៍ និងហិរញ្ញវត្ថុ

**វិស័យទូរគមនាគមន៍:** វិស័យនេះ រួមមានប្រតិបត្តិករ ៣ក្រុម សំខាន់ៗគឺ: ទូរស័ព្ទអចល័ត ទូរស័ព្ទចល័ត និងអ៊ីនធឺណិត ។ វិស័យនេះ បានរីកលូតលាស់គួរឱ្យកត់សំគាល់ក្នុង ៥ឆ្នាំចុងក្រោយនេះ ទោះបីជាប្រព័ន្ធទូរស័ព្ទអចល័តបានរីកលូតលាស់យឺតក្តី ។ នៅដើមឆ្នាំ២០០៨ មាន ៣ប្រតិបត្តិករទូរស័ព្ទអចល័ត ៥ប្រតិបត្តិករទូរស័ព្ទចល័ត និងអ្នកផ្តល់សេវាអ៊ីនធឺណិត (ISPs) ៩ក្រុមហ៊ុន ។ តាំងពីដើមទសវត្សរ៍១៩៩០ ដល់ ឆ្នាំ២០០៦ សេវាទូរស័ព្ទអចល័ត ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MPTC) ហើយបន្ទាប់មកក៏មានក្រុមហ៊ុនឯកជនមួយឈ្មោះថា Telecom Cambodia បានបើកដំណើរការលើវិស័យនេះ ។ ក្រោយពីនោះ មានប្រតិបត្តិករ ២ ផ្សេងទៀត គឺ Camintel[៣] និង Camshin ដែលផ្តល់សេវាទូរស័ព្ទអចល័តគ្មានខ្សែ (wireless loop line—WLL) ។ សេវាទូរស័ព្ទចល័ត បានកើតមានឡើងនៅឆ្នាំ១៩៩២ បន្ទាប់ពីការបើកចំហវិស័យនេះដល់វិនិយោគិនឯកជន ។ នៅដើមទសវត្សរ៍២០០០ ប្រតិបត្តិករប្រព័ន្ធទូរស័ព្ទចល័តមាន ៣ គឺ CamGSM, Telekom Malaysia[៤] និង Camshin ។ ក្នុងពីរបីឆ្នាំចុងក្រោយនេះ វិស័យទូរស័ព្ទចល័ត បានរីកលូតលាស់យ៉ាងឆាប់រហ័ស ដោយមានការដាក់ឱ្យប្រើនូវផលិតផលថ្មីៗជាច្រើនទៀត ។ នៅឆ្នាំ២០០៧ មានប្រតិបត្តិករថ្មីចំនួន ២ បានឈានចូលទីផ្សារ ហើយនៅឆ្នាំ២០០៨ មានប្រតិបត្តិករថ្មីមួយទៀត បានចូលមកផ្តល់សេវា ។ នៅដើមឆ្នាំ២០០៨ អ្នកប្រើប្រាស់ទូរស័ព្ទចល័ត មានសរុប ២.៨៨៥.៦៦៩នាក់ ក្នុងនេះ ៦៩% ប្រើប្រាស់បណ្តាញរបស់ក្រុមហ៊ុន CamGSM/MobiTel (MPTC 2008) ។ ពាណិជ្ជកម្មសេវាអ៊ីនធឺណិត បានចាប់ផ្តើមនៅឆ្នាំ១៩៩៧ ហើយពីដំបូង

៣ Camintel ពីមុនជាក្រុមហ៊ុនសហកម្មសិទ្ធិរវាង MPTC និង PT Indosat របស់ឥណ្ឌូនេស៊ី ។ នៅខែតុលា ២០០៥ PT Indosat បានលក់ភាគហ៊ុនទាំងអស់របស់ខ្លួន (៤៩%) ទៅឱ្យក្រុមហ៊ុន A-Z (កម្ពុជា) ។

៤ Telekom Malaysia បានចាប់ដំណើរការនៅឆ្នាំ១៩៩២ ក្នុងលក្ខណៈជាក្រុមហ៊ុនសហកម្មសិទ្ធិរវាង Casacom ជាមួយ Samart របស់ថៃ និងក្រុមហ៊ុន MPTC (៣០%) ។ បន្ទាប់មក Casacom បានទទួលគ្រប់គ្រងទាំងស្រុង ហើយបានប្តូរឈ្មោះក្រុមហ៊ុនទៅជា Hello GSM ។

មានក្រុមហ៊ុនឈានមុខ ៣ គឺ Bigpond (online), Camnet និង Telesurf ។ ទោះបីមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត និងកំណើនអ្នកផ្តល់សេវានេះរហូតដល់ ១២ ក្រុមហ៊ុនក្តី ក៏ថ្លៃសេវាអ៊ីនធឺណិតនៅតែខ្ពស់នៅឡើយ (ទោះបីជាបានធ្លាក់ចុះជាបណ្តើរៗក្នុងទសវត្សរ៍កន្លងទៅនេះក្តី)[៥] ។ ប្រជាជនកម្ពុជា ភាគច្រើនមានលទ្ធភាពប្រើប្រាស់ត្រឹមតែបណ្តាញអ៊ីនធឺណិត ដែលមានល្បឿនយឺតៗជាងគេប៉ុណ្ណោះ ។ នៅដើមឆ្នាំ២០០៨ អ្នកប្រើប្រាស់សេវាអ៊ីនធឺណិត មានសរុប ១៥.៩៥០នាក់ ក្នុងនេះ ៧៥០០នាក់ ប្រើសេវា dial-up service និង ៨៤៥០នាក់ ប្រើសេវា broadband ។ ដោយសារការតភ្ជាប់បណ្តាញមានថ្លៃខ្ពស់ ប្រជាជនកម្ពុជាភាគច្រើនតែងទៅប្រើសេវាអ៊ីនធឺណិតនៅតាមហាងអ៊ីនធឺណិត ដែលយកថ្លៃសេវាទាបជាង ។ នាបច្ចុប្បន្ន នៅកម្ពុជាមានហាងអ៊ីនធឺណិតប្រហែល ២៦៦កន្លែង (MPTC 2008) ។

**វិស័យហិរញ្ញវត្ថុ:** វិស័យនេះបានបើកចំហនៅដើមទសវត្សរ៍១៩៩០ ដោយមានការផ្លាស់ប្តូរពីប្រព័ន្ធមានមួយថ្នាក់ មកជាប្រព័ន្ធមានពីរថ្នាក់ (two-tier banking system) ដែលកំពុងដំណើរការនាពេលបច្ចុប្បន្ន ។ រហូតមកទល់ពេលនេះ វិស័យហិរញ្ញវត្ថុរបស់កម្ពុជា ស្ថិតក្រោមការគ្រប់ដណ្តប់របស់ធនាគារផ្សេងៗ ហើយធនាគារជាតិនៃកម្ពុជា (NBC) ដើរតួជានិយតករនៃវិស័យនេះ ។ ដើមឡើយ វិនិយោគឯកជន ត្រូវបានអនុញ្ញាតឱ្យដំណើរការក្នុងទំរង់ជាធនាគារសហកម្មសិទ្ធជាមួយរដ្ឋ ។ នៅឆ្នាំ១៩៩៣ មានការបង្កើតឡើងនូវធនាគារសហកម្មសិទ្ធិ ៣ ដែលត្រូវបានធ្វើឯកជនភាវូបនីយកម្មពេញលេញនៅឆ្នាំ១៩៩៧ ។ ធនាគារពាណិជ្ជកម្មក្រៅប្រទេស (Foreign Trade Bank) ត្រូវបានឯកជនភាវូបនីយកម្មពេញលេញនៅឆ្នាំ២០០៥ ។ មកដល់ឆ្នាំ២០០០ មានស្ថាប័នធនាគារចំនួន ៣១ បើកដំណើរការ ដោយមានអាជ្ញាប័ណ្ណត្រឹមត្រូវ ហើយស្ថាប័នទាំងនោះ ភាគច្រើនត្រូវបានបង្កើតឡើងក្នុងបំណងផ្តល់ហិរញ្ញប្បទានដល់ក្រុមហ៊ុនតែមួយគត់ (IFC 2007:3) ។ នៅដើមឆ្នាំ២០០៨ មានធនាគារពាណិជ្ជចំនួន ១៧ ធនាគារជំនាញ ៧ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ១៧ បានដំណើរការនៅកម្ពុជា ។ វិស័យធានារ៉ាប់រងរបស់កម្ពុជាបានចាប់ផ្តើមនៅឆ្នាំ១៩៩២ បន្ទាប់ពីច្បាប់ស្តីពីការបង្កើតអាជីវកម្មធានារ៉ាប់រងត្រូវបានអនុម័ត ។ ក្រុមហ៊ុនធានារ៉ាប់រងរបស់រដ្ឋ ឈ្មោះ Caminco ត្រូវបានបង្កើតឡើងជានិយតករ ប្រតិបត្តិករ និងជាអ្នកធានារ៉ាប់រងបន្ត ហើយបន្ទាប់មកមានក្រុមហ៊ុនឯកជន ៣ ទៀត ត្រូវបានបង្កើតឡើង ដោយដើរតួជាភ្នាក់ងាររបស់ Caminco គឺ ក្រុមហ៊ុនធានារ៉ាប់រងឥណ្ឌូចិន (Indochine Insurance)[៦] (១៩៩៤) ក្រុមហ៊ុនធានារ៉ាប់រងអាស៊ី (Asia Insurance) (១៩៩៥) និងក្រុមហ៊ុនធានារ៉ាប់រងហ្វ័រតេ (Forte Insurance) (១៩៩៦) ។ នៅឆ្នាំ២០០០ ច្បាប់ស្តីពីធានារ៉ាប់រងត្រូវបានអនុម័ត ហើយរដ្ឋាភិបាលបានផ្ទេរតួនាទីនិយតកម្មរបស់ក្រុមហ៊ុន Caminco ទៅឱ្យនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ។ នៅខែមករា ឆ្នាំ២០០២ Caminco បានបញ្ឈប់អាជីវកម្ម

---

៥ បច្ចុប្បន្ន AT&T ដែលជាក្រុមហ៊ុន telecom ដ៏ធំមួយរបស់សហរដ្ឋអាមេរិក បានផ្តល់នូវអត្រា download ក្នុងល្បឿន 3 MBPS ក្នុងតំលៃ ៣០ដុល្លារ/ខែ ប៉ុន្តែក្រុមហ៊ុន Wicam គ្រោងនឹងផ្តល់ឱ្យកម្ពុជានូវអត្រា download ក្នុងល្បឿន 2 MBPS ដោយតំលៃ ៧០០០ដុល្លារ/ខែ ។ កាលពីមុន ក្រុមហ៊ុន Camnet បានផ្តល់អត្រា download ក្នុងល្បឿន 1 MBPS ដោយតំលៃ ៦០០០ដុល្លារ/ខែ ហើយចាប់ពីឆ្នាំ ២០០៥ មក ក្រុមហ៊ុននេះ បានបន្ទាបអត្រាតំលៃអ៊ីនធឺណិតមកត្រឹម ២០០០ដុល្លារ/ខែ (Cambodia Daily, ២១ កុម្ភៈ ២០០៨ ទំព័រ 21) ។

៦ ក្រុមហ៊ុននេះ បានបិទទ្វារនៅឆ្នាំ២០០៤ ដោយសារការលំបាកផ្នែកហិរញ្ញវត្ថុក្នុងអំឡុងពេលធ្វើបំលាស់ប្តូរ ដើម្បីទទួលបានអាជ្ញាប័ណ្ណ ។

ធានារ៉ាប់រងបន្តរបស់ខ្លួន ដោយជំនួសដោយក្រុមហ៊ុនធានារ៉ាប់រងបន្តថ្មីគឺ Cambodia Re ហើយក្រោយមកក្រុមហ៊ុនធានារ៉ាប់រងបន្តនេះ បានក្លាយជាក្រុមហ៊ុនសហកម្មសិទ្ធិ ជាមួយក្រុមធានារ៉ាប់រងអាស៊ី (Asia Insurance Group) ដែលកាន់កាប់ភាគហ៊ុន ២០% ។

## ៨.៣. របបច្បាប់គ្រប់គ្រង និងលទ្ធផលតាមវិស័យ

**វិស័យទូរគមនាគមន៍:** វិស័យទូរគមនាគមន៍បានបើកចំហដល់វិនិយោគឯកជននៅឆ្នាំ១៩៩២ ហើយនៅមុនការបើកចំហនេះ មិនមានគោលការណ៍អ្វីណែនាំច្បាស់លាស់អំពីសេរីភាវូបនីយកម្មនេះទេ។ នៅមុនឆ្នាំ២០០៦ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ទទួលបន្ទុករៀបចំគោលនយោបាយ/បទបញ្ញត្តិដោះស្រាយជំលោះ ហើយនិងគ្រប់គ្រងភាគហ៊ុនរបស់រដ្ឋនៅក្នុងអាជីវកម្មរួមទុន ព្រមទាំងកិច្ចសន្យាពាណិជ្ជកម្មជាមួយវិនិយោគិនបរទេស និងឯកជន ក្នុងវិស័យនេះ ។ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាប្រតិបត្តិករចំបងគេ ក្នុងផ្នែកសេវាទូរស័ព្ទអចល័ត ដែលមានកម្មសិទ្ធិលើខ្សែកាបអុបទិកឆ្លងកាត់ប្រទេសកម្ពុជា ដែលតភ្ជាប់ពីប្រទេសថៃ ទៅប្រទេសវៀតណាម ។ ដោយទទួលស្គាល់ពីតំរូវការបែងចែកឱ្យដាច់ នូវតួនាទីអ្នកធ្វើគោលនយោបាយ និងតួនាទីប្រតិបត្តិករ និងដើម្បីផ្តាច់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចេញពីប្រតិបត្តិការអាជីវកម្មនេះ រដ្ឋាភិបាលបានបង្កើតសហគ្រាសសាធារណៈមួយ គឺ ទូរគមនាគមន៍កម្ពុជា (Telecom Cambodia) នៅខែមករា ១៩៨៦ ដើម្បីឱ្យទទួលបន្ទុកលើប្រតិបត្តិការជំនួញជំនួសក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។ នេះជាការងារដ៏សំខាន់របស់រដ្ឋាភិបាល ក្នុងទសវត្សរ៍កន្លងទៅ ។ ប៉ុន្តែ រហូតមកទល់បច្ចុប្បន្ន អាជ្ញាធរទូរគមនាគមន៍ឯករាជ្យ មិនទាន់បានបង្កើតឡើងនៅឡើយទេ ហើយសេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍ ដែលបានរៀបចំស្រេចបាច់តាំងពីឆ្នាំ២០០៥ កំពុងរង់ចាំការអនុម័តពីរដ្ឋសភាជាតិនៅឡើយ ។ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក៏នៅតែដើរតួយ៉ាងសំខាន់ ក្នុងការបង្កើតគោលនយោបាយ និងបទបញ្ញត្តិច្បាប់គ្រប់គ្រងលើវិស័យនេះ ។ ដូច្នេះ និយតករ (គឺក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍) ទំនងជាមិនអាចដំណើរការឱ្យដាច់ស្រឡះ ពីការងារគ្រប់គ្រងប្រតិបត្តិការឡើយ ។ ខណៈដែលមិនទាន់មានច្បាប់ទូរគមនាគមន៍ថ្មី បទបញ្ញត្តិផ្សេងៗ (ដូចជា អនុក្រឹត្យស្តីពីការផ្តល់អាជ្ញាប័ណ្ណបណ្តាញស្តង់ដារ និងអាជ្ញាប័ណ្ណសេវាទូរគមនាគមន៍ បទបញ្ញត្តិស្តីពីកំរិតថ្លៃនិងការហៅឆ្លងប្រព័ន្ធ កាតព្វកិច្ចផ្តល់សេវាជាសាកល និងមូលនិធិសេវាកម្មសាកល ជាដើម) និងគោលនយោបាយប្រកួតប្រជែងក្នុងវិស័យ អាចធ្វើឱ្យបរិយាកាសអាជីវកម្មប្រែប្រួលស្ថានមិនត្រូវ ពីព្រោះគ្មានវិធានអ្វីសោះ សំរាប់គ្រប់គ្រងលើសកម្មភាពរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

ក្នុង ៥ ឆ្នាំចុងក្រោយនេះ វិស័យទូរគមនាគមន៍បានរីកលូតលាស់គួរឱ្យកត់សំគាល់ ដោយសារចំនួនអ្នកប្រើប្រាស់សេវាទូរស័ព្ទចល័ត កើនឡើងយ៉ាងលឿនដល់ ៣៣% ជាមធ្យមក្នុងមួយឆ្នាំ ខណៈដែលសេវាទូរស័ព្ទអចល័ត និងអ៊ីនធឺណិត រីកលូតលាស់យឺតៗត្រឹម ២% និង ៨% ជាមធ្យមក្នុងរយៈពេលប្រាំឆ្នាំនេះ ។ កំណើនតំរូវការតិចតួចនូវសេវាទូរស័ព្ទអចល័ត អាចបណ្តាលពីកង្វះវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធបណ្តាញ ដែលមានតំលៃខ្ពស់ និងកំណើនតំរូវការសេវាទូរស័ព្ទចល័ត ។ ចំនួនអ្នកផ្តល់សេវាអ៊ីនធឺណិតបានកើនឡើងខ្លាំង ដែលនាំឱ្យមានការប្រកួតប្រជែងកាន់តែខ្លាំងក្នុងវិស័យនេះ ។ ប៉ុន្តែ តំរូវការសេវាអ៊ីនធឺណិតនៅថេរដដែល ដោយសារការតភ្ជាប់ និងសេវាប្រចាំខែ នៅតែមានថ្លៃខ្ពស់ ទាំងសំរាប់អ្នកជាវជាអាជីវកម្ម និងជាគ្រួសារឯកជន ។ ចាប់ពី

ខែមីនា ២០០៨ មក ទូរគមនាគមន៍កម្ពុជា ដែលជាអ្នកផ្តល់សេវាទូរស័ព្ទអចល័តចំបងគេ មានចំណែក ៩៤% នៅក្នុងទីផ្សារ ខណៈពេលដែលក្រុមហ៊ុន CamGSM មានចំណែក ៦៩% ក្នុងទីផ្សារសេវាទូរស័ព្ទចល័ត ។

**វិស័យហិរញ្ញវត្ថុៈ** ការបើកចំហវិស័យធនាគារដល់វិនិយោគឯកជននៅដើមទសវត្សរ៍១៩៩០ បាននាំមកនូវបំលាស់ប្តូរយ៉ាងសំខាន់ ជាពិសេស ការប្តូរទៅប្រើប្រាស់ប្រព័ន្ធធនាគារពីរថ្នាក់ ដែលបានដកតួនាទីធនាគារពាណិជ្ជ ចេញពីធនាគារជាតិនៃកម្ពុជា ។ ធនាគារជាតិនៃកម្ពុជា ដើរតួនាទីជានិយតករ ក្នុងវិស័យធនាគារដោយអនុវត្តយ៉ាងខ្ជាប់ខ្ជួនទៅតាមច្បាប់ ស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលរដ្ឋសភាជាតិបានអនុម័តនៅឆ្នាំ១៩៩៦ ។ ធនាគារជាតិនៃកម្ពុជា អះអាងថា ខ្លួនជាអង្គភាពស្វយ័ត ដែលផ្អែកលើចំណូលពីប្រភពសំខាន់ៗពីរ គឺកំរៃលើអាជ្ញាប័ណ្ណ និងអត្រាការប្រាក់ពីបរទេស ។

ក្នុង ៤ ឆ្នាំចុងក្រោយនេះ វិស័យធនាគារជារួម មានស្ថានភាពល្អប្រសើរ ដោយមានអត្រាជាមធ្យម ២% នៃចំណូលលើទ្រព្យសកម្ម (rate of return on assets) និង ១១% នៃចំណូលលើទ្រព្យម្ចាស់ (return on equity) ។ នៅឆ្នាំ ២០០៧ វិនិយោគក្នុងវិស័យនេះ កើនដល់ ៥១៩,៥លានដុល្លារ ធៀបនឹង ២២៤,៤លានដុល្លារកាលពីឆ្នាំ២០០៤ ដែលឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីកំណើនចំនួនធនាគារពាណិជ្ជថ្មីៗ ។ ផលិតផល និងសេវាកម្មថ្មីៗ ដូចជាកាត ATM (ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ) សេវាធនាគារតាមបណ្តាញអ៊ីនធឺណិត ប័ណ្ណឥណទាន ប័ណ្ណឥណពន្ធ ការផ្ទេរប្រាក់តាមទូរលេខ និងសេវាផ្សេងៗទៀត ត្រូវបានបង្កើតឱ្យប្រើប្រាស់ ។ ការចូលមកដល់នៃធនាគារ ANZ ដែលជាក្រុមហ៊ុនសហកម្មសិទ្ធិ នៃធនាគារ Australia-New Zealand និងក្រុមហ៊ុន Cambodia Royal Group បានជំរុញឱ្យធនាគារនានា ដែលកំពុងមានដំណើរការស្រាប់ ខិតខំលើកកំពស់គុណភាព និងបង្កើនសេវាកម្មឱ្យមានលក្ខណៈល្អប្លែកៗពីគ្នា ។ ក្នុងរយៈពេល ៤ ឆ្នាំចុងក្រោយនេះ ចំនួនអ្នកផ្ញើប្រាក់បានកើន ២១៥% ហើយចំនួនអ្នកខ្ចីប្រាក់ កើន ៦០% ស្របពេលដែលប្រាក់បញ្ញើកើនឡើង ៣ដង និងប្រាក់កំចី កើន ៣,៥ដង ។ មួយភាគធំនៃប្រាក់កំចី និងប្រាក់បញ្ញើទាំងនោះ ប្រមូលផ្តុំនៅក្នុងធនាគារឈានមុខចំនួន ៤ ដែលធ្វើឱ្យវិស័យហិរញ្ញវត្ថុមានការពឹងផ្អែកទៅលើការប្រតិបត្តិរបស់ធនាគារទាំង ៤ នោះ ។ នៅខែធ្នូ ២០០៨ ក្នុងចំណោមធនាគារឈានមុខទាំង ៤ ខាងប្រាក់កំចី និងប្រាក់បញ្ញើ ធនាគារ ANZ ទទួលបានចំណូលលើទ្រព្យម្ចាស់ក្នុងកំរិតទាបបំផុតត្រឹម ៤,៨៩% ស្របពេលដែលធនាគារ ៣ ផ្សេងទៀត ទទួលបានប្រាក់ចំណូលនេះ ក្នុងកំរិតខ្ពស់ជាង ANZ ច្រើន ។

សំរាប់វិស័យធានារ៉ាប់រងវិញ ក្នុងទសវត្សរ៍១៩៩០ វិស័យនេះស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុនធានារ៉ាប់រងរបស់រដ្ឋមួយ ឈ្មោះ Caminco ដែលដើរតួផងដែរ ជាប្រតិបត្តិករ និងអ្នកទទួលធានារ៉ាប់រងបន្ត ។ នៅឆ្នាំ២០០០ តួនាទីធ្វើបទបញ្ញត្តិគ្រប់គ្រងរបស់ក្រុមហ៊ុននេះ ត្រូវបានផ្ទេរទៅឱ្យនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ វិស័យនេះ កំពុងស្ថិតក្នុងដំណាក់កាលដំបូងនៃការរីកលូតលាស់វិវត្តន៍ ហើយត្រូវមានកិច្ចប្រឹងប្រែង និងធនធានច្រើនណាស់ ដើម្បីធានានូវការអភិវឌ្ឍប្រកបដោយចីរភាព ។ អង្គភាពធានារ៉ាប់រងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពឹងផ្អែកលើការបែងចែកថវិការបស់រដ្ឋាភិបាល ព្រោះចំណូលបានពីថ្លៃអាជ្ញាប័ណ្ណ និងប្រភពផ្សេងៗទៀត ត្រូវផ្ទេរចូលចំណូលទូទៅ ។ អង្គភាពធានារ៉ាប់រង ទំនងជាមិនអាចដំណើរការដោយឯករាជ្យពីថ្នាក់ដឹកនាំក្រសួងឡើយ ។ នៅពាក់កណ្តាលឆ្នាំ២០០៨ អង្គភាពធានារ៉ាប់រង មានសមាជិក ១០នាក់ និងទទួលបន្ទុកត្រួតពិនិត្យ និងវាយតម្លៃលើ ៥ក្រុមហ៊ុនធានារ៉ាប់រង ដែលកំពុងដំណើរការនាបច្ចុប្បន្ន ។ ចំនួន

បុគ្គលិក និងសមត្ថភាពជំនាញ មិនអាចបំពេញតាមតម្រូវការនៃអង្គភាពដែលធ្វើបទបញ្ញត្តិច្បាប់ឡើយ ។ ដូច្នេះ បុគ្គលិកអង្គភាពធានារ៉ាប់រង ត្រូវទទួលបានជាបន្ទាន់នូវការបណ្តុះបណ្តាលសមត្ថភាព ផ្នែកត្រួតពិនិត្យ និងកសាងគោលនយោបាយ ។

វិស័យធានារ៉ាប់រង បានរីកដុះដាលយ៉ាងឆាប់រហ័សនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ក្រុមហ៊ុនធានារ៉ាប់រងចំនួន ២ គឺ Infinity និង CampuBank Lonpac បានចូលប្រឡូកក្នុងទីផ្សារធានារ៉ាប់រង (ក្រៅពីធានារ៉ាប់រងជីវិត) នៅឆ្នាំ២០០៧ ។ នៅចុងឆ្នាំ ២០០៧ មូលធនបានបង់ជំរះ (paid-up capital) កើនដល់ ៣៣,២១លានដុល្លារ ខណៈដែលចំណូលបុព្វលាភសុទ្ធ កើនដល់ ៦,២៥លានដុល្លារ ធៀបនឹង ៤,១៩លានដុល្លារ កាលពីឆ្នាំ២០០៦ ។ ចំនួនអ្នកមានប័ណ្ណសន្យាធានារ៉ាប់រង ក៏កើនឡើងយ៉ាងច្រើនដែរ តាំងពី ១៨.៤០៧នាក់នៅឆ្នាំ២០០៥ ដល់ ២៩.១២៤នាក់នៅឆ្នាំ២០០៧ ។ នៅឆ្នាំ២០០៧ មានការធានារ៉ាប់រង ៣ ប្រភេទសំខាន់ៗគឺ ធានារ៉ាប់រងយានយន្ត ធានារ៉ាប់រងអគ្គីភ័យ និងធានារ៉ាប់រងនាវា ដែលមានចំណែក ៥២% ១៣% និង ៥,៥% នៃទីផ្សារធានារ៉ាប់រង ។ ទាក់ទិននឹងចំណូលបុព្វលាភសុទ្ធសរុប ក្រុមហ៊ុន Forte មានដំណើរការល្អបំផុតក្នុង ៣ ឆ្នាំចុងក្រោយនេះ ។ ពីឆ្នាំ២០០៥ ដល់ ២០០៧ ក្រុមហ៊ុន Caminco បានលក់ប័ណ្ណសន្យាធានារ៉ាប់រងយានយន្តភាគច្រើន ហើយក្រុមហ៊ុន Forte រកចំណូលបានច្រើនបំផុតលើធានារ៉ាប់រងអគ្គីភ័យ ធានារ៉ាប់រងនាវា និងធានារ៉ាប់រងផ្នែកវិស្វកម្ម ។

## ៨.៤. កំហិតលើពាណិជ្ជកម្មសេវាកម្ម ក្នុងវិស័យទូរគមនាគមន៍ និងហិរញ្ញវត្ថុ

សន្ទស្សន៍កំហិតលើបរទេស (foreign restrictiveness index: FRI) គឺជារង្វាស់នៃកំហិតគ្មានការរើសអើង និងមានការរើសអើងទាំងអស់ ទៅលើអ្នកផ្គត់ផ្គង់បរទេស ។ FRI ក៏មានរាប់បញ្ចូលផងដែរនូវសន្ទស្សន៍ក្នុងស្រុក (domestic index: DI) ដែលជាភាពខុសគ្នារវាង FRI និង សន្ទស្សន៍រើសអើងលើបរទេស (foreign discriminatory index: FDR) (McGuire et al. 2000) ។ សន្ទស្សន៍នេះ ត្រូវបានគណនាដោយប្រើវិធីសាស្ត្រដាក់ពិន្ទុ និងដាក់ទំងន់ ។ វិធីសាស្ត្រនេះ មានគុណវិបត្តិមួយចំនួន: ឧទាហរណ៍ ការកំណត់ទំងន់ផ្អែកលើការវិនិច្ឆ័យរបស់អ្នកនិពន្ធ ដោយយោងតាមការស្រាវជ្រាវពីមុន និងការយល់ដឹងលើវិស័យនេះ ។ ដូច្នេះ ចំណុចសំខាន់បំផុតគឺ ត្រូវចាត់ទុកសន្ទស្សន៍ជាការផ្តល់គំនិត មិនមែនជាភស្តុតាងដាច់ណាត់ទេ ។

**តារាង ៨.១: សមាសភាពសន្ទស្សន៍កំហិតពាណិជ្ជកម្ម** (Trade Restrictiveness: TRI) **សំរាប់វិស័យទូរគមនាគមន៍ ធនាគារ និងធានារ៉ាប់រង**

| ទូរគមនាគមន៍ | ហិរញ្ញវត្ថុ |
|---|---|
| ១. សេវាទូរស័ព្ទអចល័ត | ១. សេវាធនាគារ |
| ២. សេវាប្រតិបត្តិការទូរស័ព្ទចល័ត | ក. ការចេញអាជ្ញាប័ណ្ណឱ្យធនាគារ |
| ៣. សេវាអ៊ីនធឺណិត | ខ. ទំរង់នៃវត្តមានពាណិជ្ជកម្ម |
| ក. ការចេញអាជ្ញាប័ណ្ណសេវាទូរស័ព្ទអចល័ត ទូរស័ព្ទចល័ត និងអ៊ីនធឺណិត | គ. ការអនុញ្ញាតឱ្យបរទេសចូលរួមក្នុងទ្រព្យម្ចាស់ |
| ខ. ទំរង់នៃវត្តមានពាណិជ្ជកម្ម | ឃ. កំហិតលើការផ្តល់សេវាប្រភេទខ្លះដោយជនបរទេស |
| គ. ការអនុញ្ញាតឱ្យបរទេសចូលរួមក្នុងទ្រព្យម្ចាស់ | ង. ការរៀបចំក្រុមហ៊ុនរួមទុន |
| ឃ. ការរៀបចំក្រុមហ៊ុនរួមទុន | ច. ចលនាអចិន្ត្រៃយ៍នៃថ្នាក់ដឹកនាំជាជនបរទេស |
| ង. ការលក់បន្តដោយភាគីទីបីនូវបណ្តាញជួលបាន | ឆ. ការប្រមូល និងការឱ្យខ្ចីទុនដោយធនាគារបរទេស |
| ច. ថ្លៃអនុវត្តលើអ្នកប្រើប្រាស់ចុងក្រោយ | ជ. កំហិតផ្សេងៗ |
| ឆ. បទបញ្ញត្តិនៃការហៅឆ្លងបណ្តាញ | ២. សេវាធានារ៉ាប់រង |
| ជ. រចនាសម្ព័ន្ធទីផ្សារ | ក. ការចេញអាជ្ញាប័ណ្ណឱ្យក្រុមហ៊ុនធានារ៉ាប់រង |
| ឈ. ចលនាបណ្តោះអាសន្ននៃប្រជាពលរដ្ឋ | ខ គ ឃ ង ដូចចំនុចខាងលើ |
| | ច. ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែនដោយក្រុមហ៊ុនធានារ៉ាប់រង |
| | ឆ. កំហិតលើអ្នកផ្គត់ផ្គង់បរទេស |
| | ជ. វិសាលភាពនៃការប្រមូលទុនក្នុងស្រុក និងទុនបរទេស |
| | ឈ. ការពង្រីកតំណាងលក់ធានារ៉ាប់រង |

*ប្រភព: Kimura et al. (2003), Findlay and Warren (2002) and Deardorff and Stern (2004)*

**សន្ទស្សន៍កំហិតក្នុងទូរគមនាគមន៍:** ទោះបីជាវិស័យទូរគមនាគមន៍ បានធ្វើសេរីភាវូបនីយកម្មស្ទើរមួយទសវត្សរ៍ហើយក្តី ក៏កំហិតលើការចូលរួមពីបរទេស នៅតែមានតឹងតែងនៅឡើយ ប៉ុន្តែកំហិតលើអ្នកផ្គត់ផ្គង់ក្នុងស្រុកបានធូរស្រាល ប្រហែលពាក់កណ្តាលដូចមានបង្ហាញក្នុងក្រាហ្វិក ៨.១ ។ ការបែងចែកវិស័យនេះ ទៅជាអនុវិស័យមួយចំនួន បានបង្ហាញថា អ៊ីនធឺណិត គឺជាទីផ្សារសេរីជាងគេបំផុត បន្ទាប់មក គឺសេវាទូរស័ព្ទចល័ត

និងទូរស័ព្ទអចល័ត ។ គេឃើញមានការរើសអើងច្រើនណាស់ ចំពោះវិនិយោគិនបរទេសក្នុងសេវាកម្មទូរស័ព្ទអចល័ត និងទូរស័ព្ទចល័ត ប៉ុន្តែចំពោះសេវាអ៊ីនធឺណិតវិញ មានតិចតួចបំផុត ។ កំហិត និងការរើសអើងក្នុងសេវាកម្មទូរស័ព្ទទាំងពីរប្រភេទ អាចបណ្តាលមកពីលក្ខណៈផ្តាច់មុខនៃសេវាទូរស័ព្ទអចល័ត និងលទ្ធភាពរបស់ក្រុមហ៊ុនសេវាទូរស័ព្ទចល័តចំបងគេ ក្នុងការប្រើអំណាចរើសអើងទៅលើក្រុមហ៊ុនតូចជាងខ្លួន ។ អវត្តមាននៃបទបញ្ញត្តិលើការចេញអាជ្ញាប័ណ្ណ និងការសំរេចចិត្តបែបមជ្ឈការ ដោយអ្នកកសាងគោលនយោបាយ និងអ្នកធ្វើបទបញ្ញត្តិគ្រប់គ្រង បង្កើតបានជាបរិយាកាសអាជីវកម្មមិនប្រាកដប្រជា ដែលធ្វើឱ្យប្រតិបត្តិករទូរគមនាគមន៍កំរិតពិភពលោក រារែកក្នុងការចូលមកក្នុងទីផ្សារកម្ពុជាដ៏តូចនេះ ។

**ក្រាហ្វិក ៨.១: សន្ទស្សន៍កំហិតខាងពាណិជ្ជកម្មនៃឧស្សាហកម្មទូរគមនាគមន៍នៅឆ្នាំ២០០៨**




*ប្រភព : ការគណនារបស់អ្នកនិពន្ធ ដោយផ្អែកលើសម្ភាសន៍ជាមួយនិយតករ*

**សន្ទស្សន៍កំហិតក្នុងផ្នែកហិរញ្ញវត្ថុ:** ក្រាហ្វិក ៨.២ បង្ហាញច្បាស់ពីលទ្ធផលដ៏សំខាន់ នៃសេរីភាវូបនីយកម្មហិរញ្ញវត្ថុ តាំងពីពាក់កណ្តាលទសវត្សរ៍១៩៩០ មក ។ កំហិតលើការចូលរួមរបស់បរទេស ក្នុងផ្នែកធនាគារ និងធានារ៉ាប់រង មានតិចតួចបំផុត ជាពិសេស បើធៀបនឹងផ្នែកទូរគមនាគមន៍ ។ ការរើសអើងក្នុង ផ្នែកធានារ៉ាប់រងមានកំរិតខ្ពស់ជាងផ្នែកធនាគារបន្តិច ។ ការបើកចំហទីផ្សារកាន់តែប្រសើរឡើង បង្ហាញឱ្យឃើញពីបំលាស់ប្តូរក្នុងច្បាប់ដែលមានស្រាប់ ការដាក់អនុវត្តបទបញ្ញត្តិបើកចំហដល់បរទេស និងការអនុវត្តរបបសេដ្ឋកិច្ចទីផ្សារសេរី ។ ឧទាហរណ៍ ការអនុញ្ញាតឱ្យជនបរទេសមានកម្មសិទ្ធិដល់ ១០០% និងការរៀបចំឡើងវិញនូវប្រព័ន្ធធនាគារ ដោយក្នុងនោះ ធនាគារត្រូវបន្ថែមធនបំរុងរបស់ខ្លួននៅដើមទសវត្សរ៍២០០០ ត្រូវបានដាក់អនុវត្តដោយគ្មានការរើសអើង ។ ម្យ៉ាងទៀត តាំងពីឆ្នាំ២០០០ មក ចំនួនប្រតិបត្តិករក្នុងវិស័យទាំងពីរ បានកើនឡើងយ៉ាងខ្លាំង ហើយតំលៃសេវាកម្មត្រូវបានអនុញ្ញាតឱ្យដើរតាមកំលាំងទីផ្សារ ។

ក្រាហ្វិក ៨.២: សន្ទស្សន៍កំហិតផ្នែកពាណិជ្ជកម្ម នៃឧស្សាហកម្មហិរញ្ញវត្ថុនៅឆ្នាំ២០០៨




*ប្រភព: ការគណនារបស់អ្នកនិពន្ធ ដោយផ្អែកលើសម្ភាសន៍ជាមួយនិយតករ និងរបាយការណ៍ប្រចាំឆ្នាំរបស់ពួកគេ*

**ផលប៉ះពាល់នៃការបើកចំហផ្នែកទូរគមនាគមន៍ និងហិរញ្ញវត្ថុ:** ដូចមានបង្ហាញនៅក្នុងផ្នែកស្តីពីសន្ទស្សន៍កំហិតផ្នែកពាណិជ្ជកម្មនៅខាងលើ វិស័យធនាគារ និងធានារ៉ាប់រង គឺជាទីផ្សារសេរីបំផុត បន្ទាប់មកទៀតគឺសេវាអ៊ីនធឺណិត និងសេវាទូរស័ព្ទ ។ សេរីភាវូបនីយកម្ម បានទាក់ទាញវិនិយោគក្នុងស្រុក និងវិនិយោគពីបរទេសយ៉ាងច្រើនមកក្នុងវិស័យទាំងនេះ ហើយការរីកដុះដាលយ៉ាងគំហុក ជាពិសេស គឺចំនួនអ្នកផ្គត់ផ្គង់សេវាកម្ម បាននាំឱ្យមានការរីកចំរើនគួរឱ្យកត់សម្គាល់ ទាំងខាងគុណភាព និងតំលៃសេវាកម្ម ។ តំលៃការហៅទូរស័ព្ទទៅបរទេស បានធ្លាក់ចុះពី ៣,៨០ដុល្លារ/នាទី នៅឆ្នាំ១៩៩៧ មកត្រឹមប្រហែល ០,៣០ដុល្លារ/នាទី នៅឆ្នាំ២០០៨[៧] ។ ទោះបីសេរីភាវូបនីយកម្មក្នុងវិស័យទូរស័ព្ទអចល័ត មានល្បឿនយឺតបន្តិចក្តី ក៏តំលៃនៃការដាក់តំឡើងប្រព័ន្ធទូរស័ព្ទអចល័ត បានធ្លាក់ចុះ ១៤% សំរាប់ក្រុមហ៊ុន Telecom និង ៥០% សំរាប់ក្រុមហ៊ុន Camintel នៅចន្លោះខែកញ្ញា ២០០១ និង តុលា ២០០៨ ។ វិស័យទូរស័ព្ទចល័ត ក៏ប្រសើរជាងមុនច្រើនដែរ ដោយថ្លៃហៅចេញក្នុងប្រព័ន្ធនៅក្នុងស្រុក បានធ្លាក់ចុះ ៥៣% សំរាប់ Camshin និង ៦៣% សំរាប់ Mobitel នៅចន្លោះខែកក្កដា ២០០១ និង តុលា ២០០៨ ។ ដូចគ្នាដែរ ការប្រើប្រាស់សេវាអ៊ីនធឺណិត dial-up បានធ្លាក់ថ្លៃពី ៨,៥០ដុល្លារ/ម៉ោង នៅឆ្នាំ១៩៩៧ មកត្រឹមប្រហែល ០,៩៥ដុល្លារ/ម៉ោង នៅឆ្នាំ២០០៨ (NiDA 2003: 27 និងតារាងថ្លៃខែតុលា ២០០៨ របស់ក្រុមហ៊ុន Online) ។ អត្រាការប្រាក់រយៈពេល ១២ខែ លើកំចីជាប្រាក់ដុល្លារ បានថយចុះបន្តិចពី ១៨,២% ក្នុងឆ្នាំ ២០០២ មកត្រឹម ១៦,៤% ក្នុងឆ្នាំ ២០០៧ (NBC 2008) ហើយសេវាកម្មផ្សេងៗរបស់ធនាគារ ដូចជា ការផ្ទេរប្រាក់តាមប្រព័ន្ធអ៊ីនធឺណិត និងប័ណ្ណឥណទាន និងឥណពន្ធ ជាដើម ត្រូវបានដាក់ឱ្យប្រើក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ។ វិស័យធានារ៉ាប់រង ក៏បានរីកលូតលាស់គួរឱ្យកត់សម្គាល់ផងដែរ ។ ការបញ្ចុះថ្លៃ

---

៧ តួលេខកាលពីឆ្នាំ ១៩៩៧ ដកស្រង់ចេញពី "សូចនាករនៃវិស័យទូរគមនាគមន៍ ឆ្នាំ១៩៩៧-២០០៧ (MPTC: 2008)" ដែលជាតារាងលេខមួយ ដែលទទួលបានពី MPTC កាលពីខែសីហា ២០០៨ រីឯតួលេខសំរាប់ឆ្នាំ២០០៨ ទទួលបានពីតារាងពន្ធរបស់ CamGSM ក្នុងខែកញ្ញា ២០០៨ ។ ក្នុងខែតុលា ២០០៨ ការហៅទូរស័ព្ទទៅបរទេស ដោយប្រើសេវាទូរស័ព្ទអចល័ត ត្រូវចំណាយពី ០,៨០ដុល្លារ ទៅ ១,១៤ដុល្លារ (Telecom Cambodia and Camintel) ។

សេវាយ៉ាងច្រើន និងកំណើនលទ្ធភាពមានសេវាកម្មទាំងនេះប្រើប្រាស់ បានផ្តល់ឱកាសកាន់តែធំទូលាយឱ្យវិស័យផ្សេងៗទៀតរីកលូតលាស់ ។ ទោះបីយើងមិនទាន់រកបានស្ថិតិចំណាយរបស់ឧស្សាហកម្មកាត់ដេរទៅលើសេវា ដូចជា សេវាទូរស័ព្ទចល័ត ទូរស័ព្ទអចល័ត អ៊ីនធឺណិត ធនាគារ និងធានារ៉ាប់រងក្តី ក៏យើងអាចសន្និដ្ឋានបានមួយក៏រិតថា គុណភាពប្រសើរឡើង និងការធ្លាក់ថ្លៃសេវាទាំងនេះ នឹងជួយបង្កើនប្រាក់ចំណេញ និងលក្ខណៈប្រកួតប្រជែងរបស់ឧស្សាកម្មកាត់ដេរ ។ វិស័យដទៃទៀត ដូចជា កសិកម្ម សំណង់ និងទេសចរណ៍ ជាដើម ក៏នឹងទទួលបានអត្ថប្រយោជន៏ពីសេវាទាំងនេះដែរ ។

## ៨.៥. តំរូវការ និងឱកាសសំរាប់សេរីភាវូបនីយកម្មវិស័យទូរគមនាគមន៍ និងហិរញ្ញវត្ថុ

ផ្នែកនេះ បង្ហាញជាសង្ខេបនូវលទ្ធផល នៃអង្កេតពីមតិយោបល់របស់ថ្នាក់ដឹកនាំអង្គភាព អំពីតំរូវការនិងឱកាសសម្រាប់សេរីភាវូបនីយកម្ម ។ ប្រហែល ៦៦ សហគ្រាសសេវាកម្ម ត្រូវបានជ្រើសរើសដោយចៃដន្យសម្រាប់អង្កេតនេះ ដោយប្រើវិធីសាស្ត្រពីរ ការចុះធ្វើសម្ភាសន៏ដល់កន្លែង និងការផ្ញើអត្ថបទសម្ភាសន៏តាមអ៊ីមែល ។ ទោះយ៉ាងនេះក្តី អត្រាឆ្លើយសម្ភាសន៏មានក៏រិតទាបខ្លាំង ត្រឹម ២៨% ដែលបណ្តាលមកពីភាពស្មុគស្មាញនៃសំណួរនិងការដាក់ចូលគ្នានូវអនុវិស័យដល់ទៅ ៥ ក្នុងបញ្ជីសំណួរតែមួយ ។ ដូច្នេះ ត្រូវប្រយ័ត្នប្រយែងក្នុងការយកលទ្ធផលអង្កេត ទៅតំណាងឱ្យមតិយោបល់ជារួមក្នុងវិស័យនីមួយៗ ។

លទ្ធផលនៃអង្កេតពីមតិយោបល់របស់ថ្នាក់ដឹកនាំសហគ្រាស ហាក់ដូចមិនទាន់ច្បាស់ល្អទេ ពីព្រោះទទួលបានចំលើយតិច ត្រឹម ២៨% ។ ប្រហែល ៥០% នៃអ្នកឆ្លើយសំភាសន៏ បានផ្តល់អាទិភាពដល់ការចរចា GATS-WTO ទៅលើព័ត៌មាន និងការផ្ទេរទិន្នន័យតាមអ៊ីនធឺណិត អ៊ីមែល សេវាទូរស័ព្ទ និងសេវាទូរលេខ ក្នុងវិស័យទូរគមនាគមន៏ ហើយមានជាង ៥០% បានផ្តល់អាទិភាពទៅលើសេវាធានារ៉ាប់រងជីវិត គ្រោះថ្នាក់ និងសុខភាព ការផ្តល់កំចីគ្រប់ប្រភេទ ការធ្វើភតិសន្យាហិរញ្ញវត្ថុ ក្នុងវិស័យហិរញ្ញវត្ថុ ។ ក្នុងអនុវិស័យភាគច្រើន មានអ្នកឆ្លើយសម្ភាសន៏ជាងពាក់កណ្តាលបានបញ្ជាក់ថា សាធារណជនងាយស្វែងរកបាននូវបទបញ្ញត្តិច្បាប់ផ្សេងៗ និងការពិគ្រោះយោបល់ជាលក្ខណៈឯកជន ។ ពួកគេភាគច្រើនបានយល់ស្របថា គុណភាពហេដ្ឋារចនាសម្ព័ន្ធនៃឧស្សាហកម្មទាំងនេះបានប្រែប្រួលប្រសើរឡើង ។ អង្កេតក៏បង្ហាញដែរថា អ្នកឆ្លើយសម្ភាសន៏ភាគច្រើនយល់ថា គុណភាពសេវាកម្មទាំងនោះ បានល្អប្រសើរឡើង ហើយតំលៃសេវាកម្មក៏បានថយចុះដែរ (សំរាប់ព័ត៌មានលំអិតនៃលទ្ធផលអង្កេតសូមមើលរបាយការណ៍ពេញលេញ ដែលមាននៅក្នុងរបាយការណ៏អភិវឌ្ឍន៏ប្រចាំឆ្នាំ ២០០៩-២០១០ ជាភាសាអង់គ្លេស របស់វិទ្យាស្ថាន CDRI) ។

## ៨.៦. សន្និដ្ឋាន

សេរីភាវូបនីយកម្មសេវាកម្ម បានជួយដល់ការអភិវឌ្ឍច្រើនណាស់ ក្នុងមួយទសវត្សរ៏កន្លងទៅនេះ ។ សេវាធនាគារ សេវាធានារ៉ាប់រង ទូរស័ព្ទចល័ត និងអ៊ីនធឺណិត បានរីកដុះដាលជាខ្លាំង ហើយកំណើនយ៉ាងលឿននេះបានជំរុញឱ្យមានភាពប្រកួតប្រជែងកាន់តែខ្លាំងឡើង នៅក្នុងទីផ្សារសេវាកម្មទាំងនេះ ដែលនាំឱ្យមានការបញ្ចុះតំលៃ និងការកែលំអគុណភាពសេវាកម្ម ។ សេដ្ឋកិច្ចអាចទទួលបានអត្ថប្រយោជន៏កាន់តែច្រើនថែមទៀត ប្រសិនបើនៅតាមវិស័យនីមួយៗខាងលើ មាននិយតករ ដែលមានសមត្ថភាព និងឯករាជ្យ ដើម្បីការពារអតិថិជន និងធានាឱ្យមានការប្រកួតប្រជែងស្មើភាពគ្នា សំរាប់អ្នកផ្គត់ផ្គង់សេវាទាំងអស់ ដោយមិនប្រកាន់សញ្ជាតិ ។

កំហិតលើការចូលរួមពីបរទេស និងការរើសអើងប្រឆាំងនឹងអ្នកផ្គត់ផ្គង់បរទេស មានតិចតួចណាស់ក្នុងវិស័យធនាគារ និងធានារ៉ាប់រង ប៉ុន្តែនៅមានច្រើនក្នុងវិស័យទូរគមនាគមន៍ ទោះបីមានការធូរស្រាលខ្លះក្នុងផ្នែកទូរស័ព្ទចល័ត និងអ៊ីនធឺណិតក្តី ។ សព្វថ្ងៃ មិនមានគោលនយោបាយណាមួយ ដាក់កំហិតតឹងរ៉ឹងលើក្រុមហ៊ុនបរទេសថ្មីៗ ដែលចូលមកក្នុងទីផ្សារធនាគារ និងធានារ៉ាប់រងឡើយ ។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ទីផ្សារអ៊ីនធឺណិត និងទូរស័ព្ទចល័តមានលក្ខណៈសេរីជាងមុន បើពិនិត្យមើលលើការប្រកួតប្រជែង និងកំណើនកម្មសិទ្ធិរបស់បរទេស ប៉ុន្តែខាងផ្នែកសេវាទូរស័ព្ទអចល័ត មានការរីកលូតលាស់យឺត ដោយសារអាជីវកម្មក្នុងវិស័យនេះមានលក្ខណៈស្ទើរតែផ្តាច់មុខ និងអវត្តមាននៃក្រុមហ៊ុនថ្មីៗ ចូលមកធ្វើអាជីវកម្មក្នុងទសវត្សរ៍ចុងក្រោយនេះ ។

សរុបមក ក្នុងទសវត្សរ៍កន្លងទៅនេះ មានការរីកចំរើនច្រើនណាស់ ។ ប៉ុន្តែ នៅខាងមុខមានបញ្ហាប្រឈមធំៗជាច្រើន ត្រូវដោះស្រាយ ដើម្បីបង្កើតឱកាសស្មើៗគ្នាសំរាប់អ្នកផ្គត់ផ្គង់ ការពារអ្នកប្រើប្រាស់ សេវា និងធានានូវចំណាត់ការស្មើភាពគ្នា ចំពោះវិនិយោគិនបរទេស និងវិនិយោគិនក្នុងស្រុក ។ ខាងក្រោមនេះ គឺជាអនុសាសន៍មួយចំនួន យោងតាមលទ្ធផលស្រាវជ្រាវដូចរៀបរាប់ខាងលើ ។

**វិស័យទូរគមនាគមន៍:**

- មិនគួរមានការពន្យាពេលទៀតទេ ក្នុងការអនុម័តច្បាប់ទូរគមនាគមន៍ ឬអនុក្រឹត្យស្តីពីសេវាកម្មស្តង់ដារ និងអាជ្ញាប័ណ្ណបណ្តាញ ដើម្បីឱ្យសាធារណជនមានការច្បាស់លាស់ពីលក្ខណៈវិនិច្ឆ័យ នៃការផ្តល់អាជ្ញាប័ណ្ណ ។ គោលនយោបាយប្រកួតប្រជែងក្នុងវិស័យនេះ ក៏គួរដាក់ចេញដែរ ។
- គួរបង្កើតប្រព័ន្ធនៃក្រុមហ៊ុនមួយ អាជ្ញាប័ណ្ណមួយ ដើម្បីចេញអាជ្ញាប័ណ្ណដាច់ដោយឡែកពីគ្នា លើប្រតិបត្តិការនៃបណ្តាញ និងសេវាកម្ម ។ ក្នុងពេលធ្វើអន្តរកាលទៅអនុវត្តរបបអាជ្ញាប័ណ្ណបណ្តាញ និងសេវាកម្មថ្មី និយតករត្រូវធានាថា ទាំងប្រតិបត្តិករដែលមានស្រាប់ និងប្រតិបត្តិករថ្មីក្នុងទីផ្សារ ពុំមានការបង់ចាញ់គ្នាក្នុងការប្រកួតប្រជែង ។
- នីតិវិធីសម្រាប់ការចរចារ លើការតភ្ជាប់បណ្តាញ និងរបៀបរបបផ្សេងទៀត ក្នុងចំណោមប្រតិបត្តិករគួរតែមានផ្សព្វផ្សាយជាសាធារណៈ ។
- ថ្លៃលក់រាយ គួរតែកំណត់ឡើងតាមការប្រកួតប្រជែង រវាងប្រតិបត្តិករ ។
- និយតករ និងអ្នកធ្វើគោលនយោបាយ គួរជួបពិគ្រោះយោបល់ជាញឹកញាប់ ជាមួយប្រតិបត្តិករ និងក្រុមអ្នកប្រើប្រាស់ មុនពេលបង្កើតវិធានស្តង់ដារ និងបទបញ្ជាផ្សេងៗ ដែលអាចនឹងប៉ះពាល់ដល់ប្រតិបត្តិករ ឬអ្នកប្រើប្រាស់ ។
- ការបណ្តុះបណ្តាលនិយតករ ដែលមានសមត្ថភាព និងឯករាជ្យ គួរមានអាទិភាពខ្ពស់ក្នុងចំណោមអាទិភាពនានារបស់រដ្ឋ និងគួរអនុវត្តដោយយកចិត្តទុកដាក់ គិតគូរពីធនធានមនុស្សដែលត្រូវមាន សម្រាប់អង្គភាពនិយតកម្ម ។

វិស័យហិរញ្ញវត្ថុ:

- មានតំរូវការជាបន្ទាន់ លើការកសាងសមត្ថភាពបុគ្គលិកត្រួតពិនិត្យ ខាងផ្នែកធនាគារ និងធានារ៉ាប់រង ដើម្បីឱ្យដើរទាន់ការរីកលូតលាស់នៃផ្នែកទាំងពីរនេះ ។
- ដោយសារបញ្ហាអភិបាលកិច្ចអន់ខ្សោយនៃអាជីវកម្ម អាចមានច្រើនខាងផ្នែកធនាគារ ដូច្នេះ ធនាគារកណ្ដាល គួរដាក់អនុវត្តនូវបទបញ្ជាផ្សេងៗ ស្ដីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងសវនករពីខាងក្រៅដែលមានលក្ខណៈស្របតាមស្តង់ដារអន្តរជាតិ ។
- ធនាគារកណ្ដាល គួរពិចារណាលើការដាក់អនុវត្តស្តង់ដារអន្តរជាតិថ្មីៗ ចំពោះក្រុមហ៊ុនចូលមកប្រកួតប្រជែងថ្មីៗ ពីព្រោះក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ចំនួនធនាគារកើនឡើងជាខ្លាំង ដែលអាចធ្វើឱ្យបញ្ហាអភិបាលកិច្ចអន់ខ្សោយនៃអាជីវកម្ម កាន់តែចោទធ្ងន់ធ្ងរ ។
- គួរដាក់អនុវត្តយ៉ាងតឹងរ៉ឹងនូវកាតព្វកិច្ចផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានសំខាន់ៗបំផុត ដែលទាក់ទងនឹងធនាគារ និងក្រុមហ៊ុនធានារ៉ាប់រង ។
- ធនាគារកណ្ដាល និងនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរដាក់អនុវត្តលើប្រតិបត្តិករទាំងអស់ នូវរបៀបរបបរាយការណ៍ហិរញ្ញវត្ថុស្តង់ដារមួយ ។
- និយតករ និងអ្នកធ្វើគោលនយោបាយ គួរមានការជួបពិគ្រោះយោបល់ជាញឹកញាប់ ជាមួយប្រតិបត្តិករ និងក្រុមអ្នកប្រើប្រាស់ មុនពេលបង្កើតច្បាប់ ស្តង់ដារ និងបទបញ្ជាផ្សេងៗ ដែលអាចនឹងប៉ះពាល់ដល់ប្រតិបត្តិករ ឬអ្នកប្រើប្រាស់ ។

# ជំពូក ៩
# ការស្វែងយល់ពីសេដ្ឋកិច្ចនយោបាយ នៃសមាហរណកម្ម ក្នុងមហាអនុតំបន់មេគង្គៈ ការសំរបសំរួល និង ពិគ្រោះយោបល់ ជាមួយអ្នកពាក់ព័ន្ធនៅកម្ពុជា ដើម្បីសំរួលដល់ពាណិជ្ជកម្មក្នុងអនុតំបន់[១]

*ដោយលោក យៀង សុធី*

## ៩.១. សេចក្តីផ្តើម

តាមរយៈបទពិសោធន៍នៃវិបត្តិហិរញ្ញវត្ថុ ទាំងពេលបច្ចុប្បន្ន និងអតីតកាល តំរូវការចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយសមធម៌ និងមានមូលដ្ឋានធំទូលាយ ព្រមទាំងអាទិភាពសំរាប់តំបន់ ដូចជា ការប្រឆាំងភេរវកម្ម គ្រឿងញៀន និងការការពារបរិស្ថាន ការគាំទ្រតម្លៃនៃកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មក្នុងតំបន់ ទាំងថ្នាក់អនុតំបន់នៅក្នុងមហាអនុតំបន់មេគង្គ (GMS) និងថ្នាក់តំបន់នៅក្នុងអាស៊ាន អាស៊ាន+៣ និងតំបន់អាស៊ីខាងកើត ។ តម្លៃពិសេស គួរផ្តល់ចំពោះអត្ថប្រយោជន៍ដែលថា កំណើនពាណិជ្ជកម្មក្នុងតំបន់ ការសំរបសំរួលពាណិជ្ជកម្ម និងការដឹកជញ្ជូន (TTF) និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ទាំង "ផ្នែករឹង" និង "ផ្នែកទន់" អាចនាំឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម និងការភ្ជិតគំលាតកំរិតអភិវឌ្ឍន៍ នៅក្នុងអាស៊ាន និងអាស៊ីខាងកើត ។

ករណីសិក្សាពីប្រទេសកម្ពុជានេះ សំដៅស្វែងយល់ពីកំលាំងផ្សេងៗ ដែលជំរុញសមាហរណកម្មកំរិតតំបន់ក្នុងចំណោមប្រទេសសមាជិក GMS ហើយនិងលក្ខណៈសំគាល់នៃ និងអន្តរកម្មរវាងអ្នកពាក់ព័ន្ធនានា ដែលមានឥទ្ធិពលលើដំណើរការសមាហរណកម្ម ជាពិសេសលើបញ្ហាពាណិជ្ជកម្ម ការសំរួលពាណិជ្ជកម្ម និងការដឹកជញ្ជូន (កិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន ឬ "CBTA") ។ ក្នុងវិធីសាស្ត្រនៃការសិក្សា មានការកសាងម៉ាទ្រីសវិភាគពីអ្នកពាក់ព័ន្ធ និងម៉ាទ្រីសសារៈសំខាន់/ឥទ្ធិពល ការប្រមូលព័ត៌មានពិតជាក់ស្តែង និងភស្តុតាង ការធ្វើសម្ភាសន៍ ដោយប្រើបញ្ជីសំនួរពាក់កណ្តាលរៀបរយ ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ ដូចជា អ្នកតំណាងសំខាន់ៗនៃស្ថាប័នរដ្ឋ និងវិស័យឯកជន ជាដើម ។ ការស្រាវជ្រាវឯកសារដោយសង្ខេបក៏បានធ្វើឡើង ដើម្បីកំណត់ឱ្យច្បាស់ពីផលប្រយោជន៍របស់អ្នកពាក់ព័ន្ធ ដោយក្នុងនោះ មានការពិនិត្យឯកសារស្តីពីសេចក្តីប្រកាសនៃកិច្ចប្រជុំ

---

១ លោក យៀង សុធី ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ។ ការសិក្សានេះ បានតាក់តែងឡើងដោយមានមតិណែនាំ និងការជួយ គ្រប់គ្រងអំពីលោក Larry strange នាយកប្រតិបត្តិនៃ CDRI ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធក្នុងការជ្រើសរើស និងការធ្វើសម្ភាសន៍អ្នកពាក់ព័ន្ធ និងការធ្វើសេចក្តីព្រាងលទ្ធផលស្រាវជ្រាវ និងអនុសាសន៍ ។ ការសិក្សានេះ បានរៀបចំឡើងជាផ្នែកមួយ នៃការផ្តួចផ្តើមកម្មវិធី ARTNeT GMS ។ យើងសូមថ្លែងអំណរគុណដល់ការគាំទ្រ ផ្នែកហិរញ្ញវត្ថុពីទីភ្នាក់ងារស៊ីស សំរាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍ (SDC) និងជំនួយបច្ចេកទេសរបស់វិទ្យាស្ថានសេដ្ឋកិច្ចសហប្រជាជាតិ និងបេសកកម្មសំរាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិច (UNESCAP) ។

កំពូលទាំងបី នៃ GMS សេចក្ដីប្រកាសរបស់ថ្នាក់ដឹកនាំនយោបាយជាប់ពាក់ព័ន្ធ កំរិតនៃការចូលរួម និងភាពជាម្ចាស់របស់អ្នកពាក់ព័ន្ធទាំងបីក្រុម នៅក្នុងដំណើរការផ្សេងៗនៃ GMS ព្រមទាំងការចូលរួមចំណែកក្នុងពេលកន្លងមកនាពេលបច្ចុប្បន្ន និងទៅអនាគត ក្នុងដំណើរការសមាហរណកម្មនៃ GMS ។

ការស្រាវជ្រាវបានរកឃើញបញ្ហាប្រឈម និងឧបសគ្គជាច្រើន ចំពោះការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធ នៅក្នុងការផ្ដួចផ្ដើមគំនិតធ្វើសមាហរណកម្មជាទូទៅនៅថ្នាក់តំបន់ និងថ្នាក់អនុតំបន់ និងការអនុវត្ត កិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនដោយរលូន ។ ការសិក្សានេះ បង្ហាញពីកង្វះការសំរបសំរួលកំរិតខ្ពស់ និងស៊ីចង្វាក់គ្នា ក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗជាច្រើននៅក្នុងស្ថាប័នរដ្ឋ ដូចជា ក្រសួងសាធារណៈការ និងដឹកជញ្ជូន អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអាជ្ញាធរកាំកុងត្រូល និងកង្វះយន្តការច្បាស់លាស់ សំរាប់ការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាពរវាងអ្នកពាក់ព័ន្ធ ដូចជា កង្វះខាតការសំរបសំរួលក្នុងចំណោមស្ថាប័នរដ្ឋ សំរាប់ការផ្ដួចផ្ដើមគំនិតធ្វើសមាហរណកម្មក្នុងតំបន់ និងអនុតំបន់ ។ ជាងនេះទៅទៀត កង្វះព័ត៌មាន និងការយល់ដឹងជាសាធារណៈ ផលប្រយោជន៍ចាក់ឫស និងកំរិតសមត្ថភាពទាបក្នុងចំណោមអ្នកពាក់ព័ន្ធ អវត្តមានអ្នកតំណាងមកពីក្រុមអ្នកពាក់ព័ន្ធសំខាន់ៗ និងតួនាទីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងពួកអ្នកផ្ដល់ជំនួយជាប់ពាក់ព័ន្ធ គឺជាការបារម្ភធំៗមួយចំនួន ដែលអ្នកឆ្លើយសម្ភាសន៍ជាច្រើននាក់ បានលើកឡើងទាក់ទិននឹងផ្លូវដើរទៅមុខ សំរាប់អនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។

ផ្អែកលើលទ្ធផលស្រាវជ្រាវចំបងៗ មានការលើកជាអនុសាសន៍ ចំនួន ១៣ ។

## ៩.២. លទ្ធផលស្រាវជ្រាវសំខាន់ៗ និងអនុសាសន៍

យោងតាមការលូតលាស់យ៉ាងលឿន នៃវិស័យនាំចេញនៅកម្ពុជា និងកំណើនភាពប្រកួតប្រជែងដោយសារចលនាសាកលភាវូបនីយកម្ម និងសេដ្ឋកិច្ចទីផ្សារសេរី ដូច្នេះនៅកម្ពុជា បញ្ហាពាណិជ្ជកម្ម ការសំរួលការដឹកជញ្ជូន និងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ គឺចាំបាច់ខ្លាំងណាស់ បើសិនចង់អោយសេដ្ឋកិច្ចដែលកំពុងផុសឡើងអាចរីកចំរើនប្រកបដោយចីរភាព ។ នៅពេលដែលកិច្ចព្រមព្រៀង CBTA អនុវត្តបានជាទូទៅហើយ លក្ខខណ្ឌនានានៃកិច្ចព្រមព្រៀងនេះ គឺជាឧបករណ៍ដ៏សំខាន់បំផុត ដើម្បីសំរេចឱ្យបានទាំងស្រុងនូវលំហូរពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ និងមនុស្ស នៅក្នុងតំបន់ និងអន្តរជាតិ ។

មុននឹងរឿងល្អដូចខាងលើអាចកើតមានឡើងបាន គេត្រូវដោះស្រាយឧបសគ្គផ្សេងៗ ក្នុងការអនុវត្តកិច្ចព្រមព្រៀង IICBTA និង CBTA និងការផ្ដួចផ្ដើមគំនិតលើ TTF ។ វាអាចសំរេចទៅបានតាមរយៈការសំរបសំរួលការពិគ្រោះយោបល់ និងចូលរួមកាន់តែប្រសើរពីអ្នកពាក់ព័ន្ធសំខាន់ៗ ការកេណ្ឌប្រមូលធនធាន និងវិនិយោគក្នុងកម្មវិធីកសាងសមត្ថភាពមូលដ្ឋាន ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការជំរុញវិស័យឯកជន ឱ្យតំណាងកាន់តែប្រសើរនូវវិស័យឧស្សាហកម្ម និងការកែលំអតួនាទីរបស់ ADB និងទីភ្នាក់ងារផ្ដល់ជំនួយដទៃទៀតក្នុងការគ្រប់គ្រងការអនុវត្តកិច្ចព្រមព្រៀង CBTA ។

ដូចបានពិភាក្សាពីខាងដើម មានបញ្ហាប្រឈម និងចំណុចរាំងស្ទះជាច្រើន ដល់ការអនុវត្តបានស័ក្តិសិទ្ធិ និងមានជោគជ័យនូវពាណិជ្ជកម្ម និងគំនិតផ្ដួចផ្ដើមធ្វើការសំរបសំរួលពាណិជ្ជកម្ម និងការដឹកជញ្ជូន ជាពិសេសការពិគ្រោះយោបល់ដ៏មានប្រសិទ្ធភាពជាមួយអ្នកភាក់ព័ន្ធ ។ ទោះបីមានកំហិតខ្លះខាងពេលវេលា និងវិសាលភាព

នៃការសិក្សាក្តី ក៏អ្នកផ្តល់ព័ត៌មានសំខាន់ៗ បានផ្តល់ឱកាសឱ្យយើងប្រមូលព័ត៌មានបានជាច្រើន ដូចជា ការជួយជាមតិ និងអនុសាសន៍ សំដៅលុបបំបាត់ឧបសគ្គ និងកែលំអការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ក្នុងការអនុវត្តកិច្ចព្រមព្រៀង CBTA និងគំនិតផ្តួចផ្តើមធ្វើសមាហរណកម្មក្នុងតំបន់ ។ លទ្ធផលវិភាគសំខាន់ៗ និងអនុសាសន៍ស្ថាបនា មានលើកជាសង្ខេបនៅខាងក្រោម ដោយផ្តុំតាមលក្ខណៈនៃការសំរបសំរួល និងបញ្ហា ។

## វត្តមាន និងប្រសិទ្ធភាព នៃការសំរបសំរួលថ្នាក់ជាតិនូវសកម្មភាពផ្សេងៗក្នុងតំបន់ និងអនុតំបន់ (GMS អាស៊ាន និងតំបន់ដទៃទៀត)

*លក្ខណៈទូទៅ:*

*លទ្ធផលស្រាវជ្រាវ ១:*

- ជាទូទៅ ការសិក្សាបានរកឃើញថា នៅមានការយល់ដឹងទាប និងមិនស្មើគ្នាទេ ក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗខ្លះនៅក្នុងរដ្ឋាភិបាល និងវិស័យឯកជន អំពីតម្លៃនៃសមាហរណកម្មក្នុងតំបន់ និងអនុតំបន់សំរាប់ប្រទេសកម្ពុជានៅក្នុងអាស៊ាន និង GMS និងអំពីយន្តការដែលមានស្រាប់ សំរាប់សំរេចបានជោគជ័យ ។

*អនុសាសន៍ ១:*

- រដ្ឋាភិបាលកម្ពុជា ដោយរួមសហការជាមួយវិស័យឯកជនក្នុងស្រុក ស្ថាប័នស្រាវជ្រាវ និងប្រព័ន្ធផ្សព្វផ្សាយ គួរតែស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍ សំរាប់កម្មវិធីអប់រំរយៈពេលវែងមានច្រើនថ្នាក់ ដើម្បីលើកកំពស់ចំណាប់អារម្មណ៍ និងការកសាងសមត្ថភាព ដើម្បីបង្កើនការយល់ដឹងពីតម្លៃនៃសមាហរណកម្ម សំរាប់ប្រទេសកម្ពុជានៅក្នុងអាស៊ាន និង GMS និងចំណេះដឹងពីយន្តការដែលមានស្រាប់ ។ រឿងនេះមានប្រយោជន៍ជាពិសេស យោងតាមមេរៀនដែលទទួលបានពីវិបត្តិសេដ្ឋកិច្ចក្នុងតំបន់ និងសាកល និងផលប៉ះពាល់មកលើកម្ពុជា ។ ការងារនេះ ត្រូវរចនារៀបចំ ដាក់អនុវត្ត និងផ្តល់ធនធាន ដោយមានពិគ្រោះយោបល់ល្អិតល្អន់ ជាមួយអ្នកពាក់ព័ន្ធថ្នាក់មូលដ្ឋានសំខាន់ៗ ជាពិសេសវិស័យឯកជន ដើម្បីធានាថាថ្នាក់មូលដ្ឋាន ជាអ្នកជំរុញ និងជាម្ចាស់លើវា ។

*លទ្ធផលស្រាវជ្រាវ ២:*

- អ្នកពាក់ព័ន្ធសំខាន់ៗ ទាំងនៅក្នុងរដ្ឋាភិបាល និងវិស័យឯកជន ផ្តល់មតិពីតំរូវការ នូវការសំរបសំរួលអន្តររដ្ឋាភិបាលដ៏ស័ក្តិសិទ្ធិនៅថ្នាក់ជាតិ ក្នុងបរិបទនៃកម្មវិធីសមាហរណកម្មក្នុងតំបន់ និងអនុតំបន់ នៃ GMS និងអាស៊ាន ។

*អនុសាសន៍ ២:*

- រដ្ឋាភិបាលកម្ពុជា គួរប្រើកិច្ចប្រជុំកំពូលអាស៊ាន និង GMS និងកិច្ចប្រជុំ SOM ជាបន្តបន្ទាប់ ដើម្បីសំរេចបានសមាហរណកម្មប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) ក្នុងអាស៊ាន និងកម្មវិធីពាក់ព័ន្ធនឹង GMS ។

- រដ្ឋាភិបាលកម្ពុជា គួរពិចារណាពីលទ្ធភាពបង្កើតទីភ្នាក់ងារ ឬការិយាល័យសំរបសំរួលមួយ ដែលទទួលបន្ទុកតែមួយមុខ លើកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអនុតំបន់ ។ គំរូមួយសំរាប់ពិចារណា អាចជាទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ច ជាមួយប្រទេសជិតខាងរបស់ថៃ (NEDA) ដែលមានគោលដៅជំរុញភាពជាដៃគូអភិវឌ្ឍន៍សេដ្ឋកិច្ចទៅវិញទៅមក ជាមួយប្រទេសជិតខាង ។

*ដោយឡែកសំរាប់ការសំរួលពាណិជ្ជកម្ម និងដឹកជញ្ជូន:*

*លទ្ធផលស្រាវជ្រាវ ៣:*

- ជំនួយអភិវឌ្ឍន៍បច្ចុប្បន្ន ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ សំរាប់កម្មវិធីសំរបសំរួលពាណិជ្ជកម្ម គឺបានមកពីដៃគូអភិវឌ្ឍន៍នានា ដូចជា ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី អាស៊ាន និងទីភ្នាក់ងារផ្សេងទៀត ដោយមានការសំរបសំរួល និងសមាហរណកម្មទន់ខ្សោយ និង "សុខដុមនីយកម្ម និងការសំរបសំរួលអ្នកផ្តល់ជំនួយទន់ខ្សោយ" ដែលមានផលប៉ះពាល់អវិជ្ជមាន លើការពិគ្រោះយោបល់ និងការចូលរួមយ៉ាងសកម្មសិទ្ធិរបស់អ្នកពាក់ព័ន្ធ ។

*អនុសាសន៍ ៣:*

- ដៃគូអភិវឌ្ឍន៍ដែលផ្តល់ជំនួយ សំរាប់កម្មវិធីសមាហរណកម្មក្នុងតំបន់ និងអនុតំបន់ ដូចជា កម្មវិធី TTF ជាដើម គួរធ្វើការយ៉ាងជិតស្និទ្ធជាមួយទីភ្នាក់ងាររដ្ឋាភិបាល ដើម្បីសំរេចបានសុខដុមនីយកម្ម និងការសំរបសំរួលកាន់តែប្រសើរ និងសំរួលដល់ការពិគ្រោះយោបល់ និងការចូលរួមយ៉ាងសកម្មសិទ្ធិរបស់អ្នកពាក់ព័ន្ធ ដែលត្រូវផ្សារភ្ជាប់ទៅនឹងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិរបស់រដ្ឋាភិបាល និងយុទ្ធសាស្ត្រសមាហរណកម្មរបស់ប្រទេសកម្ពុជា ។ វិធីដ៏សំខាន់មួយ គឺត្រូវប្រើប្រាស់ទិន្នន័យនៅលើគេហទំព័រស្តីពីគំរោងជំនួយបច្ចេកទេសក្នុងអនុតំបន់ ដើម្បីជួយសំរួលលំហូរព័ត៌មានអំពីគំរោងផ្តួចផ្តើម ផ្តល់ជំនួយបច្ចេកទេសដែលកំពុងដំណើរការ ជួយកាត់បន្ថយសកម្មភាពជំនួយបច្ចេកទេសដែលអនុវត្តជាន់គ្នា និងរួមចំណែកជំរុញឱ្យការផ្តល់ជំនួយបច្ចេកទេសកាន់តែមានប្រសិទ្ធភាព ។ ទិន្នន័យ ODA[២] របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលផ្តល់នូវឧបករណ៍គ្រប់គ្រងជាយុទ្ធសាស្ត្រ សំរាប់គាំទ្រការអនុវត្តតាមរបៀបល្អៗក្នុងការគ្រប់គ្រងជំនួយពាក់ព័ន្ធនឹងការសំរបសំរួល ការធ្វើផែនការ ការអនុវត្ត និងធ្វើរបាយការណ៍សំរាប់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា គឺគួរតែរៀបចំឱ្យស៊ីគ្នានឹងតំរូវការ កែលំអថែមទៀត និងយកមកប្រើប្រាស់ឱ្យពេញលេញ ដើម្បីសំរេចបានតាមតំរូវការដ៏ជាក់លាក់នៃការសំរបសំរួល ។

**វត្តមាន និងប្រសិទ្ធភាព នៃការសំរបសំរួលអន្តរក្រសួងនៅថ្នាក់ជាតិ (គឺការសំរបសំរួលរវាងតួអង្គនៅក្នុងរដ្ឋាភិបាល) សំរាប់សកម្មភាពរបស់ GMS:**

---

២ http://www.cdc-crdb.gov.kh/database/index.htm

*លក្ខណៈទូទៅ:*

*លទ្ធផលស្រាវជ្រាវ ៤:*

- ការសិក្សាបង្ហាញថា លេខាធិការដ្ឋានជាតិនៃ GMS នៅក្នុងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គឺជាយន្តការសំរបសំរួលដ៏ស័ក្តិសិទ្ធិ ហើយតួនាទីនេះកាន់តែមានប្រសិទ្ធភាពខ្ពស់ បើសិនមានធនធានមនុស្ស ហិរញ្ញវត្ថុ និងបច្ចេកទេសបន្ថែមទៀត និងការតភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងអាស៊ាន និងយន្តការសមាហរណកម្មក្នុងតំបន់ដទៃទៀត ។

*អនុសាសន៍ ៤:*

- យន្តការសំរបសំរួលថ្នាក់ជាតិ សំរាប់កម្មវិធីសមាហរណកម្មថ្នាក់តំបន់ និងអនុតំបន់ របស់អាស៊ាន និង GMS ដូចបានលើកឡើងក្នុងអនុសាសន៍២ គួរអនុវត្តតួនាទីសំខាន់មួយឱ្យជាប់លាប់ គឺធ្វើឱ្យលេខាធិការដ្ឋានជាតិ នៃ GMS មានធនធានកាន់តែប្រសើរ ក្នុងក្របខណ្ឌនៃការសំរបសំរួលថ្នាក់ជាតិដ៏ស័ក្តិសិទ្ធិ ។

*ដោយឡែកសំរាប់ការសំរួលពាណិជ្ជកម្ម និងការដឹកជញ្ជូន (CBTA):*

*លទ្ធផលស្រាវជ្រាវ ៥:*

- អ្នកពាក់ព័ន្ធមួយចំនួន ទាំងក្នុងរដ្ឋាភិបាល និងវិស័យឯកជន ស្នើថា ជាពិសេសសំរាប់ TTF បច្ចុប្បន្ន មានសិទ្ធិអំណាចច្រើនពេក ដែលប្រមូលផ្តុំនៅក្នុងក្រសួង/ស្ថាប័នតែពីរ-បី ដែលមានការងារមមាញឹកពេក និងខ្វះសមត្ថភាពផង មានស្ថាប័នសំខាន់ៗខ្លះ ដែលទទួលបន្ទុកលើការងារអនុវត្ត គឺមានផលប្រយោជន៍ចាក់ឫសខ្លាំងណាស់ (ឧ. លទ្ធភាពទទួលបានប្រាក់កំរៃក្រៅផ្លូវការ) និងក្រាញននៀលមិនចង់ឱ្យមានការផ្លាស់ប្តូរអ្វីទេ ហើយអាជ្ញាធរថ្នាក់ខេត្តពុំមានព័ត៌មានគ្រប់គ្រាន់ ដើម្បីចូលរួមឱ្យបានស័ក្តិសិទ្ធិនៅក្នុងដំណើរការពិគ្រោះយោបល់ឡើយ ។

*អនុសាសន៍ ៥:*

- យោងតាមបទពិសោធន៍ និងមេរៀនដ៏លំបាក ដែលអ្នកពាក់ព័ន្ធគ្រប់ៗគ្នាទទួលបានកន្លងមក ក្នុងបញ្ហា CBTA ការបន្តអនុវត្តកិច្ចព្រមព្រៀង CBTA និងគំនិតផ្តួចផ្តើម TTF គួរមានលក្ខណៈដូចតទៅ:
  - ភាពជាម្ចាស់ និងការត្រួតពិនិត្យកាន់តែតឹងរ៉ឹង ដោយរដ្ឋាភិបាលកម្ពុជា និងស្ថាប័នរដ្ឋនានា ដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ (ឧ. វិស័យឯកជន) អំពីដំណើរការពិគ្រោះយោបល់ ការប្រើប្រាស់ជំនួយបច្ចេកទេសឱ្យសមស្រប ការរៀបចំកម្មវិធី ការអភិវឌ្ឍសមត្ថភាព ស្ថាប័ន និងអ្នកពាក់ព័ន្ធសំខាន់ៗ ព្រមទាំងការធ្វើផែនការ និងតារាងពេលសំរាប់ការអនុវត្ត ។
  - ការពិគ្រោះយោបល់កាន់តែសក្តិសិទ្ធិ ពិតប្រាកដ និងជាប្រព័ន្ធ ជាមួយអ្នកពាក់ព័ន្ធថ្នាក់ជាតិ ដោយ ADB និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត ក្នុងការធ្វើផែនការ ការរចនារៀបចំ និងការអនុវត្ត ។
  - គួរមានធនធានច្រើនថែមទៀត សំរាប់ការពិគ្រោះយោបល់ និងការអភិវឌ្ឍសមត្ថភាពស្ថាប័នរដ្ឋសំខាន់ៗ និងអ្នកពាក់ព័ន្ធក្នុងវិស័យឯកជន ដើម្បីឱ្យគេអាចចូលរួមបានកាន់តែស័ក្តិសិទ្ធិ ក្នុងនេះ

មានទាំងការគាំទ្រឱ្យមានការចូលរួមធំទូលាយ ពីអ្នកពាក់ព័ន្ធក្នុងវិស័យឯកជន (អង្គភាពកំពូល និងក្រុមហ៊ុន) ទាំងក្នុងសមាហរណកម្មក្នុង អ៊ុំ ជាទូទៅ និងក្នុង ទទធ-ជពទា ជាពិសេស ។

- ការពិគ្រោះយោបល់ និងអភិវឌ្ឍន៍សមត្ថភាព សំរាប់អ្នកពាក់ព័ន្ធសំខាន់ៗ គួររៀបចំតាមលំដាប់ និងកំណត់ពេលឱ្យស៊ីចង្វាក់គ្នាជាមួយផែនការ និងដំណាក់កាលអនុវត្តកម្មវិធីនីមួយៗ ដែលវាត្រូវ គាំទ្រ និងដោយគិតគូរដល់ចំណុចខ្លាំង និងចំណុចខ្សោយ នៃស្ថាប័នរដ្ឋ និងអ្នកពាក់ព័ន្ធសំខាន់ៗ ។
- រដ្ឋាភិបាល គួរផ្សព្វផ្សាយព័ត៌មានពីគំរោងដឹកជញ្ជូន និងពាណិជ្ជកម្មក្នុងតំបន់ ដល់មន្ត្រីថ្នាក់ក្រោមនៃអាជ្ញាធរខេត្ត និងមូលដ្ឋាន នៅជាប់ព្រំដែនប្រទេសជិតខាង ។ កិច្ចប្រជុំពិគ្រោះយោបល់ គួរធ្វើក្នុងខេត្តសំខាន់ៗជាប់ព្រំដែន ដើម្បីឱ្យគេបានចូលពាក់ព័ន្ធ ។

**វត្តមាន និងប្រសិទ្ធភាពនៃការសំរបសំរួល និងយន្តការពិគ្រោះយោបល់ថ្នាក់ជាតិ រវាងរដ្ឋាភិបាល និងក្រុមអ្នកពាក់ព័ន្ធផ្សេងៗ សំរាប់សកម្មភាពក្នុង GMS: តើក្រុមអ្នកពាក់ព័ន្ធនីមួយៗ មានអ្នកតំណាង និង/ឬ ការពិគ្រោះយោបល់គ្រប់គ្រាន់ឬទេនៅថ្នាក់ជាតិ ថ្នាក់អនុតំបន់ និងថ្នាក់តំបន់**

*លក្ខណៈទូទៅ:*

*លទ្ធផលស្រាវជ្រាវ ៦:*

- ការសិក្សា បានបង្ហាញពីការចូលរួមមិនស្មើគ្នា និងច្រើនតែទន់ខ្សោយ ក្នុងយន្តការពិគ្រោះយោបល់ថ្នាក់ជាតិ និងក្នុងសកម្មភាព GMS ជាទូទៅ ពីសំណាក់អង្គភាពកំពូល ជាអាទិ៍ សភាពាណិជ្ជកម្មកម្ពុជា និងសភាពាណិជ្ជកម្មខេត្ត សំរាប់វិស័យខ្លះ ដូចជា ធានារ៉ាប់រង និងធនាគារ ទោះបីជាមានវេទិការដ្ឋាភិបាល-ផ្នែកឯកជន (G-PSF) ត្រូវបានគេទទួលស្គាល់ជា យន្តការពិគ្រោះយោបល់ថ្នាក់ជាតិដ៏សក្តិសិទ្ធិ លើបញ្ហាវិស័យឯកជនក៏ដោយ ។ ពួកអ្នកពាក់ព័ន្ធយល់ថា រឿងនេះបណ្តាលមកពីកង្វះធនធានសំរាប់ឱ្យវិស័យឯកជនចូលរួមបានទូលំទូលាយក្នុងសកម្មភាព GMS កង្វះលទ្ធភាពទទួលបានព័ត៌មានពីតម្លៃ និងឱកាសសំរាប់ការចូលរួម វត្តមានក្រុមហ៊ុនធំៗមួយចំនួនតូច ដែលក្តោបក្តាប់លើឱកាសទាំងនេះ និងអ្នកដឹកនាំអាជីវកម្មដែលមានផលប្រយោជន៍ចាក់ឫស ។

*អនុសាសន៍ ៦:*

- រដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក គួរចូលរួម និងផ្តល់ធនធាន សំរាប់ការចូលរួមធំទូលាយរបស់អ្នកពាក់ព័ន្ធសំខាន់ៗ (ជាអាទិ៍ ពាណិជ្ជករនៅតាមព្រំដែន សហគមន៍នៅតាមព្រំដែន អាជ្ញាធរមូលដ្ឋាន និងវិស័យឯកជនសំខាន់ៗ ដូចជា ខាងធានារ៉ាប់រង និងធនាគារ) នៅក្នុងសកម្មភាពវិស័យឯកជននៃ GMS ជាពិសេស ក្នុងយន្តការពិគ្រោះយោបល់សំរាប់ TTF និងការអភិវឌ្ឍវិស័យឯកជន ។ រដ្ឋាភិបាលគួរស្វែងរកការគាំទ្រ ដែលមានការសំរបសំរួលល្អពី ADB និងដៃគូ អភិវឌ្ឍន៍ឯទៀត ដើម្បីផ្តល់ព័ត៌មាន ការកសាងសមត្ថភាព និងការគាំទ្រដល់អង្គភាពកំពូលៗ ដូចជា សភាពាណិជ្ជកម្មកម្ពុជា ដើម្បីជំរុញឱ្យមានការចូលរួមកាន់តែសក្តិសិទ្ធិ និងកាន់តែដឹងព័ត៌មានច្បាស់ ។

- រដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក គួររៀបចំកិច្ចប្រជុំពិគ្រោះយោបល់នៅជិតច្រកទ្វារព្រំដែនក្នុងខេត្តមួយចំនួននៅកម្ពុជា ដើម្បីឱ្យអ្នកពាក់ព័ន្ធសំខាន់ៗនៅតាមព្រំដែនបានចូលរួម ។

*លទ្ធផលស្រាវជ្រាវ ៧:*

- អ្នកពាក់ព័ន្ធជាច្រើន បានលើកពីកង្វះព័ត៌មានងាយទទួលបានជាសាធារណៈ និងថ្មីទាន់ពេល ស្តីពីតម្លៃ និងអត្ថប្រយោជន៍នៃសមាហរណកម្មក្នុងតំបន់ និងគំនិតផ្តួចផ្តើមផ្សេងៗ ថាជា ឧបសគ្គរាំងស្ទះចំបងដល់ការចូលរួមចំណែក និងសហប្រតិបត្តិការដ៏ស័ក្តិសិទ្ធិរបស់អ្នកពាក់ព័ន្ធ នៅក្នុងគំរោងសមាហរណកម្មថ្នាក់តំបន់ និងអនុតំបន់ ។

*អនុសាសន៍ ៧:*

- រដ្ឋាភិបាល (និង ADB) គួរលើកកំពស់ការយល់ដឹងពីគំរោងសមាហរណកម្មថ្នាក់តំបន់ ដល់អ្នកពាក់ព័ន្ធ ដូចជា:
  - អាជីវកម្មក្នុងស្រុក ដើម្បីឱ្យពួកគេជួយផ្តល់គំនិតដល់កម្មវិធី និងត្រៀមខ្លួនសំរាប់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ។
  - សហគមន៍នៅតាមព្រំដែន ដើម្បីជៀសវាងការប៉ះពាល់ជាយថាហេតុ (ដូចជា ការជំលៀសចេញពីទីតាំងសាងសង់កន្លែងត្រួតពិនិត្យរួម ១ជជាច និងការជួសជុលកែលំអផ្លូវដែលមានស្រាប់) ។
  - ធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូអភិវឌ្ឍន៍ឯទៀត ដែលចូលរួមក្នុងការផ្តួចផ្តើមធ្វើសមាហរណកម្មថ្នាក់តំបន់ និងអនុតំបន់ គួរតែរចនារៀបចំ និងផ្តល់ធនធាន សំរាប់កម្មវិធីរយៈពេលវែងមួយនៃការស្រាវជ្រាវខាងគោលនយោបាយ សំរាប់ស្ថាប័នសិក្សា និងវិទ្យាស្ថានស្រាវជ្រាវ នៅក្នុង GMS ដោយមានស្ថាប័នពិគ្រោះយោបល់ដ៏ស័ក្តិសិទ្ធិមួយ សំរាប់ធានាឱ្យការស្រាវជ្រាវផ្តល់លទ្ធផល ពាក់ព័ន្ធល្អនឹងតំរូវការ និងងាយបានទៅដល់អ្នកកសាងគោលនយោបាយ ។ គួរមានការចែក រំលែកក្នុងចំណោមប្រទេសសមាជិក GMS នូវករណីសិក្សា ដែលមានលើកច្រើននូវបញ្ហា និង បទពិសោធន៍របស់ប្រទេសនីមួយៗ ដើម្បីជួយកែលំអការកំណត់អាទិភាព និងការរចនារៀបចំ កម្មវិធីសំរាប់ជំរុញសមាហរណកម្ម GMS ឱ្យបានកាន់តែស័ក្តិសិទ្ធិ ក្នុងនេះមានទាំងបទពិសោធន៍ ជាក់លាក់ពីការអនុវត្ត CBTA ផង ។

*ដោយឡែកសំរាប់ការសំរួលពាណិជ្ជកម្ម និងដឹកជញ្ជូន (CBTA):*

*លទ្ធផលស្រាវជ្រាវ ៨:*

- អ្នកពាក់ព័ន្ធខ្លះៗបានអះអាងយ៉ាងខ្លាំងថា យន្តការថ្នាក់ជាតិបច្ចុប្បន្ន សំរាប់ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនឹង CBTA ពោលគឺ គណៈកម្មាធិការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ (NTTCC) នៅខ្វះអ្នកតំណាងដ៏សក្តិសិទ្ធិពីអ្នកពាក់ព័ន្ធសំខាន់ៗ ជាពិសេសពីវិស័យឯកជន និងជួបប្រជុំមិនបានទៀងទាត់សោះ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការអនុវត្ត CBTA ឱ្យបានស័ក្តិសិទ្ធិ និងទាន់ពេលតាមវិធីពិគ្រោះយោបល់ពិតប្រាកដ ។

*អនុសាសន៍ ៨:*

- គណៈកម្មាធិការ NTTCC គួរតែរៀបចំឡើងវិញ ដើម្បីពង្រឹងការងារ ហើយកិច្ចប្រជុំក៏គួរធ្វើឡើងឱ្យបានទៀងទាត់ ដោយមានការចូលរួមពីអ្នកតំណាងវិស័យឯកជនច្រើនផ្នែក និងអ្នកតំណាងជាន់ខ្ពស់មានសិទ្ធិសំរេចនៃស្ថាប័នរដ្ឋ ។
- រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដូចជា ADB គួរផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ NTTCC និងទីភ្នាក់ងារចូលរួមការងារ ដើម្បីពង្រឹងសមត្ថភាពបុគ្គលិក ជួយឱ្យពួកគេបំពេញមុខងារបានកាន់តែល្អនៅតាមដំណាក់កាលនីមួយៗ នៃការរចនារៀបចំ និងអនុវត្ត TTF-CBTA ។

*លទ្ធផលស្រាវជ្រាវ ៩:*

- ជំងឺហត្ថលេខាមុន រួចចាំដោះស្រាយតាមក្រោយ" អ្នកពាក់ព័ន្ធសំខាន់ៗជាច្រើន បានរកឃើញនៅក្នុង TTF-CBTA និងសមាហរណកម្មអនុតំបន់ GMS ថាជាកត្តាមូលដ្ឋាន និងជាបញ្ហាចោទយ៉ាងធំ ក្នុងការរចនារៀបចំ និងអនុវត្តការផ្តួចផ្តើមគំនិតទាំងនេះ ជាពិសេសពាក់ព័ន្ធនឹងតួនាទីរបស់ ADB ។ រឿងនេះពាក់ព័ន្ធនឹងស្ថានភាព ដូចជា ការអនុវត្តកិច្ចព្រមព្រៀង CBTA ដែលប្រឈមនឹងសំពាធការិយាធិបតេយ្យ និង/ឬ នយោបាយខ្លាំងក្លាមកពីទាំងខាងក្នុង និងខាងក្រៅ បណ្តាប្រទេស GMS ដើម្បីចុះហត្ថលេខាយ៉ាងប្រញាប់ប្រញាល់លើកិច្ចព្រមព្រៀងដ៏សំខាន់ និងស្មុគស្មាញ មុនពេលការងារត្រៀមរៀបចំដ៏ចាំបាច់បានអនុវត្តហើយស្រេចបាច់ និងសមស្រប ដើម្បីវិភាគពីផលប៉ះពាល់ជាយថាហេតុ ទៅលើប្រទេស GMS នានា ព្រមទាំងកំណែទំរង់លើបទបញ្ញត្តិរបស់ប្រទេសនីមួយៗ និងការចរចាទ្វេភាគីផ្សេងៗ ដែលត្រូវធ្វើ ។ ការចុះហត្ថលេខា ក៏បានមើលស្រាលជារឿយៗ លើបញ្ហាប្រឈមដ៏ពិបាកៗក្នុងការអនុវត្ត ជាពិសេសសំរាប់ប្រទេសអភិវឌ្ឍន៍តិចជាគេ (LDCs) មួយចំនួន ដែលជាសមាជិកក្នុង GMS និងតំរូវការពង្រឹងជាមុននូវសមត្ថភាពវិជ្ជាជីវៈ និងសមត្ថភាពស្ថាប័នសំខាន់ៗក្នុងស្រុកមួយចំនួន ដើម្បីជួយឱ្យការងារអនុវត្តបានស័ក្តិសិទ្ធ និងស្របតាមពេលវេលាដែលបានព្រមព្រៀង ។

*អនុសាសន៍ ៩:*

- រដ្ឋាភិបាលកម្ពុជា និងស្ថាប័នរដ្ឋសំខាន់ៗ ដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង TTF-CBTA និងការផ្តួចផ្តើមគំនិតផ្សេងៗរបស់ GMS ដោយមានភាពជាដៃគូយ៉ាងជិតស្និទ្ធ ជាមួយអ្នកពាក់ព័ន្ធក្នុងវិស័យឯកជនផងត្រូវធ្វើការយ៉ាងខ្លាំងក្លាជាមួយបណ្តាប្រទេស GMS ADB និងដៃគូអភិវឌ្ឍន៍សំខាន់ៗឯទៀត ដើម្បីដោះស្រាយបញ្ហាប្រឈមនៅសេសសល់ ដែលអាចមានផលប៉ះពាល់ច្រើន ទៅលើជោគជ័យនៃការផ្តួចផ្តើមគំនិតធ្វើសមាហរណកម្មក្នុងអាស៊ាន និង GMS ។

*លទ្ធផលស្រាវជ្រាវ ១០:*

- អ្នកពាក់ព័ន្ធជាច្រើនបានគូសបញ្ជាក់ថា សមត្ថភាពករិតទាបជារឿយៗ និងមិនស្មើគ្នា ហើយនិងកង្វះធនធាននៅក្នុងវិស័យឯកជន (ក៏ដូចជា សមាគម និងអង្គភាពកំពូលៗ) និងជាពិសេសនៅក្នុងស្ថាប័នរដ្ឋខ្លះៗ

ដែលនៅកំពុងប្រឹងប្រែងកសាងសមត្ថភាពស្ថាប័ន បានបង្កឧបសគ្គធ្វើឱ្យយឺតពេល និងអនុវត្តមិនបានស្មើគ្នាល្អនូវកិច្ចព្រមព្រៀង CBTA ។

*អនុសាសន៍ ១០:*

- ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍ដទៃទៀត គួរផ្តល់ជំនួយគាំទ្រការកសាងសមត្ថភាពដល់ស្ថាប័នរដ្ឋសំខាន់ៗ ដូចជា អគ្គនាយកដ្ឋានគយ និងកាំកុងត្រូល និងអ្នកពាក់ព័ន្ធសំខាន់ៗក្នុងវិស័យឯកជន ដើម្បីពង្រឹងសមត្ថភាព និងជំនាញវិជ្ជាជីវៈ ដូចជា ក្នុងបច្ចេកទេសមន្ទីរពិសោធន៍អនាម័យ និងភូតគាមអនាម័យ (SPS) ក្នុងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន និងការសំរួលដល់ការដឹកជញ្ជូន ។
- កម្មវិធីកសាងសមត្ថភាព ដែលផ្តោតចំលើអ្នកវិជ្ជាជីវៈវ័យក្មេងៗ និងស្តីពីការផ្តួចផ្តើមគំនិតធ្វើសមាហរណកម្មពាណិជ្ជកម្មក្នុងតំបន់ និងអនុតំបន់ គួរប្រើជាយានដើម្បីសំរេចការងារ ដោយមានការគាំទ្រខ្លាំងនិងការប្តេជ្ញាចិត្តពីពួកដៃគូអភិវឌ្ឍន៍ និងដៃគូជាស្ថាប័នស្រាវជ្រាវនៅតាមប្រទេស ។
- ដើម្បីសំរេចបានការអភិវឌ្ឍសមត្ថភាពស្ថាប័នក្នុងរយៈពេលវែង អំពីកិច្ចព្រមព្រៀង TTF-CBTA ដៃគូអភិវឌ្ឍន៍ ដូចជា ADB គួរធ្វើវិនិយោគធនធានជាយុទ្ធសាស្ត្រ នៅក្នុងស្ថាប័នពាក់ព័ន្ធមូលដ្ឋានសំខាន់ៗ (រដ្ឋាភិបាល វិស័យឯកជន និងវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយ) សំរាប់ការពិគ្រោះយោបល់ ការរចនារៀបចំ និងការអនុវត្តគំរោង ជាជាងពឹងផ្អែកខ្លាំងទៅលើទីប្រឹក្សាបច្ចេកទេស រយៈពេលខ្លីមកពីបរទេស ។

*លទ្ធផលស្រាវជ្រាវ ១១:*

- ផលប្រយោជន៍ចាក់ឫសរបស់អ្នកពាក់ព័ន្ធសំខាន់ៗក្នុងវិស័យឯកជន ជាពិសេស អត្ថប្រយោជន៍ ពាណិជ្ជកម្មសំរាប់អាជីវកម្មប្រកួតប្រជែង ត្រូវបានគូសបញ្ជាក់ដោយភាគីពាក់ព័ន្ធជាច្រើន ថាជាបញ្ហារាំងស្ទះចំបងដល់ការពិគ្រោះយោបល់ និងសហប្រតិបត្តិការដ៏ស័ក្តិសិទ្ធិ ក្នុងការអនុវត្តកិច្ចព្រមព្រៀង CBTA និងកិច្ចព្រមព្រៀងឆ្លងកាត់ព្រំដែនជាប់ពាក់ព័ន្ធ ។
- អ្នកពាក់ព័ន្ធបានបញ្ជាក់ពីការបារម្ភថា ការចូលរួមចំណែករបស់វិស័យឯកជន ច្រើនតែជាការត្រួតត្រា ឬការជះឥទ្ធិពល ដោយក្រុមហ៊ុនធំៗមួយចំនួនតូច ដែលទំនងទទួលបានផលចំណេញខាងពាណិជ្ជកម្មពីកិច្ច ព្រមព្រៀង CBTA និងរបៀបរបបផ្សេងៗទៀតនៃ TTF ឆ្លងកាត់ព្រំដែន ។

*អនុសាសន៍ ១១:*

- ប្រសិនបើគេចង់ប្រើ TTF-CBTA ធ្វើជាយានសំរាប់សំរួលសកម្មភាពអាជីវកម្មប្រកួតប្រជែង និងពាណិជ្ជកម្មនៅក្នុង GMS នោះ ការផ្តួចផ្តើមគំនិត និងយន្តការនៃ TTF-CBTA គួរតែរចនារៀបចំទាំងនៅថ្នាក់ជាតិ និងអនុតំបន់ ដើម្បីធានានូវសមធម៌ក្នុងការទទួលបានព័ត៌មាន អំពីអត្ថប្រយោជន៍នៃការផ្តួចផ្តើមគំនិតទាំងនេះ សំរាប់វិស័យឯកជន និងក្នុងការទទួលបានឱកាស ដើម្បីចូលរួមក្នុងយន្តការពិគ្រោះយោបល់សំខាន់ៗ រួមទាំង NTTCC និង G-PSF ផង ។

- តំណាងអ្នកពាក់ព័ន្ធសំខាន់ៗមកពីវិស័យឯកជន គួរជាតំណាងពិតប្រាកដ នូវផលប្រយោជន៍រួមរបស់វិស័យ និងឧស្សាហកម្មនានា ដែលទទួលរងផលប៉ះពាល់ ជាជាងតំណាងឱ្យបុគ្គលដ៏មានឥទ្ធិពល និងសាជីវកម្មធំៗ តែមួយចំនួនតូចនោះ ។

*លទ្ធផលស្រាវជ្រាវ ១២:*

- អ្នកពាក់ព័ន្ធ បានចង្អុលបង្ហាញពីបញ្ហាមិនទាន់ដោះស្រាយជាច្រើន ខាងបទបញ្ញត្តិច្បាប់ និងគោលនយោបាយ (ដូចជា ច្បាប់ធានារ៉ាប់រង ដឹកជញ្ជូន និងចរាចរណ៍) ក្នុងបណ្តាប្រទេស GMS ដែលនៅតែចោទបញ្ហាខ្លាំង និងបង្កការឃឹតយ៉ាវអស់សោហ៊ុយច្រើន ដល់រថយន្តដឹកទំនិញ និងរថយន្តដឹកអ្នកដំណើរ នៅពេលឆ្លងកាត់ព្រំដែន[៣] ។

*អនុសាសន៍ ១២:*

- រដ្ឋាភិបាលនៃបណ្តាប្រទេស GMS និង ADB គួរធ្វើការជាមួយគ្នា កំណត់តារាងពេលឱ្យប្រាកដនិយម និងមានលំដាប់លំដោយម៉ត់ចត់ ដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ក្នុងវិស័យឯកជន ដើម្បីកាត់បន្ថយ និងសំរួលបញ្ហាខុសគ្នាផ្សេងៗ ក្នុងវិធានការខាងការកំណត់ស្តង់ដារ គោលនយោបាយ វិធាន និងបទបញ្ញត្តិផ្សេងៗ ដូចជា នៅក្នុងច្បាប់ចរាចរណ៍ និងគោលនយោបាយធានារ៉ាប់រង នៅតាមប្រទេសនីមួយៗជាដើម ។ ការពង្រឹងអនុវត្តច្បាប់ និងបទបញ្ញត្តិ ក៏គួរជំរុញផងដែរ ។

*លទ្ធផលស្រាវជ្រាវ ១៣:*

- អ្នកពាក់ព័ន្ធជាច្រើនបានបញ្ជាក់ថា ឆន្ទៈនយោបាយមិនស្មើកំលាំងគ្នា និងកង្វះឆន្ទៈក្នុងការអនុវត្តឱ្យបានសក្តិសិទ្ធិ និងមានសមធម៌ នូវកិច្ចព្រមព្រៀង CBTA ក្នុងចំណោមរដ្ឋជាសមាជិក GMS និងវិធានការការពារផលិតផលខ្លួន ដែលរដ្ឋមួយចំនួនបន្តអនុវត្ត ។ ចំណុចបារម្ភនេះ ទំនងកាន់តែធ្ងន់ធ្ងរឡើងទៀត ដោយសារឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចសាកល និងតំបន់ ។

*អនុសាសន៍ ១៣ :*

- រដ្ឋជាសមាជិក GMS គួរប្រើដំណើរការនៃកិច្ចប្រជុំកំពូល GMS អាស៊ាន និងអាស៊ាន+៣ និងវិធានការឆ្លើយតបនឹងវិបត្តិរបស់ខ្លួន ដើម្បីបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តធ្វើសមាហរណកម្មក្នុងតំបន់ និងអនុតំបន់ ដោយផ្អែកលើពាណិជ្ជកម្មសេរី និងយុត្តិធម៌ និងការបដិសេធវិធានការការពារផលិតផលក្នុងស្រុក ។ ដោយឡែកបណ្តាប្រទេសអភិវឌ្ឍន៍តិចជាងគេ (LDCs) នៅក្នុង GMS គួរទទូចឱ្យមានកិច្ចសហការ និងគាំទ្រពីអាស៊ាន និង អាស៊ាន+៣ ដើម្បីឱ្យមានជំនួយអភិវឌ្ឍន៍អន្តរជាតិកាន់តែច្រើន និងកាន់តែផ្តោតចំគោលដៅ ដើម្បីជួយភ្ជិតគំលាតអភិវឌ្ឍន៍នៅក្នុងអាស៊ាន និង អាស៊ាន+៣ ។

---

៣ ឱ. គោលនយោបាយធានារ៉ាប់រងបច្ចុប្បន្ន សំរាប់តែប្រទេសកម្ពុជាប៉ុណ្ណោះ និងមិនសំរាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែនទេ ។

# ជំពូកទី ១០

# ការចូលរួមរបស់កសិករអ្នកប្រើប្រាស់ទឹក និងជោគជ័យនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រដោយកសិករៈ ករណីសិក្សានៅសហគមន៍កសិករអ្នកប្រើប្រាស់ទឹក អូរត្រែង ខេត្តកំពង់ស្ពឺ[១]

*ដោយកញ្ញា រស់ បណ្ឌិត*

## ១០.១. សេចក្តីផ្តើម

ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ឃើញមានអនុវត្តក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ដើម្បីធានាអោយមានចីរភាព និងសមធម៌នៅក្នុងការប្រើប្រាស់ និងការបែងចែកធនធានដល់ប្រជាជនមូលដ្ឋាន ។ ប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ ដោយមានការចូលរួមពីកសិករ គឺជាឧទាហរណ៍មួយនៃការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ដែលចាប់ផ្តើមឡើងតាំងពីទសវត្សរ៍១៩៨០ ។ ការរៀបចំប្រព័ន្ធគ្រប់គ្រងបែបនេះ ផ្អែកលើការសន្មតថា កសិករអ្នកប្រើប្រាស់ទឹកមានសមត្ថភាព ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រខ្នាតតូច ដោយសារពួកគេមានចំណេះដឹងអំពីធារាសាស្ត្រនៅក្នុងតំបន់របស់គេ ។

ប្រទេសកម្ពុជា បានអនុវត្តប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ ដោយមានការចូលរួមពីកសិករតាំងពីឆ្នាំ២០០០ ក្រោមកម្មវិធី "ការគ្រប់គ្រង និងអភិវឌ្ឍន៍ធារាសាស្ត្រដោយមានការចូលរួម" ដើម្បីលើកកំពស់ប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រនៅក្នុងប្រទេស និងជួយដោះស្រាយកង្វះថវិការបស់រដ្ឋាភិបាល និងម្ចាស់ជំនួយ ។ កម្មវិធីនេះមានទិសដៅផ្តល់សិទ្ធិអោយកសិករ ធ្វើការគ្រប់គ្រងធារាសាស្ត្រក្នុងតំបន់របស់ខ្លួន ដោយបង្កើតជាសហគមន៍កសិករអ្នកប្រើប្រាស់ទឹក ដើម្បីជួយលើកកំពស់កំរិតជីវភាពតាមរយៈការបង្កើនផលិតកម្ម និងប្រាក់ចំណូល ។

ការគ្រប់គ្រងធារាសាស្ត្រ ដោយមានការចូលរួមពីកសិករមានសារៈសំខាន់ណាស់ ពីព្រោះក្រោយពេលបានរៀបចំជាសហគមន៍ហើយ ពួកកសិករនឹងចូលរួមគ្រប់គ្រងធារាសាស្ត្រក្នុងតំបន់របស់ខ្លួន ដោយជួយលើកកំពស់គុណភាពនៃការងារនេះឱ្យទទួលបានជោគជ័យ ។ កន្លងមក មានការសិក្សាតិចតួចនៅឡើយលើសំនួរថា តើការចូលរួមរបស់កសិករ អាចជួយជំរុញជោគជ័យរបស់សហគមន៍ ឬយ៉ាងណា និងថាតើកត្តាអ្វីដែលជំរុញអោយកសិករចូលរួមនៅក្នុងសហគមន៍ ។ ការសិក្សានេះ មានគោលដៅស្វែងយល់ពីបញ្ហាខាងលើ ដោយព្យាយាមឆ្លើយនឹងសំនួរគន្លឹះចំនួន ៣ ដូចខាងក្រោមៈ

១. តើការចូលរួមរបស់កសិករនៅក្នុងការគ្រប់គ្រងធារាសាស្ត្រមានប៉ុន្មានប្រភេទ?

២. តើការចូលរួមរបស់កសិករក្នុងប្រភេទនីមួយៗ ចូលរួមចំណែកដល់ជោគជ័យរបស់សហគមន៍យ៉ាងណាខ្លះ?

៣. តើកត្តាអ្វីដែលជំរុញអោយកសិករចូលរួម?

---

១ កញ្ញា រស់ បណ្ឌិត ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ។

ការសិក្សានេះ បានជ្រើសរើសសហគមន៍កសិករអ្នកប្រើប្រាស់ទឹកអូរត្រែង ធ្វើជាករណីសិក្សាដោយផ្អែកលើលក្ខណៈសមស្រប ៣ គឺ (១) ប្រព័ន្ធធារាសាស្ត្រអូរត្រែង ជាប្រព័ន្ធមួយក្នុងចំណោមប្រព័ន្ធទាំង១២ ដែលរដ្ឋាភិបាលបានជ្រើសរើស សំរាប់ដំណើរការកម្មវិធី "ការគ្រប់គ្រង និងអភិវឌ្ឍន៍ធារាសាស្ត្រដោយមានការចូលរួម" (២) សហគមន៍នេះ មានការចូលរួមច្រើនពីកសិករ និង (៣) សហគមន៍នេះ មានការចាត់ទុកជាទូទៅថា ទទួលជោគជ័យខ្លាំងជាងគេនៅកម្ពុជាក្នុងឆ្នាំ២០០៨ ។ សហគមន៍មានជោគជ័យ ពីព្រោះអាចដំណើរការដោយខ្លួនឯងនូវការងារគ្រប់គ្រងធារាសាស្ត្រ ហើយជីវភាពប្រជាជនក៏បានរីកចំរើន (កិច្ចសម្ភាសន៍ក្រៅផ្លូវការជាមួយបុគ្គលិកក្រសួងធនធានទឹក និងឧតុនិយម ថ្ងៃទី០៣ តុលា ២០០៨) ។

សហគមន៍កសិករអ្នកប្រើប្រាស់ទឹកអូរត្រែង មានទីតាំងស្ថិតនៅក្នុងឃុំព្រៃញាតិ និងឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ សហគមន៍នេះ មានសមាជិកមកពី ១៣ភូមិ ក្នុងឃុំព្រៃញាតិ និងឃុំជង្រុក ។ កសិករជាសមាជិកសហគមន៍ ប្រកបរបរធ្វើស្រែវស្សា និងធ្វើស្រែប្រាំង ហើយនិងដាំដំណាំផ្សេងៗ ដូចជា ឪឡឹក ត្រឡាច ល្ពៅ នៅរដូវប្រាំង ។

## ១០.២. ការចូលរួមរបស់កសិករក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ

ការសិក្សានេះរកឃើញថា ការចូលរួមរបស់កសិករនៅក្នុងសហគមន៍កសិករអ្នកប្រើប្រាស់ទឹកអូរត្រែង មានកំរិតខ្ពស់ ទាំងចំនួនសមាជិក ការចូលរួមជាថវិកា ការចូលរួមជាកំលាំងពលកម្ម និងការចូលរួមក្នុងការសំរេចចិត្ត ។ ការចូលរួមនេះ អាចបែងចែកជា ៤ប្រភេទ: ការចូលរួមបង់ថ្លៃសេវាប្រើប្រាស់ទឹក ការចូលរួមក្នុងការងារចែកចាយទឹក ការចូលរួមថែទាំប្រព័ន្ធប្រឡាយនិងទំនប់ និងការចូលរួមប្រជុំក្នុងសហគមន៍ ។

### ការចូលរួមបង់ថ្លៃសេវាប្រើប្រាស់ទឹក

ការចូលរួមបង់ថ្លៃសេវាប្រើប្រាស់ទឹក នៅក្នុងសហគមន៍កសិករអ្នកប្រើប្រាស់ទឹកអូរត្រែង មានកំរិតខ្ពស់ ។ ការសិក្សានេះរកឃើញថា កសិករអ្នកប្រើប្រាស់ទឹកស្ទើរតែគ្រប់គ្នា បានបង់ថ្លៃសេវាទៅអោយគណៈកម្មការ លើកលែងតែកសិករអ្នកខូចខាតផលដំណាំ ដែលតែងតែស្ទាក់ស្ទើរ និងសុំពន្យារពេលបង់ថ្លៃ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏កសិករទាំងនោះ នៅតែចូលរួមបង់ថ្លៃបានមួយភាគទៅអោយគណៈកម្មការដែរ ។

ការចូលរួមបង់ថ្លៃសេវាប្រើប្រាស់ទឹករបស់កសិករ បានជួយជំរុញជោគជ័យរបស់សហគមន៍ តាមរយៈការផ្តល់ជាថវិកាយ៉ាងទៀងទាត់ សំរាប់ដំណើរការប្រព័ន្ធ និងការថែទាំប្រព័ន្ធប្រឡាយ ដើម្បីអាចបែងចែកទឹកបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់កសិករ និងការផ្តល់ជាប្រាក់វិភាគទានដល់គណៈកម្មការ សំរាប់ការចូលរួមចំណែកក្នុងការងារគ្រប់គ្រងប្រព័ន្ធ ។ ម្យ៉ាងទៀត ការចូលរួមបង់ថ្លៃសេវារបស់កសិករ ក៏ជួយបង្កើនចំណូលដល់សហគមន៍ ដែលធ្វើអោយសហគមន៍ពុំសូវពឹងផ្អែកលើជំនួយពីខាងក្រៅ និងអាចដំណើរការដោយខ្លួនឯងបាន ។ មានកត្តាចំនួន ៦ ដែលជំរុញអោយកសិករចូលរួមបង់ថ្លៃសេវាប្រើប្រាស់ទឹក ។

*កត្តាទីមួយ:* កសិករ បង់ថ្លៃសេវាប្រើប្រាស់ទឹក ពីព្រោះពួកគាត់បានយល់ដឹងពីសារៈសំខាន់ នៃការបង់ថ្លៃសេវា ។ កសិករ មានការយល់ដឹង ពីព្រោះពួកគាត់មានបទពិសោធន៍ក្នុងការរួបរួមគ្នាចូលជាថវិកា សំរាប់យកទៅ

ថែទាំប្រព័ន្ធប្រឡាយ តាំងពីមុនពេលមានសហគមន៍ ព្រមទាំងធ្លាប់ទទួលបានការបណ្ដុះបណ្ដាល និងការណែនាំពីសំណាក់គណៈកម្មការ អាជ្ញាធរដែនដី និងក្រសួងធនធានទឹក និងឧតុនិយម ជាច្រើនលើក ។

*កត្តាទីពីរ:* កសិករចូលរួមបង់ថ្លៃសេវា ពីព្រោះពួកគាត់ទទួលបានផលចំណេញច្រើនពីប្រព័ន្ធ ។ ជាក់ស្ដែង កសិករតែងតែប្រើប្រាស់ទឹកក្នុងប្រព័ន្ធ សំរាប់ជួយសង្គ្រោះស្រូវវស្សានៅពេលទឹកភ្លៀងមិនគ្រប់ ហើយនៅរដូវប្រាំង ពួកគាត់តែងប្រើប្រាស់ទឹកក្នុងប្រព័ន្ធ ដើម្បីដាំដំណាំដូចជា ឪឡឹក ត្រឡាច ឬល្ពៅ ។ ស្រូវវស្សា ផ្ដល់ជាស្បៀងសំរាប់គ្រួសារ រីឯដំណាំផ្សេងទៀត ផ្ដល់ជាប្រាក់ចំណូល ។

*កត្តាទីបី:* កសិករបង់ថ្លៃសេវា ពីព្រោះវាមានកំរិតទាប បើប្រៀបធៀបទៅនឹងផលចំណេញដែលទទួលបាន ។ ជាក់ស្ដែង កសិករអាចរកបាន ២លានរៀល ពីការលក់ដំណាំក្នុងមួយហិកតា ដោយគ្រាន់តែចំណាយ ៤០.០០០រៀល លើថ្លៃសេវាប្រើប្រាស់ទឹកប៉ុណ្ណោះ ។ តំលៃសេវានេះ ក៏មានកំរិតទាបដែរ បើប្រៀបធៀបទៅនឹងការចំណាយលើការជីកស្រះឯកជន សំរាប់យកទឹកប្រើប្រាស់ ។

*កត្តាទីបួន:* កសិករបង់ថ្លៃសេវា ដោយសារមើលឃើញថា ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ មានគុណភាពល្អ ។ នៅពេលប្រព័ន្ធធារាសាស្ត្រដំណើរការល្អ កសិករជឿថា គណៈកម្មការបានប្រើប្រាស់ថវិកាប្រមូលមកពីការបង់ថ្លៃសេវា ទៅលើការជួសជុល និងការថែទាំប្រព័ន្ធ ដូច្នេះ ពួកគេក៏មានទឹកចិត្តចូលរួមបង់ថ្លៃសេវា ។

*កត្តាទីប្រាំ:* ភាពជាអ្នកដឹកនាំរបស់គណៈកម្មការ ដើរតួនាទីសំខាន់ណាស់ ក្នុងការជំរុញអោយកសិករចូលរួមបង់ថ្លៃសេវាប្រើប្រាស់ទឹក ។ នៅពេលគណៈកម្មការធ្វើការគ្រប់គ្រងប្រព័ន្ធដោយយុត្តិធម៌ និងមានតម្លាភាព តែងគិតគូរដល់ផលប្រយោជន៍សហគមន៍ជាធំ ចេះបែងចែកទឹកជូនកសិករ ថែទាំប្រព័ន្ធ និងដោះស្រាយបញ្ហារបស់កសិករ កសិករច្បាស់ជាជឿទុកចិត្ត គោរពដល់គណៈកម្មការ និងពេញចិត្តចូលរួមបង់ថ្លៃសេវា ។

*កត្តាទីប្រាំមួយ:* ការដាក់សំពាធពីកសិករអ្នកប្រើប្រាស់ទឹកផងគ្នា ក៏ជួយជំរុញអោយកសិករយល់ព្រមបង់ថ្លៃសេវាដែរ ។ កសិករ មិនចង់អាម៉ាស់មុខជាមួយអ្នកជិតខាងទេ នៅពេលឃើញគេចូលរួមបង់ថ្លៃសេវាយ៉ាងកុះករ ។

### ការចូលរួមក្នុងការងារចែកចាយទឹក

ការចូលរួមក្នុងការងារចែកចាយទឹករបស់កសិករ រួមមាន ការស្នើសុំទឹក ការតាមដានទឹក ការជីកប្រឡាយរង ការចែករំលែកទឹកជាមួយអ្នកជិតខាង ការត្រួតពិនិត្យកុំអោយមានលំហៀរទឹកជន់លិចដំណាំអ្នកជិតខាង និងការចូលរួមបូមទឹកពីអាងមកដាក់ស្រែ ។

ការចូលរួមក្នុងការងារចែកចាយទឹកនេះ បានលើកកំពស់ជោគជ័យរបស់សហគមន៍ តាមរយៈការជួយធានាអោយមានការបែងចែកទឹកទាន់ពេលវេលា និងគ្រប់គ្រាន់ដល់កសិករ ។ គណៈកម្មការ ត្រូវការនូវការចូលរួមពីកសិករ ដើម្បីធានាអោយការបែងចែកទឹកមានប្រសិទ្ធភាព ។ ការងារបែងចែកទឹក រួមបញ្ចូលកិច្ចការជាច្រើន ដូចជា ការជីកប្រឡាយរង ការទប់ទឹក និងការត្រួតពិនិត្យទ្វារទឹក ។ ការចូលរួមរបស់កសិករនៅក្នុងការចែកចាយទឹក ក៏ជួយកាត់បន្ថយការបាត់បង់ទឹកក្នុងសហគមន៍ និងការចំណាយកំលាំងរបស់គណៈកម្មការដែរ ។

មានកត្តាបី ដែលជំរុញអោយកសិករចូលរួមក្នុងការងារចែកចាយទឹកជាមួយគណៈកម្មការ ពោលគឺ ចំណេះដឹងរបស់កសិករអំពីលក្ខន្តិកៈសហគមន៍ ដែលមានចែងពីការចូលរួមរបស់សមាជិក ក្នុងការងារចែកចាយទឹក ការពង្រឹងលក្ខន្តិកៈរបស់សហគមន៍លើការបែងចែកទឹក និងផលចំណេញទទួលបានពីប្រព័ន្ធធារាសាស្ត្រ ។ កសិករ

បានយល់ដឹងពីលក្ខន្តិកៈ ពីព្រោះធ្លាប់ចូលរួមបង្កើតលក្ខន្តិកៈនេះ និងទទួលការបណ្តុះបណ្តាល និងការណែនាំពីក្រសួងជំនាញ អាជ្ញាធរដែនដី និងគណៈកម្មការ ។ គណៈកម្មការ ក៏ធ្វើការពង្រឹងលក្ខន្តិកៈ ដោយបែងចែកទឹកឱ្យតែកសិករណា ដែលបានដាក់ពាក្យស្នើសុំទឹកដល់គណៈកម្មការ ។ ម្យ៉ាងទៀត កសិករចូលរួមក្នុងការងារចែកចាយទឹក ព្រោះពួកគាត់មើលឃើញពីផលចំណេញដែលបានមកពីប្រព័ន្ធ ។ កសិករចូលរួមចែកចាយទឹក ព្រោះចង់បានទឹកទៅដល់ស្រែរបស់គាត់ឆាប់ៗ និងមុនកសិករដទៃ ដើម្បីអាចចាប់ផ្តើមដាំ និងប្រមូលផលមុនគេ ហើយលក់បានថ្លៃខ្ពស់ ។

### ការចូលរួមថែទាំប្រព័ន្ធប្រឡាយ និងទំនប់

ការចូលរួមរបស់កសិករក្នុងការថែទាំប្រព័ន្ធប្រឡាយ និងទំនប់ មានជាអាទិ៍ ការជួយរាយការណ៍ពីការខូចខាត និងវិភាគទានជាកំលាំងពលកម្ម សម្ភារៈ និងថវិកា ដើម្បីធ្វើការជួសជុល ។ កិច្ចសម្ភាសន៍ជាមួយគណៈកម្មការ បានអោយដឹងថា មានការតម្រូវឱ្យកសិករចូលរួមលើការងារថែទាំទ្រង់ទ្រាយតូច ដូចជា ដាំស្មៅ ដាំកូនឈើ ចាក់ដីបំពេញរណ្តៅនិងរន្ធតូចៗ ជីកនិងសំអាតប្រឡាយរង ជីកដីដាក់លូទឹកជាដើម ។ សំរាប់ការងារដែលទាមទារជំនាញពិសេស ឬនៅពេលសហគមន៍ខ្វះកំលាំងពលកម្ម គណៈកម្មការត្រូវជួលកំលាំងពលកម្ម ។

ការចូលរួមថែទាំប្រព័ន្ធប្រឡាយ និងទំនប់ ជួយបង្កើនជោគជ័យរបស់សហគមន៍ តាមរយៈការជួយកាត់បន្ថយពលកម្មរបស់គណៈកម្មការ ក្នុងការថែទាំ និងជួសជុលប្រព័ន្ធប្រឡាយ ធ្វើអោយគណៈកម្មការមានទឹកចិត្តចូលរួមក្នុងការងារគ្រប់គ្រងសហគមន៍ ។ ការចូលរួមផ្តល់ព័ត៌មានពីការខូចខាតផ្សេងៗ លើប្រព័ន្ធប្រឡាយ និងទំនប់ ជួយកាត់បន្ថយការចំណាយរបស់សហគមន៍ និងធ្វើអោយការថែទាំមានប្រសិទ្ធភាព ។

មានកត្តាពីរ ដែលជំរុញអោយកសិករចូលរួមថែទាំប្រព័ន្ធប្រឡាយ និងទំនប់ ។ កត្តាទីមួយ កសិករយល់ច្បាស់ថា ការជួយធានាអោយមានការបែងចែកទឹកគ្រប់គ្រាន់ និងទាន់ពេលវេលា ជារឿងសំខាន់ណាស់ ។ កត្តាទីពីរ ការចូលរួមរបស់កសិករ ក៏អាស្រ័យផងដែរទៅលើការដឹកនាំរបស់គណៈកម្មការ ។ កសិករតែងតែចូលរួមកុះករ ប្រសិនបើគេមើលឃើញថា គណៈកម្មការក៏ចូលរួមក្នុងកិច្ចការថែទាំនេះដែរ ។ ជាក់ស្តែង មេភូមិម្នាក់បានលើកឡើងថា "កសិករត្រូវការអ្នកដឹកនាំ ដើម្បីធ្វើការងារ" ។

### ការចូលរួមប្រជុំក្នុងសហគមន៍

កិច្ចប្រជុំសំខាន់ៗក្នុងសហគមន៍មាន ៤ដងក្នុងមួយឆ្នាំ គឺមាន កិច្ចប្រជុំមុនដាំ កិច្ចប្រជុំមុនប្រមូលផល កិច្ចប្រជុំក្រោយការលក់ផល និងកិច្ចប្រជុំក្រោយការប្រមូលថ្លៃសេវាប្រើប្រាស់ទឹក ។ ការសិក្សារកឃើញថា ក្នុងកិច្ចប្រជុំនីមួយៗ ការចូលរួមរបស់កសិករមាន ២ប្រភេទៈ ការចូលរួមរបស់កសិករក្នុងពេលប្រជុំ និងការចូលរួមបញ្ចេញយោបល់ក្នុងពេលប្រជុំ ។ ការចូលរួមប្រជុំទាំង ២ប្រភេទនេះ មានសារៈសំខាន់ណាស់ សំរាប់ជោគជ័យរបស់សហគមន៍ ពីព្រោះវាផ្តល់ឱកាសអោយកសិករបញ្ចេញមតិយោបល់ និងបញ្ជាក់ពីតំរូវការរបស់ខ្លួន ហើយគណៈកម្មការក៏អាចដាក់បញ្ចូលមតិយោបល់ទាំងនោះ ទៅក្នុងការសំរេចចិត្ត និងការធ្វើផែនការរបស់ខ្លួន ។ ដំណើរការនេះ ធ្វើអោយកសិករមានភាពជាម្ចាស់លើការសំរេចចិត្តរបស់គណៈកម្មការ និងសមិទ្ធផលនានារបស់សហគមន៍ ។ ការចូលរួមប្រជុំ ដើម្បីស្តាប់របាយការណ៍លើការចំណាយថវិកា និងធ្វើការចោទសួរដល់គណៈកម្មការ

ក៏ជួយបង្កើនតម្លាភាព និងទំនុកចិត្ត រវាងកសិករ និងគណៈកម្មការដែរ ។ ម្យ៉ាងទៀត ការអនុញ្ញាតអោយកសិករ នៅគ្រប់ទីតាំងក្នុងសហគមន៍ (ដើមប្រឡាយ កណ្ដាលប្រឡាយ និងចុងប្រឡាយ) មកចូលប្រជុំរួមគ្នា ផ្ដល់ឱកាសអោយពួកគាត់បានពិភាក្សាគ្នា ដែលអាចជួយកាត់បន្ថយជំលោះ និងការមិនយោគយល់គ្នា ក្នុងការងារចែកចាយទឹក ។

ការសិក្សានេះរកឃើញថា មានកត្តាជាច្រើន ដែលជំរុញអោយកសិករចូលរួមប្រជុំក្នុងសហគមន៍ ។ កសិករចូលប្រជុំនៅពេលពួកគាត់មិនសូវរវល់នឹងការងារស្រែចំការ នៅពេលគណៈកម្មការមានជំនាញ និងអំណាចក្នុងការប្រមូលកសិករ និងនៅពេលកសិករយល់ដឹងពីសារៈសំខាន់នៃការចូលប្រជុំ ។ ដោយឡែក កសិករចូលរួមបញ្ចេញមតិយោបល់នៅពេលពួកគាត់យល់ដឹងពីសិទ្ធិរបស់ខ្លួន នៅពេលគណៈកម្មការចេះលើកទឹកចិត្តអោយកសិករចូលរួមផ្ដល់យោបល់ និងបង្ហាញពីការយកចិត្តទុកដាក់លើមតិយោបល់ទាំងនោះ និងនៅពេលកសិករយល់ថា ការជជែកពិភាក្សាមានសារៈសំខាន់ សំរាប់ការរកចិញ្ចឹមជីវិតរបស់គាត់ ។

## ១០.៣. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

រដ្ឋាភិបាល បានខិតខំអនុវត្តប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រដោយកសិករ តាមរយៈការបង្កើតសហគមន៍កសិករអ្នកប្រើប្រាស់ទឹក ។ លទ្ធផលនៃការសិក្សានេះ បង្ហាញថា ដំណើរការរបស់សហគមន៍កសិករអ្នកប្រើប្រាស់ទឹក អាចទទួលបានជោគជ័យ លុះត្រាតែមានការចូលរួមពីកសិករអ្នកប្រើប្រាស់ទឹក ។ ការចូលរួមរបស់កសិករមាន ៤ប្រភេទៈ ការចូលរួមបង់ថ្លៃសេវាប្រើប្រាស់ទឹក ការចូលរួមក្នុងការងារចែកចាយទឹក ការចូលរួមថែទាំប្រព័ន្ធប្រឡាយ និងទំនប់ និងការចូលរួមប្រជុំក្នុងសហគមន៍ ។

ការចូលរួមរបស់កសិករ ជួយជំរុញជោគជ័យរបស់សហគមន៍អ្នកប្រើប្រាស់ទឹក តាមរយៈការផ្តល់ជាធនធាន និងព័ត៌មាន សំរាប់ជួយដល់ការដឹកនាំរបស់សហគមន៍ និងលើកកំពស់គុណភាពហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ។ ជាក់ស្តែង ការចូលរួមបង់ថ្លៃសេវាប្រើប្រាស់ទឹករបស់កសិករ ផ្ដល់ជាថវិកាសំរាប់ការថែទាំប្រព័ន្ធប្រឡាយ និងទំនប់អោយបានទៀងទាត់ ។ ការចូលរួមចែកចាយទឹករបស់កសិករ ជួយធានាអោយមានការផ្គត់ផ្គង់ទឹកបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់អ្នកប្រើប្រាស់ និងកាត់បន្ថយការប្រើប្រាស់ពលកម្មរបស់គណៈកម្មការ ។ ការចូលរួមថែទាំប្រឡាយ និងទំនប់របស់កសិករ ក៏ផ្ដល់ជាកំលាំងពលកម្ម និងព័ត៌មាន សំរាប់ជួយកាត់បន្ថយចំណាយលើការថែទាំរបស់សហគមន៍ និងលើកកំពស់គុណភាពហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ។ ការចូលរួមប្រជុំក្នុងសហគមន៍ ជួយផ្ដល់ជាព័ត៌មាន សំរាប់ធានាអោយមានការសំរេចចិត្តប្រកបដោយប្រសិទ្ធភាពរបស់គណៈកម្មការ ភាពជាម្ចាស់លើការគ្រប់គ្រង តម្លាភាព ការពេញចិត្ត និងទំនុកចិត្តគ្នា រវាងគណៈកម្មការ និងកសិករ ។

ការចូលរួមរបស់កសិករ មានកត្តាកំណត់ជាច្រើន ។ កត្តាទីមួយ ទាក់ទងនឹងការយល់ដឹងរបស់កសិករ អំពីសិទ្ធិ លក្ខន្តិកៈរបស់សហគមន៍ និងសារៈសំខាន់នៃការចូលរួម ។ ការយល់ដឹងរបស់កសិករជួយបង្កើនការចូលរួមរបស់កសិករ ទាំងក្នុងការបង់ថ្លៃសេវាប្រើប្រាស់ទឹក ការងារចែកចាយទឹក ការថែទាំប្រព័ន្ធប្រឡាយ និងទំនប់ និងការចូលរួមប្រជុំក្នុងសហគមន៍ ។ ក្នុងចំណុចនេះ រាជរដ្ឋាភិបាល និងអាជ្ញាធរដែនដី គួរផ្តោតការប្រឹងប្រែង លើការផ្ដល់ឱ្យកសិករនូវចំណេះដឹងពីសិទ្ធិ លក្ខន្តិកៈរបស់សហគមន៍ និងសារៈសំខាន់នៃការចូលរួម ។ កត្តាទីពីរ គឺការពង្រឹងលក្ខន្តិកៈ ដែលជួយបង្កើនការចូលរួមរបស់កសិករ ក្នុងការងារចែកចាយទឹក ប៉ុន្តែពុំមាន

ឥទ្ធិពលអ្វីលើការចូលរួមបង់ថ្លៃសេវាប្រើប្រាស់ទឹក ការចូលរួមថែទាំប្រព័ន្ធប្រឡាយ និងទំនប់ និងការចូលរួមប្រជុំក្នុងសហគមន៍របស់កសិករឡើយ ។ កត្តាទីបី ទាក់ទងនឹងផលចំណេញពីប្រព័ន្ធធារាសាស្ត្រ ដែលជួយបង្កើនការចូលរួមបង់ថ្លៃសេវាប្រើប្រាស់ទឹក ប៉ុន្តែគ្មានឥទ្ធិពលជំរុញការចូលរួមថែទាំប្រព័ន្ធប្រឡាយ និងទំនប់ និងការចូលរួមប្រជុំក្នុងសហគមន៍នោះទេ ។ ការចូលរួមថែទាំប្រព័ន្ធប្រឡាយ និងទំនប់ ព្រមទាំងការចូលរួមប្រជុំក្នុងសហគមន៍ ជាប់ទាក់ទងជាសំខាន់នឹងភាពជាអ្នកដឹកនាំ របស់គណៈកម្មការសហគមន៍ ដែលត្រូវចេះធ្វើការទន្ទឹមគ្នានឹងកសិករ ហើយមានជំនាញ និងអំណាចដើម្បីប្រមូលកសិករ ។

ដើម្បីលើកកំពស់ភាពជាអ្នកដឹកនាំរបស់គណៈកម្មការ ខាងរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងអាជ្ញាធរដែនដី ត្រូវជួយសំរបសំរួលលើដំណើរការរៀបចំសហគមន៍ ។ កសិករ ត្រូវជ្រើសរើសអ្នកដឹកនាំដោយខ្លួនឯង ជាពិសេស ត្រូវផ្តោតទៅលើអ្នកដឹកនាំ ដែលមានអាកប្បកិរិយាត្រឹមត្រូវ ព្រមទាំងមានចំណេះដឹង និងជំនាញលើការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រក្នុងតំបន់ ។ ការជ្រើសរើសអ្នកដឹកនាំ គួរផ្តោតផងដែរទៅលើអ្នកដែលមានឋានៈ ឬតួនាទីនៅក្នុងសហគមន៍ ។

ផលចំណេញពីប្រព័ន្ធធារាសាស្ត្រ ត្រូវតែខ្ពស់ជាងការចំណាយ ដើម្បីធានាអោយមានការចូលរួមពីកសិករ ។ ដូច្នេះ ថ្លៃសេវាប្រើប្រាស់ទឹកត្រូវមានកំរិតទាប ស្របទៅតាមផលចំណេញដែលទទួលបាន និងស្របទៅតាមតំលៃទឹកដែលអាចទទួលបានពីប្រភពផ្សេង ។ គណៈកម្មការត្រូវបញ្ចុះថ្លៃសេវាប្រើប្រាស់ ប្រសិនបើផលដំណាំរបស់កសិករជួបគ្រោះអន្តរាយ ។ ដើម្បីអោយមានការចូលរួមបង់ថ្លៃសេវា គណៈកម្មការ និងកសិករ ត្រូវមានទំនុកចិត្តគ្នាផងដែរ ។ ទំនុកចិត្តនេះអាចកើតមានឡើង អាស្រ័យលើអាកប្បកិរិយា ចំណេះដឹង និងជំនាញ ព្រមទាំងការសំរេចចិត្តរបស់គណៈកម្មការ ។ នៅពេលគណៈកម្មការធ្វើការគ្រប់គ្រងប្រព័ន្ធ ដោយយុត្តិធម៌ មានតម្លាភាព ចេះគិតគូរដល់ផលប្រយោជន៍សហគមន៍ជាធំ ខិតខំធ្វើការងារថែទាំប្រព័ន្ធ និងជួយដោះស្រាយបញ្ហាជូនសមាជិកកសិករ កសិករច្បាស់ជាផ្តល់ការជឿទុកចិត្តលើគណៈកម្មការនោះហើយ ។

ការចូលរួមរបស់កសិករអាចកើតឡើងបាន លុះត្រាតែសហគមន៍មានហេដ្ឋារចនារចនាសម្ព័ន្ធធារាសាស្ត្រល្អ ដែលទាមទារនូវការជួយគាំទ្រពីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងអាជ្ញាធរដែនដី ក្នុងការងារជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ ។ ជំនួយពីខាងក្រៅនេះ ក៏មានសារៈសំខាន់ក្នុងការលើកកំពស់ការដឹកនាំរបស់គណៈកម្មការ តាមរយៈការជួយសំរបសំរួលលើដំណើរការរៀបចំសហគមន៍ ការបណ្តុះបណ្តាលចំណេះដឹងដល់កសិករ និងការពង្រឹងលក្ខន្តិកៈរបស់សហគមន៍ ។ ដូច្នេះ ការសិក្សានេះ អាចធ្វើការសន្និដ្ឋានបានថា ដើម្បីធានាអោយមានការចូលរួមពីកសិករ ត្រូវមានជំនួយគាំទ្រពីខាងក្រៅ ។

ដើម្បីធានាអោយមានការចូលរួមពីកសិករ ក៏ត្រូវពិនិត្យទៅលើស្ថានភាពរស់នៅរបស់កសិករ នៅក្នុងសហគមន៍ផងដែរ ។ នៅតាមសហគមន៍ដែលកសិករធ្លាប់មានបទពិសោធន៍ចងក្រងជាក្រុមដោយខ្លួនឯង ដើម្បីគ្រប់គ្រងប្រព័ន្ធ ហើយត្រូវពឹងផ្អែកលើប្រព័ន្ធធារាសាស្ត្រដើម្បីចិញ្ចឹមជីវិត ការជំរុញអោយពួកគាត់ចូលរួម ពុំសូវជួបការលំបាកឡើយ ពីព្រោះគាត់ធ្លាប់មានប្រពៃណីសហការគ្នា និងចូលរួមគ្រប់គ្រងធារាសាស្ត្រ ។ កសិករក៏ចាប់អារម្មណ៍ចូលរួមក្នុងការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដែរ ប្រសិនបើពួកគាត់មានទីផ្សារសំរាប់លក់ផលិតផលដែលផ្តល់ជាប្រាក់ចំណូលបន្ថែមលើសន្តិសុខស្បៀងក្នុងគ្រួសារ ។

## បញ្ជីឯកសារបោះពុម្ពផ្សាយរបស់ CDRI


១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា: ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សាលេខ ១) ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល: ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ។

៣. Kannan, K. P. (មករា ១៩៩៧) *កំណែទំរង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធនិងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ។

៤. ជីម-ចរិយា ស្រ៊ុន-ពិធូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៊ុន-ដូរីណា និងរ៉ូប៊ីន-ប៊ុដឹលវី (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាខ្មែរថ្លៃ ៩.000រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និងឡុង-វូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.000រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨) *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥00រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥00រៀល ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato ឡុង-វូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជា: បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តំលៃ ៦.000រៀល ។

៩. តេង-យូគី ប៊ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនឌ្រូ (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥00រៀល ។

១០. Gorman, Siobhan, ជាមួយ ប៊ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា: ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ១០) ជាភាសាខ្មែរតំលៃ ៤.៥00រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ: ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរតំលៃ ៣.000រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និង ជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍: ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥00រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២000) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.000រៀល ។
១៤. Toshiyasu-Kato Jeffrey A. Kaplan, ច័ន្ទ-សុផល និង វៀល-សុភាព (សីហា ២000) *ប្រទេសកម្ពុជា: លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.000រៀល ។
១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២000) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរតំលៃ ១០.000រៀល ។
១៦. ស៊ុក បូរ័ក្ស (ធ្នូ ២000) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា: ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរថ្លៃ ៨.000រៀល ។
១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២00១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.000រៀល ។
១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សាវ៉ារី ប៊ុន-ដូរីណា Claude-Katz Sarthi-Acharya ស៊ីសុវត្ថិ-ឌូង-ចាន់តូ និងហ៊ីង ថូរ៉ាក់ស៊ី (តុលា២00១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា: ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតំរូវចំពោះវិបត្តិ* (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។
១៩. ច័ន្ទ-សុផល ទេព-សាវ៉ារី និង Sarthi Acharya (ធ្នូ២00១) *ការកាន់កាប់ដីនៅកម្ពុជា: ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។
២០. សូ-សុវណ្ណារិទ្ធ វៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្នមុនី, Brett Ballard និង Sarthi Acharya (មីនា ២00២) *ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២0) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។
២១. Bhargavi Ramamurthy ស៊ុក-បូរ័ក្ស, Per Ronnås និងសុក-ហាច (មីនា២00២) *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២000: ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ* (ឯកសារពិភាក្សាលេខ ២១) តំលៃ ៨.000រៀល ។
២២. ច័ន្ទ-សុផល និង Sarthi Acharya (កក្កដា២00២) *ការលក់ដូរដីធ្លីនៅកម្ពុជា: ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។
២៣. Bruce McKenney និង ព្រុំ-តុលា (កញ្ញា ២00២) *ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា: ការវាយតំលៃជាមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៣) ជាភាសាខ្មែរ តំលៃ ១០.000រៀល ជាអង់គ្លេស ១០ដុល្លារ ។
២៤. ច័ន្ទ-សុផល គីម-សេតារា និង Sarthi Acharya (ធ្នូ ២00២) *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា: ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរតំលៃ

៦.០០០រៀល ជាអង់គ្លេសតំលៃ ៧ដុល្លារ ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ធ្នូ ២០០២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទ: ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា* (ឯកសារពិភាក្សា លេខ២៥) ជាខ្មែរតំលៃ ៨.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៦. Sarthi Acharya គីម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (កញ្ញា ២០០៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម: ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ២៦) ជាខ្មែរ ៧.០០០រៀល អង់គ្លេស ៥ដុល្លារ ។

២៧. យឹម-ជា និង Bruce McKenney (ធ្នូ ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ: ការវិភាគលើ ការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសំរាប់ការលូតលាស់* (ឯកសារពិភាក្សាលេខ២៧) ជាខ្មែរតំលៃ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៨. ព្រុំ-តុលា និង Bruce McKenney (ធ្នូ ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា: ការប្រឈម ការគំរាមកំហែង និងឱកាសសំរាប់ពាណិជ្ជកម្មជ័រទឹក* (ឯកសារពិភាក្សាលេខ២៨) ជាខ្មែរ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៩. យឹម-ជា និង Bruce McKenney (វិច្ឆិកា ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក: ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ* (ឯកសារពិភាក្សាលេខ២៩) ជាខ្មែរ ៥.០០០រៀល ជាអង់គ្លេស ៥ដុល្លារ ។

៣០. Caroline Hughes និង គីម-សេតារា (មិថុនា ២០០៤) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា: ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣០) ជាភាសាខ្មែរ ១០.០០០រៀល ជាភាសាអង់គ្លេស ១៣,៥០ដុល្លារ ។

៣១. Robert Oberndorf (កក្កដា ២០០៤) *សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា* (ឯកសារពិភាក្សាលេខ៣១) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៦,៥០ដុល្លារ ។

៣២. K.A.S. Murshid និង ទូត-សុខផល្លី (ឧសភា ២០០៥) *សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ប្រទេសកម្ពុជា: ការសិក្សាជំហានដំបូង* (ឯកសារពិភាក្សាលេខ៣២) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ ។

៣៣. Kasper K. Hansen និង តុប-នេត (ធ្នូ ២០០៦) *Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia* (ឯកសារពិភាក្សាលេខ៣៣) ជាភាសាអង់គ្លេស ៨,០០ដុល្លារ ។

៣៤. ប៉ក់-គីមជឿន ហ៊ង-វុទ្ធី អេង-នេត្រា អាន-សុវត្ថា គីម-សេតារា, Jenny Knowles និង David Craig (មីនា ២០០៧) *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review* (ឯកសារពិភាក្សាលេខ៣៤) ជាភាសាអង់គ្លេស ៦ដុល្លារ ។

៣៥. គីម-សេតារា និង Joakim Öjendal (ឧសភា ២០០៧) *Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia* (ឯកសារពិភាក្សាលេខ៣៥) ជាភាសាអង់គ្លេស ៤ដុល្លារ ។

៣៦. លឹម-សុវណ្ណារា (វិច្ឆិកា ២០០៧) *Youth Migration and Urbanisation in Cambodia* (ឯកសារពិភាក្សាលេខ ៣៦) ជាភាសាអង់គ្លេស ៣,៥ដុល្លារ ។

៣៧. Brett M. Ballard, Christian Sloth, David Wharton, Ingrid FitzGerald, K.A.S Murshid, Kasper K. Hansen, ភីម-រុនស៊ីណារិទ្ធិ និង លឹម-សុវណ្ណារា (មេសា ២០០៧) *"We Are Living with Worry All the Time": A Participatory Poverty Assessment of the Tonle Sap (PPA)* ជាភាសាអង់គ្លេស ១៨ដុល្លារ ។

៣៨. Ingrid FITZGERALD និង សូ-សុវណ្ណារិទ្ធិ (កញ្ញា ២០០៧) *Moving Out of Poverty: Trends in Community Well-Being and Household Mobility in Nine Cambodian Villages (MOPs)* ជាភាសាអង់គ្លេស ២០ដុល្លារ ។

៣៩. CDRI (ធ្នូ ២០០៧) *Cambodia Land Titling Rural Baseline Survey Report* ជាភាសាអង់គ្លេស ៧ដុល្លារ ។

៤០. CDRI (ធ្នូ ២០០៧) *Cambodia Land Titling Urban Baseline Survey Report* ជាភាសាអង់គ្លេស ៧ដុល្លារ ។

៤១. Chem Phalla *et al.*, *Framing Research on Water Resources Management and Governance in Cambodia: A Literature Review* (Working Paper No. 37)

៤២. Pak Kimchoeun and David Craig, *Accountability and Public Expenditure Management in Decentralised Cambodia* (Working Paper No. 38)

៤៣. Horng Vuthy and David Craig, *Accountability and Planning in Decentralised Cambodia* (Working Paper No. 39)

៤៤. CDRI, *Impact of High Food Prices in Cambodia*

៤៥. Eng Netra and David Craig (forthcoming), *Accountability and Human Resource Management in Decentralised Cambodia* (Working Paper No. 40)

៤៦. Hing Vutha and Hossein Jalilian (April 2009), *The Environmental Impacts of the ASEAN-China Free Trade Agreement for Countries in the Greater Mekong Sub-region.*

៤៧. Thon Vimealea, Ou Sivhuoch, Eng Netra and Ly Tem (October 2009), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces.*

៤៨. HING Vutha and THUN Vathana (December 2009), *Agricultural Trade in the Greater Mekong Sub-region: The Case of Cassava and Rubber in Cambodia.*

៤៩. Chan Sophal (December 2009), *Costs and Benefits of Cross-border Labour Migration in the GMS: Cambodia Country Study.*

៥០. CDRI Publication (December 2009), *Costs and Benefits of Cross-country Labour Migration in the GMS: Synthesis of the Case Studies in Thailand, Cambodia, Laos and Vietnam.*

៥១. CDRI Publication (December 2009), *Agricultural Trade in the Greater Mekong Sub-region: Synthesis of the Case Studies on Cassava and Rubber Production and Trade in GMS Countries*

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

☞ អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ / ០១២ ៨៦៧-២៧៨
🖶 (៨៥៥-២៣) ៨៨០-៧៣៤
E-mail: cdri@wicam.com.kh
Website: http://www.cdri.org.kh





តំលៃ ៨.000រៀល

9789995052348